ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត




- អាហារគឺជាព្រះ
- អំពើប្រល័យពូជសាសន៍ដែលអាក្រក់បំផុត

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៧៩ ខែកក្កដា ឆ្នាំ២០០៦

ស្វែងរកការពិត
លេខ៧៩ ខែកក្កដា ឆ្នាំ២០០៦

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ អាហារគឺជាព្រះ ..........១

**ផ្នែកឯកសារ**

◆ ហេង សុងហ៊ី ៖ និស្សិតមកពីប្រទេសបារាំង ..........៥
◆ មជ្ឈមណ្ឌលឯកសារកម្ពុជាប្រគល់ឯកសារ ..........៩
◆ បញ្ជីឈ្មោះជនរងគ្រោះដែលកម្ទេចនៅមន្ទីរ ស-២១ ..........១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រឿងរ៉ាវដែលមិនចេះសាបសូន្យ ..........១២
◆ គុកខ្មែរក្រហម ..........១៨
◆ អំពើប្រល័យពូជសាសន៍ដែលអាក្រក់បំផុត ..........២៤
◆ ផែនការបដិវត្តន៍សង្គមនិយមរបស់ខ្មែរក្រហម ..........៣៣
◆ តាម៉ុក ស្លាប់ ..........៤២
◆ ដំណើរទស្សនកិច្ចរបស់មេឃុំមកកាន់អគារអង្គជំនុំជម្រះ ..........៤៤

**ផ្នែកច្បាប់**

◆ តើចៅក្រម សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ..........៤៦
◆ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ..........៤៨

**វេទិកាពិភាក្សាសាធារណៈ**

◆ ចំណាប់អារម្មណ៍របស់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ..........៥២
◆ ការធានាភាពមិនលម្អៀងនិងឯករាជ្យភាព ..........៥៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ក្រុមគ្រួសារខ្ញុំ ..........៥៨
◆ បទពិសោធន៍របស់ម៉ែ ..........៥៩


ការធ្វើទារុណកម្មនៅក្នុងគុកធំ ខេត្តសៀមរាប


យោធាខ្មែរក្រហមបណ្ដើរអ្នកទោសចូលទៅក្នុងគុកធំ ខេត្តសៀមរាប

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** ប៉ាង ពីរ៉ែន, ស៊ុរិ សាវីណា, វ៉ាន់ថាន់ ពៅដារ៉ា, អៀ ម៉េងទ្រី, ផេង ពង្សរ៉ាស៊ី, សួ ប៊ុនស៊ូ, ចូសេហ្វ អេ មូសូមេលី, ស៊ូហ្សាណា លីនតុន, ឡាត់ សោភ័ណ, ព្រំ សាម៉ុន **អ្នកនិពន្ធ និងស្រាវជ្រាវ ៖** លី សុផល, ណយ សុផារី, ឌី ខាំបូលី **អ្នកបកប្រែ ៖** បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ ៖** គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន តារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# អាហារគឺជាព្រះ

ពីចុងឆ្នាំកន្លងទៅនៅវេលាព្រឹកម៉ោងប្រមាណ៨:៣០នាទី ខ្ញុំដើរចេញទៅក្រៅតាមសំយ៉ាបបន្ទប់ធ្វើរបស់ខ្ញុំ ស្រាប់តែខ្ញុំឃើញចោរម្នាក់ដែលកំពុងតែប្រុងនឹងលួចចូលក្នុងអគារ ។ នៅពេលដែលខ្ញុំដេញតាមចាប់ចោរនោះ ខ្ញុំដឹងថាចោរនោះគឺជាក្មេងប្រុសដែលទើបតែមានអាយុប្រហែល១២ឬ១៨ឆ្នាំប៉ុណ្ណោះ ។ ចោរក្មេងនោះមានសម្លៀកបំពាក់ពណ៌ខ្មៅនិងមានកន្សែងពណ៌សនៅលើក្បាល និងចង្កេះ ។

ចោរក្មេងនោះបានរត់ទៅខាងក្រោយអគារ ដោយព្យាយាមរត់គេចលោតផ្លោះចុះតាមរបងអគារ ។ នៅពេលដែលខ្ញុំចាប់ដៃចោរក្មេងនោះ ខ្ញុំឃើញថាក្មេងនោះមានរូបរាងស្គមស្គាំងដែលធ្វើឲ្យខ្ញុំមានអារម្មណ៍នឹកឃើញឡើងវិញនូវរឿងរ៉ាវក្នុងអតីតកាលរបស់ខ្ញុំ ។

នោះគឺការចងចាំដែលកើតចេញពីអ្វីដែលប្រជាជនកម្ពុជាហៅថា “របប ប៉ុល ពត” គឺរបបកម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ។ ក្នុងពេលដែលក្រុមគ្រួសាររបស់ខ្ញុំក៏ដូចនឹងក្រុមគ្រួសារដទៃទៀតដែលរស់នៅក្នុងទីក្រុងរាប់លាននាក់ទៀតត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញទៅកាន់ទីជនបទ ខ្ញុំទើបតែមានអាយុប្រហាក់ប្រហែលនឹងចោរក្មេងនោះនៅឡើយ ។

ខ្ញុំជាក្មេងទីក្រុងម្នាក់ ដែលមិនមានជំនាញអ្វីដើម្បីរស់នៅក្នុងស្ថានភាពនាពេលនោះទេ ប៉ុន្តែការស្រេកឃ្លានអាហារបានបង្រៀនឲ្យខ្ញុំចេះជំនាញជាច្រើន ។ ខ្ញុំបង្រៀនខ្លួនឯងឲ្យចេះអ៊ុំទូកចេះហែលទឹកដើម្បីអាចមុជទៅកាន់ដើមអំពៅដែលដុះនៅក្នុងវាលស្រែដែលលិចទឹក ។ ខ្ញុំចេះលួចអាហារ ខ្ញុំចេះសម្លាប់សត្វពស់និងកណ្ដុរដើម្បីបរិភោគ ព្រមទាំងចេះស្វែងរកស្លឹកឈើដែលអាចបរិភោគបាននៅក្នុងព្រៃ ។

មានពេលមួយខ្ញុំបានលួចបេះបន្លែខ្លះពីស្រែយកមកដាំឲ្យបងស្រីខ្ញុំដែលកំពុងតែមានផ្ទៃពោះនិងស្រេកឃ្លានអាហារ ។ កងសន្តិសុខខ្មែរក្រហមចាប់ខ្ញុំនិងវាយខ្ញុំនឹងពូថៅ ។ បន្ទាប់មកកងសន្តិសុខខ្មែរក្រហមបានចាប់ខ្ញុំយកទៅដាក់គុកដែលនៅទីនោះខ្ញុំត្រូវទទួលរងនូវការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ ។

បុរសម្នាក់ដែលរស់នៅក្នុងភូមិជាមួយម្ដាយរបស់ខ្ញុំបានទៅអង្វរប្រធានសន្តិសុខឲ្យដោះលែងខ្ញុំ ដោយនិយាយថាខ្ញុំនៅក្មេងណាស់ ។ ប្រហែល២សប្ដាហ៍ក្រោយមក ខ្ញុំត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ។ ក្រោយមក បុរសដែលជួយអង្វរឲ្យខ្ញុំបានរួចខ្លួនត្រូវខ្មែរក្រហមចោទថាមានសាច់ញាតិរស់នៅក្នុងតំបន់ខ្មាំង ។ តាំងពីពេលនោះមក គាត់បាត់ខ្លួនជារៀងរហូត ។

នៅពេលដែលខ្ញុំចាប់ដៃចោរក្មេងនោះខ្ញុំនឹកឃើញឡើងវិញនូវការឈឺចាប់របស់ខ្ញុំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែ ការចាប់ដៃចោរក្មេងនោះក៏បានធ្វើឲ្យខ្ញុំគិតថាតើហេតុអ្វីបានជាចោរក្មេងនោះ ព្យាយាមលួចចូលក្នុងបន្ទប់របស់ខ្ញុំ ប្រហែលជាចោរក្មេងនោះស្រេកឃ្លានហើយមើលទៅ ។

អាហារគឺជាព្រះនិងគឺជារបស់តែម៉្យាងគត់ដែលខ្ញុំចង់បានបំផុតនៅពេលនោះ ។ ខ្ញុំស្រមៃឃើញម្ហូបអាហារគ្រប់មុខ ហើយការស្រមៃនេះបានជួយឲ្យខ្ញុំដេកលក់និងផ្ដល់ជាកម្លាំងចិត្តសម្រាប់ធ្វើការងារបន្តទៀត ។ សូម្បីតែសព្វថ្ងៃនេះក៏ដោយ ខ្ញុំមិនសប្បាយចិត្តទាល់តែសោះនៅពេលដែលខ្ញុំឃើញក្មេងៗដែលមិនមានអាហារបរិភោគនៅតាមដងផ្លូវ ។ ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាក្មេងទាំងនោះមិនមានអាហារបរិភោគគ្រប់គ្រាន់នៅពេលដែលយើងលែងស្ថិតនៅក្រោមការគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

ហេតុដូច្នេះ នៅពេលដែលខ្ញុំឃើញផ្ទៃមុខស្រេកឃ្លានរបស់ចោរក្មេងនោះ ខ្ញុំក៏បានលែងដៃរបស់ចោរក្មេងនោះឲ្យរត់គេចទៅបាត់ ។ ប្រសិនបើខ្ញុំរុញចោរក្មេងនោះបន្តិច ចោរក្មេងនោះនឹងធ្លាក់ចុះទៅដីពីអគារបីជាន់ ហើយទំនងជានឹងបាត់បង់ជីវិតទៀតផងក៏មិនដឹង ។

ប៉ុន្តែ បើទោះបីជាខ្ញុំបានដោះលែងចោរនោះក៏ដោយ ខ្ញុំចង់បង្រៀនចោរនោះឲ្យដឹងថាការលួចមិនមែនជាទង្វើត្រឹមត្រូវនោះទេ ។ ដោយមានអារម្មណ៍ភ័យខ្លាចនិងច្របូកច្របល់ ចោរក្មេង

បានរត់ប្រវេសប្រវាសចុះតាមអគារ ហើយបានរត់ឆ្ពោះទៅផ្លូវដែលមានអំពូលភ្លើងបំភ្លឺ និងដែលមនុស្សម្នាកំពុងតែហាត់ប្រាណពេលព្រឹកនិងកងសន្តិសុខកំពុងតែនិយាយគ្នា ។ កងសន្តិសុខម្នាក់ដៃកាន់ដំបងឈើធំមួយបានដេញចាប់ក្មេងចោរនោះ ។ ភ្លាមៗនោះមនុស្សម្នាបានស្រែកថា "ចាប់វាតែកុំវាយវាអី" ។

ទោះបីជាក្មេងប្រុសនោះអង្វរកងសន្តិសុខយ៉ាងណាក៏ដោយ កងសន្តិសុខនៅតែវាយចោរក្មេងនោះយ៉ាងធ្ងន់ធ្ងរ ទំនងជាវាយខ្លាំងជាងខ្មែរក្រហមវាយខ្ញុំទៅទៀត ។ ក្រោយពីបានវាយចោរក្មេងនោះ កងសន្តិសុខក៏បានដោះលែង ។

ខ្ញុំបានពុះពារអស់រយៈពេលជិត៣០ឆ្នាំដើម្បីជម្នះនឹងការស្រេកឃ្លាន ការភ័យខ្លាច និងការខឹងគុំកួន ដែលខ្ញុំជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិងបន្តដំណើរជីវិតរបស់ខ្ញុំទៅមុខជានិច្ច ។ ខ្ញុំឆ្ងល់ថាតើចោរក្មេងនឹងត្រូវចំណាយពេលយូរប៉ុន្មានក្នុងការអត់ឱនដល់ខ្ញុំ ។ ខ្ញុំជាក្មេងមានសំណាងម្នាក់ក្នុងចំណោមក្មេងមានសំណាងជាច្រើនទៀត ។ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់ ខ្ញុំបានរត់កាត់ព្រៃទៅដល់ជំរំជនភៀសនៅក្នុងប្រទេសថៃនិងជាចុងក្រោយខ្ញុំបានមកដល់សហរដ្ឋអាមេរិក ។ នៅសហរដ្ឋអាមេរិក ខ្ញុំបានចូលរៀននៅមហាវិទ្យាល័យនិងមានជីវភាពរស់នៅសមរម្យ ។ ក្រោយមក ខ្ញុំមានបំណងធ្វើកិច្ចការចាំបាច់មួយ ។ ភាពចាំបាច់ក្នុងការស្វែងរកចម្លើយទៅនឹងមូលហេតុដែលខ្ញុំត្រូវទទួលរងនូវក្តីឈឺចាប់ជាខ្លាំងនិងការបាត់បង់សមាជិកគ្រួសារអស់ជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះបានជំរុញឲ្យខ្ញុំសិក្សាស្រាវជ្រាវអំពីរបបនេះ ។

ប៉ុន្តែភាគច្រើននៃអ្នកដែលនៅរស់ពីរបបកម្ពុជាប្រជាធិប-តេយ្យជួបនូវសំណាងអាក្រក់ ។ អ្នកទាំងនោះមិនមានភាពងាយស្រួលក្នុងការធ្វើឲ្យស្ថានភាពរបស់ខ្លួនប្រសើរឡើងវិញ និងចាប់ផ្តើមជីវិតជាថ្មីម្តងទៀតនោះទេ ។

ខ្មែរក្រហមចង់បង្កើតនូវបដិវត្តន៍កសិកម្មស្រែចម្ការដ៏ស្អាតស្អំមួយ ពីព្រោះខ្មែរក្រហមយល់ថាអ្នកដែលមានមុខរបរជាគ្រូបង្រៀន ឬការអប់រំជ្រៅជ្រះ ឬអ្នកដែលចេះនិយាយភាសាបរទេស ឬរស់នៅក្នុងទីក្រុងគឺសុទ្ធតែជាជនសង្ស័យទាំងអស់ ។ ខ្មែរក្រហមចង់លុបបំបាត់ចោលនូវសង្គមមនុស្សអាក្រក់ទាំងនេះ ហើយបង្កើតនូវសង្គមមនុស្សបែបថ្មីមួយ ។ ហេតុដូច្នេះបានជាខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុង ចាប់ដាក់គុក ឬសម្លាប់អ្នកដែលធ្លាប់បម្រើឲ្យរបប លន់ នល់ ទប់ស្កាត់មិនឲ្យប្រជាជនឆ្លងកាត់តាមច្រកព្រំដែន និងលុបបំបាត់ចោលនូវហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសជាតិទាំងអស់ដូចជា សាលារៀន ធនាគារ ទីសក្ការៈបូជា កន្លែងពាណិជ្ជកម្ម ប៉ុស្តិ៍ប្រៃសណីយ៍ និយាយរួមគឺអ្វីៗទាំងអស់តែម្តង ។

ក្រៅពីការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរនេះ គឺមានចំនួនមនុស្សស្លាប់ជាច្រើនក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បើគិតជាភាគរយវិញ ប្រទេសកម្ពុជាបានឆ្លងកាត់របបប្រល័យពូជសាសន៍ដ៏អាក្រក់បំផុតនេះក្នុងប្រវត្តិសាស្ត្រ ព្រោះមានប្រជាជនកម្ពុជាចន្លោះពី២៥ទៅ៣៣ភាគរយនៃចំនួនប្រជាជនកម្ពុជាសរុបបានស្លាប់ក្នុងរយៈពេលជិតបួនឆ្នាំ ។ ភាគច្រើនអ្នកដែលនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យសុទ្ធតែជាស្ត្រី ។ ដោយមិនបានទទួលការបណ្តុះបណ្តាលនូវជំនាញផ្សេងៗឬការអប់រំ អាហារហូបចុកមិនគ្រប់គ្រាន់ និងរស់នៅក្នុងសភាពភ័យខ្លាច និងអស្ថិរភាពនយោបាយ ស្ត្រីជាជនរងគ្រោះទាំងនេះខិតខំព្យាយាមពុះពារជម្នះការបាត់បង់យ៉ាងធ្ងន់ធ្ងរដែលខ្លួនបានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យព្រមទាំងស្តារជីវភាពរស់នៅនិងប្រទេសជាតិរបស់ខ្លួនឡើងវិញ ។

ចាប់តាំងពីពេលនោះមក កម្ពុជាខិតខំប្រឹងប្រែងយ៉ាងយូរដើម្បីកសាងប្រទេសជាតិឡើងវិញ ។ សព្វថ្ងៃនេះ កម្ពុជាជាប្រទេសក្រីក្រមួយក្នុងចំណោមប្រទេសក្រីក្របំផុតនៅលើពិភពលោកនៅឡើយ ។ កំហឹង គំនុំគុំកួន អំពើហិង្សាក្នុងគ្រួសារ និងនយោបាយ និងបទឧក្រិដ្ឋតូចៗដូចករណីដែលចោរក្មេងបានលួចចូលតាមសំយ៉ាបបន្ទប់របស់ខ្ញុំ គឺកើតឡើងដោយសារតែភាពក្រីក្រ ។ ឪពុកម្តាយជាញឹកញាប់បញ្ឈប់កូនពីសាលារៀនដើម្បីជួយការងារស្រែចម្ការក្នុងគ្រួសារវិញ ហើយការខ្វះការយល់ដឹងរបស់កូន គឺធ្លាក់បន្ទុកបន្ថែមទៅលើភាពក្រីក្រ ។ នេះហាក់ដូចជាប្រវត្តិសាស្ត្រនោះកំពុងតែកើតមានឡើងម្តងទៀត ។

មានមធ្យោបាយជាច្រើនជួយដល់ប្រជាជនកម្ពុជាឲ្យបញ្ចប់ភាពក្រីក្រ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាព្យាយាមប្រើប្រាស់

មធ្យោបាយមួយចំនួន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកត់ត្រានូវប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យតាមមធ្យោបាយផ្សេងៗ ។ មធ្យោបាយសាមញ្ញបំផុតដែលមជ្ឈមណ្ឌលយើងយកមកប្រើ-ប្រាស់នោះ គឺតាមរយៈការប្រមែប្រមូលឯកសារជាប្រភេទក្រដាស ភាពយន្តឯកសារ រូបថត និងការថតសំឡេង ។ ឯកសារទាំងនេះនឹងយកមកប្រើប្រាស់នៅក្នុងសាលាក្តីខ្មែរក្រហមដែលនឹងចាប់ផ្តើមនៅក្នុងខែមករា ឆ្នាំ២០០៧ ខាងមុខនេះ ។ ការចង់ដឹងចង់ឃើញយុត្តិធម៌ពិតគឺជាមធ្យោបាយតែមួយគត់ដែលប្រជាជនកម្ពុជាអាចជម្នះនឹងកំហឹងគុំកួនរបស់ខ្លួនបាននិងចាប់ផ្តើមទទួលស្គាល់នូវអតីតកាលរបស់ខ្លួន ។

ប៉ុន្តែមានតែមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់តែប៉ុណ្ណោះដែលនឹងត្រូវនាំយកមកធ្វើការកាត់ទោស ។ ជនដៃដល់ជាច្រើន ជាពិសេសអ្នកដែលបានប្រព្រឹត្តអំពើកាប់សម្លាប់និងអំពើព្រៃផ្សៃផ្សេងៗទៀតកំពុងតែរស់នៅក្នុងភូមិដែលខ្លួនធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋកម្ម ។ ដូច្នេះ យើងប្រើប្រាស់មធ្យោបាយយ៉ាងសាមញ្ញមួយចំនួនជួយប្រជាជនកម្ពុជាឲ្យនឹកឃើញឡើងវិញនូវអតីតកាលរបស់ខ្លួនដើម្បីផ្សះផ្សាគ្នាឡើងវិញ ។

អ្នកស្រាវជ្រាវរបស់យើងចុះទៅសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហមនិងជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានចំនួនរាប់ពាន់នាក់ ។ បន្ទាប់មក យើងយករឿងរ៉ាវរបស់គាត់មកចុះផ្សាយលើទំព័រទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សាយផ្សេងៗ ដើម្បីជួយដល់ជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យ កុំឲ្យមានអារម្មណ៍ឯកោ និងដើម្បីឲ្យអ្នកទាំងនោះយល់ថាទាំងជនរងគ្រោះនិងជនដៃដល់ គឺសុទ្ធតែទទួលរងនូវការឈឺចាប់និងការបាត់បង់អ្នកដែលខ្លួនស្រលាញ់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានការកម្មវិធីអានសៀវភៅដូចជាសៀវភៅកំណត់ហេតុកុមារី អាន់ ហ្វ្រែន តាមវិទ្យុ ដើម្បី ជួយប្រជាជនកម្ពុជាឲ្យបានយល់ដឹងថានៅលើពិភពលោកកម្ពុជាមិនមែនជាប្រទេសតែមួយគត់ទេ ដែលមានអំពើព្រៃផ្សៃបែបនេះបានកើតឡើងនោះ ។

ជាងនេះទៅទៀត យើងបានរៀបចំការប្រកួតប្រជែងស្នាដៃ ដែលប្រជាជនកម្ពុជាសរសេរអំពីរឿងរ៉ាវរបស់ខ្លួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាបញ្ចេញមតិយោបល់របស់ខ្លួន ជួយឲ្យគាត់ប្រែក្លាយការខឹងគុំកួននិងភាពសោកសៅរបស់គាត់ទៅជាការពិតនិងមានតម្លៃ ។ អ្នកទាំងនេះតែងរៀបរាប់អំពីរឿងរ៉ាវរបស់ខ្លួនទុកសម្រាប់កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយក៏ដូចទុកសម្រាប់ខ្លួនគាត់ផ្ទាល់ដែរ ។

អ្នកដែលនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យយល់ឃើញថា កូនខ្មែរជំនាន់ក្រោយនឹងធ្វើការសិក្សាអំពីកំហុសអតីតកាល ហើយនឹងមិនប្រព្រឹត្តកំហុសទាំងនេះម្តងទៀតឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ឪពុកម្តាយជាច្រើនរៀបរាប់ឲ្យដឹងថាក្មេងៗជំនាន់ក្រោយមិនជឿនូវអ្វីដែលឪពុកម្តាយ និយាយប្រាប់អំពីជីវិតគាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។ ក្មេងៗជំនាន់ក្រោយពិបាកនឹងជឿថា ឪពុកម្តាយរបស់ខ្លួនធ្លាប់ឆ្លងកាត់ការអត់ឃ្លាន ធ្វើការជាច្រើនម៉ោងនៅក្នុងវាលស្រែ ឬរស់នៅក្នុងភាពភ័យខ្លាចនឹងជីវិតរបស់ខ្លួនឡើយ ។ ម្យ៉ាងទៀត ដោយសារតែការខ្វែងគំនិតគ្នាទៅលើសៀវភៅសិក្សាសម្រាប់ថ្នាក់វិទ្យាល័យបានបង្ហាញអំពីលទ្ធផលនៃការបោះឆ្នោតឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានផ្លាស់ប្តូរអត្ថបទទាំងអស់ នៅក្នុងផ្នែកប្រវត្តិសាស្ត្របែបទំនើបចេញពីអត្ថបទសិក្សាដោយបញ្ចូលតែពីរ-បីកថាខណ្ឌ ដែលសរសេរអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែដោះស្រាយបញ្ហានេះតាមរយៈការសរសេរប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យសម្រាប់សិស្សវិទ្យាល័យធ្វើការសិក្សាស្វែងយល់ ។ យើងគ្រោងបោះពុម្ពសៀវភៅប្រវត្តិសាស្ត្រនេះនៅរដូវស្លឹកជ្រុះនេះ ។

ចាប់តាំងពីឆ្នាំកន្លងទៅ យើងធ្វើការពិសោធន៍តាមរបៀបផ្សេងៗជាច្រើនដើម្បីជួយប្រជាជនកម្ពុជាឲ្យចេះផ្សះផ្សាគ្នាដោយផ្ទាល់ឲ្យបានច្រើនជាងមុន ។ នៅក្នុងគម្រោងមួយដែលយើងឲ្យឈ្មោះថា «គម្រោងឯកសាររស់» យើងតែងដឹកនាំជនរងគ្រោះទៅធ្វើទស្សនកិច្ចនូវទីកន្លែងដ៏ល្បីល្បាញចំនួនពីរដែលជានិមិត្តរូបនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺវាលពិឃាតបឹងជើងឯកនិងគុកទួលស្លែងដ៏ល្បីល្បាញដែលមានអ្នកទោសតែ១២នាក់គត់ ក្នុងចំណោមអ្នកទោស១៤.០០០នាក់បានរួចពីការសម្លាប់ ។ នេះជាកិច្ចការដែលប៉ះពាល់ដល់អារម្មណ៍របស់អ្នកស្រុក

អ្នកភូមិដែលយើងអញ្ជើញឲ្យចូលរួមទស្សនាកន្លែងអស់ទាំងនេះ ក៏ប៉ុន្តែអ្នកស្រុកអ្នកភូមិភាគច្រើនបានឲ្យដឹងថា ឥឡូវនេះគាត់ដឹងថាតើការឈឺចាប់នោះមានធំប៉ុនណានិងថែមទាំងដឹងថាមិនមែនមានតែគាត់ទេដែលទទួលរងនូវការឈឺចាប់តែម្នាក់ឯងនោះ ។

ក្នុងករណីខ្លះទៀត ជនរងគ្រោះនិងជនដៃដល់មកទស្សនាទីកន្លែងជាប្រវត្តិសាស្ត្រទាំងនេះជាលើកដំបូង ។ បើទោះបីជាជនរងគ្រោះនិងជនដៃដល់រស់នៅក្នុងភូមិជាមួយគ្នាអស់មួយជីវិតក៏ដោយ ក៏ក្រុមទាំងពីររស់នៅគេចមុខពីគ្នាទៅវិញទៅមកអស់ជាច្រើនទសវត្សរ៍មកហើយដែរ ។ ប៉ុន្តែនៅពេលដែលគាត់ជំរុញឲ្យចូលរួមក្នុងដំណើរទស្សនកិច្ចរួមគ្នា គាត់ចាប់ផ្តើមមានការពិភាក្សាគ្នា និងមានការយល់ដឹងមួយចំនួនពីគ្នាទៅវិញទៅមក ។

កាលពីខែកញ្ញាកន្លងទៅ យើងបានរៀបចំដំណើរទស្សនកិច្ចគុកខ្មែរក្រហមនិងវណ្តៅសាកសពជាច្រើនកន្លែងសម្រាប់អតីតជនដៃដល់និងជនរងគ្រោះចំនួន៥០នាក់ ។ គោលបំណងរបស់យើងចង់ដឹងថាតើភាគីទាំងពីរនេះអាចយល់ដឹងរួមគ្នាអំពីការពិតដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ ។ លទ្ធផលដែលទទួលបាននោះគឺការលើកទឹកចិត្ត ហើយមានអតីតជនដៃដល់ម្នាក់បានផ្ញើអត្ថបទរបស់គាត់មកកាន់មជ្ឈមណ្ឌលយើងដែលជនដៃដល់នោះបាននិយាយថា គាត់ចង់ឲ្យមានការផ្សះផ្សាគ្នា ។ ដំណើរទស្សនកិច្ចក្នុងពេលនោះត្រូវបានសារព័ត៌មានក្នុងស្រុកនិងអន្តរជាតិយកមកចុះផ្សាយ ។ ការចុះផ្សាយនេះជួយជម្រុញមានឲ្យការចាប់អារម្មណ៍កាន់ខ្លាំងឡើងទៅលើគំនិតនេះ ។

ដំណាក់ការចុងក្រោយ យើងសហការជាមួយនឹងអង្គការចិត្តសង្គមអន្តរវប្បធម៌លើកគម្រោងជួយជនរងគ្រោះដោយអំពើទារុណកម្ម ដើម្បីជួយព្យាបាលជនរងគ្រោះនិងជនដៃដល់ដែលមានជំងឺបាក់ស្បាត ។ នេះមិនមែនជាកិច្ចការតូចមួយនោះទេ ព្រោះថាជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រហែល៧៥ភាគរយត្រូវបានគេគិតថាមានជំងឺបាក់ស្បាត ក្នុងខណៈនោះដែរប្រទេសកម្ពុជាមានគ្រូពេទ្យចិត្តសាស្ត្រចំនួនប្រហែល២០នាក់ប៉ុណ្ណោះ ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាសម្គាល់ឃើញជនរងគ្រោះដែលមានជំងឺបាក់ស្បាត ។ ក្រោយមកជនរងគ្រោះទាំងនេះទទួលបាននូវការផ្តល់ប្រឹក្សាព្យាបាល ។

អ្នកស្រុកអ្នកភូមិត្រូវបានជួយណែនាំមើលឃើញថាការថប់អារម្មណ៍ ការគេងមិនលក់ កំហឹង និងរោគសញ្ញាផ្សេងៗទៀតដែលគាត់មាន គឺជាលទ្ធផលនៃការប៉ះទង្គិចផ្លូវចិត្តដែលគាត់ទទួលរងនូវការឈឺចាប់អស់រយៈពេល៣០ឆ្នាំ ។ អ្នកស្រុកអ្នកភូមិទាំងនោះបានទទួលនូវការផ្តល់ប្រឹក្សាជាក្រុមដែលគាត់អាចនិយាយអំពីបញ្ហាការប៉ះទង្គិចផ្លូវចិត្តរបស់គាត់ដោយសេរីនិងធ្វើការសិក្សាអំពីវិធីសាស្ត្រផ្សេងៗក្នុងការដកដង្ហើមនិងបន្ធូរអារម្មណ៍តាមទំនៀមទម្លាប់បែបព្រះពុទ្ធសាសនា ។

ដូច្នេះនៅពេលដែលយើងចាប់ផ្តើមការងារលើគម្រោងនេះទូទាំងប្រទេសក្នុងប៉ុន្មានឆ្នាំខាងមុខនេះ យើងក៏មានគម្រោងនឹងដោះស្រាយដោយផ្ទាល់លើបញ្ហាសំខាន់មួយក្នុងចំណោមបញ្ហាសំខាន់ជាច្រើន គឺភាពក្រីក្រដែលជាកេរតំណែលដែលបន្សល់ទុកពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលនៅបន្តកើតមាននៅក្នុងប្រទេសកម្ពុជារហូតមកទល់សព្វថ្ងៃ ។ ដោយជួយរៀបចំបង្កើតនូវកិច្ចការរកប្រាក់ចំណូលសម្រាប់ចិញ្ចឹមជីវិត យើងសង្ឃឹមថាប្រជាជនកម្ពុជាដូចចោរក្មេងដែលបានលួចចូលតាមសំយ៉ាបបន្ទប់របស់ខ្ញុំក្នុងយប់នោះជាដើម នឹងមានជម្រើសច្រើនជាងមុនសម្រាប់ជីវិតរស់នៅ ។ យើងក៏សង្ឃឹមថាគ្រួសាររបស់ចោរក្មេងនោះនិងក្រុមគ្រួសារដទៃទៀត នឹងមានលទ្ធភាពអាចផ្សះផ្សាអតីតកាលរបស់ខ្លួនបានជាមិនខាន ។

**ឆាំង យុ**


ស៊ុំ រិទ្ធី សែងបបរពីចង្ក្រានត្រូវអ្នកយាមគុកច្រានពីក្រោយបណ្តាលឲ្យរលាកក្បាលនិងដងខ្លួននៅក្នុងគុកធំ ខេត្តសៀមរាប

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ហេង សុងហ៊ី : និស្សិតមកពីប្រទេសបារាំង

ហេង សុងហ៊ី ហៅគា អាយុ២៨ឆ្នាំ (ឆ្នាំ១៩៧៦) មានស្រុកកំណើតនៅឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ សុងហ៊ី ចំណូលចិត្តរឿងនយោបាយតាំងពីនៅរៀន ។ ក្រោយពីបញ្ចប់ការសិក្សានៅមហាវិទ្យាល័យនិងសាលាគរុកោសល្យជាន់ខ្ពស់ សុងហ៊ី បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំងពីរឆ្នាំទៀត ។ នៅខែឧសភា ឆ្នាំ១៩៧៥ សុងហ៊ី បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីលាក់ខ្លួននៅជួរបដិវត្តន៍ក្នុងគោលបំណងជួយស្រោចស្រង់ប្រទេសជាតិ ។ តាំងពីមកដល់កម្ពុជា សុងហ៊ី ស្ថិតនៅក្នុងគំនាបអង្គការរហូតមកដល់ខែ១០ ឆ្នាំ១៩៧៦ សុងហ៊ី ត្រូវអង្គការចាប់ខ្លួនតែម្តង ។

ហេង សុងហ៊ី មានចំណាប់អារម្មណ៍នឹងនយោបាយរបស់សម្តេច សីហនុ តាំងរៀននៅថ្នាក់ទី៣សង្គមចាស់ក្នុងអាយុ១៧ឆ្នាំម៉្លេះ ។ សុងហ៊ី ចូលចិត្តស្តាប់សម្តេចសីហនុមានព្រះបន្ទូលនៅតាមវិទ្យុនានា ហើយថែម ទាំងបានសម្រួចចិត្តខ្លួនឯងថានឹងបម្រើសម្តេច សីហនុ នៅពេលណាដែលខ្លួនទទួលបានសញ្ញាប័ត្រខ្ពង់ខ្ពស់ ។ សុងហ៊ី បានបណ្តុះគំនិតខ្លួនឯងឲ្យស្អប់ខ្មែរក្រហមតាំងពីនោះមក ។ នៅឆ្នាំនោះ សុងហ៊ី បានប្រាស្រ័យទាក់ទងយ៉ាងជិតស្និទ្ធជាមួយមនុស្សបីនាក់ឈ្មោះ អ៊ឹម ប៊ុនហ៊ត, យៃ ហោម៉េងនឹងឈ្មោះ ជាប ឆេងហ៊ត ជាអធិការប៉ូលិស ។

បន្ទាប់ពីមានការឃោសនាប្រឆាំងនឹងខ្មែរក្រហមនៅអនុវិទ្យាល័យរបស់ ប៉ុក សំអាន និង អ៊ុន តាំ, សុងហ៊ី និងមិត្តភក្តិបីនាក់បានចូលរួមធ្វើបាតុកម្មជាមួយសិស្សនៅអនុវិទ្យាល័យសួងប្រឆាំងនឹងខ្មែរក្រហមដែរ ។ សុងហ៊ី បានស្រែកថ្កោលទោសខ្មែរក្រហមតាមខ្សែប្រសនស័ព្ទ និងគាំទ្រនយោបាយរបស់សម្តេចយ៉ាងអស់ពីចិត្តពីថ្លើម ។ ក្រោយមកមានសាស្ត្រាចារ្យម្នាក់ឈ្មោះ គង់ នឿន បានអប់រំគាត់ថា ខ្មែរក្រហមសុទ្ធតែជាពួកក្បត់ជាតិ ។ ពេលជជែកជាមួយមិត្តភក្តិម្តងៗ សុងហ៊ី តែងវាយប្រហារពាក្យសម្តីទៅលើសាស្ត្រាចារ្យ ដែលមាននិន្នាការទៅរកខ្មែរក្រហម ។

នៅឆ្នាំ១៩៦៦ សុងហ៊ី ប្រឡងជាប់ឌីប្លូម ។ សុងហ៊ី និងមិត្តភក្តិរបស់គាត់បីនាក់បានមករៀននៅទីរួមខេត្តកំពង់ចាមជាមួយគ្នា ។ នៅពេលនោះ សុងហ៊ី នៅតែបំពាក់បំប៉នគំនិតខ្លួនឯងប្រឆាំងខ្មែរក្រហមតាមរយៈការអានកាសែតនិងស្តាប់វិទ្យុដដែល ទោះបីជាខ្លួនកំពុងមមាញឹកនឹងការរៀនសូត្រក៏ដោយ ។

ឆ្នាំ១៩៦៧ សុងហ៊ី និងមិត្តភក្តិទាំងបីនាក់បានប្រឡងជាប់បាក់អង ។ នៅក្នុងឆ្នាំនោះនៅស្រុកត្បូងឃ្មុំ មានព្រឹត្តិការណ៍ផ្សេងៗកើតឡើង ។ សុងហ៊ី បានឃើញប្រជាជនស្លាប់និងរបួសនៅតាមផ្លូវពីក្រែកទៅស្រុកមេមត់ស្ទើររាល់យប់ដោយសារខ្មែរក្រហមលួចបាញ់ឆ្មក់ ។ តថភាពទាំងអស់នេះបានធ្វើឲ្យ សុងហ៊ី កាន់តែមានកំហឹងជាមួយខ្មែរក្រហមថែមទៀត ។ សុងហ៊ី តែងគាំទ្រសម្តេច សីហនុ នៅពេលដែលចាប់បានខ្មែរក្រហមយកទៅឃុំឃាំង ។ ក្រៅពីនេះ សុងហ៊ី បានចូលរួមសកម្មភាពផ្សេងៗប្រឆាំងនឹងខ្មែរក្រហមដូចជាធ្វើបដាទាក់ទងជាមួយមិត្តមួយចំនួនទៀតមាន អ៊ាត ចន្ទ ជាប៉េអ៊ុមស័ក្តិ២, ហ៊ាន វុឌ្ឍា និង លី ហេងប៉េអ៊ុម និងឈ្មោះ សំ ណុល ជាជនបង្កប់នៅក្នុងកងទ័ពបដិវត្តន៍ ។

ឆ្នាំ១៩៦៨ សុងហ៊ី បានប្រឡងជាប់បាក់ឌុបនិងចូលរៀននៅឆ្នាំទី១នៃមហាវិទ្យាល័យវិទ្យាសាស្ត្រនៅភ្នំពេញ ។ នៅក្នុងឆ្នាំនេះខ្មែរក្រហមបានធ្វើសកម្មភាពខ្លាំងនៅស្រុកសំឡូត និងតំបន់ផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ។ ចំណែកខាងភាគីលន់នល់បានផ្តួចផ្តើមគំនិតឲ្យនិស្សិតនៅតាមមហាវិទ្យាល័យហ៊ឹកហាត់ក្បួនយោធារយៈពេលពីរសប្តាហ៍ ហើយ សុងហ៊ី ក៏បានចូលរួមហាត់ជាមួយនឹងគេដែរ ។ ក្រោយពីហ៊ឹកហាត់ចប់ មានការសម្តែងសិល្បៈរួមមួយក្រោមអធិបតីភាពរបស់សម្តេច ប៉ែន នុត និងលន់នល់ ។ នៅក្នុងពិធីនេះក៏មានការឃោសនាឲ្យប្រឆាំងនឹងខ្មែរក្រហម និងគាំទ្រសម្តេច សីហនុ ដែលចង់លាលែងតំណែងជាប្រមុខរដ្ឋ ។ ប៉ុន្មានថ្ងៃក្រោយមក មានក្បួនបាតុកម្មមួយរបស់និស្សិតបានសុំឲ្យសម្តេចឲ្យទ្រង់នៅកាន់តំណែងដដែល ។

ឆ្នាំ១៩៦៩ សុងហ៊ី បានផ្លាស់ប្តូរឥរិយាបទលែងគាំទ្រ សម្តេច សីហនុ ពីព្រោះមើលឃើញថា នយោបាយរបស់សម្តេច ផាកទៅខាងយៀកកុង ដែលពេលនោះពួកយៀកកុងបាននិងកំពុង ចូលមករស់នៅក្នុងប្រទេសកម្ពុជាតាមទំនើងចិត្ត ហើយថែមទាំង មានការជួយឧបត្ថម្ភជាស្បៀងនិងសម្ភារផ្សេងៗរហូតដល់ខ្វះខាត អង្ករធ្វើឲ្យប្រជាជននាំគ្នាដណ្តើមទិញអង្ករពីទីផ្សារ ដោយសារតែ ពាក្យចចាមអារ៉ាមថា សម្តេចដឹកស្បៀងទៅឲ្យពួកយៀកកុង ។ ដោយឃើញមានអំពើពុករលួយគ្រប់បែបយ៉ាង សុងហ៊ី យល់ថា សម្តេចកំពុងតែដើរនយោបាយមួយផ្សេងខុសពីរដ្ឋាភិបាល លន់ នល់ ដែលកំពុងជួយខ្នះខ្នែងដោះស្រាយបញ្ហាជាតិ ។ សុងហ៊ី និង សាស្ត្រាចារ្យមួយចំនួនមាន ឡុង បុត្តា, ឃឹះ ដៀវ, ស៊ូ ឃឹម, តាន់ ប៊ុនសួរ ក៏មានគំនិតចុះសម្រុងគ្នាគាំទ្ររដ្ឋា ភិបាលស្រោចស្រង់ ជាតិនេះដែរ ។ ប៉ែន ម៉ានីល, គិត ជា, ប៊ូ ទឹម សុងហ៊ី តែងធ្វើ សកម្មភាពយ៉ាងញឹកញាប់ជាមួយសមាគមនិស្សិតនៅភ្នំពេញក្នុង ការគាំទ្ររដ្ឋាភិបាលស្រោចស្រង់ជាតិ ។

ឆ្នាំ១៩៧០ សុងហ៊ី រៀននៅឆ្នាំទី៣ ។ នៅថ្ងៃរដ្ឋប្រហារ ១៨ មីនា ឆ្នាំ១៩៧០ សុងហ៊ី បានចូលរួមយ៉ាងសកម្មក្នុងការ ដង្ហែរក្បួនបាតុកម្មគាំទ្ររដ្ឋប្រហារគាំទ្រប្រមុខដឹកនាំថ្មីដែលមាន លន់ នល់, សិរិមតៈ និង អ៊ិនតាំ ។ សុងហ៊ី បានសន្មតថាថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ គឺជាថ្ងៃដែលប្រទេសកម្ពុជារួចផុតពីរបប សក្តិភូមិនិងជាថ្ងៃដែលនាំមកនូវសេរីភាពពេញលេញដល់ប្រជាជន កម្ពុជា ។ នៅក្នុងការប្រជុំជាបន្តបន្ទាប់ សុងហ៊ី តែងឡើងមាន ចំណាប់អារម្មណ៍ពេញចិត្តនឹងរដ្ឋាភិបាលថ្មីនេះ ហើយថែមទាំង បានប្រាស្រ័យទាក់ទងជាមួយសាស្ត្រាចារ្យ ឡុង បុត្តា, តាន់ ប៊ុន សួរ, ស៊ូ ឃឹម, ឃឹះ ដៀវ, ជាវ ស៊ាងលាន, ឧក វ៉ាន់ដេត, ផាន់ បួយហាក់, និងនិស្សិតមួយចំនួនទៀតមាន ប៉ែន ម៉ានីល, សេង ស៊ីផា, អេង ម៉េងហ៊ុន, អេង ម៉េងហ៊ាង, មៀច សួន, សារី ស៊ីផាន់, គី ផាត់, នី ឆេងអ៊ិន និង សន ផាត ដើម្បីឲ្យខ្លួនមាន លទ្ធភាពបានចូលរួមក្នុងសកម្មភាពគាំទ្ររបបថ្មីនេះប្រឆាំងនឹងពួក យៀកកុងដែលមកឈ្លានពានទឹកដីខ្មែរ ។ ប៉ុន្តែ សុងហ៊ី បែរជាខក ចិត្តយ៉ាងខ្លាំង ពីព្រោះថាក្រោយពេលរដ្ឋប្រហារថ្ងៃ១៨ មីនា ១៩៧០ ប្រជាជននៅតាមជនបទនាំគ្នាធ្វើបាតុកម្មគាំទ្រសម្តេច សីហនុ ទៅវិញ ។ នៅពេលដែលសហរដ្ឋអាមេរិកចូលមកប្រទេស កម្ពុជា សុងហ៊ី យល់ឃើញថាសហរដ្ឋអាមេរិកនឹងជួយស្វែងរក សន្តិភាពឲ្យប្រទេសកម្ពុជា ។

ដោយមានគំនិតស្ងួននឹងរបបសាធារណរដ្ឋ សុងហ៊ី បាន សម្រេចចូលជាសមាជិកសេ.អ៊ី.អា នៅខែមេសា ឆ្នាំ១៩៧០ តាមរយៈ ឡុង បុត្តា ។ សុងហ៊ី បានចូលរួមគ្រប់សកម្មភាពរបស់ សេ.អ៊ី.អា ដូចជាចូលរួមហ៊ឹកហ៊ឺននយោបាយដើម្បីពង្រឹងគោល ជំហរស្នេហាជាតិនិងបាតុកម្មគាំទ្ររបបសាធារណរដ្ឋខ្មែរ ។

ឆ្នាំ១៩៧១ សុងហ៊ី ជានិស្សិតឆ្នាំទី៤និងជានិស្សិតសាលា គរុវិជ្ជាជាន់ខ្ពស់ ។ សុងហ៊ី និងមិត្តរបស់គាត់ពីរនាក់ឈ្មោះ ប៊ូ នឹម និង ប៉ែន ម៉ានីល បន្តធ្វើសកម្មភាពនយោបាយនៅក្នុងសាលា គរុវិជ្ជាជាន់ខ្ពស់ទៀត ដែលមាន បុត្តា ជាមេសេ.អ៊ី.អា ។ សុងហ៊ី បានឃោសនានៅក្នុងពិធីប្រជុំតូចធំនៅសាលារៀន ដោយបាន ពន្យល់ណែនាំនិស្សិតជាច្រើនឲ្យត្រៀមខ្លួនចូលជាសមាជិកគណបក្ស សង្គមសាធារណរដ្ឋខ្មែរ ។នៅក្នុងទស្សនាវដ្តី សុងហ៊ី ឃោសនានិង ទម្លាក់កំហុសទៅលើខ្មែរក្រហមអំពីភាពសាហាវឃោរឃៅរបស់ ពួកនេះ ។ ក្រៅពីនេះ សុងហ៊ី ដើរស៊ើបរកឃើញនិស្សិតបីនាក់ ឈ្មោះ យុន ស្រ៊ុន, ស៊ុន ដារា និង ទេព ស៊ុន បានដើរធ្វើវិទ្ធង្សនា សម្ងាត់ប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ ។ សុងហ៊ី បានបញ្ជូន ទាំងបីទៅឲ្យ ឡុង បុត្តា យកទៅដាក់ឃុំឃាំងនិងវាយសួរចម្លើយ ។ ក្រៅពីនេះ សុងហ៊ី បានរាយការណ៍ឲ្យគេចាប់សាស្ត្រាចារ្យមួយ ចំនួនមាន សុខ ឃី, លឹម នា និង វ៉ាន់ ស ។

នៅឆ្នាំ១៩៧២ ជាឆ្នាំដែលត្រូវបោះឆ្នោតជ្រើសរើស ប្រធានាធិបតី សុងហ៊ី ជាអនុប្រធានទី២នៅសាលាគរុកោសល្យ ជាន់ខ្ពស់ ។ សុងហ៊ី បានធ្វើសកម្មភាពយ៉ាងអស់ពីចិត្តពីថ្លើមក្នុង គាំទ្របេក្ខភាពរបស់លន់នល់ ។ សុងហ៊ី មានភារកិច្ចស៊ើបពីសកម្ម ភាពរបស់គណបក្សប្រជាធិបតេយ្យដែលគាំទ្រ អ៊ិន តាំ និងតែង តែផ្តល់ព័ត៌មានអំពីគណបក្សនេះទៅឲ្យគណបក្សសាធារណរដ្ឋខ្មែរ ។

នៅឆ្នាំ១៩៧៣ សុងហ៊ី បានទទួលអាហារូបករណ៍ទៅ សិក្សានៅប្រទេសបារាំង ។ នៅពេលទៅដល់ប្រទេសបារាំងភ្លាម ផាន់ បួយហាក់ ដែលជាអ្នកទទួលខុសត្រូវខាងនិស្សិតនិងជា សេ.អ៊ី.អា ធ្វើការនៅស្ថានទូតខ្មែរ បាននាំ សុងហ៊ី ទៅស្នាក់នៅ

ខេត្តណង់ស៊ី ដែលជាកន្លែងនិស្សិតខ្មែររស់នៅច្រើន ហើយអ្នកទាំងនោះសុទ្ធតែគាំទ្ររបបសាធារណរដ្ឋខ្មែរ ។

នៅឆ្នាំ១៩៧៤ សុងហ៊ី ត្រូវបានជ្រើសរើសឲ្យធ្វើជាអគ្គលេខាធិការនៃសមាគមនិស្សិតនៅខេត្តណង់ ស៊ី បន្ទាប់ពី ជ័យ សឿន ។ នៅក្នុងការទំនាក់ទំនងនយោបាយ សុងហ៊ី តែងតែទាក់ទងយ៉ាងជិតស្និទ្ធ សារី ស៊ីផាន់, គី ផាត់, មៀច សួន, ហូ ផៃវ៉ត់, លាង លឹមហេង និង កើត សាវ៉ាត ។ សុងហ៊ី បានធ្វើសកម្មភាពប្រឆាំងនឹងសមាជិករណសិរ្សរួបរួមជាតិកម្ពុជា នៅប្រទេសបារាំង និងសរសេរអត្ថបទថ្កោលទោសខ្មែរក្រហម និង សម្តេច សីហនុ ថាជាអ្នកទទួលខុសត្រូវក្នុងការធ្វើឲ្យប្រទេសជាតិធ្លាក់ក្នុងគ្រោះមហន្តរាយនិងជាអ្នកសមគំនិតជាមួយវៀតណាមមកសម្លាប់ជាតិឯង ។

ដើម្បីជួយលើកតម្កើងរបបសាធារណរដ្ឋខ្មែរ សុងហ៊ី បានរៀបចំការសម្តែងសិល្បៈខ្មែរបុរាណមួយដើម្បីឲ្យបរទេសទស្សនា នៅក្នុងពេលនោះ សុងហ៊ី បានធ្វើការប្រឆាំងដាច់ខាតចំពោះនយោបាយរបស់រណសិរ្ស ហើយថាអ្នកទាំងអស់នេះសុទ្ធតែជាកូនចៅរបស់ ហូជីមិញ និងម៉ៅសេទុង ។ នៅពេលពួកគ្រាប់ផ្លោងចូលទីក្រុងភ្នំពេញម្តងៗ សុងហ៊ី តែងហៅសមាជិកសមាគមថ្កោលទោសខ្មែរក្រហមនិងរៃអង្គាសថវិកា ដើម្បីផ្តល់ជាជំនួយមនុស្សធម៌ដល់អ្នករងគ្រោះនៅភ្នំពេញ ។ លើសពីនេះ សុងហ៊ី ថែមទាំងបានផ្ញើញត្តិទៅអង្គការសហប្រជាជាតិសុំឲ្យមានការចរចាគ្នារវាងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរនិងខ្មែរក្រហមដើម្បីបញ្ចប់សង្គ្រាមនៅក្នុងប្រទេសកម្ពុជា ។ នៅខែសីហា សុងហ៊ី ត្រូវបានសាលាអនុញ្ញាតឲ្យទៅបំពេញកម្មសិក្សានៅប្រទេសកាណាដាដែលនៅទីនោះ សុងហ៊ី បានជួបនិស្សិតខ្មែរជាច្រើន ។ សុងហ៊ី បានឆ្លៀតឱកាសនោះឃោសនាពីអំពើឃោរឃៅរបស់ខ្មែរក្រហម ។

ឆ្នាំ១៩៧៥ សុងហ៊ី បានទទួលតំណែងជាប្រធានសមាគម ។ សុងហ៊ី បានទាក់ទងយ៉ាងជិតសិទ្ធជាមួយ កេង វ៉ាន់សាក់, ប៊ុង ម៉ានយ៉ា និង ហុង ហឿងខឿង ដែលជាអគ្គរដ្ឋទូតប្រចាំនៅប្រទេសអេស្ប៉ាញ ។ នៅក្នុងសកម្មភាពនយោបាយ សុងហ៊ី មិនបានធ្វើអ្វីក្រៅតែពីដឹកនាំសម្តែងសិល្បៈនិងដឹកនាំការប្រឆាំងតាមទស្សនាវដ្តីប៉ុណ្ណោះ ។ ប៉ុន្តែមួយខែក្រោយមក សុងហ៊ី បានលាលែងពីតំណែងនេះដើម្បីទុកពេលវេលាធ្វើសកម្មភាពប្រឆាំងនឹងខ្មែរក្រហម ។ ការលាលែងតំណែងនេះបានធ្វើឲ្យមជ្ឈដ្ឋានសមាជិកនៅក្នុងសមាគមមានការភ្ញាក់ផ្អើលមែនទែន ។ សុងហ៊ី បានផ្អាកសកម្មភាពរបស់ខ្លួនរហូតដល់ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ។

នៅដើមខែឧសភា ឆ្នាំ១៩៧៥ កេង វ៉ាន់សាក់ បានមកប្រាប់ដំណឹងឲ្យ សុងហ៊ី ត្រៀមខ្លួនត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍ ។ នៅថ្ងៃទី១៧ ធ្នូ សុងហ៊ី បានវិលត្រឡប់មកប្រទេសកម្ពុជា ។ ពេលមកដល់ព្រលានយន្តហោះពោធិ៍ចិនតុងភ្លាម សុងហ៊ី ស្លុតចិត្តជាអតិបរមាដោយឃើញសភាពស្ងាត់ជ្រងំនៅទីក្រុងភ្នំពេញ ។ សុងហ៊ី ត្រូវអង្គការនាំមកដាក់នៅអគារមួយដែលជាផ្ទះរបស់សាស្ត្រាចារ្យសូវៀតពីមុនអស់រយៈពេល៥ខែ ។

ឆ្នាំ១៩៧៦ អង្គការបានឲ្យ សុងហ៊ី បំពេញប្រវត្តិរូបរបស់ខ្លួនជូនអង្គការ ។ នៅក្នុងការឆ្លើយនឹងសំណួរពាក់ព័ន្ធនឹងជីវទស្សន៍ សុងហ៊ី សារភាពថាសេពគប់តែជាមួយអ្នកណាដែលមិនមែនជាខ្មែរក្រហម និងច្រើនតែនិយាយវាយប្រហារអង្គការពីក្រោយខ្នង ប៉ុន្តែសកម្មភាពជាក់ស្តែង សុងហ៊ី ខិតខំធ្វើការងារយ៉ាងសកម្មដើម្បីឲ្យអង្គការមើលឃើញន្ទាលនឹងខ្លួនឆាប់បានចេញពីមន្ទីរទៅធ្វើការនៅជនបទ ។ សុងហ៊ី តែងបានទាក់ទងការងារសម្ងាត់ជាមួយ ប៊ុន ចន្ទសេរី (មកពីបារាំង) និយាយអំពីផែនការផ្សេងៗដែលខ្លួនបានទទួល ។ ក្រៅពីឈ្មោះនេះ សុងហ៊ី មិនបានទាក់ទងអ្នកផ្សេងទេ ព្រោះខ្លាចលេចឮដល់អង្គការ ។ ក្រោយមកអង្គការបានបញ្ជូន សុងហ៊ី មកនៅសហករណ៍តាឡីរយៈពេលមួយខែ ។ សុងហ៊ី បានជួប ឌឹក យង់ជាតិ, ចាំង សេងណុង, ណុប សារុំ, ឈូក សាគុន និង វ៉ង់ ម៉ុងស្រេង ។ តាមរយៈមិត្តភក្តិរបស់គាត់មួយចំនួនទៀត ដែលទើបមកពីប្រទេសបារាំង សុងហ៊ី បានដឹងថានៅប្រទេសបារាំងកាសែតបានផ្សព្វផ្សាយថា អង្គការបានចាប់បញ្ញាជនជាច្រើននាក់ទៅសម្លាប់ចោល ។ បន្ទាប់មកទៀត សុងហ៊ី ត្រូវអង្គការបញ្ជូនទៅនៅព្រែកឫស្សី ។ នៅទីនោះ សុងហ៊ី តែងបង្កទំនាស់ដើម្បីឲ្យបរិយាកាសរស់នៅក្នុងមន្ទីរមានសភាពមិនល្អ ។ ជាមួយមិត្តភក្តិខាងលើ សុងហ៊ី តែងតែជជែកអំពីអនាគតរបស់ប្រទេសកម្ពុជា និងបញ្ញាជនគ្រប់រូបដែលទើបវិល

ចូលប្រទេស ។

សុងហ៊ី នៅតែមិនពេញចិត្តនឹងលទ្ធិកុម្មុយនិស្តដដែល ហើយត្រៀមខ្លួនថានឹងធ្វើសកម្មភាពនៅថ្ងៃណាដែលរបបសេរីវិលត្រឡប់មកវិញ ។ ប៉ុន្តែឋិតក្នុងស្ថានភាពនេះ សុងហ៊ី មិនអាចមានលទ្ធភាពបំពេញភារកិច្ច សេ.អ៊ី.អា បានឡើយ ហើយគាត់ស្តាយក្រោយដែលបណ្តោយខ្លួនឲ្យធ្លាក់ចូលក្នុងអន្ទាក់របស់ខ្មែរក្រហម ។ ទោះជាយ៉ាងណា សុងហ៊ី នៅតែមានជំនឿថា អង្គការមិនអាចរកឃើញខ្លួនគាត់ជាសេ.អ៊ី.អាឡើយ ។ ប៉ុន្តែ ទីបំផុត សុងហ៊ី ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១២ តុលា ឆ្នាំ១៩៧៦ នៅព្រែកឫស្សី និងសម្លាប់ចោលនៅថ្ងៃទី២៨ ខែមករា ១៩៧៧ ។ សុងហ៊ី ត្រូវបានសួរចម្លើយចំនួន១១លើកដោយពួកទី៩ ឈ្មោះ នៅ នី ។

**អំពីសាច់ញាតិ**

ឪពុកឈ្មោះ ហេង យួង និងម្តាយឈ្មោះ សំ នាង ។

**បងប្អូនបង្កើត** : ◆ សុងហ៊ី មានបងប្អូន៧នាក់ ◆ បងប្រុសទី១ ឈ្មោះ សុង លី ធ្វើការនៅហាងស៊ាំងគេលាខ្មែរ ◆ ទី២) ហេង គីមហន ប្តីឈ្មោះ ភោគ សម្បត្តិ ជាគ្រូបង្រៀននៅខេត្តកំពង់ចាម ◆ ទី៣) ហេង សុងជ្រា ធ្វើគ្រូបង្រៀននៅខេត្តកំពង់ចាម និងប្អូនបីនាក់ទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយ ។

**ឪពុកមា** : ◆ ឈ្មោះ កង លីហ៊ាង ធ្វើតំណាងរាស្ត្រនឹងក្រោយមកចូលធ្វើទាហានពាក់ស័ក្តិ៤ក្នុងរបបសាធារណរដ្ឋខ្មែរ ◆ យូ តែអុង ធ្វើសាស្ត្រាចារ្យកំពង់ចាម ។

**បងប្អូនជីដូនមួយ** : ◆ ចាំង ស៊ាងឡុង វិស្វករនៅក្រសួងសាធារណការ ◆ ឈុន ហួរ វិស្វករនៅមន្ទីរអន្តរជាតិខាងមេកុង ។

ខាងក្រោមនេះជាឈ្មោះដែល សុងហ៊ី ស្គាល់និងមានទំនាក់ទំនងក្នុងការងារ ÷

**សូមរាយការណ៍ជូនអង្គការពីបក្សពួកក្បត់** : ◆ កេង វ៉ាន់សាក់ ធ្វើទូតនៅប្រទេសបារាំង ស្រុកកំណើត នៅកំពង់ចាម ◆ ជ័យ សឿន និស្សិតនៅប្រទេសបារាំង ស្រុកកំណើតនៅព្រៃវែង ◆ ហូ ដៃវ៉ែត និស្សិតនៅប្រទេសបារាំង ស្រុកកំណើតនៅបាត់ដំបង ◆ លាង លីមហេង និស្សិតនៅប្រទេសបារាំង ស្រុកកំណើតនៅកំពង់ចាម ◆ កើយ សាវ៉ាត និស្សិតនៅប្រទេសបារាំង ស្រុកកំណើតនៅភ្នំពេញ ◆ ឡុង បុត្តា សាស្ត្រាចារ្យ ស្រុកកំណើតភ្នំពេញ ◆ ជាវ ស៊ាងលាន សាស្ត្រាចារ្យ ស្រុកកំណើតនៅភ្នំពេញ ◆ តាន់ ប៊ុនសួរ សាស្ត្រាចារ្យ ស្រុកកំណើតនៅកណ្តាល ◆ ស៊ូ ឃឹម សាស្ត្រាចារ្យ ស្រុកកំណើតនៅកណ្តាល ◆ ឃឹះ ជៀវ សាស្ត្រាចារ្យ ស្រុកកំណើតនៅខេត្តសៀមរាប ។

**នៅភូមិតាឡី** : ◆ គង់ ប៊ុនចន្ទសេរី ស័ក្តិ៤កន្ទះ ស្រុកកំណើតនៅខេត្តកណ្តាល ◆ សុខា សក្តិពីរ ស្រុកកំណើតនៅខេត្តតាកែវ ◆ តុល ស័ក្តិបី ស្រុកកំណើតនៅកំពង់ឆ្នាំង ◆ ខុក ជី ស័ក្តិពីរ ស្រុកកំណើតនៅខេត្តបាត់ដំបង ◆ ជាញ់ ស័ក្តិពីរ ស្រុកកំណើតនៅកម្ពុជាក្រោម ◆ តាន់ ឈុនម៉េង ស័ក្តិមួយ ស្រុកកំណើតនៅខេត្តកណ្តាល ◆ សារីស៊ីផាន់ គីផាត់ និស្សិតស្រុកកំណើតនៅកម្ពុជាក្រោម ។

**នៅក្រសួងការបរទេស** : ◆ គាត ឆុន រដ្ឋមន្ត្រី ស្រុកកំណើតនៅខេត្តកំពង់ចាម ◆ អ៊ិន សុភាព និស្សិត ស្រុកកំណើតនៅខេត្តក្រចេះ ◆ ស៊ាង ប៉ៅសែ អភិបាលខាងសុរិយោដី ស្រុកកំណើតនៅខេត្តកណ្តាល ◆ ហោ ភិន និស្សិត ស្រុកកំណើតនៅខេត្តកណ្តាល ◆ លី ហួវ និស្សិត ស្រុកកំណើតនៅខេត្តកណ្តាល ◆ លឹម មេត្តា និស្សិត ស្រុកកំណើតនៅបាត់ដំបង ។

**ផ្នែកនៅក្នុងកងទ័ព** : ◆ យូ គីមយាត សាស្ត្រាចារ្យ ស្រុកកំណើតនៅកំពង់ចាម ◆ យឹប ចន្ទថា និស្សិត ស្រុកកំណើតនៅភ្នំពេញ ◆ លី ដារា និស្សិត ស្រុកកំណើតនៅភ្នំពេញ ◆ សំ ណុល សិស្ស ស្រុកកំណើតនៅកំពង់ចាម ◆ លី ភាវ សិស្ស ស្រុកកំណើតនៅកំពង់ចាម ◆ កង សុធា និស្សិត ស្រុកកំណើតនៅបាត់ដំបង ។

**ផ្នែកនៅរោងចក្រ** : ◆ ហេង កាអូន សាស្ត្រាចារ្យ ស្រុកកំណើតនៅកំពង់ចាម ◆ អេង ម៉េងហ៊ុន និស្សិតស្រុកកំណើតនៅកំពង់ចាម ◆ អេង ម៉េងហ៊ាង និស្សិតស្រុកកំណើតនៅកំពង់ចាម ◆ ស៊ាង ប៉ោយាង អ្នកជំនួញ ស្រុកកំណើតនៅកណ្តាល ◆ ឃិន សុខ អភិបាលកសិកម្ម ស្រុកកំណើតនៅកណ្តាល ◆ ប៉ែន ម៉ានីល សាស្ត្រាចារ្យ ស្រុកកំណើតនៅកណ្តាល ◆ សេង ស៊ីផា សាស្ត្រាចារ្យ ស្រុកកំណើតនៅបាត់ដំបង ។

**លី សុផល**

# មជ្ឈមណ្ឌលឯកសារកម្ពុជាប្រគល់ឯកសារពីរបបកម្ពុជាប្រជាធិបតេយ្យ ជូនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រគល់ឯកសារដែលទាក់ទងទៅនឹងរបបខ្មែរក្រហមជូនការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការប្រគល់ឯកសារទាំងនេះគឺក្នុងគោលបំណងបម្រើដល់ការស៊ើបអង្កេតរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និងចៅក្រមគ្រប់លំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ឯកសារទាំងនេះមានទម្រង់ជាមីក្រូហ្វីលដែលមានចំនួន៥២៨ដុំស្មើនឹង៣៨៣.១៨៩ទំព័រ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានថតចម្លងចេញពីឯកសារដើមនៅក្នុងបណ្ណសារដ្ឋានរបស់ខ្លួន ។ ក្នុងចំណោមឯកសារទាំងនេះ រួមមានឯកសារប្រវត្តិរូបរបស់កម្មាភិបាលខ្មែរក្រហម ឯកសារចម្លើយសារភាពបញ្ជីជនរងគ្រោះដែលឯកសារសាទូរលេខ ទស្សនាវដ្តីទង់បដិវត្តន៍និងយុវជនយុវនារីបដិវត្តន៍ កំណត់ហេតុស្តីពីកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បក្សកុម្មុយនិស្តកម្ពុជា អត្ថបទកាសែត កំណត់ហេតុប្រចាំថ្ងៃរបស់កម្មាភិបាលខ្មែរក្រហមដែលបានកត់ត្រាពីការសិក្សានយោបាយយុទ្ធសាស្ត្រកងទ័ព កសិកម្ម និងលក្ខន្តិកៈរបស់បក្ស ។ ក្រៅពីប្រភេទឯកសារទាំងនេះ នៅមានឯកសារពីរបប សាធារណរដ្ឋខ្មែរឯកសាររណសិរ្សដែលជាពាក្យបណ្តឹងរបស់ប្រជាជនធ្វើឡើងក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងឯកសារជាបទសម្ភាសន៍នៃគម្រោងជម្រុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រភេទឯកសារផ្សេងៗជាច្រើនទៀត ។

**ឌី ខាំបូលី**







# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយ : យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ៣៧៧៥ | ឆុំ ទុយ | ភ័ស្តុភារ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៧៦ | ដាម ថុន ហៅ ម៉ៃ | អនុនយោបាយ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៧៧ | ម៉ុ កិ ហៅ យ៉េង | លេខាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៧៨ | ង៉ំា ស្រ៊ាង ហៅ ក្តី | យោធាកងធំ | កងពល៩២០ | ៣០-៣-៧៧ | ១០-៦-៧៧ |
| ៣៧៧៩ | ពាន ខា ហៅ ឆាត | លេខាកងធំ | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ៣៧៨០ | ស៊ឹម សុង | អនុនយោបាយ | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ៣៧៨១ | គីម ជ្រឿន ហៅ បុល | លេខាកងធំ | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ៣៧៨២ | ឆឹម ខន ហៅ ខែម | យោធាកងធំ | កងពល៩២០ | ១៦-៤-៧៧ | ១០-៦-៧៧ |
| ៣៧៨៣ | សួន មាន | យោធាកងធំ | កងពល៩២០ | ១៨-៤-៧៧ | ១០-៦-៧៧ |
| ៣៧៨៤ | ឌិត ព ហៅ ឃី | លេខាកងធំ | កងពល៩២០ | ២៩-៤-៧៧ | ១០-៦-៧៧ |
| ៣៧៨៥ | ដឹប សំ ហៅ សន | យុទ្ធជន | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ៣៧៨៦ | មឿង សុផុន ហៅ ផេង | យុទ្ធជន | កងពល៩២០ | ២-៥-៧៧ | ១០-៦-៧៧ |
| ៣៧៨៧ | សូ រឹម | យុទ្ធជន | កងពល៩២០ | ២-៥-៧៧ | ១០-៦-៧៧ |
| ៣៧៨៨ | អ៊ុម យឿន ហៅ រឿន | យុទ្ធជន | កងពល៩២០ | ២-៥-៧៧ | ១០-៦-៧៧ |
| ៣៧៨៩ | អ៊ិន អ៊ុន ហៅ យុទ្ធ | យុទ្ធជន | កងពល៩២០ | ២-៥-៧៧ | ១០-៦-៧៧ |
| ៣៧៩០ | ក្រូច ចិត ហៅ ធឹម | យុទ្ធជន | កងពល៩២០ | ២-៥-៧៧ | ១០-៦-៧៧ |
| ៣៧៩១ | ដុំ ជឿន ហៅ ភាព | យុទ្ធជន | កងពល៩២០ | ២-៥-៧៧ | ១០-៦-៧៧ |
| ៣៧៩២ | ម៉ក់ យ៉ាហ៊ុង ហៅ ឈើ | យុទ្ធជន | កងពល៩២០ | ២៩-៤-៧៧ | ១០-៦-៧៧ |
| ៣៧៩៣ | ដួប ស្តើង ហៅ ធី | យុទ្ធជន | កងពល៩២០ | ១៨-៤-៧៧ | ១០-៦-៧៧ |
| ៣៧៩៤ | ប៉ុល បាវ ហៅ រិត | យុទ្ធជន | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៩៥ | ឡុង រ៉េត ហៅ ម៉ុន | យុទ្ធជន | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៩៦ | នូ ខន | យុទ្ធជន | កងពល៩២០ | ២៤-៣-៧៧ | ១០-៦-៧៧ |
| ៣៧៩៧ | ដូ ឡាំងអាង ហៅ សាត | យុទ្ធជន | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ៣៧៩៨ | មាន ឈឹន ហៅ ឈឹន | ប្រធានកងតូច | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៩៩ | ដាម ទឹង | ប្រធានកងតូច | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៨០០ | សំ បូរ ហៅ ចិត្ត | យោធាកងតូច | កងពល៩២០ | ៣០-៣-៧៧ | ១០-៦-៧៧ |
| ៣៨០១ | សុក លី ហៅ រ៉េន | ប្រធានកងតូច | កងពល៩២០ | ៣០-៣-៧៧ | ១០-៦-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២៨០២ | ខៀវ អ៊ន់ ហៅ វៀន | យោធាកងតូច | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៨០៣ | ក្រូច សឹម ហៅ រិន | ប្រធានកងតូច | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៨០៤ | សៀង សន ហៅ សឹន | យោធាកងតូច | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៨០៥ | ប្រាក់ ទ្រី ហៅ អុន | យុទ្ធជន | កងពល៩២០ | ១៨-៤-៧៧ | ១០-៦-៧៧ |
| ២៨០៦ | យី យន ហៅ សន្តាន់ | មេពួកបើកបរ | កងពល៩២០ | ១៨-៤-៧៧ | ១០-៦-៧៧ |
| ២៨០៧ | ដៀប ឈឿន ហៅ ហុន | យុទ្ធជន | កងពល៩២០ | ២-៥-៧៧ | ១០-៦-៧៧ |
| ២៨០៨ | សួង អៀប | យុទ្ធជននេសាទ | កងពល៩២០ | ១៤-៤-៧៧ | ១០-៦-៧៧ |
| ២៨០៩ | អ៊ី សំអុន | យុទ្ធជន | កងពល១៧០ | ១០-៦-៧៧ | ១១-៦-៧៧ |
| ២៨១០ | តី បុល | យុទ្ធជន | កងពល១៧០ | ១០-៦-៧៧ | ១១-៦-៧៧ |
| ២៨១១ | ហេង សាមុត ហៅ វិបុល | យុទ្ធជន | កងពល១៧០ | ១០-៦-៧៧ | ១១-៦-៧៧ |
| ២៨១២ | សោម សឹង ហៅ សាំ (ស្រី) | ប្រពន្ធ ឃួន ហៅ ឆុន | ? | ? | ១៤-៦-៧៧ |
| ២៨១៣ | ញាវ លន ហៅ លាត (ស្រី) | ប្រពន្ធ យូ ហៅ ហាន | ? | ? | ១៤-៦-៧៧ |
| ២៨១៤ | គ្រឹម គ្រឿន ហៅ គៀន (ស្រី) | ប្រពន្ធ ធួន | ? | ? | ១៤-៦-៧៧ |
| ២៨១៥ | ប៉ុល គា ហៅ វឿន (ស្រី) | ប្រពន្ធ ភី | ? | ? | ១៤-៦-៧៧ |
| ២៨១៦ | ហ៊ុម យ៉ាន់ ហៅ យិន (ស្រី) | ប្រពន្ធ ហៀង ហៅ គ្រឿន | ? | ? | ១៤-៦-៧៧ |
| ២៨១៧ | អ៊ិត ម៉ុន (ស្រី) | ប្រពន្ធ ប៊ុន ដឿន ហៅ ដុំ | ? | ? | ១៤-៦-៧៧ |
| ២៨១៨ | គង់ ចាន់ថា (ស្រី) | ប្រពន្ធ អួង ថុន | ? | ? | ១៤-៦-៧៧ |
| ២៨១៩ | ឡេង ហួយ (ស្រី) | ប្រពន្ធ យឹម ហៅ វ៉ាន់ | ? | ? | ១៤-៦-៧៧ |
| ២៨២០ | សាយ គឹមអេន (ស្រី) | ប្រពន្ធ ប៉ាន់ ស៊ុម | ? | ? | ១៤-៦-៧៧ |
| ២៨២១ | ម៉ែន ផលជាតិ (ស្រី) | ប្រពន្ធ ឌុច ផែល | ? | ? | ១៤-៦-៧៧ |
| ២៨២២ | ង៉ួន ហ៊ាន់ ហៅ ស៊ីណា (ស្រី) | គ្រួសារ ស៊ុំនួន | ? | ? | ១៤-៦-៧៧ |
| ២៨២៣ | ហុក ម៉េត ហៅ ម៉ុន (ស្រី) | ប្រពន្ធ ហឹង ឃ្វី ហៅ ថែម | ? | ? | ១៤-៦-៧៧ |
| ២៨២៤ | គង់ សាវ៉ាត (ស្រី) | ប្រពន្ធ ខៀវយស់ សាវត្ថិ | ? | ? | ១៤-៦-៧៧ |
| ២៨២៥ | សួន សុខហ៊ាង ហៅ ភាព (ស្រី) | ប្រពន្ធ ឡឹក សុង | ? | ? | ១៤-៦-៧៧ |
| ២៨២៦ | ហេង សេរី ហៅ ធា (ស្រី) | ប្រពន្ធ អៀង ហៅ សូត្រ | ? | ? | ១៤-៦-៧៧ |
| ២៨២៧ | អួន អេង ហៅ អាត (ស្រី) | ប្រពន្ធ ឈឹម ហៅ ស្រ៊ន់ | ? | ? | ១៤-៦-៧៧ |
| ២៨២៨ | សូ អេត ហៅ ពុំ (ស្រី) | ប្រពន្ធ អេង សេង ហៅ សឹម | ? | ? | ១៤-៦-៧៧ |
| ២៨២៩ | លឹម ថេត ហៅ ដេត (ស្រី) | ប្រពន្ធ ធឹម ឌឿន | ? | ? | ១៤-៦-៧៧ |
| ២៨៣០ | ខោល យ៉េ ហៅ ឃឹម (ស្រី) | ប្រពន្ធ ជា ឆៃហេង ហៅ ភី | ? | ? | ១៤-៦-៧៧ |
| ២៨៣១ | អ៊ិត អឿន (ស្រី) | ប្រពន្ធ ឃ្លោក សយ | ? | ? | ១៤-៦-៧៧ |
| ២៨៣២ | គឹម វៀន ហៅ រី (ស្រី) | ប្រពន្ធ ហ៊ាង ហៅ ហុង | ? | ? | ១៤-៦-៧៧ |

**(នៅមានត)**

# រឿងរ៉ាវដែលមិនចេះសាបសូន្យ

## វ៉ែន សំ និងប្តីឈ្មោះ កង ណាន
## អតីតទាហានលន់នល់

***វ៉ែន សំ :*** ក្នុងរបបសង្គមរាស្ត្រនិយម ខ្ញុំលក់នំ បង្អែម និងផ្លែឈើ នៅរោងកុនសុរិយាភ្នំពេញ ។ ក្រុមគ្រួសារខ្ញុំរស់នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ កាលនោះឪ្យតែរួចរដូវធ្វើស្រែ ខ្ញុំនិងម្តាយខ្ញុំមករកស៊ីនៅភ្នំពេញ ។ យើងជួលផ្ទះនៅម្តុំអូរឫស្សី ។

ខ្ញុំមិនបានរៀនសូត្រច្រើនទេ គឺរៀនបានត្រឹមតែថ្នាក់អក្ខរកម្មប៉ុណ្ណោះ ។ ម្តាយខ្ញុំគ្មានលទ្ធភាពឲ្យកូនទាំងអស់ទៅរៀនទេ ហេតុនេះទើបខ្ញុំឈប់រៀនខ្ញុំដើម្បីជួយរកស៊ីជាមួយម៉ែនៅភ្នំពេញ ។

ខ្ញុំជួបប្តីខ្ញុំនៅភ្នំពេញ ។ គាត់ខស្សាហ៍មកហូបបង្អែមរបស់ខ្ញុំ ។ យើងស្គាល់គ្នាបានប្រហែលមួយឆ្នាំគាត់ចូលដណ្តឹងខ្ញុំរៀបការ ។ យើងរៀបការនៅស្រុកកំណើតរបស់ខ្ញុំនៅចុងឆ្នាំ១៩៧០ ។ ពិធីរៀបការប្រព្រឹត្តទៅរយៈពេលមួយយប់មួយថ្ងៃ ។ កាលនោះបាយសម្លដាក់តែនៅក្នុងពាង គ្មានឆ្នាំងដែកដូចឥឡូវនេះទេ ។ ក្រោយរៀបការរួច ខ្ញុំឈប់លក់បង្អែមនៅភ្នំពេញ ហើយវិលទៅរស់នៅស្រុកកំណើតវិញ ។

ឆ្នាំ១៩៧១ យើងបានភៀសខ្លួនទៅនៅថ្នល់បត់ដោយសារភូមិខ្ញុំមានវត្តមានរបស់ខ្មែរក្រហមនិងមានការប្រយុទ្ធតទល់គ្នាជាញឹកញាប់ជាមួយកងទ័ពលន់នល់ ។ នៅថ្នល់បត់ ខ្ញុំសម្រាលកូនស្រីច្បងបានមួយខែ បន្ទាប់មកផ្លាស់ទៅស្នាក់នៅជាមួយម្តាយមីងរបស់ខ្ញុំនៅទីក្រុងភ្នំពេញម្តុំឃ្លាំងរំសេវ ចំណែកឪពុកម្តាយនិងបងប្អូនរបស់ខ្ញុំនៅបន្តស្នាក់នៅថ្នល់បត់ដដែល ។ កាលនោះប្តីរបស់ម្តាយមីងខ្ញុំជាទាហានលន់នល់ពាក់ស័ក្តិបួនកន្ទះ ដូច្នេះប្តីខ្ញុំក៏ចូលធ្វើទាហានដែរ ប៉ុន្តែគាត់មិនចេញទៅច្បាំងញឹកញាប់ទេ ។

ខ្ញុំរស់នៅភ្នំពេញបាន៥-៦ខែ ទីក្រុងភ្នំពេញធ្លាក់ក្នុងកណ្តាប់ដៃខ្មែរក្រហម គ្រួសារខ្ញុំក៏ត្រូវជម្លៀសចេញពីភ្នំពេញដូចជាប្រជាជនដទៃទៀតដែរ ។ ខ្ញុំមិនជឿតាមពាក្យឃោសនារបស់ខ្មែរក្រហមដែលថាចេញតែបីថ្ងៃនោះទេ ព្រោះខ្ញុំឃើញខ្មែរក្រហមចងមនុស្សនឹងអំបោះតូចឆ្មារទាំងខ្សែៗ ហើយអ្នកទាំងនោះមិនហ៊ានកម្រើកប្តូរវ៉ាអ៊ីទាំងអស់ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមិនទាន់ចាកចេញពីផ្ទះនៅឡើយទេ ខ្ញុំនៅដំអក់រង់ចាំម្តាយមីងខ្ញុំ ប៉ុន្តែចាំបាត់ៗមិនឃើញគាត់ត្រឡប់មកផ្ទះវិញសោះ ។ ទីបំផុតខ្ញុំសម្រេចចិត្តចេញទៅចាំគាត់នៅថ្នល់បត់ដោយសង្ឃឹមថាយើងនឹងបានជួបជុំជាមួយម្តាយឪពុកនិងសាច់ញាតិខ្ញុំ ប៉ុន្តែពេលខ្ញុំទៅដល់ថ្នល់បត់ទាំងអស់គ្នាក៏ចេញផុតទៀត ។ នៅរង់ចាំនៅថ្នល់បត់ប្រមាណជា១០ថ្ងៃនិងដោយខ្មែរក្រហមចេះតែដេញសង្កៀញពេក ប្តីខ្ញុំក៏បបួលខ្ញុំទៅស្រុកកំណើតគាត់នៅឃុំពពេល ខេត្តតាកែវ ។ យើងមានស៊ីក្លូមួយសម្រាប់ដឹកអីវ៉ាន់ព្រមទាំងខ្ញុំ និងកូន ។

ពេលយើងទៅដល់ឃុំពពេលដំបូង ខ្មែរក្រហមចែកស្រូវឲ្យតាមគ្រួសារ ហើយបែងចែកការងារឲ្យយើងធ្វើ ។ ការងារខ្ញុំនៅពេលនោះគឺដេរស្លឹក បេះកប្បាស និងធ្វើដី ។ ខ្ញុំរស់នៅផ្ទះជាមួយឪពុកម្តាយក្មេកខ្ញុំ ។ គាត់ជាប្រជាជនមូលដ្ឋាន ហើយជារឿយៗគាត់លួចលាក់ម្ហូបចំណីយកមកឲ្យខ្ញុំ ។ បានប្រហែលពីរបីខែអង្គការបានបំបែកខ្ញុំនិងប្តីលែងឲ្យនៅជាមួយឪពុកម្តាយ យើងបានទៅរស់នៅភូមិមួយទៀត ដែលមានសុទ្ធតែប្រជាជនថ្មីទាំងអស់ ។ ខ្ញុំនិងប្តីខ្ញុំធ្វើការនៅកងផ្សេងពីគ្នាមួយខែឬពីរខែទើបយើងបានជួបគ្នាម្តង ចំណែកកូនខ្ញុំត្រូវយកទៅប្រគល់ឲ្យយាយៗមើល ។

នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ជូនគ្រួសារខ្ញុំទៅដាំពោតនៅស្រុកកៀនស្វាយ ។ ទៅរស់នៅកៀនស្វាយបាន៦ខែ ខ្ញុំសម្រាលបានកូនប្រុសម្នាក់ទៀត ។ ខ្ញុំឆ្លងទន្លេនៅក្នុងពេទ្យសំរោងធំ ហើយគ្មានថ្នាំពេទ្យទេមានតែថ្នាំបុរាណ ។ អង្គការមិនអនុញ្ញាតឲ្យប្តីខ្ញុំមកថែខ្ញុំទេ ប៉ុន្តែគាត់ឆ្លៀតពេលមកមើលខ្ញុំបានមួយភ្លែតៗ ។ ខ្ញុំត្រូវចុះក្នុងស្ទឹងបោកគក់កន្ទបកូនតាំងពីមិនទាន់ ទម្លាក់ចង្រ្កាន ។ ហេតុនេះហើយបានជាខ្ញុំកើតជំងឺស្ពឹកជើងរហូតមកដល់សព្វថ្ងៃ ។ ខ្ញុំឆ្លងទន្លេមិនដល់មួយខែផងរបបខ្មែរក្រហមក៏ដួលរលំ ។

ក្រុមគ្រួសារខ្ញុំធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ ។

យើងរកឈើអារធ្វើជារទេះដើម្បីដាក់អីវ៉ាន់និងកូនទាំងពីររបស់ខ្ញុំវិញទៅទម្រាំនឹងទៅដល់ស្រុកកំណើតរបស់ខ្ញុំ យើងចំណាយពេលជិតមួយខែ ។


វ៉ែន សំ នៅថ្ងៃអាពាហ៍ពិពាហ៍ ចុងឆ្នាំ១៩៧០

រូបថតមួយសន្លឹកនេះខ្ញុំថតមុនពេលរៀបការ ។ កាលនោះខ្ញុំគិតថាចង់ថតរូបទុកមើលនៅពេលដែលខ្ញុំចាស់ទៅ ។ ខ្ញុំទៅថតនៅហាងថតរូបមួយនៅឃុំកន្ទួត ក្នុងស្រុកកណ្តាលស្ទឹង ។ កាលជំនាន់នោះគ្មានរូបថតពណ៌ទេ មានតែរូបថតស-ខ្មៅ ។ ពេលខ្ញុំផ្លាស់ទៅនៅភ្នំពេញ ខ្ញុំមិនបានយករូបថតនេះទៅជាមួយទេ ខ្ញុំផ្ញើររូបថតនេះជាមួយមិត្តភក្តិម្នាក់ដែលរស់នៅភូមិជាមួយគ្នា ឈ្មោះ អែម ។ ខ្ញុំបានទទួលរូបថតនេះ មកវិញនៅពេលខ្ញុំត្រឡប់មកភូមិក្រោយឆ្នាំ១៩៧៩ ។ កាលនោះខ្ញុំមានរូបថតមួយចំនួនទៀត ដូចជារូបថតរៀបការ ប៉ុន្តែ ខ្ញុំបានទុកចោលនៅលើផ្ទះ ហើយក៏បាត់អស់រលីងដោយសារមិនបានយកចិត្តទុកដាក់ ។ ខ្ញុំមានរូបថតមួយសន្លឹកទៀតដែលទុកនៅនឹងខ្ញុំ ជារូបថតរបស់ប្តីខ្ញុំថតជាមួយមិត្តភក្តិបីនាក់ដែលបានមកចូលរួមក្នុងពិធីរៀបការខ្ញុំដែរ ប៉ុន្តែខ្ញុំមិនស្គាល់ឈ្មោះទេ ។ នៅជំនាន់ប៉ុលពត ខ្ញុំទុករូបថតនេះនៅជាប់នឹងបាតស្មុគរួចទុកចោលនៅផ្ទះ ឈ្លបខ្មែរក្រហមឆែកឆេររកមិនឃើញទើបសល់រហូតដល់សព្វថ្ងៃ ។


កង ណេន នៅថ្ងៃអាពាហ៍ពិពាហ៍ ចុងឆ្នាំ១៩៧០

ខ្ញុំចង់ប្រមូលរូបថតមករក្សាទុកឲ្យកូនមើលដើម្បីឃើញរូបខ្ញុំកាលពីក្មេង និងដើម្បីរំឭករឿងរ៉ាវដែលខ្ញុំធ្លាប់ឆ្លងកាត់ ។ ខ្ញុំបានឆ្លងកាត់សង្គ្រាមជាច្រើនឆ្នាំ ធ្វើឲ្យខ្ញុំព្រាត់ប្រាសបងប្អូន ខ្លះស្លាប់ដោយសារអត់អាហារ ខ្លះស្លាប់ដោយសារខ្មែរក្រហមយកទៅសម្លាប់ ។ ខ្ញុំចង់ឲ្យក្មេងជំនាន់ក្រោយដឹងអំពីការលំបាកដែលឪពុកម្តាយឬមីងមារបស់វាបានជួបប្រទះ ។

**កង ណេន** ៖ ក្រោយរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ខ្ញុំភៀសខ្លួនមករស់នៅទីក្រុងភ្នំពេញ ដើម្បីគេចពីការបង្ខំឲ្យចូលបម្រើកងទ័ពខ្មែរក្រហម ។ បងប្អូនជីដូនមួយរបស់ខ្ញុំ៤-៥នាក់ មកជាមួយខ្ញុំដែរ ប៉ុន្តែក្រោយមកក៏ត្រឡប់ទៅស្រុកវិញអស់នៅសល់តែខ្ញុំម្នាក់ឯង ។ រូបថតនេះខ្ញុំថតនៅហាងថតរូបភ្នំពេញមុំផ្សារធំថ្មី ។ មិត្តភក្តិខ្ញុំនៅក្នុងរូបថតនេះមានឈ្មោះ ង៉ួយ ឡាយ, វល្លិ និង ស ។ យើងស្គាល់គ្នានៅភ្នំពេញ ហើយខស្បាហ៍ដើរលេងជាមួយគ្នាណាស់ ។ យើងមិនមានគម្រោងថតរូបនេះទេ ហេតុនេះទើបមិនបានស្លៀកពាក់ឲ្យស្អាតបាត ។ យើងស្លៀកខោជើងជ៉ាត់ពាក់អាវយឺតនិងអាវសឺមីដៃវែង ហើយពាក់ស្បែកជើងផ្ទាត់ ។ កាលនោះខ្ញុំមិនទាន់ចូលទាហានលន់នល់នៅឡើយទេ ។


កង ណេន មុនឆ្នាំ១៩៧៥

ខ្ញុំចូលធ្វើទាហានលន់នល់នៅឆ្នាំ១៩៧៣ ហើយមិនមែនចូលដោយស្ម័គ្រចិត្តទេ ។ ខ្ញុំធ្លាប់រត់គេចពីជួរទាហានម្តង ។ លើកទី១ខ្ញុំត្រូវបញ្ជូនឲ្យទៅរៀនក្បួនទ័ពនៅកំបូល ប៉ុន្តែខ្ញុំបានរត់រត់គេច ក្រោយមក ខ្ញុំត្រូវខាងលន់នល់ចាប់ឲ្យធ្វើទាហានម្តងទៀត ហើយបញ្ជូនទៅរៀននៅអំពែភ្នំចំនួនបីខែ ។ បន្ទាប់ពីបញ្ចប់ការហាត់រៀន ខ្ញុំមកឈរជើងនៅកងជំនួយនៅតាខ្មៅ ។ ខ្ញុំបានចូលសមរភូមិទួលក្រសាំង ។ ក្រោយមកមិនយូរប៉ុន្មានឪពុកមាខាងប្រពន្ធខ្ញុំឈ្មោះ អ៊ូម ថន ជាទាហានស័ក្តិបួនកន្លះ បានហៅខ្ញុំនិងប្រពន្ធខ្ញុំទៅរស់នៅជាមួយគាត់ ។ ចាប់តាំងពីទៅរស់នៅជាមួយឪពុកមា ខ្ញុំមិនដែលបានចេញទៅសមរភូមិទេ គាត់ឲ្យខ្ញុំនៅផ្ទះជួយមើលការខុសត្រូវកូនទាហានរបស់គាត់ ។

ខ្ញុំមានបងប្អូនបង្កើត៦នាក់ ។ ក្នុងចំណោមបងប្អូនខ្ញុំទាំងអស់មានតែខ្ញុំនិងបងប្រុសខ្ញុំឈ្មោះ កង ណេន ទេដែលធ្លាប់ធ្វើទាហាន ។ យើងមានស្រុកកំណើតនៅភូមិចោមពល ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ។

ម្តាយធម៌ខ្ញុំជាអ្នកនាំខ្ញុំទៅស្តីដណ្តឹងប្រពន្ធខ្ញុំ ។ ប្រពន្ធខ្ញុំឈ្មោះ វ៉ែន សំ ។ កាលពីពេលខ្ញុំមិនទាន់ស្គាល់គាត់ ខ្ញុំធ្លាប់ទៅហូបបន្អែមនៅកន្លែងរបស់គាត់ដែរ ប៉ុន្តែខ្ញុំមិនបានចាប់ភ្នែកទេ ទើបតែក្រោយពេលដែលម្តាយធម៌ខ្ញុំបង្ហាញរូបថតរបស់គាត់ ទើបខ្ញុំស្គាល់ហើយក៏ចូលដណ្តឹងរៀបការតាមប្រពៃណី ។ ខ្ញុំរៀបការនៅចុងឆ្នាំ១៩៧០ ។ ក្រោយរៀបការរួច យើងផ្លាស់ប្តូរលំនៅជាច្រើនកន្លែងដើម្បីរត់គេចពីការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនិងទាហានលន់នល់ ។

រូបថតមួយសន្លឹកទៀតនេះគឺជារូបថតមួយកំណាត់ខ្លួនដែលខ្ញុំថតសម្រាប់បិទកាតនៅឆ្នាំ១៩៧១ គឺក្រោយពេលរៀបការប្រហែលមួយឆ្នាំ ។ ខ្ញុំដាក់រូបថតនេះជាប់ខ្លួនរហូតទោះជានៅក្នុងរបបប៉ុលពតក៏ដោយ ។ ខ្ញុំលាក់វានៅក្នុងសម្លៀកបំពាក់ ។ នៅពេលខ្ញុំចេញទៅធ្វើការ ឈ្លបខ្មែរក្រហមបានមករើកកាយសម្លៀកបំពាក់របស់ខ្ញុំហើយបានឃើញរូបថតនេះដែរ ប៉ុន្តែមិនបានចាប់កំហុសខ្ញុំទេ ដោយសារខ្ញុំថតក្នុងសំលៀកបំពាក់ស៊ីវិល ។ នៅពេលរបបខ្មែរក្រហមដួលរលំទៅ ខ្ញុំនៅសល់តែរូបថតនេះទេ ចំណែកឯកាតត្រូវទឹកខូចអស់ទៅហើយ ។

ពេលខ្ញុំមើលរូបថតទាំងអស់នេះ ខ្ញុំនឹកមិត្តភក្តិខ្ញុំណាស់ ។ ខ្ញុំនឹកឃើញសម្លៀកបំពាក់ដែលខ្ញុំស្លៀកថតនៅពេលនោះ ។ ខ្ញុំបានយកសម្លៀកបំពាក់នោះទៅជាមួយនៅពេលជម្លៀសចេញពីភ្នំពេញដែរ ប៉ុន្តែខ្ញុំបានយកសម្លៀកបំពាក់ទាំងនោះទៅដូរជាមួយប្រជាជនមូលដ្ឋានអស់ហើយ ។ អ្នកមូលដ្ឋានចូលចិត្តអាវយឺតណាស់ ។

ម្យ៉ាងទៀត រូបថតនេះធ្វើឲ្យខ្ញុំនឹកឃើញជីវិតខ្ញុំកាលពីពេលនោះ ដែលមានឪពុកម្តាយបងប្អូននៅជួបជុំគ្នាទាំងអស់ ។ សង្គ្រាមធ្វើឲ្យយើងព្រាត់ប្រាសគ្នា ។ បងប្អូនខ្ញុំស្លាប់អស់៥នាក់ នៅសល់តែខ្ញុំនិងប្អូនប្រុសខ្ញុំម្នាក់ប៉ុណ្ណោះ ។ ខ្ញុំស្តាយរូបថតឪពុកម្តាយដែលបានបាត់បង់នៅក្នុងរបបខ្មែរក្រហម បើមិនដូច្នោះទេខ្ញុំអាចបង្ហាញដល់កូនៗរបស់ខ្ញុំដែរហើយ ។ ◆◆◆

## ជា ជឿន និង ប៊ិត រិន

***សព្វថ្ងៃរស់នៅភូមិស្ពានថ្មី ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកំពង់ចាម***

ជា ជឿន និង ប៊ិត រិន ត្រូវជាប្តីប្រពន្ធនឹងគ្នា ដែលអង្គការបានរៀបការឲ្យនៅក្នុងឆ្នាំ១៩៧៨ ។ អ្នកទាំងពីរជម្លៀសចេញពីស្រុកភូមិជាមួយគ្នា ប៉ុន្តែមិនស្គាល់គ្នាទេ ។ ខាងក្រោមនេះគឺជាការរៀបរាប់របស់ ជា ជឿន និង ប៊ិត រិន ÷

**អំពី ជា ជឿន**


ជា ជឿន អាយុ២០ឆ្នាំ ជំនាន់សម្តេចសីហនុ

ខ្ញុំរៀនបានថ្នាក់ទី៤ នៅសាលាវត្តក្នុងភូមិរបស់ខ្ញុំ ។ ខ្ញុំរៀនមុខវិជ្ជាអក្សរសាស្ត្រ ។ ពេលខ្លះខ្ញុំរៀនអក្សរបាលីជាមួយលោក ។ ពេលណាលោកបិណ្ឌបាត ខ្ញុំដើរបិណ្ឌបាតជាមួយលោកដែរ ។ ក្រោយមកដោយសារជីវភាពខ្ញុំក្រខ្សត់ពេក ខ្ញុំសុំលោកឈប់រៀនដើម្បីទៅជួយធ្វើស្រែចម្ការឪពុកម្តាយ ។ នៅក្នុងរបបលន់នល់ ភូមិរបស់ខ្ញុំត្រូវខ្មែរក្រហមគ្រប់គ្រង ហើយខ្មែរក្រហមឃោសនាឲ្យប្រជាជនចូលធ្វើកងទ័ព ។ បើសិនជាអ្នកណាប្រឆាំងពិតជាត្រូវស្លាប់ ។ នៅពេលយប់ខ្មែររំដោះចូលក្នុងភូមិ ។ នៅពេលថ្ងៃទាហានលន់នល់ចូលភូមិខ្ញុំ ។ អង្គការចាត់តាំងឲ្យខ្ញុំចូលបម្រើបដិវត្ត ប៉ុន្តែខ្ញុំមិនព្រមចូល ព្រោះប្រថុយគ្រោះថ្នាក់ច្រើនពេក ហើយខ្ញុំមិនចង់ចូលបដិវត្តន៍ដែរ ។ ខ្ញុំសុខចិត្តធ្វើស្រែចម្ការនៅភូមិរបស់ខ្ញុំវិញ ។

ប្អូនប្រុសខ្ញុំចូលធ្វើកងទ័ព ។ យើងជាកសិករ បើយើងរត់ចោលផ្ទះ ចោលដីស្រែ យើងប្រាកដជាអត់មានអីហូប ។ កងទ័ពដែលចូលភូមិខ្ញុំដំបូងធ្វើជាចិត្តល្អជាមួយយើង ខ្លះមកសុំបន្លែផ្លែឈើយើងហូប ខ្លះទៀតព្រលឹមឡើងមកក្រោមផ្ទះយើងជួយដឹកគោយកទៅឲ្យស៊ីស្មៅរួចជាស្រេច ។ អង្គការឃោសនាយើងឲ្យជឿជាក់លើបដិវត្តន៍ដោយការលើកទឹកចិត្តឲ្យយុវនារីយកកង់ទៅឌុបយុវជនពីក្នុងភូមិឲ្យចូលបម្រើបដិវត្តន៍ ។

នៅក្នុងរបបខ្មែរក្រហមអង្គការចាត់តាំងឲ្យខ្ញុំធ្វើប្រធានឈ្លបមើលការខុសត្រូវប្រជាជន១៧មេសាចំនួន២៧នាក់ ដែលអ្នកទាំងនោះភាគច្រើនជាគ្រូបង្រៀន ពេទ្យ និងអ្នកធ្វើការនៅអាកាសចរណ៍ស៊ីវិល ។ បើសិនជាខ្ញុំប្រកែក ខ្ញុំពិតជាត្រូវចោទប្រកាន់ថា ខ្ញុំជាខ្មាំងស៊ីរូងផ្ទៃក្នុងឬក៏ចោទថាជាជន ចក្រពត្តិ ឬជា

សេ.អ៊ី.អា របស់អាមេរិក ។ ខ្ញុំត្រូវតែសម្របខ្លួនតាមបដិវត្តន៍ ។ ពេលខ្ញុំធ្វើឈ្លបអ្នកភូមិស្រលាញ់រាប់អានខ្ញុំគ្រប់ៗគ្នា ។

ខ្ញុំដឹកនាំប្រជាជនថ្មីទៅធ្វើការ ។ ខ្ញុំទៅបើករបបអង្ករក្នុងម្នាក់បានតែ១ស្លាបព្រាប៉ុណ្ណោះ ។ ក្រុមរបស់ខ្ញុំមានសមាជិក ២៧នាក់បើកអង្ករបាន៤ខាំ ។ យើងហូបមិនគ្រប់គ្រាន់ទេ បើយើងមិនចេះច្នៃប្រឌិតរកបន្លែអ្វីមកហូបបន្ថែមទេ យើងមុខជាមិនបានរស់ឡើយ ។

ក្រោយមកអង្គការជម្លៀសខ្ញុំទៅនៅបាក់ខែង ។ ពេលនោះ អង្គការចាត់តាំងឲ្យខ្ញុំឃ្វាលគោ ។ នៅទីនោះមានការសម្លាប់មនុស្សច្រើនណាស់ ។ ការសម្លាប់មនុស្សគឺយកក្រណាត់ខ្មៅចងមុខ ហើយធាក់ចូលទៅក្នុងរណ្តៅ បន្ទាប់មកដោះខោអាវចេញពីអ្នកស្លាប់ ។ ១ថ្ងៃក្រោយមក អង្គការយកខោអាវទាំងនោះយកមកចែកឲ្យយើងវិញ ។

នៅបាក់ខែង អង្គការបែងចែកអ្នកមានសាច់ញាតិធ្វើទាហាន ឬប្រជាជន១៧មេសាឲ្យរស់នៅដាច់ដោយឡែកពីគ្នា ដោយអង្គការនិយាយថាបានបោសសម្អាតខ្មាំងអស់ហើយ ។ ប្រជាជនភាគច្រើនបាត់ខ្លួននៅពេលយប់ ។ អង្គការប្រាប់ប្រជាជនឲ្យទៅប្រជុំទាំងយប់ ហើយអ្នកដែលហៅទៅប្រជុំទាំងប៉ុន្មានបាត់ខ្លួនទាំងអស់មិនឃើញត្រឡប់មកវិញទេ ។

អង្គការចាត់តាំងឲ្យខ្ញុំដាំដំណាំ ។ ពេលទទួលផលបានអង្គការមិនឲ្យយើងហូបឯកជនទេ គឺឲ្យយកផលទាំងនោះទៅដាក់រួម ។ ក្រុមរបស់ខ្ញុំគឺជាក្រុមសាមគ្គីផលិត ។ យើងគ្រាន់តែជាអ្នកផលិតតែប៉ុណ្ណោះ ។ យើងអត់មានអ្វីជាកម្មសិទ្ធិផ្ទាល់ខ្លួនទេ ក្រៅពីបង្ហិចខោអាវតូចមួយប៉ុណ្ណោះ ។

មានពេលមួយអង្គការចាប់ខ្ញុំដាក់គុក ដោយកុហកថាឲ្យខ្ញុំទៅរាវខ្មៅ ។ អង្គការចោទខ្ញុំថាជាខ្មែរស ធ្វើចលនាបំផុសបំផុលប្រជាជន ។ នៅក្នុងបន្ទប់នោះមានពាងទឹកមួយនិងអ្នកទោស ២៥នាក់ ។ នៅក្នុងគុកខ្ញុំមើលមិនឃើញពន្លឺថ្ងៃទេ ។ អ្នកទោសនៅទីនោះមានទាំងប្រជាជន១៧មេសានិងប្រជាជនមូលដ្ឋាន ។ ពេលយើងឃើញមុខគ្នាម្តងៗ យើងយំទាំងអស់គ្នា ។ ខ្ញុំត្រូវបានដោះលែងមកវិញដោយសារគណៈស្រុកជួយខ្ញុំ ។

នៅពេលមួយពេលខ្ញុំចែវទូកទៅច្រូតស្មៅឲ្យគោស៊ី ឈ្លបឃាត់ខ្ញុំមិនឲ្យចេញទូក ហើយក៏មិនប្រាប់ថាខ្ញុំត្រូវរៀបគ្រួសារដែរ ។ អង្គការសួរខ្ញុំថា តើខ្ញុំមានឪពុកម្តាយទេ? ខ្ញុំនិយាយថាមានតែឪពុក ។ ឈ្លបក៏ទៅតាមឪពុកខ្ញុំមក ។ ខ្ញុំរៀបការនៅក្នុងឆ្នាំ១៩៧៨ ជាមួយនារី បិត រិន ដែលជាប្រពន្ធរបស់ខ្ញុំសព្វថ្ងៃនេះ ។ ប្រពន្ធដែលអង្គការចាត់តាំងឲ្យខ្ញុំរៀបការជាមួយ គឺខ្ញុំមិនដែលស្គាល់គ្នាពីមុនមកទេ ។ មុនពេលរៀបការ អ្នកជិតខាងម្នាក់បានឲ្យយោបល់ខ្ញុំថាគួរតែរៀបការទៅ ។ ខ្ញុំប្រាប់គាត់វិញថា ខ្ញុំមិនទាន់ចង់បានប្រពន្ធទេ ព្រោះសេចក្តីស្លាប់មិនទៀងទាត់ទេ មិនដឹងជាយើងត្រូវស្លាប់នៅពេលណាទេ ។ ខ្ញុំផ្តាំផ្ញើគាត់ថាបើបាត់ខ្ញុំសូមទៅយកខោអាវខ្ញុំផង ។ យើងស្លៀកពាក់សម្លៀក បំពាក់ខ្មៅបង់កក្រម៉ានិងពាក់ស្បែកជើងកង់ឡាន ។ ពេលខ្ញុំមកដល់កន្លែងរៀបចំពិធី ខ្ញុំឃើញមានរៀបទង់ក្រហម ញញួរ និងកណ្តៀវរួចជាស្រេច ។ អង្គការឲ្យយើងឡើងប្តេជ្ញាថាស្រលាញ់គ្នានិងទទួលយកគ្នាអស់មួយជីវិត ហើយយើងក៏បែកគ្នារៀងៗខ្លួន ។ ខ្ញុំអត់ស្គាល់ផ្ទះប្រពន្ធខ្ញុំទេ ។ នៅពេលល្ងាចប្រធានភូមិថា ហេតុអ្វីបានជាខ្ញុំគេច ។ ខ្ញុំស្ទាក់ស្ទើរព្រោះខ្ញុំមិនសូវស្រលាញ់ ។ អង្គការតាមខ្ញុំឲ្យទៅផ្ទះខាងស្រីបីដង ។ ខ្ញុំមិនដឹងផ្ទះនោះនៅទីណាទេ ខ្ញុំចេះតែដើរៗទៅជួប ឈួន ជាអ្នកនៅក្នុងភូមិនោះដែរ គាត់ប្រាប់ខ្ញុំអំពីផ្ទះប្រពន្ធរបស់ខ្ញុំ ។ យើងរស់នៅជាមួយគ្នាបានតែ១សប្តាហ៍កងទ័ពវៀតណាមក៏វាយរំដោះប្រទេស ។ មានមនុស្សម្នាជាច្រើនផ្អើលទៅយកអង្ករ ចំណែកខ្ញុំល្ងាចឡើងបានខ្ញុំទៅយក ។ កងទ័ពវៀតណាមចាប់ខ្ញុំដាក់គុកអស់កន្លះខែដោយចោទប្រកាន់ខ្ញុំថាជាខ្មែរក្រហម ។ ខ្ញុំជាប់ឃុំឃាំងនៅស្តាតអូឡាំពិកមួយរយៈកងទ័ពវៀតណាមក៏ដោះលែងខ្ញុំ ដោយសារមានអ្នកទោសចាប់មកកាន់តែច្រើនឡើងៗ ។

រូបថតរបស់ខ្ញុំមួយសន្លឹកនេះ ខ្ញុំថតតាំងពីអាយុ២០ឆ្នាំនៅក្នុងជំនាន់សម្តេច ។ ខ្ញុំថតនៅផ្សាររកាកោង ជាងថតរូបឈ្មោះ ហុក ។ រយៈពេល១អាទិត្យទើបខ្ញុំយករូបថតនេះបាន ។ ខ្ញុំថតរូបនេះដើម្បីយកទៅធ្វើកាតប្រជាជន ព្រោះបើយើងគ្មានកាតនេះទេ យើងមិនអាចធ្វើដំណើរផ្លូវឆ្ងាយបានឡើយ ។ បើយើងធ្វើសំបុត្របញ្ជាក់យើងអាចប្រើប្រាស់បានតែរយៈពេល ៣ខែទេ ប៉ុន្តែបើធ្វើកាតយើងអាចប្រើបានរហូត ។ នៅក្នុងជំនាន់

លន់ នល់ ខ្ញុំឈប់ប្រើកាតនេះទៀតហើយ ខ្ញុំត្រូវប្រើកាតមួយទៀត ។ កាតទី២នេះ ខ្ញុំធ្វើនៅខែមករា ឆ្នាំ១៩៧១ ។ នៅក្នុងរបបខ្មែរក្រហម អង្គការអត់មានឆែករកកាតនិងរូបថតទេ គឺដកហូតយកតែចាន ឆ្នាំង មាស ប្រាក់តែប៉ុណ្ណោះ ហើយទុកតែស្លាបព្រាមួយ ចានមួយ និងកំសៀវដាំទឹកមួយ យើងទៅណាក៏ស្ពាយកាមែលដាក់បាយទៅដែរ ។

បងប្អូនរបស់ខ្ញុំមាន៦នាក់ ។ នៅក្នុងរបប លន់ នល់ បងប្អូនខ្ញុំត្រូវរស់នៅបែកគ្នា ខ្លះជាប្រជាជនមូលដ្ឋាន និងខ្លះទៀតជាប្រជាជនជម្លៀស ។ បងប្អូនខ្ញុំខ្លះនៅខាងទឹកដីរំដោះ និងបងប្អូនខ្ញុំខ្លះទៀតនៅខាងទឹកដីដែលកាន់កាប់ដោយ លន់ នល់ ។ យើងមិនអាចទាក់ទងគ្នាបាន ។ យើងរស់នៅខណ្ឌដោយវណ្ណៈមួយដែលផ្ដាច់មនោសញ្ចេតនាបងប្អូន ។ ខ្ញុំមិនចង់ជួបរបបនេះម្ដងទៀតទេ ។

**អំពី បិត រិន**


បិត រិន ក្នុងវ័យ១៩ឆ្នាំ ជំនាន់សម្ដេចសីហនុ

ខ្ញុំគឺជាកូនទី៣នៅក្នុងចំណោមបងប្អូន៤នាក់ ។ បងប្រុសខ្ញុំពីរនាក់បាត់ខ្លួននៅក្នុងរបបខ្មែរក្រហម ។ សព្វថ្ងៃនៅរស់តែខ្ញុំនិងប្អូនពៅរបស់ខ្ញុំប៉ុណ្ណោះ ។ ពីដើមខ្ញុំរៀនអក្សរសាស្ត្រខ្មែរដល់ថ្នាក់ទី៩ ។ នៅអាយុ១៨ឆ្នាំខ្ញុំឈប់រៀនដោយសារម្ដាយខ្ញុំស្លាប់នៅសល់តែឪពុកខ្ញុំ ។ ដូច្នេះខ្ញុំត្រូវនៅផ្ទះដាំបាយឲ្យគាត់ និងមើលខុសត្រូវកិច្ចការក្នុងផ្ទះ ។ ឪពុកម្ដាយខ្ញុំធ្វើជាកសិករ ។

ខ្ញុំរៀបការនៅអាយុ២៧ឆ្នាំ ។ នៅមិនទាន់ចង់រកប្ដីពីក្មេងទេ ព្រោះមិនទាន់ចេះធ្វើម្ហូប ។ ម្យ៉ាងចង់ជួយរកលុយដើម្បីឲ្យបងប្រុសខ្ញុំបានទៅរៀននឹងគេ ។ ពេលខ្ញុំនៅរៀនក៏មានមិត្តភក្តិរៀនជាមួយគ្នាចាប់អារម្មណ៍ខ្ញុំដែរ ប៉ុន្តែខ្ញុំមិនចាប់អារម្មណ៍ ។ កាលពីដើមមនុស្សភាគច្រើនរៀបការនៅអាយុក្មេងៗ ។ ប្រុសរៀបការចាប់ពីអាយុ១៩ឆ្នាំឡើងទៅ និងស្រីរៀបការចាប់ពីអាយុ១៦ឆ្នាំ ។

នៅក្នុងជំនាន់ លន់ នល់ ស្ថានភាពក្នុងភូមិរបស់ខ្ញុំមានភាពជ្រួលច្របល់ ។ ភូមិរបស់ខ្ញុំ កាន់កាប់ដោយកងទ័ពរំដោះ ។ អង្គការហៅខ្ញុំនិងប្រជាជននៅក្នុងភូមិទៅសែងអ្នករបួសនៅសមរភូមិ ។ អ្នកនៅក្នុងភូមិខ្ញុំក៏ទៅធ្វើការដូចខ្ញុំដែរ ។ ដោយសារសុខភាពខ្ញុំល្អ ខ្ញុំមិនដែលមានជំងឺឬបញ្ហាអ្វីទេ ។ ពេលកងទ័ពខ្មែរក្រហមចូលដល់ភូមិរបស់ខ្ញុំ ចរាចរធ្វើដំណើរត្រូវបានផ្អាក ទំនិញនៅលើទីផ្សារកាន់តែឡើងថ្លៃ ។ យើងចាប់ផ្ដើមស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅតាំងពីឆ្នាំ១៩៧២ ។ ខ្ញុំត្រូវបង្ខំចិត្តប្រគល់គង់ឲ្យទៅអង្គការសម្រាប់ឲ្យយុវនារីដឹកយុវជននៅក្នុងភូមិទៅធ្វើការ ។ ខ្ញុំលះបង់អស់ហើយទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ខ្ញុំ ។

នៅឆ្នាំ១៩៧៥ ខ្ញុំជម្លៀសទៅបាក់ខែង ។ ខ្ញុំយកបានគោមួយនឹមនិងរទេះមួយគ្រឿង ។ ពេលនោះខ្មែរក្រហមជម្លៀសប្រជាជនពីភ្នំពេញមកនៅភូមិរបស់ខ្ញុំ ។ មុនពេលដែលខ្ញុំចេញទៅរស់នៅបាក់ខែង ភូមិរបស់ខ្ញុំសុទ្ធតែអ្នកមូលដ្ឋានចាស់រស់នៅ ។ ប៉ុន្តែអ្នកទាំងនោះក៏ត្រូវផ្លាស់ប្តូរទីកន្លែងទៅនៅភូមិក្បែរៗនោះដែរ ។ ខ្ញុំជម្លៀសទៅនៅបាក់ខែងពីរនាក់ប្អូនខ្ញុំ ព្រោះឪពុកខ្ញុំស្លាប់ដោយជំងឺតាំងពីនៅពេលបែកទីក្រុងភ្នំពេញ ។

ពេលខ្ញុំទៅដល់បាក់ខែង មានប្រជាជនដែលជម្លៀសចេញពីភ្នំពេញនៅទីនោះជាស្រេច ។ ខ្ញុំរស់នៅជាមួយគ្រួសារមួយឈ្មោះ យាយសុំ និងតាជា នៅក្នុងផ្ទះក្បឿងមួយ ។ យើងរស់នៅជាមួយគ្នាបានសុខសប្បាយណាស់ ។ យើងស្រលាញ់គ្នាដូចជាឪពុកម្ដាយនិងកូន ។

កាលណោះខ្ញុំយករូបថតនិងធាតុឪពុកម្ដាយខ្ញុំទៅជាមួយដែរ ។ ធាតុគាត់ទាំងពីរខ្ញុំលាក់នៅលើក្បាលដំណេកក្រោយរាំងនន ។ ឈ្លបមិនហ៊ានរើបន្ទប់ដេករបស់ខ្ញុំទេ ។ ក្រោយមកអង្គការដកហូតផ្ទះដែលខ្ញុំស្នាក់នៅធ្វើជាកន្លែងដាក់ពោតវិញ ។

អង្គការចាត់តាំងឲ្យខ្ញុំគាស់ដំឡូង កាប់ព្រៃគាស់គល់រាំងនិងទៅស្ទូងស្រូវ ។ ខ្ញុំធ្វើការនៅក្នុងក្រុមសាមគ្គី ។ រស់នៅក្នុងកងចល័តនិងស្នាក់នៅវត្តជាមួយមនុស្សជាង៤០០នាក់ទៀត ។ អង្គការចាត់តាំងឲ្យខ្ញុំធ្វើប្រធានក្រុមគ្រប់គ្រងសមាជិក១២នាក់ ដែលអ្នកទាំងនោះជាអ្នកមកពីស្រុកភូមិជាមួយខ្ញុំ ។ នៅក្នុងក្រុម ខ្ញុំមានវ័យចំណាស់ជាងគេ ។ ក្រៅពីធ្វើការងារដូចកូនក្រុម អង្គការឲ្យខ្ញុំធ្វើជាគ្រូបង្រៀន ។

ក្រោយមក អង្គការចាត់តាំងឲ្យខ្ញុំដេរសម្លៀកបំពាក់នៅវត្ត

ចំបក់មាស ។ នៅទីនោះមានម៉ាស៊ីនដេរចំនួន៦គ្រឿង ។ ខោអាវដែលដេរហើយយកទៅចែកឲ្យប្រជាជននៅក្នុងសហករណ៍ ។ ក្រណាត់ដែលខ្ញុំដេរជាប្រភេទក្រណាត់ជាឌីបពណ៌ខ្មៅ ។ ខ្ញុំដេរផង និងធ្វើការនៅស្រែផង ។ ពេលណាធ្វើស្រូវបានផលច្រើនអង្គការ ឲ្យយើងហូបបាយជាមួយសម្លការីនិងស្ងោរត្រពាំងដើងជ្រូក ។ ក្រោយមកយើងហូបបបរវិញ ។ ពេលខ្លះយើងហូបបបរលាយជាមួយពោត ។ ទោះបីហូបមិនឆ្អែតក៏យើងមិនហ៊ានរអ៊ូប្តូរវ៉ាអ៊ីទេ ។ របបអាហាររវាងអ្នកមូលដ្ឋាននិងប្រជាជនជម្លៀសគឺដូចគ្នា ។

នៅឆ្នាំ១៩៧៨ អង្គការចាត់តាំងឲ្យខ្ញុំរៀបការជាមួយបុរសម្នាក់ឈ្មោះ ជា ជឿន ។ នៅថ្ងៃនោះមានកូនកំលោះនិងកូនក្រមុំ១០គូ ។ ពិធីរៀបការធ្វើនៅក្នុងរោងបាយសហករណ៍ ។ នៅពេលពិធីនេះចប់ យើងត្រឡប់មកនៅមូលដ្ឋានរៀងៗខ្លួនវិញ ។ ក្នុង១ឆ្នាំមានរៀបចំពិធីមង្គលការពីរវគ្គ ។ ខ្ញុំរៀបការនៅវគ្គទី២ ។ អង្គការឲ្យយើងអង្គុយតម្រៀបគ្នា ហើយឡើងប្តេជ្ញាម្នាក់ម្តងៗ ទទួលយកគ្នាជាប្តីប្រពន្ធ ។ ខ្ញុំមិនដែលបានឃើញមុខកូនកំលោះពីមុនមកទេ ។ ពេលរៀបការហើយ យើងរស់នៅជាមួយគ្នា អង្គការឈប់ឲ្យយើងទៅធ្វើការទីឆ្ងាយៗហើយ គឺយើងធ្វើការនៅតែក្នុងភូមិ ។ ក្រោយមកយើងផ្លាស់ទៅរស់នៅផ្ទះមួយទៀត ព្រោះផ្ទះ ចាស់របស់ខ្ញុំអង្គការយកធ្វើជាឃ្លាំងដាក់ពោត ។


បិត វិន (រូបខាងឆ្វេង) និងអ្នកភូមិ នៅជំនាន់សម្តេចសីហនុ

ពេលកងទ័ពវៀតណាមវាយរំដោះ ខ្ញុំត្រឡប់មកផ្ទះរបស់ខ្ញុំវិញ ហើយប្តីខ្ញុំក៏មកតាមដែរ ព្រោះស្រុកកំណើតគាត់នៅទីនោះដែរ ។ បងប្អូនរបស់ខ្ញុំកាលណោះខ្លះជាប្រជាជនមូលដ្ឋាន និងខ្លះទៀតជាប្រជាជនជម្លៀស ។ នៅក្នុងរបបខ្មែរក្រហមយើងមិនអាចទាក់ទងគ្នាបាន ។ ខ្ញុំទើបតែបានជួបគ្នាវិញក្រោយពេលដែលរបបខ្មែរក្រហមត្រូវបានបញ្ចប់ ។

ពេលខ្ញុំជម្លៀសទៅបាក់ខែង ខ្ញុំយករូបថតដែលនៅក្នុងសុំកញ្ចក់ដាក់វាត្រួតៗគ្នា ហើយរក្សាទុកក្នុងហិបធំមួយ ។ ពេលទៅធ្វើការនៅការដ្ឋាន ប្អូនខ្ញុំដែលធ្វើការនៅក្នុងភូមិឃើញឈ្លបឡើងផ្ទះខ្ញុំឆែកឆេរដែរ ។

រូបថតដែលមានរូបស្រីៗឈរគឺថត នៅឆ្នាំ១៩៧៣ កាលនោះកម្មាភិបាលមកពីខាងភូមិភាគបូព៌ាគេថតឲ្យក្នុងខណៈពេលយើងចុះទៅធ្វើកានៅតាមភូមិ ។ ខ្ញុំមិនដឹងថា កាលណោះថតយកទៅធ្វើអ្វីទេ ។ យើងចេះតែថតតាមគេតាមឯងទៅ ហើយជាងថតចែកឲ្យយើងមួយសន្លឹកទុកមើល ។ នៅក្នុងរូបថតនេះមាន ងឹមម៉ាច និង វ៉ាលី ។ អង្គការហាមមិនឲ្យយើង ពាក់អាវសិចស៊ី ឬមានពណ៌ឆើតឆាយទេ ។ អង្គការឲ្យយើងកាត់សក់ខ្លីគ្រប់ៗគ្នាតាំងពីពេលដែលភូមិរបស់យើងត្រូវខ្មែរក្រហមកាន់កាប់ហៅថាតំបន់រំដោះ ។ ទឹកដីដែលមិនទាន់រំដោះ អង្គការហៅថាជាតំបន់ខ្មាំង ។

រូបថតមួយសន្លឹកដែលស្ត្រី៤នាក់ឈរថតទន្ទឹមគ្នា គឺថតនៅរកាកោង ផ្ទះរបស់ ចឹកហុក ដែលមានអ៊ុតសក់និងថតរូប ។ ចឹកហុក ក៏ធ្វើជាគ្រូបង្រៀនដែរ ។ រូបថតមួយសន្លឹកតម្លៃ២០០០រៀល ក្នុងជំនាន់សម្តេច សីហនុ ។ ខ្ញុំនៅខាងឆ្វេងដៃ ចំណែក៣នាក់ទៀត គឺជាអ្នកភូមិជាមួយគ្នា ។ យើងថតទុកមើលទៅថ្ងៃក្រោយ ។ យើងពាក់អាវប៉ាក់និងសំពត់ដូចៗគ្នា ។ ក្រណាត់សំពត់របស់យើងគឺ ជាក្រណាត់មុយអាដែលមានគុណភាពល្អជាងគេ ។ សម្លៀកបំពាក់នេះគឺសម្រាប់ចូលរួមក្នុងពិធីបុណ្យទានផ្សេងៗ ។ ឯរូបថតមួយសន្លឹកទៀត ខ្ញុំថតពាក់កណ្តាលខ្លួននៅហាងផ្សាររកាកោងក្នុងវ័យ១៩ឆ្នាំ ។

**ប៊ាន ពីរ័ន និង ស៊ីវ សាវីណា**

# គុកខ្មែរក្រហម

*(តពីលេខមុន)*

## ស្រុកកំពង់លែង

### ៥) មន្ទីរសន្តិសុខភូមិចាស់ "មន្ទីរគុណវិបត្តិ"

បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចសីហនុពីតំណែងនៅឆ្នាំ ១៩៧០ ទឹកដីមួយ ផ្នែកធំក្នុងស្រុកកំពង់លែងបានធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់ខ្មែររំដោះ ។ ប្រជាជនភាគច្រើនបានងាកទៅគាំទ្រការដឹកនាំរបស់ខ្មែររំដោះវិញ ។ មន្ទីរអប់រំមួយមានឈ្មោះថា "មន្ទីរគុណវិបត្តិ" បានត្រូវបង្កើតឡើងដើម្បីអប់រំសតិអារម្មណ៍ប្រជាជនដែលក្រុមគ្រួសាររបស់ខ្លួន ត្រូវបាត់បង់ជីវិតដោយសារខ្មែររំដោះសម្លាប់ ព្រោះតែរឹងទទឹង និងប្រជាជនមួយចំនួនដែលពុំទាន់យល់ច្បាស់ពីការដឹកនាំរបស់អង្គការ ។ ជឹម ចុន អាយុ៥៤ឆ្នាំ សព្វថ្ងៃជាប្រធានឃុំដារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំងបានរៀបរាប់ប្រាប់ថា គាត់ត្រូវខ្មែររំដោះចាប់ខ្លួនមកដាក់ក្នុងមន្ទីរគុណវិបត្តិនៅចុងឆ្នាំ១៩៧៤ ព្រោះគាត់បានរត់ចេញពីស្រុកកំណើត ហើយត្រឡប់មករស់នៅវិញដោយមិនគោរពវិន័យអង្គការ ។ អ្នកទោសមួយចំនួនតូចដែលខ្ជិលច្រអូសមិនប្រឹងប្រែងធ្វើការ អ្នកនិយាយប៉ះពាល់ រឿងនយោបាយនិងអ្នកមានជំងឺប្រចាំកាយត្រូវបានសម្លាប់ ចោលដោយគ្មានចាំបាច់សួរចម្លើយ ។ អ្នកទោសខ្លះទៀតត្រូវកងសន្តិសុខបញ្ជាឲ្យធ្វើពលកម្មទាំងយប់ទាំងថ្ងៃនិងផ្តល់របបអាហារឲ្យតិចតួចបំផុត ។

បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មន្ទីរសន្តិសុខមួយទៀតឈ្មោះថាមន្ទីរសន្តិសុខភូមិចាស់ត្រូវបានបង្កើតឡើង ហើយផ្ទេរអ្នកទោសពីមន្ទីរគុណវិបត្តិទាំងអស់ទៅកាន់ទីនោះដើម្បីឃុំឃាំងបន្ត ។ មួយរយៈក្រោយមក អ្នកទោសដែលជាប្រជាជន១៧មេសាយ៉ាងច្រើនបានត្រូវកងឈ្លបនាំយកទៅឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខនេះ ហើយបន្ទាប់មកទៀតបាននាំយកទៅសម្លាប់ចោលនៅក្នុងព្រៃមួយឈ្មោះ "ទួលតាសំ" ដោយគ្មានបានសួរនាំអ្វីទាំងអស់ ។ ទួលនេះស្ថិតនៅចម្ងាយប្រហែល១០០ម៉ែត្រពីមន្ទីរសន្តិសុខភូមិចាស់ ។ ខេ ខឿន ជាមេសន្តិសុខប្រចាំភូមិចាស់ ហើយសព្វថ្ងៃគាត់មានទីលំនៅ ភូមិគុយ ឃុំដារ ។ ជឹម ចុន និយាយថា ខេ ខឿន មិនបានសម្លាប់ មនុស្ស ដោយផ្ទាល់ដៃទេ ប៉ុន្តែបានបញ្ជាឲ្យអ្នកនៅក្រោមបង្គាប់ខ្លួនយកមនុស្សទៅសម្លាប់ ។

មន្ទីរសន្តិសុខភូមិចាស់ បានរលាយបាត់ស្រមោលនៅដើមឆ្នាំ១៩៧៩ ហើយទីតាំងទាំងមូលត្រូវទុកចោលរហូតមកដល់សព្វថ្ងៃ ។ ប្រជាជនទូទៅតែងហៅអតីតមន្ទីរសន្តិសុខនេះខុសៗគ្នាថា មន្ទីរចាស់ មន្ទីរភូមិចាស់ មន្ទីរភូមិគុយ និងមន្ទីររវៀងជួរចាស់ ។

#### ទិន្នន័យសង្ខេប

**ទីតាំង** ៖ មន្ទីរគុណវិបត្តិ ស្ថិតនៅក្នុងភូមិគុយ ឃុំដារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ** ៖ មន្ទីរគុណវិបត្តិ បានបង្កើតឡើងមុនមន្ទីរសន្តិសុខភូមិចាស់ សម្រាប់ឃុំឃាំងជនរងគ្រោះជាប្រជាជនមូលដ្ឋានដែលមានបងប្អូនសាច់ញាតិត្រូវខ្មែរក្រហមសម្លាប់ដោយសារប្រឆាំងនឹងអង្គការ ។ អ្នកទោសមួយភាគដែលជាប់នៅក្នុងមន្ទីរនេះត្រូវកងឈ្លបសម្លាប់ចោល ព្រោះតែមិនគោរពបទបញ្ជារបស់អង្គការ ។

### ៦) មន្ទីរសន្តិសុខវែង "មន្ទីរតាពាង"

មន្ទីរសន្តិសុខវែង ឬមន្ទីរសន្តិសុខតាពាង ឬមន្ទីរសន្តិសុខស្រុកកំពង់លែង ត្រូវបានបង្កើតឡើងនៅដើមឆ្នាំ១៩៧៥ក្បែរជើងភ្នំថ្មរៀង ឃុំប្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។ រោងជាច្រើនត្រូវបានសាងសង់ឡើងតាមខ្នាតតែមួយ មានសណ្ឋានជាបន្ទាយទាហានដែលមានទំហំបណ្តោយចាប់ពី២០ម៉ែត្រទៅ ៥០ម៉ែត្រ និងទទឹង៥ម៉ែត្រ ។ បណ្តាញអគ្គិសនី និងម៉ាស៊ីនកិនស្រូវមួយគ្រឿងត្រូវបានរៀបចំនិងតម្លើងនៅក្នុងមន្ទីរនេះ ។ អគារពីរខ្នងដែលនៅទល់មុខគ្នា ជាកន្លែងសម្រាប់កម្មាភិបាលខ្មែរក្រហមស្នាក់នៅ ហើយមានតែអគារពីរនេះប៉ុណ្ណោះដែលមានអគ្គិសនីសម្រាប់ប្រើប្រាស់ ។ ក្រៅពីនេះ នៅមានមន្ទីរមួយចំនួនទៀតសម្រាប់ឃុំឃាំងអ្នកទោសជាប្រជាជនមូលដ្ឋាន ឬអ្នក

មានគុណវិបត្តិធ្ងន់ធ្ងរដែលបញ្ជូនមកពីមន្ទីរសន្តិសុខភូមិចាស់ ។ ចំណែកផ្ទះមួយខ្នងស្ថិតនៅចុងខាងត្បូងមន្ទីរសន្តិសុខវែង គឺជាមន្ទីរឃុំឃាំងប្រជាជនជម្លៀស ។ ប៉ុន្តែផ្ទះនេះមិនអាចឃុំឃាំងប្រជាជនជម្លៀសអស់ទេ ព្រោះមានចំនួនច្រើនពេក ដែលខ្លះស្នាក់នៅខាងក្រៅផ្ទះ ក្រោមដើមឈើ និងនៅលើដីទួលជុំវិញបរិវេណមន្ទីរឃុំឃាំង ។ អ្នកទោសជាប្រជាជនជម្លៀសមិនអាចឆ្លងចូលទៅស្នាក់នៅក្នុងបរិវេណមន្ទីរឃុំឃាំងអ្នកមានគុណវិបត្តិឡើយ ។

ពាង ជាប្រធាន សន្តិសុខនៅមន្ទីរវែង និងជាអ្នកគ្រប់គ្រងលើផ្នែកទាំងអស់ ។ ពាង បានបម្រើអង្គការយ៉ាងល្អឥតខ្ចោះ ។

មានមន្ទីរធំៗចំនួនបីគឺ មន្ទីរឃុំឃាំងប្រជាជនមូលដ្ឋាន មន្ទីរឃុំឃាំងប្រជាជនជម្លៀសនិងរោងកិនស្រូវសុទ្ធតែមានកម្មាភិបាលខ្មែរក្រហមមួយចំនួនបង្កប់នៅក្នុងនោះ នៅក្នុងមន្ទីរនីមួយៗ ដើម្បីស៊ើបរកអ្នកដែលមានគំនិតមិនស្មោះត្រង់ចំពោះអង្គការ ។ ប្រជាជនមូលដ្ឋានត្រូវកងឈ្លបយកទៅសម្លាប់តិចជាងប្រជាជនជម្លៀស ។


វត្តសម្តេចមុនី

ជីម ចុន ដែលជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខភូមិចាស់ ហើយដែលត្រូវបញ្ជូនមកមន្ទីរសន្តិសុខវែង បានរៀបរាប់ពីអ្នកគ្រប់គ្រងនៅមន្ទីរនីមួយៗថា បានខិតខំធ្វើការតាមបញ្ជារបស់គាពាង ដោយយកចិត្តទុកដាក់បំផុត ហើយតែងធ្វើការប្រជុំជារៀងរាល់ថ្ងៃ ។ អ្នកទោសជាប្រជាជនជម្លៀស មិនត្រូវបានអនុញ្ញាតឲ្យចេញទៅបំពេញការងារពលកម្មឡើយ គឺរង់ចាំតែថ្ងៃយកទៅសម្លាប់ចោលប៉ុណ្ណោះ ។ ចុន សង្កេតឃើញអ្នកទោសខ្លះអង្គុយក្រោមដើមឈើទាំងអស់សង្ឃឹម ព្រោះដឹងថាខ្លួនពិតជាត្រូវសម្លាប់នៅរយៈពេលប៉ុន្មានថ្ងៃខាងមុខមិនខាន ។ ចុន បន្តថា នៅពេលរសៀលម៉ោង៣ មានប្រជាជនជម្លៀសពី៥០ទៅ១០០នាក់ ត្រូវបាននាំចូលមន្ទីរឃុំឃាំងជារៀងរាល់ថ្ងៃ ហើយអ្នកដែលត្រូវខ្មែរក្រហមនាំយកទៅសម្លាប់ចោលនៅតាមវាលស្រែនិងជើងភ្នំថ្មរៀងក៏មានចំនួនប្រហាក់ប្រហែលនេះដែរ ។ ចុន បានឃើញរណ្តៅសាកសពជាច្រើន និងស្នាមឈាមពាសពេញវាលស្រែនៅនឹងជើងភ្នំថ្មរៀង នៅពេលដែលគាត់ត្រូវអង្គការចាត់តាំងឲ្យទៅភ្ជួរស្រែនៅជាប់នឹងជើងភ្នំនោះ ។ លាន លូ ជាអតីតអ្នកទោសម្នាក់ដែលជាប់គុកនៅមន្ទីរសន្តិសុខវែងតាំងពីឆ្នាំ១៩៧៣ បាននិយាយថា នៅពេលដែលខ្មែរក្រហមបញ្ជូនគាត់ឲ្យទៅធ្វើស្រែនៅជើងភ្នំថ្មរៀង គាត់ឃើញមានគល់ឬស្សីពីងពង់និងរណ្តៅសាកសពជាច្រើន ។ អ្នកទោសជាប្រជាជនជម្លៀសត្រូវបាននាំយកទៅសម្លាប់ចោលជារៀងរាល់ថ្ងៃ ដោយពុំមានសួរចម្លើយអ្វីឡើយ ។ ចុន បន្តថា ការសម្លាប់មនុស្សបានកើតឡើងតាំងពីពាក់កណ្តាលឆ្នាំ១៩៧៥មក ។ អ្នកទោសជាប្រជាជនមូលដ្ឋានកម្រយកទៅសម្លាប់ដូចប្រជាជនជម្លៀសណាស់ លុះត្រាតែអ្នកទាំងនោះធ្វើឲ្យឃើតយ៉ាវក្នុងការកសាងបដិវត្ត ។

លៀន លូ អាយុ៧៨ឆ្នាំ ដែលរស់នៅភូមិធ្លក ឃុំប្រណូក ស្រុកកំពង់លែង ត្រូវបានដោះលែងឲ្យមកនៅតាមសហករណ៍វិញ បន្ទាប់ពីគាត់ជាប់ទោសអស់រយៈពេលជាច្រើនឆ្នាំនៅក្នុងមន្ទីរសន្តិសុខវែង ។ លូ បានប្រាប់ថា គាត់ត្រូវខ្មែរក្រហមចោទប្រកាន់ថាជាអ្នកមានជាងគេម្នាក់នៅក្នុងភូមិ ។

មន្ទីរសន្តិសុខវែង បានបញ្ចប់សកម្មភាពនៅក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ វត្ថុតាងជាច្រើនមាននៅសល់ក្នុងមន្ទីរសន្តិសុខវែងដូចជា រោងម៉ាស៊ីនកិនស្រូវ កន្ធែងចិញ្ចឹមសត្វនិងឧបករណ៍មួយចំនួនទៀត ។ ប៉ុន្តែក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ

វត្តគាស់ទាំងនោះត្រូវប្រជាជនរុះរើ និងបំផ្លាញគ្មានសល់ឡើយ ។ រហូតមកដល់សព្វថ្ងៃ អតីតមន្ទីរសន្តិសុខវែង គឺជាវាលស្រែធំល្វឹងល្វើយ និងមានតែដើមឈើមួយដើមពីរដើមប៉ុណ្ណោះដុះនៅលើដីមើលដាច់កន្ទុយភ្នែកនេះ ។ ចំណែករណ្តៅទាំងអស់ដែលនៅនឹងដើងភ្នំថ្មរៀងវិញ ក៏ត្រូវដើមឈើគ្រប់ប្រភេទដុះគ្របដណ្តប់ដ៏ជិត ។

### ទិន្នន័យសង្ខេប

**ទីតាំង** ៖ មន្ទីរសន្តិសុខវែង ស្ថិតនៅក្នុងឃុំប្រឡូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ** ៖ មន្ទីរសន្តិសុខវែង ជាមន្ទីរសន្តិសុខធំជាងគេនៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។ មន្ទីរនេះមានឃុំឃាំងអ្នកទោសពីរប្រភេទគឺ ១)មន្ទីរសន្តិសុខវែងសម្រាប់ឃុំឃាំងអ្នកទោសមូលដ្ឋានដែលមានអត្តចរិតពុំសមរម្យនឹងអង្គការប៉ុណ្ណោះ ។ អ្នកទោសប្រភេទនេះភាគច្រើនត្រូវបានដោះលែងវិញ ។ ២)មន្ទីរដែលស្ថិតនៅចុងខាងត្បូងមន្ទីរសន្តិសុខវែង គឺសម្រាប់ឃុំឃាំងប្រជាជនជម្លៀស ហើយក្រោយមកអ្នកទោសទាំងនេះត្រូវនាំយកទៅសម្លាប់ចោលទាំងអស់ ។

## ស្រុកកំពង់ត្រឡាច

### ៧) មន្ទីរសន្តិសុខវត្តចំប៉ា

ក្នុងចម្ងាយប្រហែល១៩គីឡូម៉ែត្រពីសាលាស្រុកប៉ែកខាងកើតមានវត្តមួយឈ្មោះថា វត្តចំប៉ា ឬ វត្តសេរីតេជះ ដែលខ្មែរក្រហមយកធ្វើជាមន្ទីរសន្តិសុខរបស់ខ្លួនរហូតដល់ឆ្នាំចុង១៩៧៨ ។ ព្រះវិហារ និងកុដិធំមួយនៅក្នុងវត្តគឺជាកន្លែងឃុំឃាំងអ្នកទោស ។ ក្រៅពីនេះ ជារោងបាយ កន្លែងស្នាក់នៅរបស់កម្មាភិបាល និងកន្លែងសម្លាប់មនុស្ស ។ គ្មាននរណាដឹងថាមន្ទីរសន្តិសុខនេះចាប់ដំណើរការតាំងពីឆ្នាំណាមកទេ ប៉ុន្តែដឹងត្រឹមតែថាតាំងពីថ្ងៃជ័យជម្នះទី១៧ ខែមេសា ឆ្នាំ១៩៧៥ប៉ុណ្ណោះ ដែលនៅក្នុងនោះមានអ្នកទោសជាប់ឃុំឃាំងយ៉ាងច្រើន ។ ប្រជាជនដែលត្រូវកងឈ្លបចាប់មកដាក់ឃុំឃាំងនៅវត្តចំប៉ា ក៏គ្មានសាក្សីណាម្នាក់បញ្ជាក់ពីអត្តសញ្ញាណឲ្យបានច្បាស់លាស់ដែរ ។ អតីតអ្នកទោសម្នាក់គ្រាន់តែឲ្យដឹងថា អ្នកទោសបី-បួននាក់ដែលជាប់ឃុំឃាំងជាមួយគាត់ជាកសិករធម្មតា និងម្នាក់ទៀតជាគ្រូបង្រៀននៅក្នុងភូមិប៉ុណ្ណោះ ។ ទេព ហឿន អតីតអ្នកទោសម្នាក់នៅក្នុងមន្ទីរសន្តិសុខវត្តចំប៉ាកាលពីឆ្នាំ១៩៧៧ដែលត្រូវកងឈ្លបចាប់ខ្លួននៅភូមិពោធិ៍សាត់ពីបទធ្វើឲ្យឆេះស្រូវក្នុងស្រែពីរ-បីម៉ែត្រក្រឡា និងធ្វើឲ្យងាប់គោមួយក្បាល ។ សព្វថ្ងៃ ហឿន រស់នៅក្នុងភូមិចក ឃុំប្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ហឿន បានរំឭករឿងរ៉ាវនៅក្នុងមន្ទីរសន្តិសុខថា អ្នកទោសដែលឈ្លបចាប់មកពីទីកន្លែងផ្សេងៗ បានត្រូវបញ្ជូនទៅឃុំឃាំងនិងដាក់ខ្នោះភ្ជាប់ៗនៅលើកុដិឈើមួយ ។ ហឿន ក៏ជាប់នៅទីនោះ ជាមួយនឹងជនរងគ្រោះជាង២០នាក់ផ្សេងទៀតដែរ ។ អ្នកទោសត្រូវជាប់ខ្នោះរហូតលើកលែងតែត្រូវវេនសួរចម្លើយប៉ុណ្ណោះ ។ ការសួរចម្លើយ និងធ្វើទារុណកម្មបានធ្វើឡើងព្រមជាមួយគ្នា ។ អ្នកទោសខ្លះត្រូវកងសន្តិសុខធ្វើទារុណកម្មយ៉ាងសាហាវរហូតដល់ស្លាប់ក៏មាន ។ ហឿន ត្រូវនាំយកទៅសួរចម្លើយពីទោសកំហុសរបស់គាត់ដែលបានប្រព្រឹត្តកន្លងមក ព្រមទាំងបានសារភាពនិងស្បថស្បែនៅចំពោះមុខអង្គការថា លែងហ៊ានប្រព្រឹត្តរបៀបនេះ នៅថ្ងៃខាងមុខទៀតហើយ ។ ចំណែក ស៊ិន សុន ភេទស្រី អាយុ ៧០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិចក ឃុំប្រេស ស្រុកកំពង់ត្រឡាច ក៏ជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តចំប៉ាដែរ ។ សុន បានប្រាប់ថា គាត់បានជាប់គុកអស់រយៈពេល១៧ខែ ដោយសារគាត់ធ្វើឲ្យឆេះស្រូវនៅពេលកំពុងរោយ ។ សុន ជាអតីតប្រធានកងហាផ្នែកនារីប្រមូលផលនៅក្នុងភូមិប្រមុះជ្រូក ឃុំប្រេស ។

មន្ទីរសន្តិសុខនៅវត្តចំប៉ា មានកម្មាភិបាលគ្រប់គ្រងសំខាន់ៗបីនាក់ បានផ្លាស់ប្តូរវេនគ្នាគ្រប់គ្រងរហូតដល់ឆ្នាំ១៩៧៨ ។ អ៊ុច អឿន ជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខក្រោយគេបន្តសប់បន្ទាប់ពី ដួង រឿន និង ដួង ដន ។ រហូតមកដល់សព្វថ្ងៃមេសន្តិសុខទាំងបីនាក់នេះនៅមានជីវិតនៅឡើយគឺ អ៊ុច អឿន រស់នៅភូមិជីទាវ ឃុំប្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ចំណែក ដួង រឿន និង ដួង ដន រស់នៅក្នុងភូមិវាលល្បៀង ឃុំប្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

នៅក្នុងឆ្នាំ១៩៧៨ មន្ទីរសន្តិសុខវត្តចំប៉ា ត្រូវបានរំសាយចោល ដោយមិនដឹងមូលហេតុច្បាស់លាស់ បន្ទាប់ពីបានសម្លាប់អ្នកទោសចោលទាំងអស់ ។

**ទិន្នន័យសង្ខេប**

**ទីតាំង :** វត្តចំប៉ា ស្ថិតនៅក្នុងភូមិចក ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ :** វត្តចំប៉ាត្រូវបានជ្រើសរើសយកធ្វើជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ដើម្បីឃុំឃាំងអ្នកទោសរាប់រយនាក់ដែលចាប់មកពីកន្លែងផ្សេងៗ ។ អ្នកទោសស្ទើរតែទាំងអស់ត្រូវកងឈ្លបសម្លាប់ចោល ។

## ស្រុករលាប្អៀរ

### ៨) មន្ទីរសន្តិសុខវត្តត្រពាំងទឹកត្រជាក់

កងឈ្លបខ្មែរក្រហមបានចាប់មនុស្សជាច្រើននាក់ពីសហករណ៍ផ្សេងៗក្នុងឃុំគោកបន្ទាយ ស្រុករលាប្អៀរ មកដាក់ឃុំឃាំងនៅក្នុងវត្តត្រពាំងទឹកត្រជាក់ស្ថិតនៅក្នុងភូមិអូរតាសេក ឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ អ្នកទោសភាគច្រើនជាអ្នកខុសសីលធម៌ ក្នុងនោះមានទាំងកម្មាភិបាលខ្មែរក្រហមជាច្រើននាក់ផង ។ អ្នកទោសត្រូវបានសម្លាប់នៅក្នុងបរិវេណវត្តត្រពាំងទឹកត្រជាក់ ហើយដាក់ក្នុងរណ្តៅធំៗចំនួន៣ ។ នៅក្រោយឆ្នាំ១៩៧៩ រណ្តៅទាំងបីត្រូវប្រជាជនគាស់កកាយដើម្បីរកមាសប្រាក់ ។ សាកសពដែលរាប់ឃើញមានចំនួនប្រហែលពី២០០ទៅ ២៣០នាក់ ។

**ទិន្នន័យសង្ខេប**

**ទីតាំង :** វត្តត្រពាំងទឹកត្រជាក់ស្ថិតនៅក្នុងភូមិអូរតាសេក ឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ :** វត្តត្រពាំងទឹកត្រជាក់ ជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហមតាំងពីឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៧៩ ។ អ្នកទោសជាច្រើនរួមទាំងអ្នកទោសជាកម្មាភិបាលខ្មែរក្រហមផង បានត្រូវកងឈ្លបចាប់មកដាក់ក្នុងមន្ទីរសន្តិសុខនេះ ។ ក្រោយឆ្នាំ១៩៧៩ រណ្តៅកប់សាកសពត្រូវបានប្រជាជនគាស់ឡើង ។

### ៩) មន្ទីរសន្តិសុខចុងជ្រោយ

នៅឆ្នាំ១៩៧៧ មន្ទីរសន្តិសុខប្រចាំស្រុក១៨មួយកន្លែងត្រូវបានបង្កើតឡើងនៅក្នុងបរិវេណវត្តចុងជ្រោយ ។ វត្តនេះស្ថិតនៅក្នុងភូមិឈើត្រាច ឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង និងនៅខាងកើតវត្តឈើត្រាច ប្រហែល៣គីឡូម៉ែត្រ ។

រឿង ថា ជាកុមារីនៅជំនាន់ខ្មែរក្រហមដែលធ្លាប់ស្នាក់នៅក្បែរមន្ទីរសន្តិសុខចុងជ្រោយ ដែលបច្ចុប្បន្នមានអាយុ៣៤ឆ្នាំ ហើយរស់នៅភូមិឈើត្រាច ឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង បានប្រាប់ថា គាត់បានឃើញកងឈ្លបបញ្ជូនមនុស្សតាមរទេះគោទៅកាន់មន្ទីរសន្តិសុខចុងជ្រោយដោយផ្ទាល់ភ្នែក ព្រមទាំងបានឮសំឡេងជនរងគ្រោះស្រែកចេញពីបរិវេណវត្តទៀតផង ។

រស់ សុខុន ភេទស្រី អាយុ៣៥ឆ្នាំ សព្វថ្ងៃនៅភូមិឈើត្រាច ឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ក៏ជាកុមារីម្នាក់ដែលមានទីលំនៅក្បែរមន្ទីរសន្តិសុខចុងជ្រោយកាលពីជំនាន់ខ្មែរក្រហមដែរ ។ សុខុន រំឭកថា នៅឆ្នាំ១៩៧៧កងឈ្លបខ្មែរក្រហមបានបណ្តើជនរងគ្រោះតាមផ្លូវមុខផ្ទះគាត់ទាំងខ្សែៗ តម្រង់ទៅកាន់មន្ទីរសន្តិសុខចុងជ្រោយ ។ មីងស្រីបង្កើតរបស់ រឿង ថា ត្រូវកងឈ្លបចាប់ខ្លួនពីកន្លែងធ្វើដីជាមួយមនុស្សពីរនាក់ផ្សេងទៀត យកមកកាន់មន្ទីរសន្តិសុខចុងជ្រោយ ។

ទារករបស់ជនរងគ្រោះដែលមានជាប់និន្នាការពីសង្គមមុនត្រូវបានសម្លាប់រួមជាមួយឪពុកម្តាយ ។ នៅក្នុងបរិវេណវត្តចុងជ្រោយ ។ ចំណែកជនរងគ្រោះដែលជាប់ខ្សែយួន ចិន និង ចាម ក៏ត្រូវកងឈ្លបនាំយកទៅសម្លាប់ភ្លាមៗ នៅក្បែរបរិវេណមន្ទីរសន្តិសុខចុងជ្រោយដែរ ។ ចាប់ពីចុងឆ្នាំ១៩៧៧រហូតមកដល់ចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានប្រមូលជនរងគ្រោះជាច្រើននាក់ពីជុំវិញស្រុកកំពង់ត្រឡាច ភូមិភាគបូព៌ា និងអ្នកជម្លៀសពីទីក្រុងភ្នំពេញមកដាក់នៅក្នុងមន្ទីរសន្តិសុខវត្តចុងជ្រោយទាំងអស់ ។ សុខុន បានឃើញស្ទើរគ្រប់ហេតុការណ៍នៅក្នុងមន្ទីរសន្តិសុខទាំងការធ្វើទារុណកម្ម ការសួរចម្លើយ និងការនាំអ្នកទោសទៅសម្លាប់ ។ នៅទីបញ្ចប់ អ្នកទោសទាំងអស់ប្រមាណពី ៧ម៉ឺនទៅ ១៥ម៉ឺននាក់ត្រូវបានសម្លាប់ដាក់ក្នុងរណ្តៅចំនួនពី២០០ទៅ ៣០០រណ្តៅ ។

បច្ចុប្បន្ន អតីតមន្ទីរសន្តិសុខចុងជ្រោយគឺជាព្រៃឫស្សីក្រាស់ឃ្មឹកដែលដុះគ្របពីលើរណ្តៅសាកសពទាំងនោះ ។

**ទិន្នន័យសង្ខេប**

**ទីតាំង :** មន្ទីរសន្តិសុខចុងជ្រោយ ស្ថិតនៅក្នុងភូមិឈើ

ត្រាច ឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ** ៖ ចុងជ្រោយ ជាទីតាំងសន្តិសុខនិងទីតាំងសម្លាប់មនុស្សកាលពីជំនាន់ខ្មែរក្រហម ។ ខ្មែរក្រហមបាននាំយកជនរងគ្រោះពីច្រើនកន្លែងមកដាក់នៅក្នុងមន្ទីរសន្តិសុខនេះ ហើយក្រោយមកត្រូវបានសម្លាប់ចោលទាំងអស់ ។ មានរណ្តៅប្រមាណពី២០០ទៅ៣០០រណ្តៅ និងសាកសពប្រហែលពី៧០.០០០ទៅ១៥០.០០០នាក់ ។

## ១០) មន្ទីរសន្តិសុខអូរបុស្ស៊ី

ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានបង្កើតមន្ទីរអប់រំកែប្រែមួយនៅកណ្តាលព្រៃក្នុងភូមិកំពង់ផ្ទឹក ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ។ អ្នកទោសជាច្រើននាក់ត្រូវកងឈ្លបក្មេងៗចាប់បញ្ជូនមកកាន់មន្ទីរសន្តិសុខនេះ ដើម្បីអប់រំនិងកែប្រែទម្លាប់ចាស់ ដែលក្នុងនោះភាគច្រើនជាអ្នកជាប់និន្នាការនយោបាយពីសង្គមចាស់ និងមួយចំនួនតូចជាអ្នកមូលដ្ឋាន ។ កងឈ្លបជាអ្នកត្រួតត្រានិងជាអ្នកចាប់ប្រជាជនយកមកដាក់ក្នុងមន្ទីរអប់រំអូរបុស្ស៊ី ។ ប្រាក់ យ៉ន បច្ចុប្បន្នជាប្រជាជនរស់នៅក្នុងភូមិកំពង់ផ្ទឹក និងធ្លាប់រស់នៅក្នុងសហករណ៍ក្បែរមន្ទីរអប់រំអូរបុស្ស៊ីនៅនឹកឃើញថា កងឈ្លបវ័យក្មេងៗ ដែលស្ពាយកាំភ្លើងអូសដី បានបណ្តើរមនុស្សជាច្រើននាក់ចូលមកក្នុងមន្ទីរសន្តិសុខនេះ ហើយអ្នកទាំងនោះពុំមែនជាមនុស្សធ្លាប់រស់នៅក្នុងភូមិឃុំរបស់គាត់ឡើយ ។ សឿ ទ្រឿង អាយុ៦៧ឆ្នាំ ជាជាងអារឈើ រស់នៅក្នុងឃុំអណ្តូងស្នាយបានប្រាប់ថា ប្រជាជនដែលកងឈ្លបនាំចូលក្នុងមន្ទីរអប់រំនេះជាប្រជាជនជម្លៀសមកពីខេត្តកណ្តាលនិងខេត្តកំពង់ស្ពឺ ។ នៅពេលថ្ងៃគ្មានអ្នកទោសណាម្នាក់ស្ថិតនៅក្នុងមន្ទីរអប់រំទេ គឺចេញទៅធ្វើការអស់ ។ ការប្រជុំបានធ្វើឡើងជារៀងរាល់ព្រឹកមុនពេលចេញទៅធ្វើការ និងរៀងរាល់ល្ងាចពេលត្រឡប់មកពីធ្វើការវិញ ។ ផែនការប្រជុំគ្មាននិយាយអ្វីក្រៅពីពង្រឹងគោលជំហរបដិវត្តន៍ និងសតិអារម្មណ៍ក្នុងការបំពេញការងារឡើយ ។

នៅពេលអ្នកទោសថ្មីត្រូវបញ្ជូនមកដល់ម្តងៗ កងឈ្លបបានធ្វើទារុណកម្មនិងសួរចម្លើយជាមុនសិន ទើបបញ្ជូនឲ្យទៅធ្វើការជាមួយអ្នកទោសផ្សេងទៀត ។ អ្នកទោសធ្ងន់ត្រូវកងឈ្លបដាក់ច្រវាក់ជើងទាំងសងខាង ហើយបណ្តើរចេញទៅធ្វើការខាងក្រៅនៅពេលថ្ងៃ និងនាំមកដាក់ក្នុងមន្ទីរវិញនៅពេលល្ងាច ។ កងការពារមន្ទីរ៤-៥នាក់បានរាយគ្នាក្នុងព្រៃស្បាត ដើម្បីយាមអ្នកទោស ។ នៅពេលព្រលប់ៗ កងឈ្លបបាននាំយកអ្នកទោសណាដែលមិនប្រឹងប្រែងធ្វើការនិងមិនស្មោះត្រង់ជាមួយអង្គការទៅសម្លាប់ដាក់ក្នុងរណ្តៅដែលជីករួចជាស្រេចនៅក្នុងព្រៃអូរបុស្ស៊ី ។ ប្រាក់ យ៉ន ប្រាប់ថា គាត់បានឃើញកងឈ្លបបណ្តើរមនុស្សចេញពីមន្ទីរយកទៅកាន់រណ្តៅ នៅពេលព្រលប់ពេលគាត់ចូលទៅយកស្រាតាមបញ្ជាប្រធានកង ។ ក្មួយស្រីតូចៗពីរនាក់និង



ចឹម ចន បង្ហាញទីតាំងមន្ទីរគុណវិបត្តិ



វត្តសុវណ្ណោ

បង្កើតម្នាក់របស់ ប្រាក់ យ៉ន បានបាត់ខ្លួនរហូតមកដល់បច្ចុប្បន្ន បន្ទាប់ពីត្រូវកងឈ្លបចាប់ខ្លួននៅឆ្នាំ១៩៧៦ បញ្ជូនមកមន្ទីរអប់រំអូរបុស្សី ។

ការសម្លាប់មនុស្សបានកើតឡើងព្រមគ្នានៅវាលខ្សាច់-សដែរ ដែលមានមនុស្សរាប់ម៉ឺននាក់ត្រូវបានសម្លាប់ ។ ចំណែកនៅមន្ទីរអូរបុស្សី មានតែជាង១.០០០នាក់ប៉ុណ្ណោះ ។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ រណ្តៅសាកសពនៅមន្ទីរអប់រំអូរបុស្សីមានសភាពក្រហេងក្រហូង ដូចរន្ធបាយខ្ញុំព្រោះត្រូវប្រជាជនគាស់កកាយ ។ រោងដែលសង់ឡើងដើម្បីឃុំឃាំងអ្នកទោសត្រូវបានរុះរើខ្ទេចខ្ទី ហើយកម្មាភិបាលគ្រប់គ្រងមន្ទីរមួយចំនួនត្រូវបានសម្លាប់ ។ អ្នកទោសដែលនៅសេសសល់បានរត់ចេញពីមន្ទីរឃុំឃាំងបាត់អស់ ។

បច្ចុប្បន្នមន្ទីរនេះបានក្លាយជាតំបន់ព្រៃរបោះដែលស្ថិតនៅឆ្ងាយរាប់គីឡូម៉ែត្រពីភូមិអ្នកស្រុក ហើយមានតែផ្លូវរទេះកាត់ខ្វាត់ខ្វែងតាមតំបន់អតីតមន្ទីរឃុំឃាំងអូរបុស្សីប៉ុណ្ណោះ ។ ប្រជាជនដែលរស់នៅក្បែរៗទីតាំងមន្ទីរសន្តិសុខអូរបុស្សីមិនសូវហ៊ានដើរឆ្លងកាត់មន្ទីរនេះទេព្រោះខ្លាចខ្មោចលងនៅត្រង់កន្លែងនោះ ។

### ទិន្នន័យសង្ខេប

***ទីតាំង*** ៖ អូរបុស្សី ស្ថិតនៅភូមិកំពង់ជ្នីក ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

***ស្ថិតិ*** ៖ អូរបុស្សី ជាមន្ទីរអប់រំកែប្រែមួយរបស់ខ្មែរក្រហម ។ នៅជុំវិញបរិវេណមន្ទីរគឺជាទីតាំងសម្លាប់អ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរនោះ ។ អ្នកទោសដែលកងឈ្លបបញ្ជូនមកដាក់ក្នុងមន្ទីរអប់រំកែប្រែអូរបុស្សី ជាប្រជាជនជម្លៀស និងប្រជាជនមូលដ្ឋាន ។

## ១១) មន្ទីរសន្តិសុខចំបក់កោង

មន្ទីរសន្តិសុខមួយត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៦ ក្នុងព្រៃនាមមួយជាប់ភូមិត្រពាំងក្រពើ ឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ មន្ទីរសន្តិសុខនេះមានឈ្មោះហៅថាមន្ទីរសន្តិសុខចំបក់កោង ។ ខ្មែរក្រហមបានបែងចែកមន្ទីរនេះជាកន្លែងសួរចម្លើយ និងសម្លាប់មនុស្សដាច់ពីគ្នា ។

សុខ ជាតិ អាយុ៧៦ឆ្នាំ រស់នៅភូមិត្រពាំងក្រពើ ឃុំទឹកហូត ស្រុករលាប្អៀរបាននិយាយថា អ្នកទោសដែលជាប់ឃុំឃាំងក្នុងមន្ទីរសន្តិសុខចំបក់កោង សុទ្ធតែប្រជាជនដែលខ្មែរក្រហមចាប់យកពីសហករណ៍នានាក្នុងឃុំទឹកហូត ។ ការសម្លាប់បានចាប់ផ្តើមតាំងពីឆ្នាំ១៩៧៦ ហើយបន្តរហូតដល់ឆ្នាំ១៩៧៨ ។

ម៉ៅ ស៊ិត អាយុ៦៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិត្រពាំងក្រពើបានរៀបរាប់ថា នៅឆ្នាំ១៩៧៨ គាត់បានឃើញខ្មែរ ក្រហមបណ្តើរមនុស្សជាច្រើននាក់ទៅកាន់មន្ទីរសន្តិសុខចំបក់កោង ក្នុងនោះមានទាំងអតីតកម្មាភិបាលខ្មែរក្រហមផង ។ ស៊ិត បាននិយាយពីអតីតកម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ ជា ដែលសម្លាប់ខ្លួនឯងនៅបរិវេណខាងក្រោមន្ទីរសន្តិសុខថា គាត់បានលួចរត់ចេញពីមន្ទីរឃុំឃាំង ហើយចងកសម្លាប់ខ្លួននឹងដើមឈើមួយដើមក្បែរ របងមន្ទីរសន្តិសុខ ។ មូលហេតុនៃការចងកសម្លាប់ខ្លួននេះ ម៉ៅ ស៊ិត បានទាញហេតុផលផ្ទាល់ខ្លួនថា មកពី ជា ឈឺចិត្តនឹងអង្គការដែលមិនអធ្យាស្រ័យដល់គាត់ពីរឿងខុសសីលធម៌ជាមួយនារី ជា ប្រជាជន ១៧ មេសា ម្នាក់ ។ ជា គឺជាអតីតកម្មាភិបាលខ្មែរក្រហមតាំងពីឆ្នាំ១៩៧៥-៧៦មក ។

ជា បានត្រូវឈ្មោះ ខាន់ ជាកម្មាភិបាលខ្មែរក្រហមបម្រើការនៅក្នុងមន្ទីរសន្តិសុខចំបក់កោងធ្វើទារុណកម្មយ៉ាងខ្លាំង ។ អ្នកទោសផ្សេងទៀតក៏មានវាសនាមិនខុសពី ជា ដែរ ។ ព្រៃកោះ គឺជាទីតាំងសម្លាប់អ្នកទោសរបស់មន្ទីរសន្តិសុខចំបក់កោង ។ រហូតមកដល់បច្ចុប្បន្ន ទីតាំងនេះនៅតែពុំមានមនុស្សចេញចូលដដែល ។ ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ អតីតមន្ទីរសន្តិសុខចំបក់កោងមាននៅសេសសល់ស្នាមឈាម សាកសព គុ កៅអី និងឧបករណ៍សម្លាប់មនុស្សជាច្រើនទៀតដូចជាដំបង និងដងចបជាដើម ។

### ទិន្នន័យសង្ខេប

***ទីតាំង*** ៖ ចំបក់កោងស្ថិតនៅភូមិត្រពាំងក្រពើ ឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

***ស្ថិតិ*** ៖ ព្រៃចំបក់ ត្រូវខ្មែរក្រហមជ្រើសរើសយកធ្វើជាមន្ទីរសន្តិសុខ ដើម្បីឃុំឃាំងជនរងគ្រោះជាច្រើន បូករួមទាំងអ្នកទោសជាកម្មាភិបាលខ្មែរក្រហមផង ។

**ផេង ពង្សរ៉ាស៊ី**

# ចំណោទឧក្រិដ្ឋកម្ម
# មន្ទីរសន្តិសុខភូមិភាគនិរតី
# ការកកើត ប្រតិបត្តិការ និង ទំនាក់ទំនង

***(តពីលេខមុន)***

***មន្ទីរអប់រំស្រុក***

មន្ទីរអប់រំស្រុកក្នុងភូមិភាគនិរតីមានចំនួន២២ ក្នុងចំណោមនោះ មន្ទីរអប់រំស្រុកចំនួន១៥មានទីតាំងក្នុងវត្ត ចំណែកមន្ទីរ៧ទៀតជាអតីតសាលារៀនឬសំណង់សាធារណៈដែលត្រូវបានប្រែក្លាយក្នុងបំណងបម្រើការងារសន្តិសុខ ។ បន្ទប់ឃុំឃាំងក្នុងមន្ទីរអប់រំស្រុកយ៉ាងហោចណាស់ត្រូវបានបែកចែកជា២ប្រភេទផ្សេងគ្នាសម្រាប់អ្នកទោសធ្ងន់ អ្នកទោសស្រាល និងអ្នកទោសស្ត្រី ។ មន្ទីរអប់រំស្រុកនីមួយៗអាចឃុំឃាំងអ្នកទោសបានចំនួនពី១០០នាក់ទៅ៥០០នាក់ ។ នៅក្នុងបន្ទប់ឃុំឃាំងនីមួយៗមានធុង ពាង ឬកេសគ្រាប់ សម្រាប់ផ្ទុកលាមករបស់អ្នកទោស ។ អ្នកទោសស្រាលជាអ្នកសែងធុងលាមកយកទៅចាក់ចោលនៅខាងក្រៅ ក្នុងរវាង១សប្តាហ៍ម្តង ។

ព្រះវិហារនិងកុដិត្រូវបានប្រែក្លាយជាបន្ទប់ឃុំឃាំងនិងបន្ទប់សួរចម្លើយអ្នកទោស ចំណែកទីធ្លាវត្តត្រូវបានប្រើប្រាស់ជាកន្លែងកប់សាកសពអ្នកទោស ។ វត្តសូភី ហៅវត្តកកោះ មានទីតាំងស្ថិតក្នុងភូមិកណ្តឹង ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ ត្រូវបានខ្មែរក្រហមប្រែក្លាយទៅជាមន្ទីរអប់រំស្រុកបាទីរហូតដល់ឆ្នាំ១៩៧៩ ។ វិហារ កុដិ និងសាលាបាលី ត្រូវបានប្រើប្រាស់ជាបន្ទប់ឃុំឃាំងអ្នកទោស ។ កុដិខាងលិចព្រះវិហារក្លាយជាបន្ទប់សួរចម្លើយ ។ កុដិខាងជើងវិហារក្លាយជាកន្លែងស្នាក់នៅរបស់កម្មាភិបាល ។ វាលជុំវិញវត្តនិងស្រះទឹកនៅខាងមុខវិហារ ក្លាយជាកន្លែងសម្លាប់អ្នកទោសនិងកប់សាកសព ។ នៅដើមឆ្នាំ១៩៨០ នៅជញ្ជាំងព្រះវិហារនៅមានស្លាកស្នាមប្រហោងដែលខ្មែរក្រហមចោះសម្រាប់ស៊កខ្នោះជើងអ្នកទោសពីជញ្ជាំងម្ខាងទៅជញ្ជាំងម្ខាងទៀត ។ ខ្នោះនេះមានពជួរ ហើយក្នុងមួយជួរអាចដាក់អ្នកទោសបានពី៣០ទៅ៤០នាក់ ។

វត្តកំពង់ត្រឡាចមានទីតាំងស្ថិតក្នុងភូមិកំពង់ត្រឡាច សង្កាត់ជ្រៃធំ ខណ្ឌកែប ក្រុងកែប ត្រូវបានប្រែក្លាយជាមន្ទីរអប់រំស្រុកកំពត ។ វិហារ កុដិ និងរោងបាយក្លាយជាបន្ទប់ឃុំឃាំង និងកន្លែងសួរចម្លើយ ។ អ្នកទោសត្រូវដាក់ខ្នោះដែករនុកចំនួន៤ជួរនៅក្នុងព្រះវិហារ ។ អ្នកទោសត្រូវនាំចេញទៅព្រៃខាងក្រោយវត្តដើម្បីសម្លាប់ ហើយសាកសពត្រូវបានកប់នៅក្នុងរណ្តៅដែលជីកនៅទីនោះស្រាប់ ។

មន្ទីរអប់រំស្រុកកៀនស្វាយមានទីតាំងនៅក្នុងវត្តមុនីសុវណ្ណហៅវត្តចំពុះក្អែក ។ វត្តនេះមានទីតាំងស្ថិតនៅក្នុងភូមិចំពុះក្អែក ឃុំព្រែកប្រា ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ខ្មែរក្រហមបានប្រើប្រាស់ព្រះវិហារ កុដិ និងសាលារៀន ជាបន្ទប់ឃុំឃាំង ហើយចេតិយជាកន្លែងសួរចម្លើយអ្នកទោស ។ កន្លែងសម្លាប់ និងកប់សាកសពស្ថិតនៅទិសពាយ័ព្យនៃព្រះវិហារ ។ នៅឆ្នាំ១៩៨០ រណ្តៅមួយចំនួនត្រូវបានជីក ហើយលលាដ៍ក្បាលសាកសពត្រូវបានដាក់ក្នុងចេតិយរួមនៅខាងកើតព្រះវិហាររហូតដល់បច្ចុប្បន្ន ។

មន្ទីរអប់រំស្រុកគិរីវង្សស្ថិតនៅក្នុងវត្តព្រះធាតុក្នុងភូមិក្បាលដំរី ឃុំគោកព្រេច ស្រុកគិរីវង្ស ខេត្តតាកែវ ។ សាលាឆាន់ធ្វើអំពីបេតុងដែលមានទទឹងប្រវែង១២ម៉ែត្រនិងបណ្តោយប្រវែង១៥ម៉ែត្រត្រូវបានប្រែក្លាយជាបន្ទប់ឃុំឃាំង ។ កុដិរបស់ព្រះសង្ឃក្លាយទៅជាទីតាំងសួរចម្លើយ និងបន្ទប់ស្នាក់នៅរបស់កម្មាភិបាលក្នុងមន្ទីរនេះ ។ កន្លែងសម្លាប់អ្នកទោសស្ថិតនៅខាងជើងនិងខាងក្រោយវត្ត ។ ឆ្អឹងជនរងគ្រោះនៅទីនេះត្រូវបានគាស់ចេញពីរណ្តៅនៅក្នុងឆ្នាំ១៩៨០ យកមកតម្កល់ក្នុងចេតិយរួមនៅក្នុងវត្ត ។

ក្រៅពីវត្តអារាម ខ្មែរក្រហមបានប្រើប្រាស់អគារនិង

សំណង់សាធារណៈជាច្រើនទៀតជាមន្ទីរអប់រំ ដើម្បីឃុំឃាំង សួរចម្លើយ និងសម្លាប់មនុស្ស ។ មន្ទីរអប់រំស្រុកកណ្តាលស្ទឹង ស្ថិតក្នុងតំបន់២៥ មានទីតាំងក្នុងភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ប្រជាជនហៅមន្ទីរនេះថា គុកសង់ ។ ក្នុងឆ្នាំ១៩៦៣ "ទីភ្នាក់ងាររបស់សហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ" បានសង់សាលាបណ្តុះបណ្តាលគ្រូបង្រៀន ក្នុងបំណងជួយអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងប្រទេសកម្ពុជា ។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រែក្លាយសាលាបណ្តុះបណ្តាលនេះឲ្យទៅជាមន្ទីរអប់រំស្រុក ។ រោងបាយរួមសម្រាប់គរុសិស្សត្រូវបានប្រែក្លាយជាបន្ទប់ឃុំឃាំង ហើយបរិវេណខាងកើត និងខាងត្បូង ក្លាយជាទីតាំងសម្លាប់ ។ ឆ្អឹងនិងលលាដ៍ក្បាលមួយគំនរធំត្រូវបានគាស់រកឃើញ និងដាក់នៅក្នុងអគារគុកដែលបែកបាក់ ក្រោយមកនៅឆ្នាំ១៩៩៩ ឆ្អឹងនិងលលាដ៍ក្បាល ដែលនៅសេសសល់ពីការពុកផុយត្រូវបានតម្កល់នៅក្នុងចេតិយមួយនៅជ្រុងខាងលិច ។

មន្ទីរអប់រំស្រុកចំនួន៣ទៀតក្នុងតំបន់២៥សុទ្ធតែមានទីតាំងស្ថិតនៅលើដីកោះ ។ មន្ទីរអប់រំស្រុកស្អាងស្ថិតនៅលើកោះគរ ក្នុងឃុំស្អាងភ្នំ ស្រុកស្អាង ។ មន្ទីរអប់រំស្រុកលើកដែកស្ថិតនៅលើកោះកន្ធាយ ក្នុងឃុំព្រែកដាច់ ស្រុកលើកដែក ចំណែកមន្ទីរអប់រំស្រុកកោះធំស្ថិតនៅលើកោះពោធិ៍ទន្លេ ឃុំកោះធំ ស្រុកកោះធំ ។ មន្ទីរអប់រំស្រុកដែលមានទីតាំងនៅលើកោះមានអគារ៤ខ្នងសង់អំពីឈើក្នុងមួយខ្នងមានទទឹងប្រមាណ៨ម៉ែត្របណ្តោយ១២ម៉ែត្រ និងបែងចែកជាអគារសម្រាប់ឃុំឃាំងចំនួន២ បន្ទប់ដាក់សម្ភារ១ និងការិយាល័យរបស់កម្មាភិបាល១ ។ កន្លែងសម្លាប់អ្នកទោសស្ថិតនៅក្បាលកោះនិងចុងកោះ ។ សាកសពមួយចំនួនត្រូវបានកប់នៅលើកោះមួយចំនួនទៀតត្រូវរុញទម្លាក់ទឹកទន្លេ ។ នៅលើកោះពោធិ៍ទន្លេមានចេតិយតម្កល់លលាដ៍ក្បាលជនរងគ្រោះ ចំណែកនៅលើកោះគរនិងកោះកន្ធាយពុំមានឡើយ ។

មន្ទីរអប់រំស្រុកត្រាំកក់ ហៅគុកក្រាំងតាចាន់ បន្សល់ទុកឯកសារជាច្រើនរហូតមកដល់បច្ចុប្បន្ន ។ មន្ទីរអប់រំនេះស្ថិតនៅភូមិក្រាំងតាចាន់ ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ។ គណៈស្រុកត្រាំកក់ឈ្មោះ ជឹម និង សាន ប្រធានសន្តិសុខស្រុកឈ្មោះ ភី និង ប្រធានមន្ទីរអប់រំឈ្មោះ អាន់ សុទ្ធតែមានដើមកំណើតនៅក្នុងស្រុកត្រាំកក់ ហើយត្រូវបានប្រគល់ភារកិច្ចឲ្យគ្រប់គ្រងស្រុកនិងមន្ទីរអប់រំស្រុកត្រាំកក់ពីឆ្នាំ១៩៧៣ដល់១៩៧៩ ។ មន្ទីរនេះស្ថិតនៅលើទីទួលមួយដែលមានដើមឈើធំៗព័ទ្ធជុំវិញ ។ មន្ទីរអប់រំនេះមានបន្ទប់ឃុំឃាំងចំនួន២និងអគារដាក់សម្ភារមួយសង់អំពីឈើប្រក់ស័ង្កសី ។ បន្ទប់សួរចម្លើយ និងកន្លែងសម្លាប់អ្នកទោសស្ថិតនៅទិសខាងត្បូង ។ ចំនួនអ្នកទោសក្នុងដើមខែវិច្ឆិកា ឆ្នាំ១៩៧៧ មានចំនួន១៨៤នាក់ប៉ុន្តែក្រោយមកនៅសល់តែ៨៥នាក់នៅក្នុងបញ្ជីបន្ទាប់ពីសម្លាប់អស់ចំនួន៩២នាក់ ឈឺស្លាប់៦នាក់ និងបញ្ជូនទៅមន្ទីរសន្តិសុខតំបន់១នាក់ ។ ចំនួនអ្នកទោសនៅក្នុងខែកក្កដា ក៏មានចំនួនប្រហាក់ប្រហែលខែវិច្ឆិកាដែរ គឺនៅសល់ក្នុងបញ្ជីមានចំនួន៨១នាក់ ។ សព្វថ្ងៃបរិវេណនេះមានស្តូបមួយសម្រាប់តម្កល់អដ្ឋិធាតុជនរងគ្រោះ និងសាលាឆទានមួយធ្វើអំពីឈើដែលមានទទឹង៥ម៉ែត្រ និងបណ្តោយ៨ម៉ែត្រ ។ រោងនេះសង់ឡើងដើម្បីប្រារព្ធពិធីបុណ្យប្រចាំឆ្នាំដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលបានស្លាប់នៅទីនេះ ។

អតីតកម្មាភិបាលនិងអ្នកទោសនៅមន្ទីរអប់រំស្រុកត្រាំកក់បានឲ្យដឹងថា វាលស្រែនិងដីចម្ការប្រមាណ៥០០ម៉ែត្រក្រឡាព័ទ្ធជុំវិញ មន្ទីរនេះត្រូវខ្មែរក្រហមហ៊ុមព័ទ្ធដោយបង្គលួសបន្លា ។ បន្ទប់ឃុំឃាំងទាំង២ត្រូវបានបែងចែកសម្រាប់អ្នកទោសស្រាល និងអ្នកទោសធ្ងន់ ។ បន្ទប់សួរចម្លើយសង់អំពីឈើនៅក្រោមដើមអំពិលស្ថិតនៅជ្រុងខាងត្បូង ។ បរិវេណជុំវិញមន្ទីរគឺជាទីតាំងសម្លាប់និងកប់សាកសព ។ ម៉ៅ អតីតអ្នកទោសម្នាក់ក្នុងមន្ទីរអប់រំស្រុកនេះបានឲ្យដឹងថា បន្ទប់ឃុំឃាំងទាំង២ធ្វើអំពីឈើប្រក់សង្កសីមានទទឹង៤ម៉ែត្រនិងបណ្តោយ៨ម៉ែត្រ និងមានទម្រង់ដូចទ្រុងកណ្តុរ ។ ជញ្ជាំងគឺជាកំណាត់ឈើដែលកប់ទៅក្នុងដី ហើយត្រូវវាយដ្ឋីបព័ទ្ធជុំវិញដោយបន្ទះក្តារ ។ នៅពីលើបន្ទះក្តារមានត្បាញបន្លាលួសយ៉ាងញឹក ។ នៅលើធ្នឹមអគារខាងកើតមានផ្លាកមួយសរសេរថា "នៅរស់ រត់ស្លាប់" ។ ឆុង អតីតអ្នកទោសម្នាក់ទៀត រៀបរាប់ថា អគារខាងលិចមានអ្នកទោសចំនួន៤២នាក់ ហើយអគារខាងកើតមានអ្នកទោស ៣៧នាក់ ។ ដាំ គឺជាអតីតកម្មាភិបាលនៅក្នុងមន្ទីរនោះ ប៉ុន្តែត្រូវខ្មែរក្រហមចាប់ដាក់

ឃុំឃាំងនៅទីនោះវិញនៅចុងឆ្នាំ១៩៧៧ ។ ដាំ និយាយថា គាត់ត្រូវចាប់ខ្លួនដោយសារគាត់ខុសសីលធម៌ជាមួយនារីមូលដ្ឋានម្នាក់ ប៉ុន្តែបើតាមរបាយការណ៍ដែលបញ្ជូនទៅមន្ទីរអប់រំស្រុក មូលហេតុនៃការចាប់ខ្លួន ដាំ គឺដោយសារគាត់បានដើរនិយាយវាយប្រហារបដិវត្តន៍ ។ ដាំ រៀបរាប់អំពីគុកនោះថា បន្ទប់ឃុំឃាំងធ្វើអំពីឈើ ។ អ្នកទោសត្រូវបានដាក់ខ្នោះជា២ជួរ ក្នុងមួយជួរៗ មានពី២០ទៅ៣០នាក់ ។ ក្នុងបន្ទប់ឃុំឃាំងនីមួយៗមានធុងលាមកសម្រាប់ឲ្យអ្នកទោសបន្ទោរបង់មានគ្រឡោកនិងវែកសម្រាប់ដាក់បបរ ។ ក្លិនអ្នកទោសដែលមិនបានងូតទឹករាប់ខែរួមផ្សំនឹងក្លិនលាមកធ្វើឲ្យបន្ទប់ឃុំឃាំងទាំងមូលមានក្លិនអសោចន៍ ។ កែវ ម៉ៅ បានហៅបន្ទប់ឃុំឃាំងនោះថា "ឋាននរក គ្មានការខ្មាសអៀនអីទេ ទាំងស្រីទាំងប្រុស ។ ឆ្នាំងមួយជុះរួចហុចគ្នារួចចាក់ដាក់ក្នុងពាងទៅ" ។ តាម៉ៅ ដែលបានចូលមើលមន្ទីរអប់រំស្រុកត្រាំកក់នៅដើមឆ្នាំ១៩៧៩ បានបញ្ជាក់ថា នៅលើក្តារមានសុទ្ធតែដង្កូវនិងសង្កើច ។ សែន រំឭកថា "អ្នកទោសមិនតិចទេដែលឈឺនិងស្លាប់ដោយសារសត្វចៃ និងសង្កើចទាំងនោះ ។ ខ្ញុំផ្ទាល់ ដំបូងសង្កើចខាំឈឺ ដល់ខាំរាល់ថ្ងៃយូរៗទៅធម្មតា ប៉ុន្តែចែសៗចេញពីសាច់ដែលកើតតាមដៃអាវ ថ្នេរអាវ ខាំរមាស់ពិបាកទ្រាំបំផុត" ។

មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មន្ទីរអប់រំស្រុកនៅមិនទាន់មានដំណើរការនិងមិនទាន់មានសកម្មភាពខ្លាំងក្លានៅឡើយទេ ។ អ្នកទោសដែលត្រូវចាប់ខ្លួននៅពេលនោះគឺប្រជាជនដែលត្រូវចោទប្រកាន់ថាជាខ្មាំងបង្កប់របស់លន់ នល់ ដែលមកយកការណ៍ពីខ្មែរក្រហម ។ ប្រជាជនដែលមានផ្ទះសម្បែងជុំវិញមន្ទីរអប់រំស្រុកមិនទាន់ត្រូវបានជម្លៀសចេញឆ្ងាយពីមន្ទីរនៅឡើយ ។ នៅពេលដែលអង្គការជម្លៀសប្រជាជនចេញពីទីក្រុង អ្នកទោសនៅក្នុងមន្ទីរអប់រំស្រុកកើនឡើង ហើយដំណើរការនិងសកម្មភាពរបស់មន្ទីរអប់រំក៏កាន់តែសស្រាក់សស្រាំ ។ ប្រជាជនដែលមានផ្ទះសម្បែងនៅក្បែរមន្ទីរត្រូវជម្លៀសចេញឆ្ងាយជាបណ្តើរៗ ។ សៀន ដែលមានផ្ទះនៅក្បែរមន្ទីរអប់រំស្រុកសំរោង បានពន្យល់មូលហេតុនៃការជម្លៀសថា "ពេលនោះការចាប់ខ្លួននិងសម្លាប់បានកើនឡើងច្រើន ។ គេ (ខ្មែរក្រហម) មិនចង់ឲ្យបែកការណ៍" ។

បន្ទាប់ពីត្រូវជម្លៀសចេញពីផ្ទះ ប្រជាជនត្រូវអង្គការហាមមិនឲ្យវិលមកផ្ទះរបស់ខ្លួនវិញជាដាច់ខាត ។ ភោគផលដំណាំ ស្រូវ បន្លែបង្ការរបស់ប្រជាជន ត្រូវកម្មាភិបាលមន្ទីរអប់រំស្រុក កាន់កាប់ជំនួស ។ សឿន ប្រជាជនមូលដ្ឋានស្រុកទ្រាំង បញ្ជាក់ថា ដីរាប់សិបហិកតានៅជុំវិញមន្ទីរអប់រំស្រុកត្រូវកម្មាភិបាលមន្ទីរអប់រំស្រុកកាន់កាប់ ។ គ្មានប្រជាជនណាម្នាក់អាចដើរជិតមន្ទីរអប់រំនេះបានឡើយ ។ សឿន ប្រាប់បន្ថែមថា "កម្មាភិបាលមន្ទីរអប់រំស្រុកទ្រាំងចិញ្ចឹមឆ្កែជាច្រើនក្បាលសម្រាប់ការពារមិនឲ្យប្រជាជនដើរចូលជិតមន្ទីរអប់រំ ។ បើប្រជាជនណាម្នាក់វង្វេងដើរមកជិតមន្ទីរអប់រំពិតជាត្រូវឆ្កែចោមរោមខាំជាមិនខាន" ។

ដូចនៅមន្ទីរអប់រំស្រុកទ្រាំងដែរ បរិវេណជុំវិញនិងភោគផលដំណាំក្បែរមន្ទីរអប់រំស្រុកផ្សេងទៀតនៅក្នុងភូមិភាគនិរតីក្លាយជាកម្មសិទ្ធិរបស់កម្មាភិបាលមន្ទីរអប់រំស្រុក ។ ធួន អតីតកម្មាភិបាលមន្ទីរអប់រំស្រុកសំរោង រៀបរាប់ថា "កម្មាភិបាលទាំងនោះការពារបរិវេណជុំវិញមន្ទីរអប់រំស្រុកជាប្រយោជន៍ ទី១) ដើម្បីរក្សាការសម្ងាត់ និងទី២) ការពារផលដំណាំទាំងនោះទុកហូបខ្លួនឯង" ។

## អ្នកទោសនៅមន្ទីរអប់រំស្រុក

វត្តមានរបស់អ្នកទោសនៅក្នុងមន្ទីរអប់រំស្រុកចាប់ពីឆ្នាំ១៩៧៥ដល់១៩៧៩អាចចែកចេញជាពីរដំណាក់កាលផ្សេងគ្នា ។ អ្នកទោសដែលត្រូវចាប់ខ្លួននៅពាក់កណ្តាលឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ ភាគច្រើនជាអតីតទាហានប៉ូលិសនៃរបបលន់ នល់ ចំណែកអ្នកទោសដែលត្រូវចាប់ខ្លួននៅក្រោយឆ្នាំ១៩៧៦ ភាគច្រើនជាប្រជាជន ដែលមានសាច់ញាតិអតីតទាហានប៉ូលិសត្រូវបានរកឃើញនិងចោទប្រកាន់ថាមានពាក់ព័ន្ធនិន្នាការនយោបាយ ឬបានប្រព្រឹត្តប្រឆាំងនឹងអង្គការ ។ ប្រការដែលមិនអាចបដិសេធបានគឺ ជាធម្មតា នៅពេលមានការចាប់ខ្លួននិងសម្លាប់ទាហានប៉ូលិសណាម្នាក់ សាច់ញាតិ ប្រពន្ធកូន ឪពុកម្តាយ របស់អ្នកទាំងនោះ តែងមើលឃើញអំពើមិនល្អរបស់ខ្មែរក្រហម និងមានគំនិតស្អប់អង្គការ ។ ខ្មែរក្រហមបានចាត់ទុកថាប្រជាជនដែលមានគំនិតនិងបំណងដូចខាងលើគឺជាខ្មាំងរបស់អង្គការយ៉ាងពិតប្រាកដ ដូច្នេះរបត់នៃការចាប់ខ្លួននិងប្រហារជីវិតក៏កើតមានឡើង ។

នៅពាក់កណ្តាលឆ្នាំ១៩៧៥ តយ គណៈឃុំកំពែង ស្រុកព្រៃកប្បាស បានទទួលផែនការពីគណៈស្រុកឲ្យស្វែងរកអតីតទាហានលន់នល់ដែលរស់នៅក្នុងឃុំកំពែង ដើម្បីចាប់ខ្លួននិងបញ្ជូនទៅថ្នាក់លើ ។ ពេលនោះ តយ បានរកឃើញនិងចាប់ខ្លួនអតីតទាហានលន់នល់ជាច្រើននាក់បញ្ជូនទៅឲ្យគណៈស្រុកព្រៃកប្បាស ។

គណៈស្រុកត្រាំកក់បានរៀបចំផែនការដាក់ឲ្យថ្នាក់ក្រោមរបស់ខ្លួនស្រង់ប្រវត្តិរូបប្រជាជន ។ សមមិត្ត ស៊ឹម គណៈឃុំញ៉ែងញ៉ង បានរកឃើញអតីតទាហានប៉ូលិសលន់នល់ដែលរស់នៅក្នុងឃុំញ៉ែងញ៉ងចំនួន១១នាក់ ។ សមមិត្តមៀន ប្រធានកងក្លាំឃុំញ៉ែងញ៉ង ក៏បានរកឃើញនិងរាយការណ៍អំពីសមាសភាពខ្មាំងជាអតីតទាហាន និងប៉ូលិសលន់នល់៤នាក់នៅក្នុងកងរបស់គាត់ជូនអង្គការស្រុកត្រាំកក់ដែរ ។ សមាសភាពខ្មាំងទាំងនោះមាន ៈ ឡូ អេងទ្រី ខាងបើកបរយន្តហោះ, យន់ ហាន លេខាធិការឃ្លាំងសម្ភារសឹក, សួស ទី **សេហុប៉េអ៊ឹម** និង បាង ណាន ទាហានថ្នាក់ពលបាលទោ ។

សមមិត្តឆោម គណៈឃុំអង្គតាសោម បានចូលរួមបំពេញការកិច្ចប្រមូលខ្មាំងយ៉ាងមានប្រសិទ្ធភាពតាមផែនការរបស់បក្ស ។ បន្ទាប់ពីបញ្ជូនសមាសភាពខ្មាំងមួយចំនួនជូនអង្គការស្រុករួចហើយ សមមិត្តឆោម តាមរកសមាសភាពខ្មាំងក្នុងឃុំរបស់គាត់បន្តទៀត ដោយសារនៅមានសមាសភាពខ្មាំងដែលបក្សតាមរកបន្កប់ក្នុងឃុំរបស់គាត់នៅឡើយ ។ ឧទាហរណ៍សេចក្តីរាយការណ៍ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៧ ដែលសមមិត្ត ឆោម ផ្ញើជូនអង្គការស្រុកត្រាំកក់ សរសេរថា «សូមបញ្ជាក់បន្ថែមចំពោះអ្នកមានបណ្តាស័ក្តិ១ ឬស័ក្តិ២ យើងខ្ញុំទាក់ទងមិត្ត យន ខាងយោធាស្រុក យកល្ងាចនេះហើយ សូមអង្គការជ្រាប» ។ គេង ប្រាប់ឲ្យដឹងថា នៅពាក់កណ្តាលឆ្នាំ១៩៧៥ ជន គណៈឃុំពពេលបានចាត់តាំងប្រធានភូមិនិងប្រធានក្រុមឲ្យសួរប្រវត្តិរូបប្រជាជននៅក្នុងឃុំពពេល ។ ការធ្វើ ប្រវត្តិរូបពេលនោះគឺសួរនាំយ៉ាងលម្អិតអំពីឈ្មោះ ការងារ ប្តី ប្រពន្ធ កូនចៅ និងមុខរបររកស៊ី ។ «បន្ទាប់ពីការធ្វើប្រវត្តិរូបមក ជន ផ្ញើរបាយការណ៍ទៅឲ្យគណៈស្រុក ។ ចាប់ពីពេលនោះមក អតីតទាហាននិងប៉ូលិសបានបាត់ខ្លួនជាបណ្តើរៗ» ។ នៅក្នុងរបាយការណ៍ផ្ញើជូនអង្គការស្រុកត្រាំកក់ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៧ ជន រៀបរាប់អំពីលទ្ធផលនៃធ្វើប្រវត្តិរូបប្រជាជននៅក្នុងឃុំរបស់គាត់ ។ «គ្រួសារទាហានដែលត្រូវអង្គការកម្ទេចមានចំនួន១០៦គ្រួសារ មានមនុស្សចំនួន៣៩៣នាក់ ។ គ្រួសារទាហានដែលនៅសល់មានចំនួន២៣១គ្រួសារ មានមនុស្សចំនួន៨៩២នាក់» ។ សមមិត្ត ជន បញ្ជាក់នៅផ្នែកខាងចុងនៃលិខិតរបស់គាត់ថា កំពុងតែព្យាយាមពិនិត្យតាមដានរកគ្រួសារទាហាន ជាពិសេសក្នុងចំណោមប្រជាជនថ្មី ។ របាយការណ៍ដោយឡែក មួយទៀតរបស់សមមិត្ត សើន គណៈឃុំគុស ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៧ បញ្ជាក់ថា បន្ទាប់ពីបានចាប់បញ្ជូនអតីតទាហាន លន់ នល់ ចំនួន៦នាក់ទៅមន្ទីរអប់រំស្រុកត្រាំកក់កាលពីថ្ងៃទី៦ ខែកញ្ញា សមមិត្ត សើន ទើបបានរកឃើញអតីតទាហានចំនួន៧នាក់ផ្សេងទៀត ។ «តើសមមិត្តបងគិតយ៉ាងណា តើត្រូវចាប់បញ្ជូនទៅឬយ៉ាងណា យើងខ្ញុំរង់ចាំអនុវត្តតាមការសម្រេចរបស់បងជានិច្ច» ។

សមមិត្ត សាំង កម្មាភិបាលមន្ទីរអប់រំស្រុកត្រាំកក់ បានទទួលយកអតីតទាហានប៉ូលិសដែលគណៈឃុំគ្រប់ឃុំចាប់បញ្ជូនទៅមន្ទីរអប់រំស្រុកត្រាំកក់ ។ សាំង បញ្ជាក់ថា «ក្នុងពាក់កណ្តាលឆ្នាំ១៩៧៥ អ្នកទោសត្រូវនាំចូលមកសម្បើមណាស់ យប់ក៏ដូចថ្ងៃ ថ្ងៃក៏ដូចយប់ ។ អត់បានដេកទេ» ។

បន្ទាប់ពីត្រូវឃុំឃាំង សួរចម្លើយរួច អតីតទាហានប៉ូលិសទាំងនោះត្រូវអង្គការសម្លាប់ចោល ។ បញ្ជីស្ថិតិអ្នកទោសនៅមន្ទីរអប់រំស្រុកត្រាំកក់បង្ហាញថា អ្នកទោសដែលជាអតីតទាហានប៉ូលិសមានចំនួនជាងពាក់កណ្តាលនៃចំនួនអ្នកទោសទាំងអស់ ។ ក្នុងចំណោមអ្នកទោសដែលត្រូវសម្លាប់នៅមន្ទីរអប់រំស្រុកត្រាំកក់ចំនួន៥០០នាក់ មាន២៥២នាក់គឺជាអតីតទាហាននិងប៉ូលិសនៃរបបលន់នល់ ។ ក្នុងបញ្ជីស្នើកម្ទេចអ្នកទោសថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៧៧ មានឈ្មោះអ្នកទោសចំនួន៤០នាក់ ក្នុងនោះមានអតីតទាហានស័ក្តិ១និងស័ក្តិ២និងប៉ូលិសចំនួន២៦នាក់ កាប៊ូរ៉ាល់៦នាក់ អាត់ស៊ីដង់៣នាក់ ពាក់ដាយចំនួន៣នាក់ រដ្ឋមន្ត្រី១នាក់ និងសិស្សថ្នាក់ទី១ម្នាក់ ។ ក្នុងចំណោមអ្នកទោសចំនួន២៦នាក់ដែលស្នើកម្ទេចថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៨ មានអតីតទាហានស័ក្តិ១និងស័ក្តិ២និងប៉ូលិសចំនួន១៨នាក់ កាប៊ូរ៉ាល់២នាក់

ពលទោ១នាក់ និងប្រជាជន៥នាក់ ។ ក្នុងចំណោមអ្នកទោស២២នាក់ដែលគណៈតំបន់ (សមមិត្តប្រាក់) បញ្ជាឲ្យកម្ទេចថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧៧ មានពលទោ៨នាក់ កាប៉ូរ៉ាល់២នាក់ ស័ក្តិ១ចំនួន៨នាក់ ស័ក្តិ២ចំនួន៣នាក់ និងអាត់ស៊ីដង់៣នាក់ ។

អតីតប្រជាជនមូលដ្ឋាន អ្នកទោស និងកម្មាភិបាលនៅមន្ទីរអប់រំស្រុកដទៃទៀត ក៏កត់សម្គាល់ឃើញមានការចាប់ខ្លួននិងសម្លាប់អតីតទាហាននិងប៉ូលិសនៃរបបលន់នល់ នៅពាក់កណ្តាលឆ្នាំ១៩៧៥ដែរ ។ ព្រំ ញាណ ប្រជាជនមូលដ្ឋានរស់នៅក្បែរមន្ទីរអប់រំស្រុកកណ្តាលស្ទឹង បានសង្កេតឃើញការបញ្ជូនអ្នកទោសចូលក្នុងមន្ទីរអប់រំស្រុកកណ្តាលស្ទឹង នៅពាក់កណ្តាល ឆ្នាំ១៩៧៥ ភាគច្រើនជាបុរសវ័យកណ្តាល ហើយមានរូបរាងនិងដំណើរដូចជាធ្លាប់បម្រើការងារជាទាហាននិងប៉ូលិស ។ អតីតកម្មាភិបាលម្នាក់ នៅមន្ទីរអប់រំស្រុកកណ្តាលស្ទឹងបានឲ្យដឹងថា នៅពាក់កណ្តាលឆ្នាំ១៩៧៥ និងដើមឆ្នាំ១៩៧៦ អ្នកទោសក្នុងមន្ទីរអប់រំស្រុកកណ្តាលស្ទឹងភាគច្រើន ជាអតីតទាហាននិងប៉ូលិសនៃរបបលន់នល់ ហើយអ្នកទោសទាំងនោះ ត្រូវសួរចម្លើយ និងនាំយកទៅសម្លាប់ស្ទើរតែទាំងអស់ ។ គេង និង ដើយ ក៏សង្កេតឃើញអត្រាអ្នកទោសដែលជាអតីតទាហាន ប៉ូលិសរបបលន់នល់ក្នុងមន្ទីរអប់រំស្រុកលើកដែកច្រើនដែរ ។ គាត់បញ្ជាក់ថា អត្រានេះបានថយចុះនៅពេលដែលអត្រាប្រជាជនជាប់និន្នាការនយោបាយនិងវណ្ណៈ កើនឡើងនៅឆ្នាំ១៩៧៧និង១៩៧៨ ។ គុណ, ដុន និង ចក់ ត្រូវចាប់ឃុំឃាំងនៅមន្ទីរអប់រំស្រុកបាទី ដោយសារគាត់ទាំង៣ត្រូវបានចោទប្រកាន់ថាជាខ្សែសន្ទាក់របស់អតីតទាហានលន់នល់ ។ អ្នកទាំងបីបានឲ្យដឹងថា អតីតទាហាន ប៉ូលិស ត្រូវសម្លាប់ក្រោយពេលសួរចម្លើយរួច ចំណែកគាត់ទាំង៣នាក់គ្រាន់តែជាប្រជាជនមូលដ្ឋានដែលត្រូវចោទប្រកាន់ ប៉ុន្តែគ្មានភ័ស្តុតាងជាក់ស្តែង ម្យ៉ាងទៀតគាត់មានជំនាញខាងជាងឈើ និងធ្វើស្ករ ដូច្នេះអង្គការទុកគាត់ឲ្យបម្រើការងារផ្នែកសេដ្ឋកិច្ចនៅក្នុងមន្ទីរអប់រំតែម្តង ។ ឈិន អតីត ចៅហ្វាយស្រុកបាទី ពីឆ្នាំ១៩៨០ដល់១៩៨៥ ធ្លាប់បានឃើញឯកសារបញ្ជីអ្នកទោសនៅមន្ទីរអប់រំស្រុកបាទី ។ ឈិន បញ្ជាក់ថា ភាគច្រើនឈ្មោះអ្នកទោសនៅក្នុងបញ្ជីកម្ទេចមានឈ្មោះនិងតួនាទី ។ តាមការសង្កេតរបស់គាត់មានអ្នកទោសជាអតីតទាហាន ប៉ូលិស នៃរបបលន់នល់ច្រើននៅឆ្នាំ១៩៧៦និង១៩៧៧ ។


សន្តិសុខគុកវាយធ្វើបាបអ្នកទោសស្ត្រីដោយយកពូថៅកាត់បបូរមាត់បែកជាពីរមុនយកតទៅសម្លាប់ នៅក្នុងគុកធំ ខេត្តសៀមរាប

នៅពាក់កណ្តាលឆ្នាំ១៩៧៦ យុទ្ធនាការចាប់ខ្លួននិងកម្ទេចប្រជាជនជាប់និន្នាការនយោបាយជាបងប្អូនសាច់ញាតិរបស់អតីតទាហាន ប៉ូលិស គ្រូបង្រៀន និងសក្តិភូមិម្ចាស់ដី និងប្រជាជនមានកំហុសដូចជារត់ចោលកងសហករណ៍ និយាយស្តីប្រឆាំងនឹងបដិវត្តន៍ និងខុសសីលធម៌ បានចាប់ផ្តើមឡើង និងបន្តរហូតដល់ចុងឆ្នាំ១៩៧៨ ។ អត្ថបទនៅក្នុងសៀវភៅទង់ក្រហមកិត្តយសបានប្រកាសអំពីលទ្ធផលនៃការស្វែងរក និងកម្ទេចខ្មាំងក្នុងឆ្នាំកន្លងមកថា “វិវត្តមកល្អជាងមុនកាន់តែច្រើនទាំងបរិមាណនិងគុណភាព” ។ ប៉ុន្តែវត្តមានខ្មាំងបង្កប់នៅតែមាននៅឡើយ ដូច្នេះ“តើយើងត្រូវដោះស្រាយយ៉ាងម៉េចតទៅទៀត?” វិធានការដោះស្រាយ ២ សំខាន់ដែលត្រូវតែយកមកអនុវត្តគឺ ÷

១) ត្រូវមានទស្សនៈនិងគោលជំហរឲ្យច្បាស់លាស់ថា ការប្រយុទ្ធជាមួយខ្មាំងបង្កប់ខាងក្នុងមិនទាន់អស់ទេ ។ សំណល់ចាស់របស់ខ្មាំងបង្កប់វានៅសេសសល់ ហើយវាអាចពង្រីងពង្រីកតទៅទៀត ។

២) ត្រូវមានវិធានការកម្ចាត់វាដាច់ខាត គ្មានសម្រុះសម្រួល

គ្មានអធ្យាស្រ័យ គ្មានញញើតញញើម វាវែកអ្វីទាំងអស់ ។

អត្ថបទនេះពុំបានបង្ហាញអំពីវិធានការលម្អិតក្នុងការកម្ចាត់ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង លើសពីវិធានការដែលបក្សបានដាក់ចុះកន្លងមកឡើយ ។ វិធានការរបស់បក្សចំពោះខ្មាំងដែលបានដាក់ចុះឲ្យថ្នាក់ក្រោមអនុវត្តកន្លងមកនោះរួមមាន ÷

១) បំផុសអប់រំមហាជននៅក្នុងអង្គការស្នូល ក្នុងកងទ័ពបដិវត្ត ក្នុងប្រជាជន ឲ្យគេឃើញច្បាស់ថាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងវាធ្វើសកម្មភាព...ដើម្បីឲ្យគេតាមរកខ្មាំងនិងវាយខ្មាំង ។

២) ខ្ទឹមសារស្រាវជ្រាវរកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងត្រូវយកខ្ទឹមសារអនុវត្តមាគ៌ានយោបាយរបស់បក្ស សតិអារម្មណ៍របស់បក្សចាត់តាំងរបស់បក្សត្រឹមត្រូវឬមិនត្រឹមត្រូវ... ។

វិធានការខាងលើទាំង២នេះ ធ្វើឲ្យប្រជាជនដែលជាប់និន្នាការនយោបាយវណ្ណៈ និងប្រជាជនដែលប្រព្រឹត្តកំហុសបន្តិចបន្តួចក្លាយជាខ្មាំងរបស់អង្គការ ហើយត្រូវចាប់ខ្លួននិងសម្លាប់ជាបន្តបន្ទាប់ ។ នៅក្នុងចំណោមអ្នកទោស៥០០នាក់ដែលមានឈ្មោះនៅក្នុងបញ្ជីមាន១៧៨នាក់ជាប្រភេទអ្នកទោសជាប់និន្នាការនយោបាយវណ្ណៈ មានតួនាទីក្នុងរបបលន់នល់ និងអ្នករត់ចោលកងសហករណ៍ ចំណែក៧០នាក់ទៀតគឺជាប្រពន្ធកូនរបស់អ្នកទោសនិងអ្នកដែលត្រូវចាប់ខ្លួនដោយពុំបានបញ្ជាក់មូលហេតុ ។ ជនជាតិបរទេសដែលរស់នៅនិងប្រកបរបររកស៊ីនៅក្នុងប្រទេសកម្ពុជា ក៏ត្រូវរាប់បញ្ចូលក្នុងប្រភេទខ្មាំងជាប់និន្នាការ និងជាខ្មាំងបង្កប់ដែរ ។ ក្នុងចំណោមអ្នកទោសចំនួន៣៦នាក់ ដែលរួមមានអ្នកទោសសញ្ជាតិឥណ្ឌាចំនួន១៣នាក់ ប៉ាគីស្ថានចំនួន១៧នាក់ និងអារ៉ាប់ចំនួន៦នាក់ ត្រូវបានចាប់ខ្លួននៅក្នុងតំបន់២៥ និងតំបន់៣៣ ក្នុងភូមិភាគនិរតី ក្នុងរយៈពេល៥ថ្ងៃ គឺចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៦ ។ អ្នកទោសទាំង៣៦នាក់ ត្រូវបានបញ្ជូនទៅឃុំឃាំង និងសួរចម្លើយនៅមន្ទីរស-២១ ។

អ្នកទោសក្នុងមន្ទីរអប់រំស្រុក មានទាំងស្រី ទាំងប្រុស ទាំងក្មេង និងទាំងចាស់ ។ ក្នុងចំណោមអ្នកទោសមន្ទីរអប់រំស្រុកត្រាំកក់ចំនួន៥០០នាក់ អ្នកទោសចំនួន៤៥០នាក់ស្ថិតក្នុងវ័យកណ្តាល និងជាភេទប្រុស ។ ដោយសារចំនួនមនុស្សវ័យកណ្តាល ដែលជាប់ឃុំឃាំងមានចំនួនច្រើនលើសវ័យឯទៀត ដូច្នេះចំនួនមនុស្សវ័យកណ្តាលដែលត្រូវប្រហារជីវិត ក៏មានចំនួនច្រើនលើសវ័យផ្សេងដែរ ។ បញ្ជីកម្ទេចអ្នកទោសក្នុងមន្ទីរអប់រំស្រុកត្រាំកក់បង្ហាញថា ក្នុងចំណោមអ្នកទោស ដែលត្រូវប្រហារជីវិតចំនួន១៨៧នាក់ មនុស្សវ័យកណ្តាលមានចំនួន១០៨នាក់ មនុស្សចាស់មានចំនួន៧១នាក់ និងកុមារមានចំនួន៨នាក់ ។ សំណាងជាកុមារម្នាក់ដែលជាប់ឃុំឃាំងក្នុងមន្ទីរអប់រំស្រុកត្រាំកក់ជាមួយកុមារចំនួន៨នាក់ខាងលើដែរ ប៉ុន្តែឈ្មោះរបស់ សំណាង មិនស្ថិតក្នុងបញ្ជីកម្ទេចឡើយ ដោយសារម្តាយរបស់គាត់មិនទាន់ត្រូវបានបញ្ចូលឈ្មោះជាខ្មាំង ដែលត្រូវប្រហារជីវិតដូចឪពុកម្តាយរបស់កុមារទាំង៨នោះ ។ សំណាង បានឲ្យដឹងថា ខ្លួន និងកុមារទាំងអស់ដែលជាប់ក្នុងបន្ទប់ឃុំឃាំងជាមួយម្តាយម្នាក់ៗសុទ្ធតែស្គមស្គាំងស្បែកដណ្តប់ឆ្អឹង យំស្រែក វារជុំវិញម្តាយដែលជាប់ខ្នោះរកអាហារ ។ ម្តាយរបស់កុមារទាំងនោះមិនអាចជួយកូនរបស់ពួកគាត់ឡើយ ។ អ្វីដែលពួកគាត់លួចលាក់ធ្វើបាន គឺសម្រក់ទឹកភ្នែកដោយការអាសូរចំពោះកូនប៉ុណ្ណោះ ។ សំណាង បញ្ជាក់ថា ក្រៅអំពីកុមារដែលស្ថិតក្នុងបញ្ជីកម្ទេចជាមួយឪពុកម្តាយរបស់ខ្លួន កុមារមួយចំនួនបានស្លាប់បាត់បង់ជីវិត ដោយសារជំងឺតម្កាត់ និងអត់អាហារមុនពេលដែលឪពុកម្តាយខ្លួន ត្រូវនាំចេញទៅប្រហារជីវិតចោលទៅទៀត ។

លីម, ហា និង ហ៊ឹ ត្រូវសមមិត្ត ឈន គណៈឃុំត្រពាំងធំខាងត្បូងចាប់បញ្ជូនខ្លួន ដោយមូលហេតុខុសៗគ្នា ។ នៅក្នុងរបាយការណ៍ទៅមន្ទីរអប់រំស្រុកត្រាំកក់នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៧៧ ឈន រាយការណ៍អំពីទោសកំហុសរបស់អ្នកទាំង៣ថា "ប្រជាជនថ្មីទាំង៣នេះ មានឈ្មោះលីម ឈ្មោះ ហា និងឈ្មោះ ហ៊ឹ ។ អាលីម (ពិការជើង) វាបាននិយាយថា សព្វថ្ងៃរស់នៅដូចសត្វ របៀបអ្នកទោសគ្មានសេរីភាព គ្មានសាសនា (ពួកទមិឡ) ។ លីម និយាយទៀតថា នៅខែ៨ ខែកញ្ញា ឆ្នាំ១៩៧៧ មានរថក្រោះ៤០គ្រឿងរបស់យួន បានចូលមកដល់ដីខ្មែរ ពេលនោះតាម៉ុក ឲ្យបាញ់ ១០០០គ្រាប់ទៅយួនវិញ...។ ចំណែកឈ្មោះហ៊ឹ (កសិករ) បាននិយាយថា នៅពេលចូលឆ្នាំ ខ្មែរខាងមុខនេះនឹងមានភាពវឹកវរនៅស្រុកខ្មែរ....ចប់សង្គ្រាមខ្មែរយើងនឹងរលួយ

ទៅរបបសេរីវិញ ហើយក្រហមតែមួយរយៈតូចហ្នឹងទេ ។ ឈ្មោះ ហា (ចៅកែឡាន) និយាយថា (អង្គការ) មិនឲ្យប្រជាជនថ្មីទៅស្រែប្រាំង ព្រោះខ្លាចរត់ទៅស្រុកយួន (ពីទីនោះទៅស្រុកយួនមានចម្ងាយ) តែ ១២គីឡូម៉ែត្រប៉ុណ្ណោះ...» ។

កាំង គីមសួរ, ព្រីង រ៉េន, ប៉ុត ចាន់ផល និង ប៉ុត ចាន់នី ត្រូវសមមិត្ត ជន គណៈឃុំពពេលចាប់ខ្លួនបញ្ជូនទៅមន្ទីរអប់រំស្រុកនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៧ ដោយសារអ្នកទាំង៦នេះ គឺជាសាច់ញាតិ និងកូនរបស់ស្ត្រីដែលអង្គការប្រកាសថាខ្មាំង ។ ប៉ុត ចាន់ផល និង ប៉ុត ចាន់នី ទាំងពីរនាក់ គឺជាកូនរបស់នារីឈ្មោះ មុំ ឡៃ ដែលអ្នកបំពុលកងចល័ត ។ គ្រួសារនេះ (អង្គការ) កម្ទេចអស់ហើយ នៅសល់តែកូនពីរនាក់នេះសូមជូនអង្គការ» ។ ញ៉ៅ ព្រមទាំងកូន និងចៅសរុបចំនួន៩នាក់ ត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរអប់រំស្រុកត្រាំកក់ នៅខែមិថុនា ឆ្នាំ១៩៧៦ ដោយសារអ្នកទាំងអស់ត្រូវជាប្រពន្ធកូន និងចៅរបស់ខ្មាំងឈ្មោះគុណ ដែលត្រូវខ្មែរក្រហមចោទប្រកាន់ថា បានប្រឆាំងនឹងសហករណ៍ ។ ក្រោយឆ្នាំ១៩៧៩ សមាជិកគ្រួសាររបស់ ញ៉ៅ ចំនួនតែ៤នាក់ប៉ុណ្ណោះមានជីវិតរស់នៅគេចផុតពីសេចក្តីស្លាប់ ។ សុម រីម អ្នកទោសស្ត្រីម្នាក់ ត្រូវចាប់ខ្លួនហើយយកមកដាក់ក្នុងមន្ទីរអប់រំស្រុកកណ្តាលស្ទឹងនៅខែកក្កដា ឆ្នាំ១៩៧៧ ជាមួយនឹងកូន២នាក់ ។ ទោសកំហុសរបស់គ្រួសារ សុម រីម មានលក្ខណៈមិនខុសពីទោសកំហុសរបស់អ្នកទោសទាំង៦របស់ ជន ដែលបានបញ្ជូនទៅឃុំឃាំងក្នុងមន្ទីរអប់រំស្រុកត្រាំកក់ឡើយ គឺពួកគាត់ជាប្រពន្ធ និងកូនរបស់ជនដែលអង្គការបានប្រកាសថា ខ្មាំងរបស់អង្គការ ។ ក្នុងអំឡុងពេលចាប់ខ្លួន សុម រីម មានផ្ទៃពោះជិតគ្រប់ខែទៅហើយ ។ ប្តីរបស់គាត់ត្រូវបានចាប់ខ្លួនក្នុងខែមករា ឆ្នាំ១៩៧៧ ក្រោមការចោទប្រកាន់ថា ជាភ្នាក់ងារ កា.ហ្សេ.បេ ។

សារុម និង ខុម បានក្លាយជាអ្នកទោសស្ត្រី ដោយមូលហេតុដូចសុម រីម និង ញ៉ៅ ដែរ ។ អ្នកទោសស្ត្រីទាំងពីរនេះត្រូវបញ្ជូនទៅឃុំឃាំងនៅមន្ទីរអប់រំស្រុកកោះធំក្រោមការចោទប្រកាន់ថាជាប្រពន្ធរបស់ទាហានស័ក្តិ៥ ។ ចំណែក ស៊ិន អ្នកទោសស្ត្រីផ្សេងទៀតបានក្លាយជាអ្នកទោសនៅមន្ទីរអប់រំស្រុកកណ្តាលស្ទឹងតាមរបៀបផ្សេងមួយទៀត ។ ស៊ិន ឆ្លល់ថា ហេតុអ្វីបានជាប្តីគាត់មិនមកជួបគាត់រៀងរាល់១០ថ្ងៃម្តង តាមការអនុញ្ញាតរបស់អង្គការយ៉ាងដូច្នេះ ។ ក្រោយការសើុបសួរគាត់បានដឹងថាប្តីគាត់ត្រូវបានចាប់ទៅឃុំឃាំងនៅមន្ទីរអប់រំស្រុកកណ្តាលស្ទឹង ។ ក្រោយពេលដែលបានដឹងដំណឹងនេះភ្លាម ស៊ិន ក៏ធ្វើដំណើរទៅរកប្តី ។ ពេលឃើញ ស៊ិន ដើរសំដៅចូលមន្ទីរអប់រំកម្មាភិបាលក្មេងនៅមន្ទីរអប់រំស្រុកកណ្តាលស្ទឹង ស្រែកថា «សត្វមមាចមិនស្គាល់ភ្លើង» ។ ស៊ិន ក៏ត្រូវក្លាយជាអ្នកទោសតាមប្តីរហូតដល់ខែមករា ឆ្នាំ១៩៧៩ ។

ម៉ៅ ត្រូវចាប់បញ្ជូនទៅមន្ទីរអប់រំស្រុកត្រាំកក់ ដោយសារគាត់ត្រូវបានចោទប្រកាន់ពីបទបង្កបាតុភាពក្នុងមន្ទីរពេទ្យ២២ក ។ ទោសកំហុសប្លែកៗដែលនឹកស្មានមិនដល់ និងសង្វេគនោះគឺទោសកំហុសរត់ចោលការដ្ឋាន ។ ឆុង និង អាំស៊ី ត្រូវចាប់ខ្លួនដោយសារគាត់បានវិលត្រឡប់ទៅលេងនឹងឪពុក និងប្រពន្ធរបស់គាត់ដោយគ្មានការអនុញ្ញាត ។ កុមារ៤នាក់ត្រូវចាប់ខ្លួនពីមូលហេតុដូចគ្នានេះដែរ ។ តាមចំណាររបស់ អាន់ ប្រធានមន្ទីរអប់រំស្រុកត្រាំកក់ទោសកំហុសរបស់កុមារទាំង៤នាក់នោះ គឺ «រត់ពីកងហើយដើរដោយគ្មានទិសដៅ» ។ ចំណែក ញូង ទឹម ត្រូវចាប់ខ្លួនដោយសារធ្វើឲ្យបាក់នង្គ័ល និងវាយគោក្នុងពេលភ្ជួរស្រែនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៧ ។

ស៊ូ ដាល់ ហៅ រាជ ត្រូវចាប់ខ្លួនបញ្ជូនទៅឃុំឃាំងក្នុងមន្ទីរអប់រំស្រុកត្រាំកក់ ដោយសារគាត់បានដើរនិយាយអំពីពុទ្ធទំនាយប្រឆាំងនឹងបដិវត្តន៍ ។ គេង អតីតអ្នកទោសមន្ទីរអប់រំស្រុកលើកដែកបានឲ្យដឹងថា គាត់ត្រូវចាប់ខ្លួនដោយសារជាប់ក្នុងចម្លើយរបស់ ថាច់ មួន ហើយបុរសម្នាក់ក្នុងចំណោមអ្នកទោសដែលត្រូវចាប់ខ្លួនក្នុងថ្ងៃតែមួយជាមួយ គេង ត្រូវចាប់ខ្លួនដោយសារបានដើរនិយាយរឿងពុទ្ធទំនាយប្រឆាំងនឹងអង្គការដែរ ។ ចម្លើយសារភាពរបស់ ស៊ូ ដាល់ ហៅ រាជ និងការបញ្ជាក់របស់ គេង អំពីខ្លឹមសាររបស់ពុទ្ធទំនាយតែមួយ គឺ«ផ្គរលាន់ទិសបូព៌ាសូរកណ្តុរ អ្នកតាចាស់ស្រុកឱបដៃយំ កំពឹសឡើងពងលើកំពូលភ្នំ...» ។

ទំនាក់ទំនងរវាងភេទដូចគ្នា គឺជាទោសមួយដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយទោសប្រភេទនេះ ត្រូវបានហៅថា «ខុសសីលធម៌» ។ ប្រជាជនដែលត្រូវមើលឃើញ និង

ចាប់ខ្លួន ក៏ត្រូវប្រឈមមុខនឹងការចាប់ខ្លួនបញ្ជូនទៅមន្ទីរអប់រំដែរ ។ មូ ផុន ត្រូវចាប់ខ្លួននៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧ ពីបទធ្វើការមិនពេញដៃពេញជើង និងលបលួចមានស្នេហាជាមួយនារីឈ្មោះ ថាន់ ។

ម៉ន បានលបលួចប្រព្រឹត្តខុសសីលធម៌ជាមួយនារីម្នាក់ឈ្មោះ ណាង ។ ម៉ន ត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរអប់រំស្រុកត្រាំកក់ នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៧ ។ សមមិត្ត យុន គណៈកងយុវជន ស្រែរនោង ដែលបានមើលឃើញហេតុការណ៍នេះ ។ គាត់សរសេររាយការណ៍ផ្ញើជូនសមមិត្ត អាន់ "ម៉ន បានប្រព្រឹត្តអំពើខុសសីលធម៌ ជាមួយនឹងនារីឈ្មោះ ណាង ហើយថែមទាំងបានបំផុសឲ្យនារី ណាង រត់ចេញពីកងទៀត" ។ អ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរអប់រំស្រុកទ្រាំង ក៏មានប្រភេទជនដែលមានកំហុស "ខុសសីលធម៌" ដែរ ។ ធួន អតីតកម្មាភិបាលនារីមន្ទីរអប់រំស្រុកទ្រាំងបំភ្លឺថា "ពុធ ប្រធានកងយុវជនខស្សរាប់ចេញចូលមន្ទីរអប់រំ ។ អាពុធ វាកំបុតដៃម្ខាងតែវានោះខ្លាំងណាស់ អត់មានយល់យោគទេ យុវជន យុវនារីណាខូចសីលធម៌អប់រំមិនបានអី គឺចាប់មកឃុំឃាំង និងប្រហារជីវិតចោលហើយ" ។

ក្រៅអំពីទោសកំហុសដោយការប្រព្រឹត្តអំពើក្បត់បដិវត្តទោសកំហុសដោយសារខ្លួនត្រូវជាប្រពន្ធ កូន សាច់ញាតិ និងទោសកំហុសដោយសារការចោទប្រកាន់លើបុគ្គលផ្ទាល់ខ្លួន អ្នកទោសមួយចំនួនត្រូវបានចាប់ខ្លួនដោយសារជាប់ឈ្មោះក្នុងចម្លើយសារភាពរបស់អ្នកទោសដែលបានចាប់ និងសួរចម្លើយក្នុងមន្ទីរអប់រំរួច ។ ស្ថិតក្រោមការធ្វើទារុណកម្មក្នុងពេលសួរចម្លើយ អ្នកទោសតែងតែរាប់ឈ្មោះអ្នកដែលខ្លួនស្គាល់ ធ្វើការជាមួយគ្នារួមទាំងសាច់ញាតិរបស់ខ្លួន ។ ដើយ ត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរអប់រំស្រុកលើកដែកនៅចុងឆ្នាំ១៩៧៥ ។ ដើយ ប្រាប់ហេតុផលថា គាត់ត្រូវបានចាត់តាំងឲ្យទៅកាប់ព្រៃនៅជើងភ្នំខាងលិច ។ នៅទីនោះគាត់បានស្គាល់បុរសម្នាក់ឈ្មោះ ថាច់ មួន ។ បន្ទាប់ពីកាប់ព្រៃចប់ ត្រឡប់ទៅភូមិវិញ ថាច់ មួន ត្រូវបានចាប់ខ្លួន ។ ការស្គាល់គ្នារវាង ដើយ និង ថាច់ មួន បណ្តាលឲ្យ ដើយ ត្រូវចាប់ខ្លួន និងជាប់ឃុំឃាំងក្នុងមន្ទីរអប់រំស្រុកលើកដែករស់ជិត៤ឆ្នាំ ។ ដើយ ប្រាប់ឲ្យដឹងថា "ខ្ញុំត្រូវចាប់ខ្លួនដោយសារ ថាច់ មួន ឆ្លើយសារភាពថា ខ្ញុំជាខ្សែក្បត់ជាមួយគាត់ ។ តាមពិតយើងទាំងពីរបានស្គាល់គ្នាត្រឹមតែជាអ្នករួមក្រុមកាប់ព្រៃជាមួយគ្នាប៉ុណ្ណោះ" ។

គង់ ឆឹម ត្រូវបានចាប់ខ្លួនបញ្ជូនទៅឃុំឃាំងក្នុងមន្ទីរអប់រំស្រុកកោះអណ្តែត ដោយសារគាត់គឺជាខ្សែក្បត់របស់ ឈិន និង រស់ អោ ដែលអង្គការបានចាប់ខ្លួនក្នុងឆ្នាំ១៩៧៧ ពីបទបង្កការប្រឆាំងនឹងអង្គការ ។ ក្រោមការសួរចម្លើយរបស់សមមិត្ត ផន ប្រធានមន្ទីរនគរបាលស្រុកកោះអណ្តែត គង់ ឆឹម បានឆ្លើយសារភាពខ្សែក្បត់របស់គាត់បន្ថែមចំនួន១០នាក់ផ្សេងទៀត ដែលក្នុងនោះមាន៣នាក់ជាខ្សែចាត់តាំង និង៧នាក់ត្រូវជាប្រពន្ធនិងកូនរបស់គាត់ផ្ទាល់ ។

ឡេន និង ស៊ូ ត្រូវចាប់ខ្លួននៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩៧៧ ដោយសារអ្នកទាំង២ជាប់ឈ្មោះក្នុងចម្លើយសារភាពរបស់ អ៊ិញ និង ថន ដែលមានបំណងរត់ទៅប្រទេសវៀតណាម ។ ម៉ឹង ស៊ុន, យួន អាង, អ៊ុច គុប, អៀម អុន អ្នកទាំង៤ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៧ ។ មូលហេតុនៃការចាប់ខ្លួនអ្នកទាំង៤ ដោយសារពួកគាត់មានជាប់ឈ្មោះក្នុងចម្លើយសារភាពរបស់ ភួង ។ នៅពេលសួរចម្លើយ ម៉ឹង ស៊ុន បានឆ្លើយសារភាពអំពីខ្សែក្បត់របស់គាត់ចំនួន២នាក់ផ្សេងទៀត គឺ ស៊ូ លយ និង ស៊ូ លាត ។

អ្នកទោសដែលត្រូវកងឈ្លបចាប់ខ្លួន ហើយបញ្ជូនទៅមន្ទីរអប់រំស្រុកត្រាំកក់ ត្រូវចងដៃនឹងខ្សែនីឡុង ក្រមា ឬខ្សែគោ ហើយបណ្តើរនិងតាមយាមពីក្រោយជាប់ ។ នៅពេលមកដល់របងមន្ទីរអប់រំកងឈ្លបត្រូវធ្វើសញ្ញាឡើង បញ្ជាក់អំពីការមកដល់របស់អ្នកទោស ។ នៅពេលឮសម្លេងសញ្ញាបញ្ជាក់ថា មានអ្នកទោសមកដល់កម្មាភិបាលមន្ទីរអប់រំ ចេញមកទទួលយកអ្នកទោស ហើយនាំចូលទៅខាងក្នុងដើម្បីឃុំឃាំង ។ នៅពេលបណ្តើរអ្នកទោសពីមន្ទីរឈ្លបឃុំសូភី ទៅដល់របងមន្ទីរអប់រំស្រុកបាទី ដើក បាញ់កាំភ្លើងមួយគ្រាប់ឡើងទៅខាងលើ បន្ទាប់មកកម្មាភិបាលមន្ទីរអប់រំចេញមកទទួលយកអ្នកទោសចូលទៅ ហើយ ដើក ក៏វិលត្រឡប់ទៅកន្លែងធ្វើការរបស់គាត់វិញ ។ វិធីផ្តល់សញ្ញាបញ្ជាក់ការមកដល់របស់អ្នកទោសនៅមន្ទីរអប់រំស្រុក

ត្រាំកក់ ខុសពីមន្ទីរអប់រំស្រុកបាទី ។ ឌុច និង សាំង អតីតកម្មាភិបាលមន្ទីរអប់រំស្រុកត្រាំកក់ប្រាប់ថា កងឈ្លបត្រូវវាយដួងដែលចងជាប់នឹងដើមស្វាយខាងលិចមន្ទីរជាសញ្ញា បន្ទាប់ពីឮសំឡេងដួងកម្មាភិបាលមន្ទីរអប់រំចេញទៅទទួលអ្នកទោសចូលមកខាងក្នុង ហើយបញ្ជូនទៅដាក់ឃុំឃាំង ។

នៅពេលដែលត្រូវទទួលយកហើយបញ្ជូនទៅដាក់ឃុំឃាំងនៅក្នុងមន្ទីរអប់រំ អ្នកទោសត្រូវបានបែងចែកជា២ប្រភេទ គឺអ្នកទោសធ្ងន់ និងអ្នកទោសស្រាល ។ អ្នកទោសធ្ងន់ជាប្រភេទអ្នកទោសដែលមានជាប់ពាក់ព័ន្ធនឹងនិន្នាការនយោបាយ និងវណ្ណៈ ។ ចំណែកអ្នកទោសស្រាល ជាប្រភេទអ្នកទោសដែលបានប្រព្រឹត្តខុស ដូចជាលួចរបស់របរសមូហភាព រត់ចេញពីកងសហករណ៍ ។ អ្នកមានទោសធ្ងន់ ជាពិសេសក្នុងចំណោមអ្នកទោសធ្ងន់នោះ គឺប្រភេទអ្នកទោសដែលបានប្រព្រឹត្តកំហុស ២យ៉ាងក្នុងពេលតែមួយ បានសេចក្តីថាអ្នកទោសមានជាប់និន្នាការនយោបាយ និងវណ្ណៈ ព្រមទាំងបានប្រព្រឹត្តកំហុសថែមទៀត ។ ការបែងចែកប្រភេទអ្នកទោសនេះហាក់ដូចជាឆ្លើយតបតាមសេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សអំពីការបែងចែកខ្មាំងរបស់បដិវត្តចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៨ ហើយវិធានការចំពោះខ្មាំងប្រភេទទី១ "ប្រភេទអន្តរាយ" ដែលជាប់ទាំងនិន្នាការ និងប្រឆាំងនឹងបដិវត្តន៍ថែមទៀតនោះគឺ "ត្រូវតែសម្រិតសម្រាំងដាច់ខាត" ។

អ្នកទោសធ្ងន់ ត្រូវជាប់ខ្នោះជើងធ្វើអំពីដែករនុកវែងដែលអាចដាក់អ្នកទោសបានចាប់ពី១០ទៅ២០នាក់ក្នុងមួយជួរ ។ ចំណែកដៃរបស់អ្នកទោសត្រូវជាប់ច្រវាក់ម្ខាង ។ អ្នកទោសប្រភេទនេះ មិនត្រូវបានអនុញ្ញាតឲ្យចេញខាងក្រៅមន្ទីរឃុំឃាំងដាច់ខាត សូម្បីតែពេលបន្ទោរបង់ ។ អ្នកទោសស្រាល ជាអ្នកទោសដែលមិនទាន់ត្រូវបានសម្រេចយកទៅប្រហារជីវិត ហើយត្រូវបានប្រើប្រាស់បណ្តោះអាសន្នធ្វើការងារបម្រើក្នុងមន្ទីរអប់រំ ។ អ្នកទោសស្រាល ត្រូវជាប់ខ្នោះជើង ដោយដែករនុកនៅពេលយប់ ហើយត្រូវបានអនុញ្ញាតឲ្យចេញក្រៅធ្វើការងារពេលថ្ងៃ ។ ការងាររបស់អ្នកទោសស្រាល គឺបម្រើការងារផ្នែកសេដ្ឋកិច្ច បម្រើការហូបចុកអ្នកទោសក្នុងបន្ទប់ឃុំឃាំង ដាំបាយ ដើររកបន្លែ បេះត្រកួន ត្រកៀត សែង លាមកនិងសាកសពអ្នកទោសដែលស្លាប់ក្នុងបន្ទប់ឃុំឃាំងយកទៅកប់ ។

បន្ទាប់ពីជាប់ឃុំឃាំងក្នុងបន្ទប់ងងឹតជាប់ខ្នោះទាំងដៃទាំងជើងអស់រយៈពេល៣ខែ ឆ្លងកាត់ការវាយដំទាត់ធាក់នៅពេលសួរ-ចម្លើយរួចមក ម៉ៅ ត្រូវបានកម្មាភិបាលមន្ទីរអប់រំស្រុកត្រាំកក់ចាត់តាំងឲ្យបម្រើការងារក្នុងមន្ទីរអប់រំ ។ ការងាររបស់ ម៉ៅ ពេលនោះមានរកត្រកួន ត្រកៀត និងដាំបន្លែ ។ រាល់ល្ងាចបន្ទាប់ពីចប់ការងារ ម៉ៅ ត្រូវត្រឡប់ចូលក្នុងបន្ទប់ឃុំឃាំង ហើយជាប់ខ្នោះវិញ ។ ស្ថានភាពរបស់ តេង និង ដើយ អ្នកទោសមន្ទីរអប់រំស្រុកលើកដែកក៏មិនខុសពីម៉ៅដែរ ។ ឆ្លងកាត់ការជាប់ឃុំឃាំងជាប់ខ្នោះជើង និងដៃរួចមក គាត់ត្រូវបានចាត់តាំងឲ្យបម្រើការងារផ្នែករកខស កាប់ឈើ និងធ្វើផ្ទះសម្រាប់កម្មាភិបាលមន្ទីរអប់រំស្នាក់នៅ ។ តេង បានឲ្យដឹងថា ពេលថ្ងៃក្រុមជាងមានភារកិច្ចអារឈើ វាយវិហារយកថ្មសង់ផ្ទះ រហូតដល់ពេលយប់ ត្រូវត្រឡប់ចូលបន្ទប់ឃុំឃាំងដាក់ខ្នោះជើងវិញ ។

ចំនួនអ្នកទោសស្រាល គឺកម្រិតតាមការងារដែលត្រូវធ្វើនៅក្នុងមន្ទីរអប់រំនីមួយៗ ។ ឧទាហរណ៍នៅក្នុងមន្ទីរអប់រំស្រុកលើកដែក មានអ្នកទោសស្រាលចំនួន៨នាក់ដែលរួមមាន ក្រុមជាងនិងក្រុមសេដ្ឋកិច្ច ។ ចំណែកអ្នកទោសស្រាលនៅមន្ទីរអប់រំស្រុកត្រាំកក់វិញ មានចំនួនត្រឹម៤នាក់ប៉ុណ្ណោះ ដែលមានក្រុមដាំដុះ រកបន្លែបង្កា និងអ្នកដាំស្លសម្រាប់អ្នកទោស ។ អ្នកទោសនៅក្នុងមន្ទីរអប់រំស្រុកទាំងអស់ គឺជាខ្មាំងរបស់អង្គការ គឺជាខ្មាំងខ្មែរស្នាក់ ដែលប៉ុនប៉ងបង្កអន្តរាយដល់អង្គការ ។ ខ្មាំងប្រភេទខាងលើនេះ ទាំងរដ្ឋធម្មនុញ្ញរបបកម្ពុជាប្រជាធិបតេយ្យ ទាំងលក្ខន្តិកៈបក្ស ទាំងសេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សវិធានការមានតែមួយគឺ "បោសសម្អាត" ។ អ្នកទោសស្រាលភាគច្រើនបានគេចផុតអំពីសេចក្តីស្លាប់ដោយសារព្រឹត្តិការណ៍ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ អ្នកទោសស្រាលមួយចំនួន ត្រូវបានបោសសម្អាតមុនព្រឹត្តិការណ៍ខាងលើមកដល់បាត់ទៅហើយ ។

***(នៅមានត)***

**អៀ ម៉េងទ្រី**

# ផែនការបដិវត្តន៍សង្គមនិយមរបស់ខ្មែរក្រហម

មេដឹកនាំខ្មែរក្រហម ជាពិសេស ប៉ុល ពត យល់ឃើញថាសង្គមកម្ពុជាជិតពីរពាន់ឆ្នាំកន្លងមកនេះ ត្រូវបានដឹកនាំដោយជនកាន់អំណាចមួយក្ដាប់តូច ដែលចាត់ទុកប្រជាជន ជាពិសេសកសិករក្រីក្រជា «ខ្ញុំកញ្ជះ» ។ អ្នកទាំងនេះមើលឃើញថា ប្រជាជនកម្ពុជាកំពុងត្រូវបានពន្លក់បំពុលដើម្បីបម្រើឲ្យផលប្រយោជន៍បុគ្គល និងថាសង្គមកម្ពុជាក្រោមឥទ្ធិពលអាណានិគមនិយមនិងចក្រពត្តិនិយមពោរពេញទៅដោយអំពើពុករលួយ ការកេងប្រវ័ញ្ច ល្បែងពាលាអាវ៉ាសែ ការរាំរែកដឹកស៊ីស្រីញីអូនបង អំពើអបាយមុខ មនុស្សជិះជាន់មនុស្ស និងអំពើអយុត្តិធម៌គ្រប់បែបយ៉ាង ។ កុនល្ខោនល្បែងកម្សាន្តគ្រប់បែបយ៉ាងសុទ្ធតែជាគ្រឿងឥតប្រយោជន៍ និងជាឧបករណ៍របស់បរទេសដែលបានផ្សព្វផ្សាយចូលមកក្នុងគោលបំណងបង្វិលខួរក្បាលប្រជាជនខ្មែរឲ្យដើរតាមមនោគមវិជ្ជារបស់ខ្លួនងាយស្រួល ឲ្យបរទេសទាំងនេះប្រើប្រាស់ដើម្បីទាញយកផលប្រយោជន៍និងលេបយកទឹកដីខ្មែរ ។ ជាងនេះទៅទៀត មេដឹកនាំខ្មែរក្រហមចាត់ទុកការលំហែរកម្សាន្ត ការហាត់កីឡា កាសិក្សាយកសញ្ញាប័ត្រធំៗ និងការគោរពជំនឿសាសនាគឺជាការចំណាយពេលឥតប្រយោជន៍ និងគ្មានបានជួយអ្វីក្នុងការពង្រឹងកម្រិតជីវភាពរស់នៅរបស់កសិករកម្មករ និងគ្មានបានជួយអ្វីក្នុងការរំដោះប្រទេសជាតិឲ្យរួចផុតពីនឹមត្រួតត្រានិងវប្បធម៌ពាលាអាវ៉ាសែរបស់បរទេសទេ ។ ដោយសារតែគំនិតជ្រុលនិយមហួសហេតុទាំងនេះហើយ ដែលធ្វើឲ្យមេដឹកនាំខ្មែរក្រហមដាក់ចេញនូវគោលនយោបាយយោយោហួសវិស័យជាច្រើន ដើម្បីសម្រេចឲ្យបាននូវគោលដៅឆ្ពោះទៅកាន់បដិវត្តន៍សង្គមនិយម និងឈានទៅការកសាងសង្គមនិយមជឿនលឿនមួយ ដែលមេដឹកនាំទាំងនេះយល់ថា ជាមធ្យោបាយតែមួយគត់ក្នុងការរំដោះប្រទេសជាតិនិងប្រជាជនបាន ។ ដើម្បីសម្រេចឲ្យបាននូវគោលដៅដ៏ធំនេះ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាបានដាក់ចេញនូវគោលនយោបាយដ៏គំហុកនិងទាំងបង្ខំជាច្រើនដូចខាងក្រោម ៖



យោធាខ្មែរក្រហមបណ្ដើរអ្នកទោសជនជាតិភាគតិចចូលទៅក្នុងគុកធំ ខេត្តសៀមរាប

**ការលុបបំបាត់ចោលរបៀបរបបពីសង្គមចាស់**

ទស្សនាវដ្ដី «យុវជននិងយុវនារីបដិវត្តន៍» របស់ខ្មែរក្រហម (លេខចេញផ្សាយខែកុម្ភៈ ១៩៧៨) បាននិយាយថា «ដើម្បីសម្រេចឲ្យបាននូវសង្គមកម្ពុជាស្អាតស្អំមួយចាំបាច់យុវជនយុវនារីត្រូវកសាងខ្លួនឲ្យបានល្អពីក្រោមឡើងលើមានន័យថាត្រូវលត់ដំខ្លួនក្នុងការងារគ្រប់បែបយ៉ាងដូចជា ធ្វើកូនក្រុមយុវកក ធ្វើនីរសារដឹកជញ្ជូន ដាំបាយ ធ្វើពេទ្យ ធ្វើស្រែចម្ការបង្កបង្កើនផល ។ល ។» ខ្មែរក្រហមយល់ថាមានតែការងារទាំងអស់នេះទេ ដែលនឹងធ្វើឲ្យប្រជាជនមានភាពស្អាតស្អំ កសាងជីវសតិអារម្មណ៍ និងផ្ដល់បទពិសោធន៍ដល់ប្រជាជនក្នុងការកសាងសង្គមជាតិ ដូចពាក្យស្លោកមួយបានលើកឡើងថា «ត្រូវយកការងារធ្វើគ្រូ តែកុំធ្វើគ្រូការងារឲ្យសោះ» ។ ក្នុងន័យនេះខ្មែរក្រហមយល់ថា គ្មានប្រយោជន៍សម្រាប់កសាងសង្គមត្រូវបានកម្ទេចចោលទាំងអស់ ។ ខ្មែរក្រហមបានលុបបំបាត់រូបិយវត្ថុ បិទផ្សារមិនឲ្យមានចរាចរដោះដូរទំនិញ បិទសាលារៀន និងបំបាត់ការ

អប់រំតាំងពីថ្នាក់បឋមរហូតដល់ថ្នាក់ឧត្តម ដែលខ្លួនយល់ថាជាការចំណាយពេលឥតប្រយោជន៍ និងបិទវត្តអារាមនិងផ្សឹកព្រះសង្ឃ ដែលត្រូវបានចោទថាជាឈ្លើងជញ្ជក់ឈាមប្រជាជន ។ល ។

ខ្មែរក្រហមមិនបានឲ្យតម្លៃទៅលើការរៀនសូត្រទេ ។ អ្នកទាំងនេះនិយាយថា «អង្គការគ្មានទេសញ្ញាប័ត្រ មានតែសញ្ញាឃើញ បើចង់បានបាក់អង់បាក់ឌុបត្រូវទៅយកនៅទំនប់ប្រឡាយ» ហើយថា «ការរៀនអក្សររៀនលេខមិនសំខាន់ទេ ការសំខាន់គឺការងារនិងចលនាបដិវត្តន៍» ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កុមារនៅទូទាំងប្រទេសមិនទទួលបានការរៀនសូត្រត្រឹមត្រូវទេ ។ កុមារទាំងអស់ត្រូវបានបញ្ចូលទៅក្នុងកងកុមារហើយធ្វើការដូចមនុស្សចាស់ដែរ ។ ការងាររបស់កុមាររួមមានរើសអាចម៍គោ កាប់ទន្រ្ទានខេត្តដើម្បីចក្រៀំធ្វើជី ។ល ។ ក្នុងមួយថ្ងៃកុមាររៀនអក្សរពីពីរទៅបីម៉ោង ដែលភាគច្រើនគឺជាការអប់រំបំពាក់បំប៉ននយោបាយ ។ ក្រៅពីនេះ កុមារត្រូវចុះទៅដកស្ទូង ឬជួយលើកទំនប់ប្រឡាយដូចឪពុកម្តាយរបស់ខ្លួនដែរ ។ សាលារៀននៅទូទាំងប្រទេសត្រូវបានបិទទ្វា ឬប្រែក្លាយជាមន្ទីរឃុំឃាំង ជាឃ្លាំងដាក់សម្ភារ ឬជាជង្រុកស្រូវ ។ ដូច្នេះការរៀនសូត្ររបស់កុមារត្រូវប្រព្រឹត្តទៅនៅក្រោមដើមឈើ ឬនៅក្រោមផ្ទះប្រជាជន ដែលមិនមានក្តារខៀនសៀវភៅ ឬប៊ិចសម្រាប់សរសេរទេ ។ ខ្មែរក្រហមបានឲ្យកុមារទន្ទេញចាំមាត់នូវពាក្យស្លោកនិងចម្រៀងបដិវត្តន៍ ដែលពោរពេញទៅដោយការចងគំនុំ ការកាប់សម្លាប់បង្ហូរឈាម ការវាយសម្រុកធ្វើស្រែ ជីកប្រឡាយ និងលើកទំនប់ និងការតស៊ូប្រយុទ្ធជាមួយវៀតណាម ។ល ។ ទាំងនេះ គឺជាទង្វើដែលផ្ទុយទាំងស្រុងទៅនឹងគោលការណ៍ទូទៅនៃការកសាងប្រទេសជាតិ ដែលការអប់រំគឺជាស្នូលនៃការអភិវឌ្ឍន៍ ហើយកុមារជាអនាគតសសរទ្រូងនៃប្រទេសជាតិ ។

សួន សីលា ដែលក្នុងរបបខ្មែរក្រហម ក្រុមគ្រួសាររបស់គាត់ត្រូវជម្លៀសចេញពីទីរួមស្រុកថ្ម ពួកទៅរស់នៅតំបន់ជនបទដាច់ស្រយាលមួយឈ្មោះភូមិតាសៀវ បានរៀបរាប់ពីជីវិតគ្រួសារនិងជីវិតផ្ទាល់ខ្លួនរបស់គាត់ថា «បងប្រុសធំរបស់ខ្ញុំត្រូវអង្គការបញ្ជូនទៅកងចល័តយុវជន ឯបងប្រុសទីពីរទៅកងចល័តកុមារ ។ កាលណោះខ្ញុំនៅតូច អង្គការមិនបានបញ្ជូនខ្ញុំទៅណាឆ្ងាយពីម្តាយទេ ។ ខ្ញុំរៀនក្រោមដើមអំពិល គ្មានតុ គ្មានសៀវភៅសរសេរ ។ គ្រូបង្រៀនគឺជាមនុស្សដែលអង្គការបញ្ជូនមកដុសខាត់ខួរក្បាលកុមារឲ្យស្រលាញ់និងគោរពអង្គការ និងស្មោះត្រង់ជាមួយអង្គការជានិច្ច ។ គ្រូឲ្យយើងទន្ទេញចាំមាត់នូវចម្រៀងបដិវត្តន៍ដ៏រុងរឿងរបស់អង្គការដែលមានទំនុកថា ៈ យើងខ្ញុំកុមារស្រលាញ់អង្គការ ឥតមានព្រំដែន ដោយសារអង្គការ យើងខ្ញុំរស់រាន ជីវិតថ្កើនថ្កាន រីករាយអស្ចារ្យ...។ យើងខ្ញុំកុមារ ជឿលើអង្គការ មិនដែលភ្លាំងភ្លេច សម្រុកពលកម្ម ខ្លាំងក្លាឥតដាច់ សម្រេចភារកិច្ច ការពារកសាង ។ ជួនកាលក្រុមរបស់ខ្ញុំត្រូវអង្គការបញ្ជូនឲ្យទៅរើសលាមកគោនៅឆ្ងាយពីភូមិ» ។ តើប្រទេសមួយអាចអភិវឌ្ឍន៍ជឿនលឿនទៅមុខបានដែរឬទេ ប្រសិនបើប្រព័ន្ធអប់រំទូទាំងប្រទេសត្រូវបានលុបបំបាត់ហើយ បច្ចេកវិជ្ជា គ្រឿងយន្ត និងឧបករណ៍សម្ភារទំនើបផ្សេងៗ ត្រូវបានបដិសេធមិនទទួលយកមកប្រើប្រាស់ក្នុងដំណើរការកសាងជាតិ?

មេដឹកនាំខ្មែរក្រហមចាត់ទុកគ្រឿងសង្ហារឹម គ្រឿងអលង្ការ ម៉ូតសម្លៀកបំពាក់ផ្សេងៗថាជាកម្ទេចក្រពត្តិ ហើយបានហាមប្រាមប្រជាជនទូទាំងប្រទេសនិងដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរចំពោះជនណាដែលពាក់គ្រឿងអលង្ការឬប្រើប្រាស់របស់ទាំងនេះ ។ ខ្មែរក្រហមបានបង្កើតពាក្យស្លោកមួយថា «ប្តេជ្ញាជម្រុះ និងកម្ទេចរបបចក្រពត្តិ សក្តិភូមិ និងអភិជន ដែលសុទ្ធតែជាប្រតិកិរិយា! កុំលនឹងអង្គការ កុំហីហារនឹងកម្ទេចក្រពត្តិ» ។ អ្នកដែលរកឃើញថា បានល្មើសនឹងបទបញ្ញត្តិនេះត្រូវបានចោទប្រកាន់ថា មិនដាច់ខាត មិនស្អាតស្អំ មិនបដិវត្តន៍ មិនរីកចម្រើន ហើយអាចត្រូវបានយកទៅសម្លាប់ទៀតផងក្នុងករណីខ្លះ ។

ខ្មែរក្រហមគ្រប់គ្រងគ្រប់ផ្នែកទាំងអស់នៃជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជន សូម្បីតែបញ្ហារើសគូស្រករក្តី ។ បុរសស្ត្រីទាំងឡាយមិនមានសិទ្ធិជ្រើសរើសគូអនាគតដោយខ្លួនឯងទេ ។ មង្គលការដែលជាអនាគតមួយជីវិតរបស់ខ្លួនគឺអង្គការជាអ្នកកំណត់ ។ ខ្មែរក្រហមមើលឃើញពិធីរៀបការតាមប្រពៃណីខ្មែរដូចដែលខ្លួនមើលឃើញការសិក្សានៅតាមសាលាដែរ ថាជាការខ្ជះខ្ជាយពេលវេលានិងធនធាន និងប៉ះពាល់ដល់ដំណើរការបដិវត្តន៍របស់ខ្លួន ។ មួយផ្នែកទៀត ខ្មែរក្រហមយល់ឃើញថាសម្ព័ន្ធអាពាហ៍

ពិពាហ៍គឺជាមូលហេតុមួយនាំទៅដល់ភាពមិនដាច់ខាតខាងបដិវត្តន៍ និងធ្វើឲ្យមានការពិបាកក្នុងការស្វែងរកចាប់ខ្មាំងបង្កប់ ដោយសារប្តីប្រពន្ធមាននយោបាយទោសភេទក្លែងក្លាយគ្នា ហើយជួយលាក់បាំងគ្នាទៅវិញទៅមក ។ ហេតុដូច្នេះហើយ ខ្មែរក្រហមមិនអនុញ្ញាតឲ្យឪពុកម្តាយបងប្អូនឬសាច់ញាតិចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនោះទេ ។ នៅក្នុងពិធីរៀបការម្តងៗ មានកូនប្រុសស្រីជាច្រើនគូ ដែលពេលខ្លះមានរហូតដល់ជាងមួយរយគូ ។ លោកទស្សនៈបដិវត្តន៍ចំពោះបញ្ហាកសាងគ្រួសារ នៅក្នុងទស្សនាវដ្តី «យុវជននិងយុវនារីបដិវត្តន៍» លេខចេញផ្សាយខែកុម្ភៈ ១៩៧៤ បាននិយាយថា អ្នកដែលអាចរៀបការបាន គឺអ្នកទាំងឡាយណា ដែលអង្គការពិនិត្យឃើញថាមានប្រវត្តិរូបស្អាតស្អំទាំងសីលធម៌រស់នៅទាំងនយោបាយ ហើយមិនមានជំពាក់ជាក់វិននឹងខ្មែរខ្មាំង ឬជាមួយពួកសមាសភាពមិនល្អ ហើយជាពិសេសត្រូវមានគោលជំហរបដិវត្តន៍រឹងប៉ឹង គោលជំហរប្រយុទ្ធដាច់ខាត និងបានបំពេញ ភារកិច្ចជូនបដិវត្តន៍បានល្អ ។ នៅក្នុងទស្សនាវដ្តីលេខដដែលនេះ ខ្មែរក្រហមនិយាយថា «បើអង្គការ-សមូហភាព ពិនិត្យឃើញយ៉ាងណាសម្រេចយ៉ាងណា ត្រូវគោរពតាមដាច់ខាត កុំទោមនស្សកុំថ្នាំងថ្នាក់ ព្រោះមានតែអង្គការមានតែសមូហភាពទេ ដែលអាចពិនិត្យមើលបានមធ្យតនិងគ្រប់ជ្រុងជ្រោយ» ។ នេះគឺជាការជ្រៀតជ្រែកនិងរំលោភទៅលើជីវភាពឯកជនរបស់ប្រជាជនគ្រប់រូបដែលជាសិទ្ធិជាមូលដ្ឋានក្នុងនាមជាមនុស្ស ។

ព្រះពុទ្ធសាសនានិងសាសនាដទៃទៀតក៏ត្រូវបានចាត់ទុកថាជាកម្អែលសង្គមចាស់ដែរ ។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ (ជំពូកទី១៥ មាត្រា២០) បានចែងថា «ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជឿជំនឿឬសាសនាណាក៏បាន ។ មិនអនុញ្ញាតឲ្យមានសាសនាប្រតិកិរិយា ដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជាដាច់ខាត» ។ គ្រប់ជំនឿនិងសាសនាទាំងអស់ ទោះព្រះពុទ្ធសាសនាក្តី សាសនាអ៊ីស្លាមក្តី សាសនាគ្រិស្តក្តី ឬជំនឿទៅលើអារក្សអ្នកតាតាំងពីបុរមបុរាណមកក្តី ត្រូវបានចាត់ទុកថាជាសាសនាប្រតិកិរិយា ហើយត្រូវតែកម្ទេចចោល ។ មានតែទ្រឹស្តីមនោគមវិជ្ជារបស់បក្សកុម្មុយនិស្តកម្ពុជាតែមួយគត់ដែលខ្មែរក្រហមចាត់ទុកថាមានតម្លៃគួរគោរពប្រណិប័ត្រ ។ ព្រះពុទ្ធសាសនាដែលប្រជាជនកម្ពុជាប្រហែល៩០ភាគរយគោរពបូជា និងជាគ្រឹះនៃវប្បធម៌ខ្មែររាប់ពាន់ឆ្នាំមកហើយនោះគឺ ជាឧបសគ្គដ៏ធំនៅក្នុងការកសាងបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ និងជាឧបករណ៍រាំងស្ទះដល់ដំណើរឆ្ពោះទៅរកបដិវត្តន៍សង្គមនិយមពិតប្រាកដរបស់ខ្លួន ។ ខ្មែរក្រហមបានបផ្ទាត់បង្រៀនកងទ័ពនិងកម្មាភិបាលទាំងអស់ «ឲ្យកសាងខ្លួនក្នុងការងារក្នុងចលនាតស៊ូមិនមែនកសាងខ្លួនតាមសមាធិក្នុងបន្ទប់ទេ ។ បើកសាងខ្លួនដោយអង្គុយសង្រួមតាមសមាធិនោះគឺកសាងមិនបានទេ» ។ នេះគឺជាការវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើលទ្ធិសាសនា ។ មិនតែប៉ុណ្ណោះ ខ្មែរក្រហមបានវាយកម្ទេចពុទ្ធបដិមារតាមវត្តអារាមនានា ដុតគម្ពីធម៌ បង្ខំព្រះសង្ឃឲ្យលាចាកសិក្ខាបទ ហើយប្រែក្លាយវត្តអារាមទៅជាឃ្លាំងដាក់សម្ភារៈឬជង្រុកស្រូវ និងហាមប្រាមមិនឲ្យប្រជាជនធ្វើការបួងសួង ប្រារព្ធពិធីសែនព្រេន ឬបង្ហាញពីមនោសញ្ចេតនាក្នុងការគោរពបូជាសាសនា ។ ខ្មែរក្រហមចាត់ទុកសាសនាគឺជាអាភៀន ហើយលោកសង្ឃជាជនបញ្ញើក្អែកនិងជាព្រូនសង្គម ហើយថែមទាំងបានលើកពាក្យស្លោកថា «កម្ទេចព្រះមួយអង្គចំណេញស៊ីម៉ងត៍មួយបាវ» ហើយថា «អង្គការគ្មានព្រះគ្មានខ្មោចលង គ្មានអបិយជំនឿ» ។ សាសនាដទៃទៀតក៏មានវាសនាមិនខុសពីព្រះពុទ្ធសាសនាដែរ ។ វិហារសាសនាគ្រិស្តមួយចំនួនត្រូវបានវាយកម្ទេច ។ មេដឹកនាំសាសនាឥស្លាមជាច្រើនត្រូវបានសម្លាប់ ហើយបរិស័ទអ៊ីស្លាមត្រូវបានបង្ខំឲ្យរស់នៅលាយឡំជាមួយប្រជាជនខ្មែរ និងត្រូវបានបង្ខំឲ្យហូបសាច់ជ្រូក និងប្តូរឈ្មោះឲ្យមានលក្ខណៈជាខ្មែរវិញ ។ គោលការណ៍លុបបំបាត់ និងបន្ទុះបង្អាប់សាសនានេះគឺដើម្បីបំពាក់បំប៉នប្រជាជនកុំឲ្យជឿលើកម្លាំងក្រៅខ្លួន តែបែមកជឿលើអង្គការ ដែលខ្មែរក្រហមជឿថាមានសារសំខាន់បំផុតក្នុងជំហាន «មហាលោតផ្លោះមហាអស្ចារ្យ» របស់ខ្លួន ។

ទាំងអស់នេះសុទ្ធតែជាគោលការណ៍សំខាន់ៗរបស់ខ្មែរក្រហមក្នុងការកម្ទេចចោលឲ្យអស់នូវគំរូ និងការអនុវត្តន៍ពីសង្គមចាស់ ។ គោលការណ៍ទាំងនេះត្រូវបានអនុវត្តសន្សឹមៗនៅក្នុងរយៈកាលនៃសង្គ្រាមតស៊ូ១៩៧០-១៩៧៥ ហើយការប្រព្រឹត្តទៀតសោតត្រូវបានធ្វើឡើងពោរពេញដោយល្បិចបោកបញ្ឆោតយ៉ាង

ប៉ិនប្រសព្វ ។ ក្នុងរយៈកាលតស៊ូនេះ កម្មាភិបាលខ្មែរក្រហម ក្នុងតំបន់រំដោះទាំងឡាយបានអប់រំអ្នកនៅក្រោមបង្គាប់និងកងទ័ព មិនឲ្យធ្វើអ្វីដែលប៉ះពាល់ដល់ប្រជាជនឡើយ "មិនត្រូវប៉ះពាល់ទ្រព្យសម្បត្តិរបស់ប្រជាជន ទោះបីអង្ករមួយគ្រាប់ ម្ទេសមួយផ្លែ ម្ជុលមួយដើមក៏ដោយ" ។ ប៉ុន្តែ បន្ទាប់ពីជ័យជម្នះ ១៧ មេសា ១៩៧៥មក គោលការណ៍ទាំងនេះត្រូវបានដាក់ឲ្យអនុវត្តន៍ដោយបង្ខំនិងទាំងកម្រោលដោយគ្មានការលើកលែងចំពោះជនណាម្នាក់ឡើយ ។ អ្នកដែលធ្វើមិនបាន ឬតាមមិនទាន់របត់សង្គមនេះត្រូវបានចោទដោយប្រលំ និងគ្មានការវិនិច្ឆ័យឲ្យបានត្រឹមត្រូវថាជាខ្មាំងប្រឆាំងនឹងបដិវត្តន៍ ប្រឆាំងនឹងអង្គការ ហើយត្រូវតែកម្ទេចចោលជាដាច់ខាត ស្របនឹងពាក្យស្លោកមួយដែលកម្មាភិបាលខ្មែរក្រហមទន្ទេញចាំមាត់សូត្រឲ្យប្រជាជនស្តាប់ថា "កង់ប្រវត្តិសាស្ត្រកំពុងតែវិលទៅមុខ លូកដៃដាច់ដៃ លូកជើងដាច់ជើង" ។

## សមូហភាពូបនីយកម្ម

កម្ពុជាប្រជាធិបតេយ្យបានបែងចែកទៅជាភូមិភាគ តំបន់ ស្រុក ឃុំ និង សហករណ៍ ។ រដ្ឋធានី គឺជាទីក្រុងប្រជុំអង្គការនយោបាយទាំងអស់របស់កម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមិនមែនជាបណ្តុំនៃសេដ្ឋកិច្ច វប្បធម៌ ពាណិជ្ជកម្ម និងការសិក្សាអប់រំទេ ។ ទីក្រុងភ្នំពេញមានប្រជាជនរស់នៅប្រហែលជាបួនម៉ឺននាក់ប៉ុណ្ណោះ ដែលសុទ្ធតែជាកម្មាភិបាលដឹកនាំជាតិជាន់ខ្ពស់ កងទ័ព និងកម្មករ ដែលបម្រើការងារនៅតាមរោងចក្រ ។ ក្រៅពីនេះ នៅទូទាំងប្រទេសកម្ពុជាត្រូវបានប្រែក្លាយរៀបចំឲ្យទៅជាសហករណ៍ ដែលជាមូលដ្ឋានសេដ្ឋកិច្ចសំខាន់ជាងគេបំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ។ ខ្មែរក្រហមបានពណ៌នាសហករណ៍ថាជាកំផែងថែបយ៉ាងរឹងមាំបំផុតសម្រាប់ការពារចលនាបដិវត្តន៍ និងការពារកម្ពុជាប្រជាធិបតេយ្យ ។ ទស្សនាវដ្តី "យុវជននិងយុវនារីបដិវត្តន៍" លេខចេញផ្សាយខែមិថុនា ឆ្នាំ១៩៧៦ បានអះអាងបន្ថែមថា "សហករណ៍គឺជាគ្រឹះនិងជាមូលដ្ឋានបង្អែកយ៉ាងរឹងប៉ឹងខ្លាំងក្លានៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជាបច្ចុប្បន្ននិងតទៅអនាគត" ។

សៀវភៅភូមិសាស្ត្រនយោបាយកម្ពុជាប្រជាធិបតេយ្យ បោះពុម្ពឆ្នាំ១៩៧៧ បាននិយាយថា សហករណ៍ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៧៣ ដែលមានសមាជិកពី១០ទៅ ៣០ គ្រួសារ ។ ក្រោយជ័យជម្នះ ១៧ មេសា ១៩៧៥ សហករណ៍ទាំងនេះត្រូវបានប្រែក្លាយឲ្យទៅជាសហករណ៍កម្រិតទាប (ឬហៅថាសហករណ៍រួមភូមិ) ដែលមានសមាជិកតិចជាង១០០០ គ្រួសារ ។ មកដល់ដើមឆ្នាំ១៩៧៧ សហករណ៍កម្រិតខ្ពស់ (ឬសហករណ៍ឃុំ) ដែលមានសមាជិកទាំងអស់ប្រហែល១០០០ គ្រួសារត្រូវបានបង្កើតឡើង ។ ខ្មែរក្រហមអះអាងថា សហករណ៍ជា "អង្គការចាត់តាំងមួយរបស់កសិករ ដែលរស់នៅហូបចុករៀនសូត្រ កម្សាន្ត ធ្វើការងារ និងទទួលផលស្មើៗគ្នាជាសមូហភាព ហើយមានធាតុពិត បដិវត្តន៍ដែលប្រឆាំងនិងកម្ទេចដាច់ខាតនូវរបបជិះជាន់ និងរបបកម្មសិទ្ធិឯកជនរបស់វណ្ណៈសក្តិភូមិនាយទុន ។ ប្រជាជនបានតម្រូវឲ្យប្រមូលទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងអស់ យកមកដាក់នៅសហករណ៍ប្រើប្រាស់រួមដូចជា គោ-ក្របី នង្គ័ល រនាស់ គ្រាប់ពូជ និងឧបករណ៍ផ្ទះបាយទៀតផង ។ ជាងនេះទៅទៀត ការបង្កើតសហករណ៍នេះគឺក្នុងគោលបំណងដើម្បីប្រមូលកម្លាំងប្រជាជនទាំងអស់មកដឹកប្រឡាយ និងលើកទំនប់ ដែលជាមូលដ្ឋានគ្រឹះក្នុងការពង្រីកវិស័យកសិកម្មដែលជាដង្ហើមសេដ្ឋកិច្ចធំជាងគេរបស់កម្ពុជាប្រជាធិបតេយ្យ ស្របនឹងពាក្យស្លោកមួយថា "មានស្រូវ គឺមានអ្វីៗទាំងអស់" ។

ដោយសារតែគំនិតស្រមើស្រមៃទៅលើតួនាទីដ៏សំខាន់របស់សហករណ៍នេះហើយ ខ្មែរក្រហមបានចាត់ទុកសហករណ៍ថាជាថ្នាលសម្រាប់បណ្តុះបណ្តាលកសាងខ្លួន និងជាសាលារៀនសម្រាប់លត់ដំប្រជាជនទូទាំងប្រទេសឲ្យមានសមត្ថភាពបដិវត្តន៍គ្រប់គ្រាន់ ដើម្បីបន្តកសាងបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជា ។ ផ្ទុយទៅវិញ ការអនុវត្តន៍ទាំងឡាយផ្ទុយទាំងស្រុងទៅនឹងទ្រឹស្តីនៃការបង្កើតសហករណ៍នេះ ។ ចលនានេះបែរជាបានបង្កឲ្យមានវិសមភាព ការជិះជាន់សង្កត់សង្កិន និងការកាប់សម្លាប់យ៉ាងសម្បើមនៅទូទាំងប្រទេស ។ ជាសម្ងាត់ សហករណ៍គឺជាជំរំប្រមូលផ្តុំមនុស្សដើម្បីចម្រាញ់ កម្ទេចចោលសមាសភាពមិនល្អដែលខ្មែរក្រហមហៅថា "ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង" ។ ជាពិសេស ប្រជាជនដែលជម្លៀសមកពីតាមបណ្តាទីក្រុង

និងទីប្រជុំជននានា ត្រូវបានខ្មែរក្រហមចាត់ទុកថាជាសមាសភាពដ៏គួរឲ្យសង្ស័យបំផុត ហើយអ្នកទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុងសហករណ៍នៅតាមជនបទនានា ហើយត្រូវបង្ខំឲ្យធ្វើការធ្ងន់ធ្ងរ និងរស់នៅក្នុងលក្ខខណ្ឌលំបាកលំបិនជាងប្រជាជនមូលដ្ឋាន ។ ពីមួយថ្ងៃទៅមួយថ្ងៃ មេដឹកនាំសហករណ៍ព្យាយាមស៊ើបពីប្រវត្តិការងាររបស់ប្រជាជនទាំងនេះ តាមរយៈការធ្វើប្រវត្តិរូប ការឈ្លបយកការណ៍នៅពេលយប់ សកម្មភាពការងារប្រចាំថ្ងៃ និងការប្រជុំជីវភាព ដើម្បីធ្វើការរិះគន់-ស្វ័យរិះគន់ជាប់ជានិច្ច ។ សមាជិកគ្រួសារទាំងអស់ត្រូវបានបំបែកឲ្យទៅធ្វើការនៅតាមក្រុមផ្សេងៗគ្នា ។ អ្នកទាំងនេះមិនដែលស្គាល់ភាពកក់ក្តៅក្នុងគ្រួសារទេនៅក្នុងអំឡុងពេលជិតបួនឆ្នាំនៃរបបនេះ ។ ក្មេងជំទង់ៗត្រូវបានយកចេញពីសហករណ៍ទៅសមរភូមិមុខ ហើយមួយចំនួនបានស្លាប់ឬបាត់ខ្លួនជារៀងរហូត ។

ការប្រជុំរិះគន់-ស្វ័យរិះគន់ត្រូវបានដាក់ឲ្យអនុវត្តនៅទូទាំងប្រទេស ។ នៅក្នុងទស្សនាវដ្តី «យុវជននិងយុវនារីបដិវត្តន៍» (លេខចេញផ្សាយខែឧសភា ១៩៧៦) ខ្មែរក្រហមបានពណ៌នាការប្រជុំនេះថាជាអាវុធដ៏សំខាន់បំផុតក្នុងការប្រយុទ្ធប្រឆាំងនឹងទស្សនៈគោលជំហរ សតិអារម្មណ៍ និងទម្លាប់ចាស់ដែលមិនបដិវត្តន៍ មិនអធន មិនសមូហភាព និងមិនចម្រើនរុងរឿង ។ ខ្មែរក្រហមបានហៅទស្សនៈនិងគោលជំហរសតិអារម្មណ៍ទាំងនេះថា ជាសត្រូវអរូបិយដែលមាននៅក្នុងខ្លួនប្រជាជនស្ទើរគ្រប់រូប និងជាសត្រូវដ៏គ្រោះថ្នាក់បំផុតសម្រាប់បដិវត្តន៍របស់ខ្លួន ។

នៅក្នុងទស្សនាវដ្តីលេខដដែលនេះ ពាក្យ «រិះគន់» ត្រូវខ្មែរក្រហមឲ្យនិយមន័យថាជាការត្រួតពិនិត្យ និងតាមដាន ទាំងគុណសម្បត្តិ ទាំងគុណវិបត្តិរបស់មនុស្សម្នាក់ៗក្នុងការរស់នៅ និងការធ្វើការងារបំពេញភារកិច្ចបដិវត្តន៍ប្រចាំថ្ងៃ» ។ ការរិះគន់នេះគឺជាការតម្រែតម្រង់ផ្លូវសម្រាប់ប្រជាជនកុំឲ្យដើរខុសផ្លូវ ឬធ្លាក់ទៅក្នុងផ្លូវមិនល្អ ដែលអាចបង្កជាគ្រោះថ្នាក់ដល់ចលនាបដិវត្តន៍ ។ ឯ «ស្វ័យរិះគន់» គឺជាការត្រួតពិនិត្យនិងតាមដានខ្លួនឯង ហើយលាតត្រដាងពីកំហុសរបស់ខ្លួនដាក់ឲ្យសមូហភាពជួយពិនិត្យនិងកសាង ។

នៅពេលប្រជុំជីវភាពម្តងៗ ប្រធានសហករណ៍បញ្ជាឲ្យប្រជាជនម្នាក់ៗឡើងសារភាពពីកំហុសខុសឆ្គងដែលខ្លួនបានធ្វើកន្លងមក ហើយដាក់ខ្លួនឲ្យសមូហភាពកសាង ។ កំហុសមួយចំនួនដែលប្រជាជនសារភាពមានដូចជា ធ្វើការមិនទាន់ផែនការ លួចទៅលេងផ្ទះដោយគ្មានការអនុញ្ញាត លួចសម្រាកខ្ជិល ធ្វើការងារបណ្តោយឲ្យគោស៊ីស្រូវ ធ្វើឲ្យបែកបាក់ចានស្លាបព្រាដែលជារបស់រួម បង្ហាញមនោសញ្ចេតនាគ្រួសារ ឬការគោរពជំនឿសាសនា ឬនិយាយអាក្រក់ពីអង្គការ ។ល ។ អ្នកទាំងឡាយណាដែលត្រូវបានរកឃើញថាបានប្រព្រឹត្តនូវកំហុសទាំងនេះ ត្រូវបានកាត់របបអាហារដ៏តិចតួច និងបង្ខំឲ្យធ្វើការបន្ថែមជាទម្ងន់ ។ អ្នកដែលមិនអាចបំពេញការងារបន្ថែមបានតាមការកំណត់ត្រូវទទួលរងទារុណកម្មយ៉ាងធ្ងន់ធ្ងរ ។ ជាងនេះទៅទៀត នៅក្នុងអង្គប្រជុំ ប្រសិនបើមនុស្សបីនាក់ចោទដូចៗគ្នាថាអ្នកណាម្នាក់ជាអ្នករដ្ឋការចាស់ ជាអតីតទាហាន ឬជាគ្រូបង្រៀន ជនម្នាក់នោះនឹងត្រូវចាត់ទុកថាជាខ្មាំងរបស់អង្គការ ហើយនឹងត្រូវយកទៅសម្លាប់ ។ វិធានការបែបនេះប្រៀបបានទៅនឹងការគូសវាសផ្លូវដ៏តូចចង្អៀតមួយ ដែលនៅសងខាងផ្លូវពោរពេញដោយគ្រោះថ្នាក់សម្រាប់ឲ្យប្រជាជនដើរ ។ នេះគឺជាការដាក់កំហិតយ៉ាងតឹងរ៉ឹងទៅសិទ្ធិរបស់បុគ្គលម្នាក់ៗក្នុងនាមជាមនុស្ស ។

## គម្រោងផែនការបួនឆ្នាំ

បន្ទាប់ពីការសម្រេចបង្កើតជាផ្លូវការនូវរដ្ឋកម្ពុជាប្រជាធិបតេយ្យ ដោយអង្គប្រជុំសន្និបាតលើកទី១ របស់សភាតំណាងប្រជាជនកម្ពុជា នៅថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦មក គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជាបានបើកការប្រជុំដ៏ប្រញាប់ប្រញាល់មួយដែលប្រព្រឹត្តទៅនៅថ្ងៃ២១ ខែកក្កដា ដល់ថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៦ ដើម្បីពិភាក្សាពីគម្រោងផែនការ៤ឆ្នាំ (១៩៧៧-១៩៨០) កសាងសង្គមនិយមគ្រប់ផ្នែករបស់ខ្លួន ។ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាចាត់ទុកគម្រោងផែនការបួនឆ្នាំនេះ ថាជាជំហានយក្សមួយដ៏អស្ចារ្យ ដែលកម្ពុជាក្រោមការដឹកនាំរបស់«អង្គការមហាភ្ញីស្វាង» នឹងលោតផ្លោះពីសង្គមអាណានិគមថ្មី និងសង្គមពាក់កណ្តាលសក្តិភូមិរបស់ពួកសក្តិភូមិនិយមនិងនាយទុនគ្រប់ប្រភេទ (សំដៅលើរបបសាធារណរដ្ឋខ្មែរគាំទ្រដោយសហរដ្ឋអាមេរិក) ទៅដល់សង្គមនិយមតែ

មួត ។

នៅក្នុងគម្រោងផែនការបួនឆ្នាំនេះ ខ្មែរក្រហមបានសង្កត់ធ្ងន់ទៅលើការកសាងសង្គមនិយមខាងកសិកម្ម ឧស្សាហកម្ម គមនាគមន៍ ដឹកជញ្ជូន ទូរគមនាគមន៍ ពាណិជ្ជកម្ម ទេសចរណ៍ បច្ចេកទេស និងហិរញ្ញវត្ថុ (ការប្រមូលទុននិងការបង្កើនទុន) ។ ក្នុងចំណោមគម្រោងទាំងនេះ ផែនការកសាងសង្គមនិយមខាងកសិកម្មមានលក្ខណៈផុសផុលនិងសំខាន់ជាងគេបំផុត ។ ខ្មែរក្រហមគ្រោងផលិតស្រូវឲ្យបាន៣តោនក្នុង១ហិកតាសម្រាប់ដីស្រែធម្មតា និង៦ទៅ៧តោនក្នុងមួយហិកតាសម្រាប់ដីស្រែលេខមួយ ដែលអាចធ្វើការដាំដុះស្រូវពីរដងក្នុងមួយឆ្នាំ ។ នៅក្នុងកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ស្តីអំពីគម្រោងផែនការ៤ឆ្នាំ ក្រៅពីផលិតផលស្រូវដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចសំខាន់ជាងគេនោះ គម្រោងផែនការបួនឆ្នាំក៏នៅមានចែងពីផលិតផលកសិកម្មបន្ទាប់បន្សំដទៃទៀត (ពោត សណ្តែក) ដំណាំឧស្សាហកម្ម (កៅស៊ូ កប្បាស ក្រចៅ ដូង អំពៅ គរ ថ្នាំជក់) ដំណាំហូបផ្លែ បន្លែបង្ការ ដំណាំឈើនិងព្រៃឈើដែលអាចយកមកច្នៃធ្វើវត្ថុធាតុដើមសម្រាប់ធ្វើថ្នាំពេទ្យ អនុផលព្រៃឈើ និងការចិញ្ចឹមសត្វ ដែលអាចបម្រើដល់តម្រូវការក្នុងស្រុកនិងនាំចេញទៅបរទេសដែរ ។ នៅក្នុងរយៈកាលបួនឆ្នាំនេះ ខ្មែរក្រហមមានគម្រោងផលិតស្រូវឲ្យបាន២៦,៦៦លានតោន ហើយគ្រោងនាំអង្ករចេញទៅលក់នៅក្រៅប្រទេសចំនួន៦,៩៥លានតោន ដែលអាចទទួលបានចំណូលជាសាច់ប្រាក់ ១៣៩០លានដុល្លារអាមេរិក ដែលក្នុងមួយតោនអង្ករលក់បានតម្លៃ២០០ដុល្លារអាមេរិក ។

ក្នុងចំនួនប្រាក់ដែលបានមកពីការលក់អង្ករក្នុងរយៈកាលបួនឆ្នាំ៧០ភាគរយត្រូវបានគ្រោងទុកចំណាយទៅលើការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ និងជីវភាពប្រជាជន ។ មេដឹកនាំខ្មែរក្រហមដែលជាអ្នករៀបចំគម្រោងនេះឡើង និងជាអ្នកដាក់ឲ្យអនុវត្តផែនការយ៉ាងច្រើនសម្បើមនៅទូទាំងប្រទេសមិនបានគិតដល់កម្លាំងពលកម្មទន់ខ្សោយរបស់ប្រជាជនដែលទើបតែងើបពីសង្គ្រាម និងកាខ្វះខាតធនធានគ្រប់ប្រភេទដែលធ្វើឲ្យការអនុវត្តផែនការនេះមិនអាចធ្វើទៅកើត ។ ដើម្បីសម្រេចឲ្យបានផែនការនេះ ខ្មែរក្រហមបានបង្ខំប្រជាជននៅទូទាំងប្រទេសឲ្យធ្វើការដាំដុះស្រូវ ហើយសូម្បីតែកងទ័ពក៏ត្រូវចុះទៅធ្វើស្រែដែរ ។ ជាងនេះទៅទៀត មេដឹកនាំទាំងនេះមិនបានខ្វល់ខ្វាយពិចារណាពីការប្រើប្រាស់ដី ការជ្រើសរើសគ្រាប់ពូជ ឬការប្រើប្រាស់ ឧបករណ៍កសិកម្មទំនើបឡើយ ដោយប្រើប្រាស់ដីធម្មជាតិនិងកម្លាំងពលកម្មរបស់ប្រជាជនសុទ្ធសាធ ។

ដោយសារខ្មែរក្រហមផ្តោតជាចម្បងតែទៅលើផលិតកម្មស្រូវ និងបដិសេធបច្ចេកវិជ្ជានោះ មិនត្រឹមតែផែនការកសាងសង្គមនិយមខាងកសិកម្មប៉ុណ្ណោះទេដែលបរាជ័យ ផែនការជាតិធំៗដទៃទៀតក៏បរាជ័យដែរ ។ ជាក់ស្តែងនៅក្នុងផែនការឧស្សាហកម្មដែលគ្រោងផលិត ចាន ឆ្នាំង ស្លាបព្រា ក្រមា មុង កាំបិត ពូថៅ និងឧស្សាហកម្មធន់ធ្ងន់មួយចំនួនដូចជា សារធាតុគីមី ត្បូងថ្ម ថាមពល អគ្គីសនី ប្រេងកាត និងគ្រឿងម៉ាស៊ីនផ្សេងៗ មួយចំនួនគ្មានដំណើរការ ហើយមួយចំនួនទៀតដំណើរការក្នុងទ្រង់ទ្រាយតូច និងគ្មានគុណភាពអាចប្រកួតប្រជែងនាំចេញយកទៅលក់នៅបរទេសបានទេ ។ នៅក្នុងបញ្ជីពាណិជ្ជកម្មរបស់ខ្មែរក្រហម ក្រៅពីការនាំចេញស្រូវ កៅស៊ូ និងផលិតផលកសិកម្មមួយចំនួនទៀត មិនមានរាយនាមផលិតផលឧស្សាហកម្មដែលអាចនាំចេញបាននោះទេ ។ ផ្ទុយទៅវិញ ខ្មែរក្រហមបាននាំចូលផលិតផលគីមី ប្រេង សំពត់ និងគ្រឿងចក្រសម្រាប់កសិកម្មពីប្រទេសចិនយ៉ាងច្រើន ។

ចំពោះផ្នែកគមនាគមន៍ ដឹកជញ្ជូន ទូរគមនាគមន៍ ខ្មែរក្រហមមានគម្រោងសាងសង់ផ្លូវជាតិ ស្ពាន និងផ្លូវនៅតាមបណ្តាខេត្តទាំងអស់ឲ្យបាន៧០ភាគរយ នៅឆ្នាំ១៩៧៧ និង ១០០ភាគរយក្នុងឆ្នាំ១៩៨០ ។ ជាងនេះទៅទៀត ខ្មែរក្រហមគ្រោងបើកឲ្យមានសេវាទូរគមនាគមន៍និងប្រៃសណីយ៍ឡើងវិញនៅឆ្នាំ១៩៧៧ និងប្រុងប្រៀបបើកផ្លូវអាកាសស៊ីវិលនៅឆ្នាំ ១៩៧៨ ជាពិសេសជើងយន្តហោះ ភ្នំពេញ-សៀមរាប សម្រាប់ភ្ញៀវទេសចរណ៍ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ផ្លូវថ្នល់ ផ្លូវដែក និងស្ពានមួយចំនួនតូចប៉ុណ្ណោះត្រូវបានសាងសង់ ហើយការសាងសង់ទៀតសោតគឺធ្វើឡើងក្នុងគោលបំណងបម្រើផ្នែកយុទ្ធសាស្ត្រកងទ័ពប៉ុណ្ណោះ ។ ឧទាហរណ៍ ការតភ្ជាប់ផ្លូវដែកភ្នំពេញ-កំពង់សោមនិងស្ពានមួយចំនួននៅតាមផ្លូវនេះ គឺដើម្បី

ដឹកគ្រឿងសព្វាវុធ រថក្រោះ គ្រឿងម៉ាស៊ីន និងសម្ភារដទៃទៀត ដែលជាជំនួយរបស់ចិន ។ ការសាងសង់ទាំងនេះមិនមែនសម្រាប់បម្រើប្រជាជនទេ ព្រោះក្នុងរយៈកាលនោះ ប្រជាជនមិនត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរចាកចេញពីសហករណ៍ដោយគ្មានការអនុញ្ញាតឡើយ ។ គម្រោងស្តីអំពីវិស័យទេសចរណ៍ក៏មិនអាចដំណើរការបាន ។ ខ្មែរក្រហមគ្រោងរៀបចំផ្ទះសំណាក់កន្លែងកម្សាន្ត និងដំណើរកម្សាន្តទៅតំបន់សៀមរាប ដើម្បីទៅទស្សនាប្រាសាទអង្គរតូច ប្រាសាទអង្គរធំ ប្រាសាទបន្ទាយស្រី ។ គម្រោងនេះគ្រោងចាប់ផ្តើមនៅឆ្នាំ១៩៧៧ ។ ប៉ុន្តែ ដូចដែលបានរៀបរាប់ពីខាងដើម ទំនាក់ទំនងរវាងប្រជាជននិងសម្ព័ន្ធភាពគ្រួសារត្រូវបានកាត់ផ្តាច់និងហាមប្រាមយ៉ាងតឹងរ៉ឹងបំផុត ។ ក្រៅពីមេដឹកនាំនិងកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនតូច មិនមានប្រជាជនណាម្នាក់ត្រូវបានអនុញ្ញាតឲ្យចេញក្រៅប្រទេស ហើយខ្មែរក្រហមក៏មិនបើកលាយឲ្យជនបរទេសចូលមកក្នុងកម្ពុជាប្រជាធិបតេយ្យដែរ ។ កម្ពុជាប្រជាធិបតេយ្យស្ទើរតែប្រទេសឯកោពីពិភពខាងក្រៅ ។ ជើងយន្តហោះពីប៉េកាំងមកភ្នំពេញ គឺជាច្រកតែមួយគត់សម្រាប់កម្ពុជាប្រជាធិបតេយ្យតភ្ជាប់ទៅពីភពខាងក្រៅ ។

ជាលទ្ធផលនៃការអនុវត្តគម្រោងផែនការនេះ ប្រជាជនទូទាំងប្រទេសត្រូវបាក់កម្លាំងដោយសារតែការងារធ្ងន់ហួសប្រមាណនិងការខ្វះខាតអាហារ ។ ការស្វែងរកចាប់ខ្លួនជនក្បត់ ឬអ្នកដែលខ្មែរក្រហមហៅថា «ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង» បានធ្វើឲ្យមានការប៉ះទង្គិចយ៉ាងខ្លាំងទៅលើស្មារតីរបស់ប្រជាជន ។ គ្រប់រូបបាក់ស្បាត និងភ័យខ្លាចយ៉ាងខ្លាំងចំពោះទារុណកម្មនិងការកាប់សម្លាប់ដែលប្រជាជនភាគច្រើនបានជួបប្រទះដោយផ្ទាល់ ។ កត្តាទាំងនេះបានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើផែនកាជាតិធំៗទាំងឡាយ ជាពិសេសផែនការបីគោនក្នុងមួយហិកតារបស់ខ្មែរក្រហម ដែលតំបន់មួយចំនួនមិនអាចបំពេញទៅតាមផែនការកំណត់ ហើយថែមទាំងខ្វះខាតទៀតផង ។ ជាងនេះទៅទៀត ការរក្សាការសម្ងាត់និងការបាត់ខ្លួនដែលមិនមានមូលហេតុច្បាស់លាស់របស់កម្មាភិបាលខ្មែរក្រហមខ្លួនឯងមួយចំនួនបានធ្វើឲ្យកម្មាភិបាលថ្នាក់ក្រោមខ្លាចមិនហ៊ានរាយការណ៍អំពីលទ្ធផលអាក្រក់ ដែលកើតមានឡើងនៅក្នុងតំបន់របស់ខ្លួន ទោះជាទិន្នផលមិនបានគ្រប់ចំនួនកំណត់ក្តី ។ កម្មាភិបាលគ្រប់គ្រងតាមតំបន់បានរាយការណ៍កុហកហើយបញ្ជូនស្រូវទៅអង្គការលើតាមចំនួនកំណត់ដោយទុកឲ្យប្រជាជននៅមូលដ្ឋានទទួលការអត់ឃ្លាន ។

## សេចក្តីសន្និដ្ឋាន

មេដឹកនាំខ្មែរក្រហមមានបំណងកសាងរបបសង្គមនិយមគំរូ



យោធាខ្មែរក្រហមចាប់ប្រជាជននិងអតីតទាហានមកពីខេត្តឧត្តរមានជ័យយកមកដាក់នៅក្នុងគុកធំ ខេត្តសៀមរាប

មួយនៅលើសកលលោក ដោយលោតពីបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ (ដំណាក់កាលអន្តរកាលដែលប្រទេសមួយទើបបញ្ចប់សង្គ្រាម ហើយទទួលបានសន្តិភាពនិងឯករាជ្យពេញលេញ) ទៅបដិវត្តន៍សង្គមនិយមតែម្តង ដោយមិនចាំបាច់ឆ្លងកាត់ដំណាក់កាលដូចបដិវិត្តន៍សង្គមនិយមរបស់ចិន ឬរបស់វៀតណាមខាងជើង ដែលក្រោយសង្គ្រាមប្រទេសទាំងនេះបានចំណាយពេលបីឆ្នាំដើម្បីស្តារសេដ្ឋកិច្ច ទើបរៀបចំផែនការប្រាំឆ្នាំដើម្បីកសាងសង្គមនិយមតាមក្រោយ ។ អ្វីដែលខ្មែរក្រហមអះអាងថា ពិសេសនិងប្លែកជាងប្រទេសសង្គមនិយមនៅលើសកលលោកនោះ គឺបដិវត្តន៍សង្គមនិយមរបស់ខ្មែរក្រហមឈរលើគោលការណ៍ "ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន" ដោយបានប្រកាសបដិសេធរាល់ជំនួយបរទេសទាំងអស់ ទោះជាបីជាខ្លួនបានទទួលជំនួយជាគ្រឿងសព្វាវុធ ជំនួយផ្នែកហិរញ្ញវត្ថុ និងជំនួយផ្នែកបច្ចេកទេសយ៉ាងច្រើនសន្ធឹកសន្ធាប់ពីកុម្មុយនិស្តចិនយ៉ាងណាក៏ដោយ ។

ខ្មែរក្រហមបានប្រៀបធៀបផែនការកសាងសង្គមនិយមរបស់ខ្លួន ទៅនឹងផែនការកសាងសង្គមនិយមរបស់ចិន កូរ៉េខាងជើង និងវៀតណាម ។ មេដឹកនាំទាំងនេះបានចោទប្រកាន់ថាប្រទេសទាំងបីចំណាយពេលឥតប្រយោជន៍យូរក្នុងដំណើរឆ្ពោះទៅកាន់សង្គមនិយម ព្រោះថាកូរ៉េខាងជើងរំដោះបានតាំងពីឆ្នាំ១៩៤៥ ហើយរហូតដល់ឆ្នាំ១៩៥៨ទើបធ្វើបដិវត្តន៍សង្គមនិយម ។ អ្នកទាំងនេះបាននិយាយដោយអំនួតថា "បើពិនិត្យពីលក្ខណៈសមូហភាពពីរបបសង្គមនិយម យើងលឿនជាងគេ៤-១០ឆ្នាំ" ។ តើខ្មែរក្រហមពិតជាបានសម្រេចនូវគោលដៅកសាងសង្គមនិយមរបស់ខ្លួនដែរឬទេ? ហើយនៅក្នុងដំណើរការនេះ តើខ្មែរក្រហមសទទួលជោគជ័យក្នុងការពង្រឹងនិងពង្រីករបបសមូហភាពនៃវណ្ណៈអធន ហើយសម្រេចកសាងសង្គមនិយមគ្រប់ផ្នែក ខាងសេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច បច្ចេកទេស ដោយជំហរឯករាជ-ម្ចាស់ការ ខ្លួនទីពឹងខ្លួន ដែលអ្នកទាំងនេះបានអួតអាងដែរឬទេ? តើខ្មែរក្រហមមានលទ្ធភាពកសាងទស្សនៈគោលជំហរ និងសតិអារម្មណ៍សង្គមនិយមឲ្យដល់ប្រជាជនកម្ពុជានៅទូទាំងប្រទេសដែរឬទេ?

ទោះជាមេដឹកនាំខ្មែរក្រហមបានអះអាងថា បដិវត្តន៍របស់ខ្លួនគឺជាបិដវត្តន៍ស្អាតស្អំដែលកើតចេញពីវណ្ណៈកសិករនិងកម្មករដែលខ្លួនចាត់ទុកថាជាវណ្ណៈអធននិងមិនយកតម្រាប់តាមបដិវត្តន៍របស់ប្រទេសណាទាំងអស់ ហើយជាបដិវត្តន៍មួយដែលឈរលើជំហរឯករាជ្យម្ចាស់ការយ៉ាងណាក៏ដោយ ជាក់ស្តែងខ្មែរក្រហមបានយកគំរូតាមបដិវត្តន៍វប្បធម៌របស់ចិន (១៩៦៦-១៩៧៦) ។ ការបណ្តេញប្រជាជនចេញពីទីក្រុងទៅធ្វើការងារកសិកម្ម ការផ្លាស់ប្តូរប្រជាជនពីកន្លែងមួយទៅកន្លែងមួយដោយបង្ខំ ការលុបបំបាត់ខឿនវប្បធម៌ ប្រពៃណីសាសនា ការសម្លាប់រង្គាលជនទាំងឡាយណាដែលប្រឆាំងជំទាស់ជាមួយកម្មាភិបាលរបស់បក្សនិងបដិវត្តន៍ និងការប្រមូលផ្តុំប្រជាជនសុទ្ធតែជាភ័ស្តុតាងដែលបង្ហាញថាខ្មែរក្រហមយកទ្រឹស្តីទស្សនមនោគមវិជ្ជាបដិវត្តន៍វប្បធម៌របស់ចិនមកអនុវត្ត ។ នៅក្នុងសៀវភៅ "ផ្លែខ្មៅនៃលទ្ធិប្រជាធិបតេយ្យ" សាស្ត្រាចារ្យ ម៉ៃឃិល ម៉ន បានអះអាងថាបដិវត្តន៍សង្គមនិយមរបស់ចិន បានយកគំរូតាមទ្រឹស្តីបដិវត្តន៍សង្គមនិយមរបស់សូវៀត ហើយមានលក្ខណៈជ្រុលនិយមជាងសូវៀតទៅទៀត និងបានប្រែក្លាយទ្រឹស្តីនេះឲ្យទៅជាមនោគមវិជ្ជាបដិវត្តន៍របស់ម៉ៅ ។ ចំណែកបដិវត្តន៍សង្គមនិយមរបស់ខ្មែរក្រហមយកតម្រាប់តាមគំរូរបស់ចិន ។ មិនតែប៉ុណ្ណោះ មេដឹកនាំខ្មែរក្រហមបានបន្ថែមគំនិតជ្រុលនិយមរបស់ខ្លួនប្រកបដោយមហិច្ឆតាទៅក្នុងទ្រឹស្តីទាំងនោះ ដែលធ្វើឲ្យការអនុវត្តមានសភាពកាន់តែសាហាវថែមទៀត ។ បដិវត្តន៍របស់ចិនបានប្រមូលផ្តុំប្រជាជនទៅជាសហករណ៍តូចៗ ហើយការប្រមូលផ្តុំទៀតសោតត្រូវបានធ្វើឡើងក្នុងរូបភាពស្ម័គ្រចិត្តនិងមានការជំទាស់តិចតួចណាស់ ។ ប៉ុន្តែមេដឹកនាំខ្មែរក្រហមបានបន្ថែមល្បាយទៅលើទ្រឹស្តីម៉ៅ ដោយចាប់បង្ខំប្រជាជនទូទាំងប្រទេសឲ្យប្រមូលផ្តុំជាសហករណ៍កម្រិតទាប ក្រោយមកប្រែក្លាយទៅជាសហករណ៍កម្រិតខ្ពស់ ដែលជាជំរំពលកម្មដោយបង្ខំ និងជាជំរំសម្លាប់មនុស្សយ៉ាងសម្វាត់ទៀតផង ។

ជំហានឆ្ពោះទៅសង្គមនិយមរបស់ចិនគឺជំហាន"លោតផ្លោះ" តែជំហានឆ្ពោះទៅសង្គមនិយមរបស់ខ្មែរក្រហមគឺជំហាន "មហាលោតផ្លោះ មហាអស្ចារ្យ" ។ ផែនការកសាងសង្គមនិយមរបស់ចិននិងវៀតណាមគឺ "គម្រោងផែនការ៥ឆ្នាំ" ចំណែកផែនការ

កសាងសង្គមនិយមរបស់ខ្មែរក្រហមគឺ «គម្រោងផែនការ៤ឆ្នាំ» ។ ណាយ៉ាន់ ចាន់ដា នៅក្នុងសៀវភៅរបស់គាត់«បងប្អូនដែលជាសត្រូវ» បានហៅការបណ្តេញប្រជាជនប្រហែលពីរលាននាក់នៅទីក្រុងភ្នំពេញ ឲ្យទៅធ្វើស្រែចម្ការនៅជនបទថាជាយុទ្ធសាស្ត្រ «មួយជំហានឈានដល់សង្គមនិយម» របស់ខ្មែរក្រហម ។

អ្វីដែលចម្លែកជាងនេះទៅទៀត ក្នុងដំណើរឆ្ពោះទៅបដិវត្តន៍សង្គមនិយមរបស់ខ្មែរក្រហមនោះ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ដែលហៅខ្លួនឯងថា «អង្គការបដិវត្តន៍» បានប្រមូលផ្តុំអំណាចគ្រប់គ្រងរដ្ឋគ្រប់ផ្នែកទាំងអស់ ។ អង្គការគឺជាស្ថាប័នតែមួយគត់ដែលមានសិទ្ធិក្នុងការបែងចែកផលិតផលកសិកម្ម និងការធ្វើទំនាក់ទំនងពាណិជ្ជកម្មជាមួយបរទេស ។ អង្គការត្រួតត្រាទៅលើជីវិតនិងការស្លាប់រស់របស់ប្រជាជន ព្រោះមេដឹកនាំទាំងនេះយល់ថាការប្រព្រឹត្តមិនល្អណាមួយរបស់បុគ្គលម្នាក់អាចប៉ះពាល់ដល់ដំណើរការបដិវត្តន៍របស់បក្សនិងប្រទេសទាំងមូល ។ ការប្រមូលផ្តុំអំណាចនៅថ្នាក់កំពូល ការអនុវត្តប្រព័ន្ធនយោបាយសេដ្ឋកិច្ចបិតជិត និងការបដិសេធមិនទទួលយកបច្ចេកវិជ្ជាទំនើបដើម្បីធ្វើទំនើបភាវូបនីយកម្មវិស័យកសិកម្ម បានបណ្តាលឲ្យសេដ្ឋកិច្ចជាតិមានការធ្លាក់ចុះយ៉ាងខ្លាំង ហើយហេតុការណ៍នេះបានធ្វើឲ្យប្រជាជនរាប់ម៉ឺននាក់ស្លាប់ដោយសារការអត់អាហារ ។

ទោះបីជាខ្មែរក្រហមទទួលបានជ័យជម្នះក្នុងផែនការសមូហភាវូបនីយកម្ម ហើយបានវាយកម្ទេចរបបសក្តិភូមិនាយទុននិងកម្មសិទ្ធិឯកជន ដោយបិទផ្សារនិងប្រែក្លាយពាណិជ្ជកម្មឯកជននិងរោងចក្រទាំងអស់ឲ្យទៅជារបស់រដ្ឋក្តី ក៏ខ្មែរក្រហមមិនអាចសម្រេចបាននូវផែនការកសាងសេដ្ឋកិច្ច វប្បធម៌ នយោបាយ និងសង្គមកិច្ចប្រកបដោយគុណភាពមួយបានដែរ ។ ផ្ទុយទៅវិញ ដំណើរការនេះបានធ្វើឲ្យកម្ពុជាប្រជាធិបតេយ្យធ្លាក់ទៅក្នុងស្ថានការណ៍កាន់តែយ៉ាប់យ៉ឺនទៅៗ ។ នៅចុងបញ្ចប់ ផែនការកសាងសង្គមនិយមស្អាតស្អំរបស់ខ្មែរក្រហមត្រូវបរាជ័យ ។ នេះបណ្តាលមកពីគំនិតអត្តនោម័តិនិយមនិងមហិចតារបស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ដែលចង់សម្រេចផែនការធំៗក្នុងរយៈពេល ដ៏ខ្លីដោយមិនបានគិតអំពីកម្លាំង ធនធានដែលមាន និងស្ថានភាពរស់នៅរបស់ប្រជាជន ។ ផែនការបោសសម្អាតខ្លាំងនៅក្នុងប្រទេសបានសម្លាប់ប្រជាជនស្លូតត្រង់ជាច្រើន និងថែមទាំងបានសម្លាប់កម្មាភិបាលជាន់ខ្ពស់របស់ខ្លួន ដែលបានចូលរួមក្នុងចលនាបដិវត្តន៍តាំងពីដើមមក ដូចជា សោ ភឹម, ញឹម រស់, ហ៊ូ នឹម, ហ៊ូ យន់ ជាដើម ។ ប្រការនេះបានធ្វើឲ្យមានការភ័យខ្លាច និងការស្អប់ខ្ពើមកាន់តែខ្លាំងឡើងទៅលើគោលនយោបាយរបស់បក្សពីសំណាក់ប្រជាជនទូទៅរួមទាំងកម្មាភិបាលខ្មែរក្រហមមួយចំនួនផង ហើយហេតុការណ៍នេះបណ្តាលឲ្យមានការបះបោរជាច្រើន ជាពិសេសការបះបោរនៅភូមិភាគបូព៌ាក្នុងអំឡុងឆ្នាំ១៩៧៨ បន្ទាប់ពីការធ្វើវិសុទ្ធកម្មយ៉ាងសាហាវយង់ឃ្នង់ទៅលើភូមិភាគនេះ ។ ខណៈពេលនោះដែរ ការបះទង្គិចនៅតាមព្រំដែនជាមួយវៀតណាមបានធ្វើឲ្យស្ថានភាពសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យមានការរង្គោះរង្គើរយ៉ាងខ្លាំង ។ កត្តាទាំងអស់នេះបានធ្វើឲ្យខ្មែរក្រហមឈានពីបដិវត្តន៍សង្គមនិយមទៅបដិវត្តន៍ផ្តួលរំលំខ្លួនឯង ដែលបានដួលរលំទាំងស្រុងនៅខែមករា ឆ្នាំ១៩៧៩ ។

**ឌី ខាំបូលី**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោម ៖

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ៖ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខ៖ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# តាម៉ុក ស្លាប់

តាម៉ុក អតីតលេខាភូមិភាគនិរតីនៃរបបកម្ពុជាប្រជាធិបតេយ្យ បានស្លាប់នៅថ្ងៃសុក្រ ទី២១ ខែកក្កដា ប្រហែលម៉ោង ៨ៈ៣០នាទីទៀបភ្លឺ នៅក្នុងមន្ទីរពេទ្យព្រះកេតុមាលា ក្នុងអាយុ៨០ឆ្នាំ ។


តា ម៉ុក ក្រោយឆ្នាំ១៩៧៩

តាម៉ុក ចាប់ផ្តើមឈឺធ្ងន់នៅចុងខែមិថុនា ។ វេជ្ជបណ្ឌិតបានពិនិត្យសុខភាពរបស់គាត់និងព្យាបាលគាត់នៅក្នុងពន្ធនាគារ ក៏ប៉ុន្តែជំងឺរបស់ តាម៉ុក មិនបានធូរស្រាល ផ្ទុយទៅវិញកាន់តែធ្ងន់ធ្ងរហើយត្រូវបញ្ជូនទៅមន្ទីរពេទ្យព្រះកេតុមាលានៅថ្ងៃទី២៩ ខែមិថុនា ។ វេជ្ជបណ្ឌិតបានរកឃើញថា តាម៉ុក មានជំងឺលើសឈាម ជំងឺបេះដូង និងជំងឺផ្លូវដង្ហើម ។ ស្ថានភាពរបស់គាត់ធ្ងន់ធ្ងរពីមួយថ្ងៃទៅមួយថ្ងៃ រហូតដល់ក្រុមវេជ្ជបណ្ឌិតដែលព្យាបាល គាត់ធ្វើសំណើបញ្ជូនគាត់ទៅមន្ទីរពេទ្យ កាល់ម៉ែត ដោយសារទីនោះមានសម្ភារបរិក្ខាទំនើបជាង ។ យោងតាមកាសែត ខេមបូឌា ដេលី លោកវេជ្ជបណ្ឌិត ហេង តៃគ្រី នាយកមន្ទីរពេទ្យកាល់ម៉ែត បដិសេធសំណើបញ្ជូន តាម៉ុក ទៅមន្ទីរពេទ្យកាល់ម៉ែតទេ ដោយលើកឡើងអំពីការលំបាកក្នុងការការពារសន្តិសុខរបស់ តាម៉ុក ហើយសន្យាបញ្ជូនវេជ្ជបណ្ឌិតជំនាញ និងដឹកសម្ភារទៅជួយនៅមន្ទីរពេទ្យព្រះកេតុមាលាវិញ ។ ក្នុងអំឡុងពេលនេះ តាម៉ុក បាត់ស្មារតីជាច្រើនដង និងមិនអាចទទួលទានអាហារនិងទឹកបាន ។

នៅថ្ងៃទី១៣ ខែកក្កដា បែនសុន សម័យ មេធាវីរបស់ តាម៉ុក បានធ្វើសេចក្តីប្រកាសព័ត៌មានមួយដែលនិយាយថា តាម៉ុក ធ្លាក់ក្នុងស្ថានភាពធ្ងន់ធ្ងរជាងមុន រហូតដល់បាត់ស្មារតី មិនអាចអង្គុយ មិនអាចនិយាយ និងមិនអាចទទួលទានអាហារនិងទឹកបាន ។

កូន ប្អូន និងសាច់ញាតិរបស់ តាម៉ុក បានមកមើលគាត់នៅមន្ទីរពេទ្យ ហើយត្រូវបានអនុញ្ញាតឲ្យចូលមើលក្នុងរយៈពេលខ្លី ក៏ប៉ុន្តែ តាម៉ុក លែងដឹងស្មារតីនិងមិនអាចនិយាយជាមួយអ្នកដែលមកមើលគាត់បានឡើយ ។

សាកសពរបស់ តាម៉ុក ត្រូវបានសាច់ញាតិដឹកយកទៅធ្វើបុណ្យនិងបញ្ចុះនៅអន្លង់វែង ខេត្តឧត្តរមានជ័យ ។

តាម៉ុក មានឈ្មោះ ដើម អ៊ុង ជឿន ឈ្មោះ ហៅក្រៅ ឈិត ជឿន ឬ ឯក ជឿន ឬអាចារ្យ ជឿន គឺជាអតីតអគ្គបញ្ជាការកងទ័ពរបស់ខ្មែរក្រហម និងជាអតីតលេខាភូមិភាគនិរតី ។ តាម៉ុក ត្រូវកងទ័ពរដ្ឋាភិបាលចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៩៩ និងដាក់ពន្ធនាគារដោយចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

តាម៉ុក ស្លាប់ខណៈដែលចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញចាប់ផ្តើមដំណើរការស៊ើបអង្កេតលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនដែលទទួលខុសត្រូវចំពោះការស្លាប់របស់ប្រជាជនកម្ពុជាប្រមាណជិត២លាននាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ការស្លាប់របស់ តាម៉ុក បង្ហាញឲ្យឃើញពីភាពចាំបាច់ក្នុងការជំរុញដំណើរការស៊ើបអង្កេតរបស់អង្គជំនុំ


សាកសព តាម៉ុក

ជម្រះវិសាមញ្ញឲ្យកាន់តែលឿនជាងនេះទៀត ដើម្បីឲ្យអង្គសវនាការអាចចាប់ផ្តើមមុនពេលដែលមេដឹកនាំខ្មែរក្រហមស្លាប់អស់ ។ នួន ជា មេដឹកនាំលំដាប់ទីពីររបស់ខ្មែរក្រហមបច្ចុប្បន្នអាយុ៨០ឆ្នាំ ខៀវ សំផន អាយុ៧៥ឆ្នាំ និង អៀង សារី អាយុ៧៦ឆ្នាំ កំពុងតែរស់នៅទីក្រុងប៉ៃលិន ។ ចំណែក ឌុច ប្រធានមន្ទីរ ស-២១ (គុកទួលស្លែង) អាយុ៦៤ឆ្នាំ កំពុងជាប់នៅក្នុងពន្ធនាគារ និងមិនទាន់បានទទួលការជំនុំជម្រះនៅឡើយ ។

**មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនដែលស្លាប់ដោយគ្មានការជំនុំជម្រះ**

◆ សុន សេន អតីតរដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ ស្លាប់ដោយឃាតកម្មនៅខែមិថុនា ឆ្នាំ១៩៩៧

◆ ប៉ុល ពត (បងទី១) លេខាបក្សកុម្មុយនិស្តកម្ពុជា ស្លាប់ដោយជំងឺនៅខែមេសា ឆ្នាំ១៩៩៨

◆ កែ ពក អតីតលេខាភូមិភាគបស្ចិម ស្លាប់ដោយជំងឺនៅខែកុម្ភៈ ឆ្នាំ២០០២

◆ ជួន ជឿន អតីតរដ្ឋមន្ត្រីក្រសួងសុខាភិបាល ស្លាប់ដោយចាស់ជរានៅខែមិថុនា ឆ្នាំ២០០៦

◆ តាម៉ុក អតីតលេខាភូមិភាគនិរតី ស្លាប់ដោយជំងឺនៅខែ កក្កដា ឆ្នាំ២០០៦

**ប្រវត្តិរូបសង្ខេបរបស់ តាម៉ុក**

◆ ឈ្មោះដើម ៖ អ៊ុង ជឿន

◆ ឈ្មោះហៅក្រៅ ៖ ឈិត ជឿន, ឯក ជឿន, អាចារ្យជឿន, ឆ្នួន កង

◆ ឆ្នាំកំណើត ៖ ឆ្នាំខាល (១៩២៦)

◆ ទីកន្លែងកំណើត ៖ ភូមិប្រកាប ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ

◆ ការសិក្សា ៖ បួសជាភិក្ខុនៅវត្តមហាមន្ត្រី និងរៀនចប់សាលាបាលីរង

◆ ឪពុក ៖ អ៊ុង ព្រាក ជាចៅអធិការវត្តមហាមន្ត្រី

◆ ម្តាយ ៖ ទូច សុច

◆ បងប្អូន ៖ ៧នាក់ (ប្រុស៣នាក់ ស្រី៤នាក់)

◆ ប្រពន្ធ ៖ អ៊ុក ខឹម

◆ កូន ៖ មានកូនស្រី៤នាក់

◆ តួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ៖ លេខាភូមិមិភាគនិរតី និងជាអគ្គបញ្ជាការរងទ័ព

**សាន់ កល្យាណ**



ពិធីដង្ហែសពតាម៉ុកទៅបញ្ចុះ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

# ដំណើរទស្សនកិច្ចរបស់មេឃុំមកកាន់ អគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅថ្ងៃទី២៤-២៥ ខែកក្កដា មេឃុំចំនួន៥១២នាក់មកពីខេត្តកោះកុង កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ព្រះវិហារ កំពង់ធំ កំពង់ចាម ឧត្តរមានជ័យ ក្រុងភ្នំពេញ និងប៉ៃលិន បានអញ្ជើញចូលរួមក្នុងដំណើរទស្សនកិច្ចនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង(មន្ទីរស-២១) វាលពិឃាតបឹងជើងឯក និងអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅទីក្រុងភ្នំពេញដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

មេឃុំទាំងអស់បានពិនិត្យមើលរូបថតនៅមន្ទីរស-២១ពីអគារមួយទៅអគារមួយយ៉ាងយកចិត្តទុកដាក់ សង្ឃឹមថានឹងអាចរកឃើញរូបថតសាច់ញាតិឬមិត្តភក្តិរបស់ខ្លួន ។ បន្ទាប់ពីបញ្ចប់ការទស្សនានៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង មេឃុំបានបន្តដំណើរឆ្ពោះទៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២ ដើម្បីចូលរួមស្តាប់ការបកស្រាយរបស់ឯកឧត្តម ម៉ោញ សាផាន អនុប្រធានគណៈកម្មាធិការនីតិកម្មនៃរដ្ឋសភាជាតិ, លោកមេធាវី កង រិទ្ធិគីរី និងលោក សួ ប៊ុនស៊ូ ប្រធានក្រុមទំនាក់ទំនងជាមួយតុលាការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអំពីខ្លឹមសារច្បាប់និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់សេចក្តីអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលរសៀលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំបញ្ចាំងខ្សែភាពយន្តឯកសារមួយមានចំណងជើងថា «ស-២១ ៖ ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម» ។ ក្រោយពីបញ្ចប់ការទស្សនាខ្សែភាពយន្តនេះ មេឃុំបានបន្តដំណើរទៅទស្សនារណ្តៅសាកសពជាច្រើននិងស្តូបតម្កល់អដ្ឋិធាតុជនរងគ្រោះនៅវាលពិឃាតជើងឯក និងបានចូលរួមបង្សុកូលឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។


មេឃុំជួបសំណេះសំណាលជាមួយ ចូសេហ្វ អេ ម៉ូសូមេលី ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក

នៅព្រឹកថ្ងៃបន្ទាប់ មេឃុំបានបន្តដំណើរទស្សនកិច្ចរបស់ខ្លួនទៅកាន់អគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីចូលរួមស្តាប់ការបកស្រាយបំភ្លឺបន្ថែមអំពីដំណើរការតុលាការ និងលើកចម្ងល់ផ្សេងៗជូនមន្ត្រីតុលាការ ។ ដំណើរទស្សនកិច្ចលើកនេះបានបញ្ចប់ បន្ទាប់ពី មេឃុំទាំងអស់បានអញ្ជើញទៅគេហដ្ឋានរបស់លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេហ្វ អេ ម៉ូសូមេលី ដើម្បីជួបសំណេះសំណាល និងស្តាប់បទសុន្ទរកថាស្វាគមន៍ ។

បច្ចុប្បន្នព័ត៌មាននៅទីក្រុងភ្នំពេញត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅតាមវិទ្យុ ទូរទស្សន៍ អ៊ិនធឺណែត និងបណ្តាញសារព័ត៌មានផ្សេងៗអំពីដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញ ។ ប៉ុន្តែប្រជាជនដែលរស់នៅតាមតំបន់ដាច់ស្រយាលមួយចំនួននៅតែមានការលំបាកក្នុងការទទួលព័ត៌មានអំពីអង្គជំនុំជម្រះវិសាមញ្ញនេះ ។ មានតែតាមរយៈមេឃុំទេដែលអាចជួយពាំនាំព័ត៌មានទាំងអស់នេះឲ្យដល់ប្រជាជនមូលដ្ឋាន តាមរយៈប្រធានភូមិ ប្រធានក្រុម ពីព្រោះថាអ្នកទាំងអស់ជាអ្នកនៅក្បែរប្រជាជន ។ មេឃុំទាំងអស់បានសម្តែងនូវការប្តេជ្ញាចិត្តក្នុងការបញ្ជូនព័ត៌មានទៅឲ្យប្រជាជន ដូចជាការជួបប្រជុំជាមួយមេភូមិៗដើម្បីឲ្យមេភូមិ


មេឃុំទស្សនានៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


មេឃុំចូលរួមបង្សុកូលឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធជនរងគ្រោះនៅវាលពិឃាតបឹងជើងឯក


មេឃុំជួបជាមួយលោក រាជ សម្បត្តិ អ្នកនាំពាក្យតុលាការខ្មែរក្រហម

ទាំងអស់បន្តការផ្សព្វផ្សាយដំណឹងនេះទៅប្រជាជនដែលគ្មានលទ្ធភាពទទួលព័ត៌មានទាំងអស់នេះ ។

អ្នកស្រី ខៀវ សុគឿន មេឃុំប្រស្នឹប ស្រុកលាប្អៀរ ខេត្តកំពង់ឆ្នាំង បានមានប្រសាសន៍ថា "ពេលដែលខ្ញុំត្រឡប់ទៅវិញ ខ្ញុំនឹងយកឯកសារព្រឹត្តិប័ត្រទាំងឡាយ ហើយនឹងផ្សព្វផ្សាយនូវទិដ្ឋភាពដែលខ្ញុំឃើញជូនប្រជាពលរដ្ឋនិងកូនចៅជំនាន់ក្រោយ ដែលមិនបានដឹងការពិតតាមរយៈការប្រជុំផ្សេងៗនិងចុះទៅតាមគ្រួសារនិងបុគ្គលផ្ទាល់" ។ លោក មី សារឿន ជាជំទប់ទី១ ឃុំស្មុំងឆាយ ខេត្តកោះកុងបានប្រាប់ឲ្យដឹងថា "ខ្ញុំនឹងធ្វើការប្រជុំរួមតាមភូមិ ចែកចាយឯកសារ និងផ្សព្វផ្សាយតាមការចាក់ ស៊ីឌី ហើយប្រសិនណាជាអង្គការមានចែកឯកសារចែកដល់គ្រប់ភូមិគ្រប់គ្រួសារទៀតរឹតតែពិសេស" ។

ដើម្បីសម្រួលដល់ការផ្សព្វផ្សាយរបស់មេឃុំ លោក រាជ សម្បត្តិ អ្នកនាំពាក្យរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានជូនកូនសៀវភៅស្តីអំពី "ការណែនាំស្រាយបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម" ចំនួន៦០ក្បាលក្នុងមួយឃុំៗដោយសង្ឃឹមថាសៀវភៅនេះនឹងជួយដោះស្រាយចម្ងល់មួយចំនួនរបស់ប្រជាពលរដ្ឋតាមមូលដ្ឋាន ។

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថាមេឃុំដែលបានចូលរួមក្នុងដំណើរទស្សនកិច្ចនិងជួយពាំនាំនូវដំណឹងអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហមនិងទិដ្ឋភាពដែលគាត់បានឃើញនៅក្នុងដំណើរទស្សនកិច្ចទៅចែកជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានតាមវិធីសាស្ត្ររៀងៗខ្លួន ហើយរំពឹងថា ជនរងគ្រោះទាំងអស់នឹងទទួលព័ត៌មាននេះបានគ្រប់ៗគ្នាដើម្បីត្រៀមខ្លួនចូលរួមក្នុងដំណើរការកាត់សេចក្តីពេលអនាគតដ៏ខ្លីខាងមុខនេះ ។

**លី សុផល**

# តើចៅក្រម សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាទទួលខុសត្រូវកម្រិតណា?

កាលពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦ វេលាម៉ោង៣រសៀល ចៅក្រម សហចៅក្រមស៊ើបអង្កេតនិងសហព្រះរាជអាជ្ញា ទាំងខាងភាគីកម្ពុជា ទាំងខាងភាគីអន្តរជាតិ បានធ្វើសច្ចាប្រណិធានដើម្បីចូលទៅកាន់តំណែងរបស់ខ្លួននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ពិធីធ្វើសច្ចាប្រណិធានបានប្រារព្ធឡើងនៅព្រះវិហារព្រះកែវមរកតនៃព្រះបរមរាជវាំង ។ ពិធីនេះចូលរួមដោយ ចៅក្រម សហចៅក្រមស៊ើបអង្កេតសហព្រះរាជអាជ្ញា ខាងភាគីកម្ពុជាចំនួន១៧រូប និងខាងភាគីអន្តរជាតិចំនួន១០រូប ក្នុងនោះ ចៅក្រមមួយរូបនិងសហព្រះរាជអាជ្ញាបម្រុងមួយរូបអវត្តមាន ។

ដោយឡែកសម្រាប់ចៅក្រម សហចៅក្រមស៊ើបអង្កេតសហព្រះរាជអាជ្ញា ខាងភាគីកម្ពុជាទាំង១៧រូបដែលបានចូលស្បថស្បែរួចហើយនឹងទទួលខុសត្រូវធ្ងន់ធ្ងរបំផុតនៅក្នុងកិច្ចការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មានឃ្លាមួយដែលអានដោយ ចៅក្រម សហចៅក្រមស៊ើបអង្កេតសហព្រះរាជអាជ្ញាកម្ពុជា១៧រូបថា "បើខ្ញុំមិនបានប្រតិបត្តិតាមតួនាទីភារកិច្ច និងអំណាចដូចដែលបានសច្ចាខាងលើនេះ សូមអស់ទេព្រក្ស អារក្ខ អារក្សអ្នកតា យាយទេព ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រនិងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកដាក់ទោសដល់រូបខ្ញុំឲ្យវិនាសអន្តរាយទាំងជីវិតនិងទ្រព្យសម្បត្តិចុះ" ។

សូមអានពិធីទាំងនេះទាំងស្រុងដូចខាងក្រោម ៖

### និតិវិធីក្នុងការធ្វើសច្ចាប្រណិធាន

ការធ្វើសច្ចាប្រណិធានត្រូវដឹកនាំដោយព្រះសង្ឃដែលត្រូវធ្វើនៅក្នុងព្រះវិហារព្រះកែវមរកត ។ មុននឹងចាប់ផ្តើមធ្វើសច្ចាប្រណិធានអ្នកស្បថត្រូវអុជទៀន ធូបបូជាចំពោះវត្ថុស័ក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ ។ បន្ទាប់មកអាចារ្យចាប់ផ្តើមអានប្រារព្ធវាទ ខ្លាំងៗ ច្បាស់ៗ ឲ្យអ្នកស្បថស្តាប់រួចអានពាក្យសច្ចាប្រណិធានដើម្បីឲ្យអ្នកស្បថថាតាម ។



ពិធីសច្ចាប្រណិធានចូលកាន់មុខតំណែងរបស់ចៅក្រម សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត អន្តរជាតិ និងកម្ពុជា នៅក្នុងព្រះបរមរាជវាំង នារសៀលថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦

### ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រនិងវត្ថុស័ក្តិសិទ្ធិទាំងអស់នៅក្នុងលោកសូមយាងនិងអញ្ជើញមកធ្វើជាសាក្សីក្នុងពិធីសច្ចាប្រណិធាននេះ ដ្បិតក្នុងពេលនេះ មានចៅក្រម សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ចូលកាន់តំណែងក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

បើអ្នកណាមិនបានប្រតិបត្តិតាមពាក្យសច្ចាប្រណិធាន សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រនិងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកបំផ្លាញឲ្យវិនាសអន្តរាយជីវិត និងទ្រព្យសម្បត្តិ ។

ប៉ុន្តែបើអ្នកណាប្រតិបត្តិតាមពាក្យសច្ចាប្រណិធាននោះ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រនិងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកជួយឲ្យជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿង សមដូចសេចក្តីបំណងប៉ងប្រាថ្នាកុំបីអាក់ខានឡើយ ។

### ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមសច្ចាជាឱឡារិកថា ខ្ញុំនឹងប្រតិបត្តិតួនាទី ភារកិច្ច និងប្រើសិទ្ធិអំណាចរបស់ខ្ញុំក្នុងឋានៈជាចៅក្រម សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យប្រកបដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្តីទៀងត្រង់ស្មោះត្រង់ ដោយតម្លាភាព ដោយស្មារតីឯករាជ្យ ដោយគោរពរដ្ឋធម្មនុញ្ញនិងច្បាប់ទាំងឡាយ ព្រមទាំងគោរពនូវការសម្ងាត់នៃវិជ្ជាជីវៈរបស់ខ្ញុំ ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ ។

បើខ្ញុំមិនបានប្រតិបត្តិតាមតួនាទី ភារកិច្ចនិងអំណាចដូចដែលបានសច្ចាខាងលើទេនោះ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកដាក់ទោសដល់រូបខ្ញុំឲ្យវិនាសអន្តរាយទាំងជីវិតនិងទ្រព្យសម្បត្តិចុះ ។

ប៉ុន្តែបើខ្ញុំបានប្រតិបត្តិតាមតួនាទី ភារកិច្ចត្រឹមត្រូវដូចបានសច្ចាខាងលើនោះវិញ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកជួយឲ្យខ្ញុំមានសុភមង្គលវិបុលសុខគ្រប់ប្រការកុំបីអាក់ខានឡើយ ។

បន្ទាប់មក ព្រះសង្ឃសូត្រប្រោះព្រំដល់ចៅក្រមនិងព្រះរាជអាជ្ញា ដែលបានធ្វើសច្ចាប្រណិធានរួចហើយដើម្បីបញ្ចប់នីតិពិធី ។

**ម៉ាន់ថាន់ ពៅដារ៉ា**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀត ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុ FM១០២MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០-៧ៈ៤៥ល្ងាច ។
- វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។
- វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។
- វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលនឹងពង្រីកការផ្សព្វផ្សាយតាមវិទ្យុខេត្តសៀមរាបទៀត ។

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ឡាត់ សោភ័ណ និង ឡេង រតនៈ**

# ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានយុត្តាធិការផ្ដន្ទាទោសបានត្រឹមតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលគ្រប់គ្រងនៃរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ តែប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញាដែលទើបតែចាប់ផ្ដើមធ្វើការស៊ើបអង្កេតលើកដំបូងនឹងត្រូវបង្ហាញថាតើឧក្រិដ្ឋជនទាំងនេះអាចត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលមាននៅក្នុងដែនយុត្តាធិការរបស់តុលាការតាមរបៀបណា ។

ឧក្រិដ្ឋកម្មក្រោម ច្បាប់អន្តរជាតិដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការ គឺអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ និងឧក្រិដ្ឋកម្មទៅលើអ្នកទទួលបានការការពារជាអន្តរជាតិ ។ ឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិដែលស្ថិតក្នុងដែនយុត្តាធិការរបស់តុលាការមានដូចជា មនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនា ។

ការបង្ហាញឲ្យឃើញនូវឧក្រិដ្ឋកម្មទាំងនេះមិនមែនជាការងាយស្រួលនោះទេ ពីព្រោះឧក្រិដ្ឋជន ភាគច្រើនមិនបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនេះដោយខ្លួនឯងផ្ទាល់នោះឡើយ ។ ប៉ុន្តែផ្ទុយទៅវិញឧក្រិដ្ឋជនទាំងនេះដាក់បញ្ជាឲ្យអ្នកនៅក្រោមបង្គាប់របស់ខ្លួនប្រព្រឹត្តដូច្នោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានមធ្យោបាយផ្សេងៗដែលមេដឹកនាំខ្មែរក្រហមអាចនឹងត្រូវបានដាក់ឲ្យទទួលខុសត្រូវឧក្រិដ្ឋកម្មដែលកើតឡើងក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទទួលស្គាល់ទម្រង់ផ្សេងៗនៃការទទួលខុសត្រូវដោយផ្ទាល់និងប្រយោល ។ ការទទួលខុសត្រូវដោយប្រយោលក៏ត្រូវបានស្គាល់ផងដែរថាការទទួលខុសត្រូវថ្នាក់លើ ឬការទទួលខុសត្រូវលើការបញ្ជា ។

**ការទទួលខុសត្រូវដោយផ្ទាល់**

អយ្យការអាចចេញដីកាចោទប្រកាន់បុគ្គលដែលសង្ស័យពីការប្រព្រឹត្ត មានផែនការ ញុះញង់ បញ្ជា ឬជួយ និងជំរុញឲ្យមានការរៀបចំផែនការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងដែនយុត្តាធិការរបស់តុលាការដូចចែងក្នុងមាត្រា២៩ នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

មិនមែនមានតែជនទាំងឡាយដែលបានប្រព្រឹត្តដោយផ្ទាល់នូវឧក្រិដ្ឋកម្មនឹងត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះទេ ។ សូម្បីតែជនទាំងឡាយដែលមិនបានប្រព្រឹត្តដោយផ្ទាល់នូវឧក្រិដ្ឋកម្មក៏នឹងត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះដែរ ។ ជាឧទាហរណ៍ ប្រសិនបើចុងចោទភាគីខ្មែរក្រហម បញ្ជា ជួយគាំទ្រ ឬជំរុញអ្នកណាម្នាក់ផ្សេងទៀតឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ចុងចោទនោះនឹងត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្ម ព្រមទាំងមិនអាចគេចផុតពីការទទួលខុសត្រូវនេះបានឡើយ ។ ករណីនេះ មានលក្ខណៈស្រដៀងគ្នានឹងច្បាប់ជាតិ ។

ប្រសិនបើជនណាម្នាក់បញ្ជាអ្នកស៊ីឈ្នួលសម្លាប់មនុស្សឲ្យមកសម្លាប់អ្នកណាម្នាក់ ជនដែលបញ្ជានោះនឹងនៅតែទទួលខុសត្រូវចំពោះអំពើមនុស្សឃាតនេះជាមួយនឹងអ្នកស៊ីឈ្នួលសម្លាប់មនុស្សនោះដែរ ពីព្រោះជននោះបានជួយ នៅក្នុងហេតុការណ៍ឧក្រិដ្ឋកម្មនិងមានចេតនាឲ្យមានការប្រព្រឹត្តនូវឧក្រិដ្ឋកម្មនោះឡើង ។

គ្រប់បទល្មើសព្រហ្មទណ្ឌមានធាតុផ្សំពីរសំខាន់ គឺធាតុសម្ភារៈនិងចិត្តសាស្ត្រ (សត្យានុម័តនិងអត្តនោម័ត) ។ “ធាតុផ្សំសម្ភារៈ” គឺជាអំពើដែលត្រូវបានហាមប្រាម ចំណែក “ធាតុផ្សំចិត្តសាស្ត្រ” គឺសតិបញ្ញារបស់ចុងចោទ (ដូចជាចេតនា ចំណេះដឹងការធ្វេសប្រហែស) ។

បើទោះបីជាមានអំពើព្រៃផ្សៃផ្សេងៗគ្នាប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ មានប្រភពព័ត៌មានជាច្រើនបង្ហាញថាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមិនបានប្រព្រឹត្ត

ឧក្រិដ្ឋកម្មដោយផ្ទាល់នោះទេ ។ ប្រការនេះធ្វើឲ្យការដាក់ឲ្យទទួលខុសត្រូវចំពោះការចូលរួមប្រព្រឹត្តមានសារសំខាន់យ៉ាងខ្លាំងសម្រាប់ដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

មាត្រា២៩នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏ចែងផងដែរថា "តួនាទីឬឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ឬជួយបន្ធូរបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ" ។ មាត្រានេះមានន័យថាឧក្រិដ្ឋជនមិនអាចប្រើប្រាស់សិទ្ធិសុំការលើកលែងទោសដែលថាខ្លួនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនម្នាក់ផ្សេងទៀត ឬធ្វើតាមការបញ្ជារបស់ថ្នាក់លើដើម្បីបញ្ចៀសឲ្យផុតពីការទទួលខុសត្រូវនូវអំពើទាំងឡាយរបស់ខ្លួនឡើយ ។

ទម្រង់នៃការទទួលខុសត្រូវដែលមានលក្ខណៈស្មុគស្មាញជាងនេះ គឺ "ការទទួលខុសត្រូវរួម" ។

## ការទទួលខុសត្រូវដោយផ្ទាល់តាមរយៈការទទួលខុសត្រូវរួមគ្នា

គោលការណ៍នៃការទទួលខុសត្រូវរួមគ្នាក៏ជាទម្រង់នៃការបង្កើតការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ។ ការទទួលខុសត្រូវរួមគ្នា គឺជាទម្រង់មួយនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាបុគ្គលហើយអ្នកចូលរួមទាំងអស់នៅក្នុងការទទួលខុសត្រូវរួមនេះទទួលទោសកំហុសនូវឧក្រិដ្ឋកម្មដោយស្មើភាពគ្នា ដោយមិនគិតពីតួនាទីរបស់ខ្លួននៅក្នុងគណៈកម្មការឧក្រិដ្ឋកម្មឡើយ ។ ការទទួលខុសត្រូវរួមគ្នាត្រូវបានយកមកអនុវត្តក្នុងសាលាក្តីនូរិមប៊ឺកក្រោយសម័យសង្គ្រាមលោកលើកទីពីរនិងត្រូវបានបង្កើតនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ។ ស្ថិតនៅក្រោមការទទួលខុសត្រូវនេះ បុគ្គលម្នាក់អាចនឹងត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តឡើងជាផ្នែកមួយនៃផែនការរួមដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសក្រោយដែនសមត្ថកិច្ចតុលាការ ប្រសិនបើចុងចោទចូលរួមជាមួយនឹងអ្នកផ្សេងៗទៀតក្នុងផែនការរួមនេះ ។

ទម្រង់នៃការទទួលខុសត្រូវមានបីយ៉ាងតែងត្រួតលើគ្នា ÷

១) ការទទួលខុសត្រូវរួមជាមូលដ្ឋានអនុវត្តចំពោះសហចារីដែលមានចេតនារួមគ្នាប្រព្រឹត្តឧក្រិដ្ឋកម្មនិងចូលរួមក្នុងផែនការមួយដោយចេតនា ព្រមទាំងមានចេតនាចង់បាននូវលទ្ធផលជាក់លាក់មួយ ។

*(ជាឧទាហរណ៍ ប្រសិនបើចុងចោទភាគីជាន់ខ្ពស់ខ្មែរក្រហមបានចូលរួមក្នុងផែនការសម្លាប់អ្នកស្រុកអ្នកភូមិអ្នកចូលរួមរៀបចំផែនការនេះទាំងអស់នឹងទទួលខុសត្រូវចំពោះការសម្លាប់ទៅលើអ្នកស្រុកអ្នកភូមិ ។)*

២) ការទទួលខុសត្រូវរួមជាប្រព័ន្ធអនុវត្តក្នុងស្ថានភាពដែលមានការគាបសង្កត់យ៉ាងធ្ងន់ធ្ងរនិងការធ្វើទុកបុកម្នេញ ។ ឧទាហរណ៍ ស្ថានភាពនៅជំរំប្រមូលផ្តុំជាដើម ។ ចុងចោទដឹងថាមានឧក្រិដ្ឋកម្មកើតឡើងនិងចូលរួមឧក្រិដ្ឋកម្ម ព្រមទាំងមានចេតនាជំរុញគណៈកម្មការឧក្រិដ្ឋកម្មបន្ថែមតាមរយៈសកម្មភាពរបស់ខ្លួន ។

*(ជាឧទាហរណ៍ កម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ដែលទទួលខុសត្រូវចំពោះការបង្កើត ស-២១ ទទួលខុសត្រូវស្ថិតក្រោមការទទួលខុសត្រូវរួមជាប្រព័ន្ធនេះ ។)*

៣) ទម្រង់ទី៣នៃការទទួលខុសត្រូវរួមពង្រីកបន្ថែមទៅលើទ្រឹស្តីការទទួលខុសត្រូវរួម ដោយដាក់ចុងចោទឲ្យទទួលខុសត្រូវនូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្រៅពីផែនការរួម ប្រសិនបើអំពើនេះកើតចេញពីផលវិបាកនៃការប្រើប្រែងប្រព្រឹត្តបទឧក្រិដ្ឋតាមធម្មជាតិឬដែលប្រមើលឃើញនៅថ្ងៃមុខ ។ ជនដែលត្រូវបានដាក់ឲ្យទទួលខុសត្រូវតែប្រថុយប្រថានក្នុងការបង្កឲ្យមានបទល្មើសឧក្រិដ្ឋកើតឡើង ។

*(ជាឧទាហរណ៍ ប្រសិនបើរកឃើញថាមានផែនការរួមមួយជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ចុងចោទត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះការស្លាប់ដែលបណ្តាលមកពីការជម្លៀសនេះ ទោះបីជាចុងចោទអះអាងថាខ្លួនគ្មានចេតនាសម្លាប់អ្នកណាម្នាក់យ៉ាងណាក៏ដោយ ។ ផលវិបាកដែលអាចគិតទុកជាមុននេះគឺអ្នកជំងឺនិងអ្នករបួសដែលត្រូវបង្ខំឲ្យជម្លៀសចេញពីមន្ទីរពេទ្យនឹងស្លាប់ដោយសារតែការជម្លៀសនេះ ។)*

ជាការគួរឲ្យចាប់អារម្មណ៍ក្នុងការស្វែងយល់ថាតើការទទួលខុសត្រូវរួមគ្នានឹងយកមកអនុវត្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយរបៀបណានោះ គឺអាចទាយទុកមុនថាការទទួលខុសត្រូវរួមគ្នានឹងជាមធ្យោបាយដែលការកាត់សេចក្តី

នឹងអាចដាក់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតឲ្យទទួលខុសត្រូវចំពោះផែនការនិងនយោបាយទ្រង់ទ្រាយធំដែលខ្មែរក្រហមបានអនុវត្តដើម្បីបំផ្លិចបំផ្លាញប្រទេសកម្ពុជា ។

### ការទទួលខុសត្រូវលើការបញ្ជា

ច្បាប់អន្តរជាតិក៏ទទួលស្គាល់ផងដែរនូវការទទួលខុសត្រូវលើការបញ្ជា ដែលជាទម្រង់នៃការទទួលខុសត្រូវដាក់លាក់ប្រាកដមួយ ។ ចុងចោទភាគីខ្មែរក្រហមក៏នឹងអាចត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋតាមរយៈទម្រង់នៃការទទួលខុសត្រូវលើការបញ្ជានេះដែលដាក់មន្ត្រីដែលជាអ្នកបញ្ជាឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួន ប្រសិនបើមន្ត្រីដែលជាអ្នកបញ្ជាមិនបានបង្ការឧក្រិដ្ឋកម្មឬដាក់ទោសអ្នកនៅក្រោមបង្គាប់ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម ។ ទម្រង់នៃការទទួលខុសត្រូវលើការបញ្ជានេះដាក់យ៉ាងមានប្រសិទ្ធភាពទៅលើបុគ្គលទាំងឡាយឲ្យទទួលខុសត្រូវចំពោះបទល្មើសអកម្មឬការបំភ្លេចចោលនូវសកម្មភាពឧក្រិដ្ឋកម្មរបស់ខ្លួន (ផ្ទុយពីសកម្មភាពដោយផ្ទាល់) ។

មាត្រា២៩ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា មន្ត្រីដែលជាអ្នកបញ្ជាអាចទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋកម្មទាំងឡាយរបស់អ្នកនៅក្រោមបង្គាប់របស់ខ្លួនទៅបានប្រសិនបើ ÷

“ថ្នាក់លើមានបញ្ជានិងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាចនិងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹងនិងមានហេតុផលដឹងថា អ្នកនៅក្រោមបង្គាប់ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់និងសមស្របដើម្បីបង្ការអំពើបែបនេះឬដាក់ទណ្ឌកម្មចំពោះអ្នកប្រព្រឹត្តបទឧក្រិដ្ឋនេះ ។”

ប្រការនេះស្រដៀងគ្នាទៅនឹងរឿងក្តីសេឡេប៊ីស៊ី ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានដាក់ចេញនូវលក្ខខណ្ឌចំនួនបីសម្រាប់ការទទួលខុសត្រូវលើការបញ្ជា ។ ករណីយុត្តិសាស្ត្របន្ទាប់ៗទៀតក៏គាំទ្រចំពោះការសម្រេចចិត្តបែបនេះដែរ ។

ដើម្បីបំពេញបន្ថែមមាត្រា២៩ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធាតុផ្សំបីត្រូវបំពេញបន្ថែមមានដូចខាងក្រោម ÷

- ◆ ថ្នាក់លើនិងអ្នកនៅក្រោមបង្គាប់ពិតជាមានទំនាក់ទំនងគ្នា ។
- ◆ ថ្នាក់លើត្រូវតែដឹងឬមានហេតុផលត្រូវដឹងថាអំពើឧក្រិដ្ឋកម្មនឹងទំនងជាឬត្រូវបានប្រព្រឹត្តមុនរួចទៅហើយ ។
- ◆ ថ្នាក់លើពិតជាបានចាត់វិធានការសមហេតុផលដើម្បីបង្ការអំពើឧក្រិដ្ឋកម្ម ឬដាក់ទោសអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មនេះ ។

ដើម្បីបង្ហាញអំពីទំនាក់ទំនងរវាងថ្នាក់លើនិងអ្នកនៅក្រោមបង្គាប់ ការកាត់សេចក្តីត្រូវតែបង្ហាញឲ្យថាមន្ត្រីដែលជាអ្នកបញ្ជាបានគ្រប់គ្រងលើអ្នកនៅក្រោមបង្គាប់ ហើយដែលការកាត់សេចក្តីនេះនឹងអាចធ្វើឲ្យមន្ត្រីដែលជាអ្នកបញ្ជាបង្ការ បញ្ឈប់ ឬដាក់ទោសនូវការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយ ។ ការកាត់សេចក្តីបែបនេះនឹងត្រូវបង្ហាញឲ្យថាមន្ត្រីដែលជាអ្នកបញ្ជាទទួលបាននូវព័ត៌មានច្បាស់លាស់ទាក់ទិនអំពើឧក្រិដ្ឋកម្ម ឬព័ត៌មានផ្សេងៗទៀតដែលប្រាប់ឲ្យមន្ត្រីដែលជាអ្នកបញ្ជាដឹងជាមុននូវភាពអាចកើតឡើងនូវឧក្រិដ្ឋកម្មនិងធ្វើឲ្យមន្ត្រីដែលជាអ្នកបញ្ជាមានការចាប់អារម្មណ៍ ។



អ្នកទោសចងកសម្លាប់ខ្លួននៅក្នុងគុកធំ ខេត្តសៀមរាប

ការទទួលខុសត្រូវលើការបញ្ជាកើតចេញពីគំនិតដែលថាអ្នកបញ្ជាមានការទទួលខុសត្រូវលើការបញ្ជាដល់ទាហានរបស់ខ្លួនដើម្បីបញ្ជាក់ថាទាហានរបស់ខ្លួនប្រព្រឹត្តឡើងប្រកបដោយការទទួល

ខុសត្រូវ ។ ប្រសិនបើអ្នកបញ្ជាមិនបានប្រព្រឹត្តដូច្នោះទេ អ្នកបញ្ជាជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយអ្នកនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។ គោលការណ៍ស្តីពីការទទួលខុសត្រូវលើការបញ្ជា គឺជាទម្រង់ស្តីពីការទទួលខុសត្រូវជួសគ្នាដែលពង្រីកវិសាលភាពនៃការទទួលខុសត្រូវលើការបញ្ជាក្នុងការគ្រប់គ្រងស្ថានភាពដែលមន្ត្រីដែលជាអ្នកបញ្ជាអនុវត្តនូវតួនាទីរបស់ខ្លួនដែលមិនអាចប្រឆាំង ហើយមិនបានអនុវត្តនូវករណីយកិច្ចរបស់ខ្លួនក្នុងនាមជាមេបញ្ជាការ ។ គោលការណ៍នេះទំនងជាមានសារសំខាន់នៅក្នុងដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញ



ក្នុងតុលាការកម្ពុជា ព្រោះគោលការណ៍នេះមាននៅក្នុងតុលាការអន្តរជាតិជាច្រើន ។

## ការលំបាកបន្ថែមទាក់ទិននឹងការទទួលខុសត្រូវរួមគ្នានិងការទទួលខុសត្រូវលើការបញ្ជា

បើទោះបីជាគោលការណ៍ស្តីពីការទទួលខុសត្រូវលើការបញ្ជាជាផ្នែកសំខាន់មួយនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហើយឥឡូវនេះការទទួលខុសត្រូវរួមជាទម្រង់នៃការទទួលខុសត្រូវលើកការបញ្ជាដែលទើបតែបង្កើតនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិយ៉ាងណាក៏ដោយគោលការណ៍បន្ថែមស្តីពីគ្មានបទល្មើសបើគ្មានច្បាប់ចែង មានន័យថាការកាត់សេចក្តីនេះនឹងមានការលំបាកក្នុងការដាក់មេដឹកនាំខ្មែរក្រហមឲ្យទទួលខុសត្រូវ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងត្រូវតែបង្ហាញឲ្យឃើញនូវស្តីពីគោលការណ៍ទាំងពីរនេះក្នុងរយៈពេលដែលឧក្រិដ្ឋកម្មនេះត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនោះ ។ តុលាការនឹងត្រូវពិនិត្យមើលនូវច្បាប់អន្តរជាតិក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដើម្បីធ្វើសេចក្តីសម្រេចថាតើគោលការណ៍ទាំងពីរខាងលើនេះជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងរយៈពេលនោះដែរឬទេ ។

ច្បាប់ទំនៀមទម្លាប់អន្តរជាតិសំដៅទៅលើទំនៀមទម្លាប់ដែលត្រូវបានអនុវត្តជាទូទៅដោយភាគីរដ្ឋ ដែលទំនៀមទម្លាប់ទាំងនេះក្លាយជាកាតព្វកិច្ចច្បាប់ ។ មានធាតុផ្សំពីរចាំបាច់គឺ ១) ត្រូវតែមានការអនុវត្តច្បាប់ដូចៗគ្នាពីរដ្ឋជាភាគី និង២) ភាគីទាំងអស់ត្រូវតែអនុវត្តដោយយោងទៅតាមទំនៀមទម្លាប់ដែលក្នុងន័យកាតព្វកិច្ចច្បាប់ ។

បន្ទុកសម្រាប់អយ្យការក្នុងការអនុវត្តច្បាប់អន្តរជាតិជាលក្ខណៈប្រតិសកម្មនឹងធ្វើឲ្យការចោទប្រកាន់របស់ខ្លួនកាន់តែមានលក្ខណៈស្មុគស្មាញដោយសារករណីយុត្តិសាស្ត្រ ដែលបញ្ជាក់អំពីទ្រឹស្តីទាំងនេះទើបតែបានសម្រេចឡើងក្នុងរយៈពេល ១០ឆ្នាំចុងក្រោយប៉ុណ្ណោះ ជាពិសេសមាននៅអតីតរ៉ាន់ដា និងយូហ្គោស្លាវី ។ ប្រសិនបើតុលាការវិនិច្ឆ័យថាការទទួលខុសត្រូវលើការបញ្ជាមិនបានអនុវត្តនៅក្នុងស្ថានភាពមានជម្លោះផ្ទៃក្នុងដូចពេលបច្ចុប្បន្ននោះ ឬតុលាការសម្រេចថាការទទួលខុសត្រូវរួមគ្នាមិនបានបង្កើតជាទ្រឹស្តីគិតមកត្រឹមចន្លោះឆ្នាំ១៩៧៥និងឆ្នាំ១៩៧៩ នោះការកាត់សេចក្តីនេះទំនងជាប្រឈមមុខនឹងបញ្ហាច្រើនថែមទៀត ។ ទោះបីជាយ៉ាងណាក៏ដោយ ការទទួលខុសត្រូវដោយផ្ទាល់ និងលើការបញ្ជាជាញឹកញាប់ច្របូកច្របល់គ្នាខ្លះ ហើយការកាត់សេចក្តីនេះទំនងជាចោទប្រកាន់ចុងចោទដោយប្រើប្រាស់ទម្រង់នៃការទទួលខុសត្រូវទាំងពីរខាងលើនេះ ។ សង្ឃឹមទុកជាមុនចុះ ប្រការនេះនឹងធានាថាខ្មែរក្រហមអាចនឹងទទួលខុសត្រូវចំពោះអំពើព្រៃផ្សៃដែលបានកើតឡើង ប្រសិនបើទ្រឹស្តីស្តីពីការទទួលខុសត្រូវលើការបញ្ជានិងការទទួលខុសត្រូវរួមគ្នាត្រូវបានកម្រិតក្នុងវង្វង់នៃការអនុវត្តធាក់ថយក្រោយនៃច្បាប់ ។ **ស្វ ប៊ុនស៊ូ**

# អំពើប្រល័យពូជសាសន៍ដែលអាក្រក់បំផុត
# ចំណាប់អារម្មណ៍របស់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេហ្វ អេ មូសូមេលី
# ចំពោះអ្នកចូលរួមដំណើរទស្សនកិច្ចមកកាន់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា
# ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៦

សួស្តី ខ្ញុំមានកិត្តិយសសូមស្វាគមន៍អស់លោក លោកស្រីទាំងអស់គ្នាដែលបានមកកាន់គេហដ្ឋានរបស់ខ្ញុំនៅថ្ងៃនេះ ។ កាលពីប៉ុន្មានខែមុននេះ ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យក៏បានមកអង្គុយនៅកន្លែងដែលអស់លោក លោកស្រីកំពុងអង្គុយនេះដែរ ហើយខ្ញុំបានប្រាប់ពួកគាត់ពីរឿងដែលឧក្រិដ្ឋកម្មធំជាងគេបំផុតមួយនេះប្រចាំសតវត្សរ៍ទី២០ មិនទាន់បានទទួលការជំនុំជម្រះសេចក្តីនៅឡើយអស់រយៈកាល៣០ឆ្នាំមកហើយ ។ ដូចយើងបានដឹងរួចហើយក្នុងរយៈកាលចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពោលគឺ មិនដល់រយៈពេល៤ឆ្នាំផង របបខ្មែរក្រហមបានធ្វើទារុណកម្ម បង្អត់អាហារ និងសម្លាប់រង្គាលជនរួមជាតិកម្ពុជារបស់គេអស់ប្រមាណជាង២លាននាក់ ។ គ្មាននរណាម្នាក់មានសុវត្ថិភាពទេ នៅពេលនោះមិនថា ចាម វៀតណាម ព្រះសង្ឃ អ្នករស់នៅទីក្រុង អ្នកមានសញ្ញាប័ត្រ ឬអ្នកដែលពាក់វ៉ែនតា ។ អ្នកទាំងនេះ និងមនុស្សដទៃជាច្រើនទៀត រួមជាមួយនឹងគ្រួសាររបស់គេផង ត្រូវបានសម្លាប់យ៉ាងរង្គាលនៅក្នុងអំពើប្រល័យពូជសាសន៍មួយដែលអាក្រក់បំផុត និងមិនដែលមានពីមុនមក ។


ចូសេហ្វ អេ មូសូមេលី
ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក

ទោះជាយ៉ាងណាក៏ដោយ អ្នកខ្លះបាននិយាយថា អំពើឧក្រិដ្ឋទាំងនោះកើតឡើងយូរមកហើយ ហើយយើងគួរតែឈប់រំឭកអំពីអតីតកាលនេះ ។ គេនិយាយថា យើងគួរក្រឡេកមើលទៅអនាគតនិងមិនគួរចំណាយថវិកាសន្ធឹកសន្ធាប់បែបនេះទៅលើសាលាជំនុំជម្រះក្តីនេះឡើយ ហើយគេនិយាយទៀតថា ថវិកានេះ គួរតែយកទៅប្រើប្រាស់ដើម្បីទិញស្បៀងអាហារ ឬផ្តល់ការថែទាំសុខភាពដល់អ្នកជំងឺវិញល្អជាង ។ ជាការពិតណាស់ អ្នកក្រគួរតែទទួលបានស្បៀងអាហារ ហើយអ្នកឈឺគួរតែទទួលបានការថែទាំសុខភាព ។ តើប៉ុណ្ណឹងគ្រប់គ្រាន់ឬទេ? តើយើងត្រូវការតែប៉ុណ្ណឹងទេឬ? តើរឿងសំខាន់មានតែត្រឹមការស្រេកឃ្លានស្បៀងអាហារទេឬ?

ឃ្លាមួយក្នុងព្រះគម្ពីរសាសនាគ្រីស្តបាននិយាយថា : «មនុស្សមិនមែនរស់ដោយសារតែនំបុ័ងមួយមុខនោះទេ» ។ យើងទាំងអស់គ្នាអាចយល់បានអំពីអត្ថន័យរបស់ឃ្លានេះ ពោលគឺមានន័យថា យើងមិនមែនជាសត្វមួយប្រភេទដែលមានការស្រេកឃ្លានអាហារដូចសត្វធាតុនោះទេ ។ អាហារតែមួយមុខមិនអាចបំពេញការស្រេកឃ្លានរបស់យើងបានទេ ។ មនុស្សគឺជាសត្វលោកដែលមានវិញ្ញាណនិងសីលធម៌ ។ តើមានអ្នកដែលនិយាយថា យើងមិនគួរមានវត្តអារាមទេ? តើមានអ្នកដែលនិយាយថា «យើងគួរតែរុះរើវិហារសាសនាគ្រីស្ត និងវិហារសាសនាអ៊ីស្លាមចេញដើម្បីយកថវិការទាំងនោះទៅផ្គត់ផ្គង់ស្បៀងអាហារដល់អ្នកដែលកំពុងតែស្រេកឃ្លានទៅវិញ»ដែរឬទេ? ភាគច្រើននៃពួកយើងទាំងអស់គ្នាដឹងថា យើងមានការស្រេកឃ្លានផ្នែកផ្លូវចិត្ត ដែលគេគួរតែបំពេញ ហើយយើងដឹងដែរថា វត្តអារាម និងព្រះវិហារគ្រីស្តសាសនាជួយបំពេញការស្រេកឃ្លាននោះ ។

មនុស្សស្រេកឃ្លានអ្វីផ្សេងទៀត យ៉ាងហោចណាស់ក៏សំខាន់ស្មើនឹងអាហារដែរ ។ យើងស្រេកឃ្លានយុត្តិធម៌ ។ យើង

មិនទទួលបានយុត្តិធម៌យូរមកហើយ ។ អំពើប្រល័យពូជសាសន៍នៅកម្ពុជាជាករណីតែមួយគត់ដែលមិនទាន់ឃើញមានការផ្តន្ទាទោសជនដៃដល់ ។ ចាប់តាំងពីការកាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ។ ប៉ុន្តែ យុត្តិធម៌របៀបនេះមិនបានកើតមានទេនៅក្នុងប្រទេសកម្ពុជា ។

អ្នកខ្លះលើកឡើងថា ការចំណាយថវិកាដែលកំពុងខ្សត់ទៅលើបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងកាលពី៣០ឆ្នាំមុន គឺជារឿងដែលគួរឲ្យអស់សំណើច ប៉ុន្តែ ខ្ញុំសង្ឃឹមថាប្រជាជនខ្មែរភាគច្រើននឹងមិនយល់ស្របតាមការអះអាងនេះទេ ។ នៅកម្ពុជាអ្នកទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ជាទូទៅ កំពុងរស់នៅដោយមានសុវត្ថិភាពនិងសេរីភាពយ៉ាងសម្បូរសប្បាយនៅក្នុងចំណោមមនុស្សដែលពួកគេធ្វើបាប ។ មិនមានគ្រួសារណាមួយនៅកម្ពុជាដែលមិនរងការប៉ះពាល់ដោយសារអំពើប្រល័យពូជសាសន៍ទេ ។ របបខ្មែរ-ក្រហមបានប្រកាសថា ខ្លួននឹងនាំប្រទេសកម្ពុជាទៅកាន់ "ឆ្នាំសូន្យ" ហើយរបបនេះពិតជាបានរក្សាពាក្យសន្យានោះមែន ។ សាមសិបឆ្នាំក្រោយមកប្រទេសកម្ពុជានៅតែមានការបាត់បង់ និងបែកបាក់ដដែល ។


មេឃុំជួបសំណេះសំណាលជាមួយ
ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកនៅនិវេសនដ្ឋានរបស់លោក

ការបែកបាក់របស់ប្រទេសកម្ពុជាមិនមែនត្រឹមតែផ្នែកនយោបាយ និងសេដ្ឋកិច្ចតែប៉ុណ្ណោះទេ ប៉ុន្តែបានប៉ះពាល់ដល់ទឹកចិត្ត និងស្មារតីផងដែរ ។ គុណវិបត្តិនៃប្រទេសកម្ពុជានៅក្នុងសម័យនេះ រាប់តាំងពីការជួយជួរមនុស្សរហូតដល់ការជួញដូរថ្នាំញៀន ពីការឆក់ប្លន់ធនធានធម្មជាតិនិងសម្បត្តិវប្បធម៌រហូតដល់អំពើពុករលួយដែលរីករាលដាលនៅគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋាភិបាល គុណវិបត្តិទាំងនេះកាន់តែធ្ងន់ធ្ងរទៅៗ ដោយសារតែការខកខានរបស់យើងក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកជំនុំជម្រះទោស ។ វប្បធម៌និទណ្ឌភាពដែលយើងឃើញមាននៅទូទាំងប្រទេសកម្ពុជាសព្វថ្ងៃនេះ មានប្រភពពីជំនឿរបស់ប្រជាជនកម្ពុជាដែលជឿថា វាមិនដែលមានបទឧក្រិដ្ឋណាធំធេងដែលត្រូវតែផ្តន្ទាទោសនោះទេ និងថាអ្វីៗដែលប្រជាពលរដ្ឋកម្ពុជាធ្វើគឺអាចទទួលយកបានទាំងអស់ ព្រោះថា ទង្វើទាំងនោះ បើទោះបីជាអាក្រក់យ៉ាងណាក៏មិនដល់ថ្នាក់អាក្រក់ជាងអ្វីដែលរបបខ្មែរក្រហមបានប្រព្រឹត្តឡើយ ហើយអ្នកប្រព្រឹត្តទាំងនោះនៅតែរួចខ្លួនពីសំណាញ់ច្បាប់ ។

វានឹងនៅតែមានឧបសគ្គធំៗទៅលើដំណើរជឿនលឿនទៅមុខ និងកំណែទម្រង់របស់ប្រទេសកម្ពុជា លុះត្រាតែមានការផ្តល់យុត្តិធម៌នៅក្នុងកម្រិតណាមួយ ។ ប៉ុន្តែឧក្រិដ្ឋជនទាំងនោះកាន់តែមានវ័យចាស់ជរាណាស់ហើយ ហើយមួយទសវត្សរ៍ទៀត អ្នកទាំងនេះទំនងជាស្លាប់យ៉ាងស្ងប់ស្ងាត់និងដោយសុខសាន្ត ។ តាម៉ុក ទើបតែស្លាប់សប្តាហ៍មុននេះ ។ ការស្លាប់នេះ ដែលបានឆក់យករួចហើយនូវជីវិតនិងសុភមង្គលពីប្រជាជនខ្មែរជាច្រើន នៅពេលនេះទៀតបានឆក់យកពីពួកគេ ម្តងទៀតនូវឱកាសទទួលបានយុត្តិធម៌ ។ តើការស្រេកឃ្លានយុត្តិធម៌របស់យើងអាចបំពេញយ៉ាងដូចម្តេច បើតុលាការមិនបន្តការងាររបស់ខ្លួន? បើតុលាការនៅតែពន្យារពេលតទៅទៀត? បើជនដៃដល់នៅតែអាចរស់នៅរហូតដល់ចាស់ស្លាប់ដោយសុខសាន្ត ដោយមិនបានទទួលស្គាល់ចំពោះអំពើឧក្រិដ្ឋរបស់ខ្លួន ឬទទួលខុសត្រូវចំពោះអំពើដ៏គួរឲ្យខ្លាចដែលពួកគេប្រព្រឹត្តមកលើប្រជាជនកម្ពុជាដែលជាជនរួមជាតិរបស់ពួកគេ?

អ្នកទាំងឡាយដែលបានស្លាប់ និងអ្នកទាំងឡាយដែលបានរងនូវការឈឺចាប់ ៖ ការស្លាប់ និងការឈឺចាប់របស់ពួកគេត្រូវការយុត្តិធម៌និងភាពស្ងប់ស្ងាត់ ។ ជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍សមនឹងទទួលបានយុត្តិធម៌ ហើយជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍ទាមទារយុត្តិធម៌ ។ ប្រជាជនកម្ពុជាត្រូវការបំពេញសេចក្តីស្រេកឃ្លានយុត្តិធម៌របស់ពួកគេ ។

# ការធានាភាពមិនលម្អៀងនិងឯករាជ្យភាពនៃក្រុមចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## អារម្ភកថា

អត្ថបទនេះផ្តោតជាសំខាន់ទៅលើបញ្ហាពិបាកដោះស្រាយមួយ ថាតើត្រូវធានាភាពមិនលម្អៀងនិងឯករាជ្យភាពនៃក្រុមចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយរបៀបណា ។ អ្នកនិពន្ធលើកយកនូវបញ្ហាមួយចំនួនដែលអ្នកនិពន្ធប្រមើលឃើញថាបញ្ហាទាំងនេះអាចកាត់បន្ថយឬរារាំងដល់ប្រសិទ្ធភាពនៃភាពមិនលម្អៀងនិងឯករាជ្យភាពនៃក្រុមចៅក្រមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អ្នកនិពន្ធផ្តល់យោបល់ដែលអាចសម្រេចបាននិងមានលក្ខណៈពិតប្រាកដសម្រាប់ដោះស្រាយស្ថានភាពនេះតាមកម្រិតមួយដែលអាចធ្វើទៅបាន ។

### ១) សេចក្តីផ្តើម

មូលដ្ឋាននៃការជំនុំជម្រះក្តីដោយយុត្តិធម៌ គឺតម្រូវឲ្យចុងចោទត្រូវកាត់សេចក្តីដោយចៅក្រមអព្យាក្រឹតនិងវិនិច្ឆ័យទោសដោយអនុលោមទៅតាមភស្តុតាងនិងច្បាប់ ។ ភាពមិនលម្អៀងនិងឯករាជ្យភាពនៃក្រុមចៅក្រមជាធាតុផ្សំដ៏សំខាន់ក្នុងការធានាសិទ្ធិមនុស្សដោយបង្កើតនូវមួយផ្នែកនៃគោលការណ៍ទូទៅស្តីពីច្បាប់អន្តរជាតិ ។ ភាពមិនលម្អៀងនិងឯករាជ្យភាពជាធាតុផ្សំពីរដាច់ដោយឡែកពីគ្នា ក៏ប៉ុន្តែមានទំនាក់ទំនងគ្នាទៅវិញទៅមក ។ ឯករាជ្យភាពគឺជាសមត្ថភាពរបស់ចៅក្រមក្នុងការសម្រេចកំណត់បញ្ហាដោយមិនទទួលឥទ្ធិពលពីអំណាចនីតិប្រតិបត្តិ នីតិបញ្ញត្តិ គណៈបក្សនយោបាយ ឬភាគីណាម្នាក់ដែលមានចំណាប់អារម្មណ៍នឹងនីតិវិធី ឬលទ្ធផលនោះឡើយ ។ ប្រការនេះមិនបានរារាំងដល់ការទទួលខុសត្រូវរបស់តុលាការឡើយ បើទោះបីជាការផ្សះផ្សារភាគីជម្លោះទាំងពីរ ជាកិច្ចការដ៏លំបាកក្នុងការធ្វើឲ្យមានតម្លាភាពយ៉ាងណាក៏ដោយ ។ ចំណែកឯភាពមិនលម្អៀងវិញតម្រូវឲ្យចៅក្រមមិនលម្អៀងក្នុងការវិនិច្ឆ័យរឿងក្តី ពីព្រោះភាពមិនលម្អៀងគឺជាធាតុសំខាន់សម្រាប់ជាសញ្ញាណនៃភាពត្រឹមត្រូវ ។ ភាពមិនលម្អៀងមានធាតុផ្សំសំខាន់ពីរ អត្តនោម័ត (ការលាក់កំបាំងភាពលម្អៀងរបស់ចៅក្រម) និងសត្យានុម័ត (ការលាក់កំបាំងអាការៈក្រៅឬទំនាក់ទំនងជារចនាសម្ព័ន្ធ ជាឧទាហរណ៍ សមាសភាពឬអំណាចដែលលើកឡើងនូវបញ្ហាពាក់ព័ន្ធនឹងភាពមិនលម្អៀង) ។ ភាពមិនលម្អៀងជាបុរេលក្ខខណ្ឌសម្រាប់ឯករាជ្យភាពនៃក្រុមចៅក្រម ។ ចៅក្រមអាចធ្វើការវិនិច្ឆ័យទោសដោយមិនលម្អៀងទៅបាន លុះត្រាណាប្រព័ន្ធតុលាការមានភាពឯករាជ្យ ពីព្រោះច្បាប់ចែងថាចៅក្រមមិនត្រូវមានអារម្មណ៍ភ័យខ្លាចនឹងការសងសឹក ឬប្រតិឃាតពីឥទ្ធិពលខាងក្រៅឡើយ ។

កិច្ចការរបស់ខ្ញុំក្នុងអត្ថបទខ្លីមួយនេះ ផ្តោតជាសំខាន់ទៅលើបញ្ហាពិបាកដោះស្រាយមួយគឺថាតើការធានាភាពមិនលម្អៀងនិងឯករាជ្យភាពនៃក្រុមចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយរបៀបណា ។ កិច្ចការនេះតម្រូវឲ្យខ្ញុំផ្តោតសំខាន់ទៅលើចៅក្រមតែម្នាក់គត់ ។ ការធានានូវអ្វីដែលមិនមាននៅកម្ពុជា គឺជាគំនិតយល់ឃើញខុសៗគ្នា ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំនឹងលើកយកបញ្ហាមួយចំនួនដែលខ្ញុំយល់ឃើញថាបញ្ហាទាំងនេះអាចកាត់បន្ថយឬរារាំងដល់ប្រសិទ្ធភាពសម្រាប់ភាពមិនលម្អៀងនិងឯករាជ្យភាពនៃក្រុមចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ខ្ញុំផ្តល់នូវយោបល់ដែលអាចសម្រេចបាននិងមានលក្ខណៈពិតប្រាកដថាតើត្រូវដោះស្រាយស្ថានភាពនេះដោយរបៀបណាតាមកម្រិតដែលអាចធ្វើទៅបាន ។

### ២) ការពិតនៅកម្ពុជា

ដូចបណ្តាប្រទេសអន្តរកាលដទៃទៀតដែរ កម្ពុជាប្រកាន់យកនូវគោលការណ៍ភាពមិនលម្អៀងនិងឯករាជ្យភាពរបស់តុលាការតែនៅលើក្រដាសតែប៉ុណ្ណោះ ។ រដ្ឋធម្មនុញ្ញកម្ពុជា (វិសោធនកម្មក្នុងឆ្នាំ២០០៨) ចែងអំពីការបែងចែកអំណាច ។ មាត្រា១២៨ ចែងថាអំណាចតុលាការជាអំណាចឯករាជ្យមួយដែលធានារក្សាអនាគតិនិងការពារសិទ្ធិសេរីភាពរបស់ប្រជា-ពលរដ្ឋ ។ ព្រះមហាក្សត្រដោយមានជំនួយពីឧត្តមក្រុមប្រឹក្សានៃ

អង្គចៅក្រម គឺជាអ្នកធានានូវឯករាជ្យភាពរបស់តុលាការ ។ មាត្រា១ នៃច្បាប់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជាគឺជាបទប្បញ្ញត្តិស្តីពីសុចរិតភាពរបស់តុលាការដែលបញ្ចូលគោលការណ៍មូលដ្ឋានស្តីពីឯករាជ្យភាពនៃក្រុមចៅក្រមនៅក្នុងច្បាប់ជាតិ ។ មាត្រា១០ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថាចៅក្រមទាំងអស់ត្រូវមានចរិតលក្ខណៈនិងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិត មានបទពិសោធន៍ក្នុងការងារជំនាញ ជាពិសេសខាងច្បាប់ព្រហ្មទណ្ឌឬច្បាប់អន្តរជាតិរួមមានច្បាប់មនុស្សធម៌អន្តរជាតិនិងច្បាប់សិទ្ធិមនុស្ស ។ មាត្រានេះតម្រូវឲ្យចៅក្រមជម្រះក្តីមានភាពឯករាជ្យក្នុងការបំពេញករណីកិច្ចរបស់ខ្លួន ហើយមិនត្រូវទទួលឬស្វែងរកការបង្គាប់បញ្ជាពីភាគីរដ្ឋាភិបាលឬពីប្រភពណាមួយផ្សេងទៀតឡើយ ។

ក៏ប៉ុន្តែមានរបាយការណ៍ជាឯកសារច្បាស់លាស់ជាច្រើនស្តីពីប្រព័ន្ធតុលាការនិងច្បាប់នៅកម្ពុជា ។ សូម្បីតែរាជរដ្ឋាភិបាលកម្ពុជាក៏ទទួលស្គាល់ថាអ្វីៗគឺស្ថិតក្នុងសភាពមិនល្អ ។ គុណភាពនៃយុត្តិភាពដូចដែលបានអនុវត្តជាក់ស្តែងនៅក្នុងតុលាការអន្តរជាតិគឺមិនត្រូវបានយកមកពិភាក្សានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះឡើយ ។ បញ្ហាប្រឈមនោះគឺការលើកកម្រិតស្តង់ដាដែលអាចទទួលយកបាន ដូចជាការឆ្លើយតបទៅស្តង់ដាអប្បបរមានៃការជំនុំជម្រះក្តីដោយយុត្តិធម៌និងដំណើរការកាត់ក្តីត្រឹមត្រូវតាមផ្លូវច្បាប់ ។

របាយការណ៍ខ្លះបញ្ជាក់ថាការជំនុំជម្រះក្តីក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងជាឱកាសមួយសម្រាប់ការចាប់ផ្តើមការជំនុំជម្រះក្តីដោយយុត្តិធម៌និងដំណើរការកាត់ក្តីត្រឹមត្រូវតាមផ្លូវច្បាប់នៅកម្ពុជា ។ ក៏ប៉ុន្តែឱកាសនេះគឺមានលក្ខណៈសាមញ្ញខ្លាំងណាស់ ពីព្រោះប្រព័ន្ធច្បាប់និងតុលាការនៅកម្ពុជាគឺមានសភាពស្មុគស្មាញនិងកើតចេញពីបញ្ហាប្រវត្តិសាស្ត្រ វប្បធម៌ លក្ខខណ្ឌនយោបាយនិងសង្គម ព្រមទាំងធនធានមនុស្សនិងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ។ ចាប់តាំងពីកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ១៩៩១មក សហគមអន្តរជាតិខិតខំប្រឹងប្រែងនិងចំណាយថវិកាយ៉ាងច្រើនលានដុល្លារសម្រាប់កំណែទម្រង់ប្រព័ន្ធច្បាប់និងតុលាការនៅកម្ពុជា ។ បើទោះបីជាមានការចំណាយថវិកាអស់ជាច្រើនយ៉ាងនេះក៏ដោយ ប្រព័ន្ធច្បាប់និងតុលាការនៅកម្ពុជានៅតែមានឈ្មោះមិនល្អនៅលើឆាកអន្តរជាតិដដែល ។ ជាងនេះទៅទៀតនោះ អង្គការសហប្រជាជាតិចូលរួមក្នុងគម្រោងមួយដែលអង្គការសហប្រជាជាតិនិងក្រុមអ្នកអង្កេតការភាគច្រើននៅមានមន្ទិលសង្ស័យដែលអាចឆ្លើយតបទៅនឹងស្តង់ដាអន្តរជាតិនៃការជំនុំជម្រះក្តីដោយយុត្តិធម៌និងដំណើរការកាត់ក្តីត្រឹមត្រូវតាមផ្លូវច្បាប់ ។

ឧបសគ្គសំខាន់ៗដែលរារាំងដល់ភាពមិនលម្អៀងនិងឯករាជ្យភាពនៃក្រុមចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះគឺ ÷

១) ការរៀបចំដំណើរការកាត់ក្តីត្រឹមត្រូវតាមផ្លូវច្បាប់ឲ្យជាផ្នែកមួយនៃតុលាការជាតិកម្ពុជាដែលមិនគោរពការបែងចែកអំណាចជាក់ស្តែង ។

២) ការចូលរួមរបស់ចៅក្រមកម្ពុជានៅក្នុងដំណើរការនេះ ។

៣) ការគ្រប់គ្រងកម្ពុជាតាមរយៈសំឡេងភាគច្រើនជាប្រធានអង្គជំនុំជម្រះនិងប្រធានការិយាល័យរដ្ឋបាល ។

៤) ការបោះឆ្នោតដោយយកសម្លេងភាគច្រើនលើសលុប ។

៥) ការតែងតាំងនិងការគ្រប់គ្រងចៅក្រមដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

៦) ការផ្តល់សេចក្តីទុកចិត្តទៅលើភាពមិនត្រឹមត្រូវនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ។

៧) ចន្លោះប្រហោងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

៨) បទប្បញ្ញត្តិដែលមិនត្រឹមត្រូវសម្រាប់ការធានានូវសន្តិសុខផ្ទាល់ខ្លួនរបស់ចៅក្រម ។

៩) ពុំមានក្រមសីលធម៌សម្រាប់គ្រប់គ្រងចៅក្រម ។

១០) ភាពមិនត្រឹមត្រូវនៃការដាក់ទណ្ឌកម្មព្រហ្មទណ្ឌចំពោះការជ្រៀតជ្រែកក្នុងបញ្ហាយុត្តិធម៌និងភាពមិនលម្អៀងនិងឯករាជ្យភាពនៃក្រុមចៅក្រម ។

ជាការពិតណាស់ គ្មានបញ្ហាអ្វីច្រើនជាងនេះដែលអាចធ្វើការផ្លាស់ប្តូរនូវសេចក្តីសម្រេចនយោបាយមួយចំនួនដែលបង្ក

ជាបញ្ហាដូចជាបញ្ហាចាប់ពី១រហូតដល់៦ជាដើម ។ ទោះបីជាយ៉ាងណាក៏ដោយ នៅមានវិសាលភាពនៅឡើយសម្រាប់ការកំណត់ការខូចខាតនិងការដោះស្រាយនូវកំហុសឆ្គងផ្សេងៗទៀតមួយចំនួន ។

### ៣) ការធានាភាពមិនលម្អៀងនិងឯករាជ្យភាពនៃក្រុមចៅក្រម

ជាការមិនគួរសន្និដ្ឋានថាដំណើរការកាត់ក្តីត្រឹមត្រូវដ៏ធំនេះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងធានានូវភាពមិនលម្អៀងនិងឯករាជ្យភាពនោះទេ ។ ដំណើរការនេះជាការប៉ាន់ប្រមាណការពិតនៅកម្ពុជា ពីព្រោះមានឧទាហរណ៍ជាច្រើនលើកឡើងស្តីពីឥទ្ធិពលនយោបាយមកលើដំណើរការកាត់សេចក្តីរបស់តុលាការបើទោះបីជាមានការពិនិត្យពិច័យជាសាធារណៈក៏ដោយ ។ ច្បាស់ណាស់ថាការពិនិត្យពិច័យតាមរយៈការជំនុំជម្រះក្តីដោយចំហគឺមានសារសំខាន់ ក៏ប៉ុន្តែប្រវត្តិតុលាការកាត់សេចក្តីឧក្រិដ្ឋកម្មទីម័រខាងកើតនៅក្នុងទីក្រុងហ្សាកាតាបង្ហាញថាការពិនិត្យការជំនុំជម្រះក្តីយ៉ាងប្រុងប្រយ័ត្នមិនត្រូវវាយតម្លៃហួសប្រមាណជាការបង្ការការជំនុំជម្រះក្តីឬការវិនិច្ឆ័យមិនត្រឹមត្រូវនោះទេ ។ កម្ពុជាក៏ដូចគ្នានឹងចិនដែរ ការចូលរួមចែករំលែកការពិតប្រាកដគឺស្ថិតនៅលើការចងក្រងឯកសារនូវអ្វីដែលបានកើតឡើង ហើយកើតឡើងដោយរបៀបណា ប្រសិនបើតម្រូវការឲ្យមានចំណាត់ដោះស្រាយនូវបញ្ហា ។ ក៏ប៉ុន្តែ ការពិតនោះគឺការគាបសង្កត់យ៉ាងខ្លាំងពីបណ្តាប្រទេសដែលមានឥទ្ធិពលមួយចំនួនដូចជាសហរដ្ឋអាមេរិកជាដើមទៅលើរាជរដ្ឋាភិបាលកម្ពុជាអំពីបញ្ហាការជំនុំជម្រះក្តីដោយយុត្តិធម៌និងដំណើរការកាត់ក្តីត្រឹមត្រូវតាមផ្លូវច្បាប់ដោយរាប់បញ្ចូលទាំងការធានាភាពមិនលម្អៀងនិងឯករាជ្យភាពរបស់តុលាការ ទំនងជាមានផលប៉ះពាល់ច្រើនជាង ។

## ក. បញ្ហាខ្សែចង្វាក់ឬរចនាសម្ព័ន្ធ

### ១) ការយល់ដឹងអំពីការធានានៅក្នុងច្បាប់កម្ពុជា

ការធានារយៈពេលយូរនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញនិងកាតព្វកិច្ចផ្លូវច្បាប់ចំពោះភាគីរដ្ឋ និងការធានារបស់ព្រះមហាក្សត្រចំពោះអំណាចតុលាការត្រូវតែយកមកអនុវត្តជាចាំបាច់ ។ គោលការណ៍មូលដ្ឋានស្តីពីឯករាជ្យភាពនៃក្រុមចៅក្រមមានអំណាចច្បាប់ចាប់តាំងពីច្បាប់អ៊ុនតាក់ត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៩២និងរាប់បញ្ចូលទាំងកាតព្វកិចទៅលើភាគីរដ្ឋឲ្យគោរពនិងអង្កេតឯករាជ្យភាពនៃក្រុមចៅក្រម ។ ព្រះមហាក្សត្រជាអ្នកធានានូវឯករាជ្យភាពនៃក្រុមចៅក្រមនិងត្រូវតែមានព្រះរាជកិច្ចជាច្រើនក្នុងព្រះនាមជាអ្នកធានា ។

តម្រូវជាចាំបាច់ឲ្យមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីគោលការណ៍រួមតាមផ្លូវច្បាប់ក្នុងសង្គមគ្រប់កម្រិតដោយរាប់បញ្ចូលអំណាចទាំងបីរបស់រដ្ឋ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិនិងអំណាចតុលាការ) ។ ឯករាជ្យភាពរបស់តុលាការគឺជាសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ដែលមានការចាប់អារម្មណ៍ក្នុងការរក្សាការពារនិងធានានូវឯករាជ្យភាពនៃស្ថាប័នមួយនេះ ដូចនេះសិទ្ធិសេរីភាពដ៏សំខាន់របស់ប្រជាពលរដ្ឋកម្ពុជាមិនអាចឲ្យជនណាម្នាក់រំលោភបំពានបានឡើយ រួមទាំងអំណាចរបស់ភាគីរដ្ឋ ។ ការផ្សព្វផ្សាយនេះផ្តោតជាសំខាន់ទៅលើការធានាការគោរពស្វ័យភាពនិងសុចរិតភាពនៃក្រុមចៅក្រមដោយអំណាចនីតិបញ្ញត្តិនិងនីតិប្រតិបត្តិ ជាជាងការច្រានចោលនូវសំណើសុំពិនិត្យចៅក្រមកម្ពុជាដែលងាយនឹងមានផលប៉ះពាល់ ។ សភាអាចធ្វើការសាកល្បងកាត់ផ្តាច់នូវខ្សែបន្ទាត់គណៈបក្សនិងបង្កើតនូវគណៈកម្មការស៊ើបអង្កេតឯករាជ្យរវាងភាគីមានជម្លោះក្នុងការស៊ើបអង្កេតលើបណ្តឹងតវ៉ាដែលពាក់ព័ន្ធនឹងការជ្រៀតជ្រែកនយោបាយមិនសមរម្យណាមួយនៅក្នុងអំណាចតុលាការ ។ ការបង្កើតគណៈកម្មការនេះនឹងពិនិត្យតែការជ្រៀតជ្រែកផ្នែកនយោបាយតែប៉ុណ្ណោះ ពីព្រោះការផ្លាស់ប្តូរការដាក់ឲ្យទទួលខុសត្រូវរបស់តុលាការនេះនឹងរំលោភបំពានគោលការណ៍ស្តីពីការបែងចែកអំណាច ។

### ២) ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

រាជរដ្ឋាភិបាលកម្ពុជានៅមិនទាន់សន្យាបញ្ចប់និងអនុម័តសេចក្តីព្រាងច្បាប់ដែលមានស្រាប់ក្នុងការដោះស្រាយភាពទន់ខ្សោយមួយចំនួនដែលកើតមាននៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមព្រមទាំងសិទ្ធិនិងកាតព្វកិច្ចមូលដ្ឋាននៃក្រុមចៅក្រមនៅឡើយទេ ។ ស្ថាប័ននេះត្រូវធ្វើកំណែទម្រង់ដើម្បីធានាឯករាជ្យភាពនិងមុខនាទីនៃក្រុមចៅក្រម ក៏ប៉ុន្តែរហូតមកទល់ពេលនេះស្ថាប័ននេះនៅមិនទាន់ធ្វើកំណែទម្រង់នៅឡើយ ។ ត្រូវតែបំបាត់

ចោលនូវលក្ខណៈនយោបាយ ហើយសមាជិករបស់រាជរដ្ឋាភិបាល ត្រូវបង្ហាញអំពីការបែងចែកអំណាច (ជាពិសេសក្រសួងយុត្តិធម៌ មិនត្រូវជាសមាជិកឡើយ) ។ ស្ថានភាពបច្ចុប្បន្នដែលពាក់ព័ន្ធនឹងក្រសួងយុត្តិធម៌ដែលធ្លាប់គ្រប់គ្រងលេខាធិការដ្ឋាននោះគឺអាចទទួលនូវឥទ្ធិពលនយោបាយច្រើនជាងមុន ។

តម្រូវឲ្យមានការធានានូវអំណាចតុលាការផងដែរ ដូចជា បទប្បញ្ញត្តិបញ្ចូលលក្ខណៈវិនិច្ឆ័យជាក់លាក់និងទទួលស្គាល់ជាអន្តរជាតិសម្រាប់ការតែងតាំងចៅក្រមនិងការតម្លើងឋានៈចៅក្រមដោយផ្អែកលើសុចរិតភាពនិងគុណសម្បត្តិក្រមសីលធម៌សម្រាប់ចៅក្រមទាំងអស់ប្រកបដោយនីតិវិធីត្រឹមត្រូវនិងមានតម្លាភាពសម្រាប់ការតែងតាំងចៅក្រមនិងដំណើរការកាត់ក្តីតាមផ្លូវច្បាប់ ។ ការធានាអំណាចតុលាការបច្ចុប្បន្ននេះមិនទាន់ត្រូវបានដាក់កម្រិត នៅមានការប្រព្រឹត្តតាមអំពើចិត្តនិងនៅមានកង្វះតម្លាភាពនៅឡើយ ។ មាត្រា១០នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើសេចក្តីណែនាំនូវលក្ខណៈវិនិច្ឆ័យដូចជាជំនាញការបច្ចេកទេសដែលពុំមាននៅក្នុងប្រទេសកម្ពុជានិងពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការដោះស្រាយនូវភាពគ្មានអ្នកគ្រប់គ្រង ។ គឺត្រូវតែមានយន្តការមួយសម្រាប់គ្រប់គ្រងការចាត់តាំងចៅក្រមជាតិបម្រើក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចនេះយន្តការនេះគឺផ្អែកទៅលើគុណសម្បត្តិនិងសមត្ថភាពចៅក្រមដោយអនុលោមទៅតាមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាជាងផ្អែកទៅលើភាពងាយទទួលការបត់បែននិងការជាប់ពាក់ព័ន្ធនឹងរឿងនយោបាយ ។ ម្យ៉ាងវិញទៀត តម្រូវការដែលចៅក្រមត្រូវតែប្រកាសទ្រព្យសម្បត្តិរបស់ខ្លួននៅពេលតែងតាំងនិងក្រោយពេលតែងតាំងរួចក្នុងមួយឆ្នាំម្តងៗ អាចចាត់ទុកថាជាមធ្យោបាយមួយក្នុងការដោះស្រាយនូវបញ្ហាអំពើពុករលួយផ្នែកហិរញ្ញវត្ថុ ។

ការជ្រើសរើសចៅក្រមជាតិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានយកមកពិនិត្យមើលជាច្រើនលើករួចមកហើយដោយសារការគ្មានតម្លាភាពនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ។ ចៅក្រមនិងព្រះរាជអាជ្ញាកម្ពុជាកំពុងតែចូលរួមក្នុងវគ្គបណ្តុះបណ្តាលច្បាប់អន្តរជាតិដែលរៀបចំឡើងដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ក៏ប៉ុន្តែមូលដ្ឋាននៃការជ្រើសរើសនេះព្រមទាំងឈ្មោះបេក្ខជនជាចៅក្រម នៅបន្តដកចេញ ។ នៅថ្ងៃដែលចៅក្រមចូលធ្វើសច្ចាប្រណិធាន ចៅក្រមត្រូវចាំបាច់ធ្វើសម្បថទៅតាមច្បាប់ជាតិនិងរដ្ឋធម្មនុញ្ញដោយរាប់បញ្ចូលគោលការណ៍មូលដ្ឋានស្តីពីឯករាជ្យភាពនៃក្រុមចៅក្រមនិងឲ្យទទួលខុសត្រូវចំពោះផលវិបាកដែលខ្លួនមិនបានអនុវត្តតាមពាក្យសម្បថរបស់ខ្លួន ។ ***(នៅមានត)***

**ស៊ូហ្សាណា លីនគុន**

# ប្រវត្តិសង្ខេបរបស់ម្ចាស់គំនូរ

គំនូរដែលបង្ហាញនៅលើទំព័រទស្សនាវដ្តីនេះគឺជារបស់លោក ស៊ុំ រិទ្ធី អតីតអ្នកទោសម្នាក់នៅគុកធំ ក្នុងខេត្តសៀមរាប បានផ្តល់មកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅក្នុងឆ្នាំ១៩៧៦ រិទ្ធី ត្រូវឈ្លបខ្មែរក្រហមមួយក្រុមឡើងមកចាប់ក្នុងខ្ទមទាំងកណ្តាលអាធ្រាត្រដោយចោទថាក្បត់បដិវត្តន៍ ។ ឈ្លបខ្មែរក្រហមបានវាយនឹងស្នូកកាំភ្លើងយ៉ាងដំណំមុនពេលបញ្ជូនយកទៅដាក់គុកធំ ។ រស់នៅក្នុងគុកធំអស់រយៈពេលជិត១ឆ្នាំ រិទ្ធី បានទទួលរងទារុណកម្មគ្រប់បែបយ៉ាង បន្សល់ទុកនូវស្លាកស្នាមជាច្រើនកន្លែងនៅលើរាងកាយ និងបានឃើញគ្រប់អំពើយង់ឃ្នង់ដែលកម្មាភិបាលខ្មែរក្រហមប្រព្រឹត្តមកលើអ្នកទោសទាំងចាស់ទាំងក្មេង ។ ឪពុកនិងបងប្អូនរបស់គាត់ស្លាប់យ៉ាងវេទនានៅក្នុងរបបនោះដែរ ។ រិទ្ធី បានរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃនេះដោយសារជំនាញជួសជុលម៉ូតូរបស់គាត់ ។ ជាលទ្ធផលដែលខ្មែរក្រហមផ្តល់ឲ្យគឺបានធ្វើឲ្យប៉ះទង្គិចផ្លូវចិត្តរបស់គាត់យ៉ាងធ្ងន់ធ្ងរ ។ រិទ្ធី បានព្យាយាមរកវិធីដើម្បីបន្ធូរអារម្មណ៍របស់គាត់តាមរយៈការសរសេរជាសាច់រឿងនិងបង្ហាញពីសកម្មភាពផ្សេងៗតាមរយៈរូបគំនូរជាច្រើនសន្លឹកដែលខ្មែរក្រហមប្រព្រឹត្តចំពោះគាត់ និងអ្នកទោសផ្សេងទៀត ។ (សូមអានអត្ថបទរបស់ ស៊ុំ រិទ្ធី នៅក្នុងទស្សនាវដ្តីលេខ ៦៩ ខែកញ្ញា ឆ្នាំ២០០៥) **លី សុផល**

# ក្រុមគ្រួសារខ្ញុំ

កាលខ្ញុំនៅតូច លោកយាយរបស់ខ្ញុំតែងតែប្រាប់បងប្អូនខ្ញុំ កុំឲ្យនិយាយគ្នាពេលហូបបាយ និងត្រូវហូបបាយឲ្យរួចរាល់មុនពេលព្រលប់ ។ នៅពេលដែលបងប្អូនខ្ញុំមិនស្តាប់តាមដំបូន្មានរបស់គាត់ គាត់និយាយថា «ចៅៗអស់នេះបើនៅក្នុងសម័យប៉ុលពត ម្ល៉េះត្រូវស្លាប់ដោយអត់បាយ ឬត្រូវគេសម្លាប់ចោលអស់ហើយដោយសារមិនស្តាប់បង្គាប់» ។ កាលនោះ ខ្ញុំមិនយល់អ្វីដែលលោកយាយនិយាយទេ ទើបតែក្រោយពីបានស្តាប់ការរៀបរាប់របស់ឪពុកម្តាយខ្ញុំអំពីរបបខ្មែរក្រហមទើបខ្ញុំយល់ ។

ម៉ែនិយាយប្រាប់ខ្ញុំថា នៅក្នុងសង្គមរាស្ត្រនិយម គាត់នៅក្នុងភូមិរការ ឃុំសិង្ហ ស្រុកអូរជ្រៅ ខេត្តបាត់ដំបង (បច្ចុប្បន្ន ខេត្តបន្ទាយមានជ័យ) គ្រួសារគាត់មានទ្រព្យសម្បត្តិច្រើនបន្តួច និងជាគ្រួសារដែលមានសុភមង្គល ។ ក្នុងផ្ទះគាត់មានសមាជិក៦នាក់ គឺលោកយាយ លោកតា ពុក ម៉ែ អ៊ំស្រី របស់ខ្ញុំ និងប្តីរបស់គាត់ ក្រោយមកសមាជិកគ្រួសារកើនដល់៨នាក់ គឺថែមបងប្រុសខ្ញុំ២នាក់ ។


ឪពុកម្តាយ ឡូត់ សោភ័ណ ខេត្តសៀមរាប ក្នុងឆ្នាំ២០០១

ពេលខ្មែរក្រហមកាន់កាប់ប្រទេស ទ្រព្យសម្បត្តិនៅក្នុងផ្ទះរបស់លោកយាយខ្ញុំត្រូវដកហូតធ្វើជាកម្មសិទ្ធរបស់អង្គការ ។ ក្រុមគ្រួសារដែលធ្លាប់តែជួបជុំគ្នា ក៏ត្រូវអង្គការបំបែកឲ្យទៅធ្វើការឆ្ងាយៗពីគ្នា ។

ឪពុកខ្ញុំ ត្រូវអង្គការបញ្ជូនទៅលើកទំនប់ត្រពាំងថ្ម នៅក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដោយសារប្រធានសហករណ៍ឈ្មោះ ពូខ្ទី យល់ថាឪពុកខ្ញុំមិនមែនជាកសិករទេ ព្រោះមានសម្បុរសនិងមានសាច់ឈាមភ្លឺថ្លា ។ ឪពុកខ្ញុំនិយាយថា គាត់ពិតជាវេទនាខ្លាំងណាស់ ។ អ្នកធ្វើការនៅទំនប់ត្រពាំងថ្មម្នាក់បានទទួលបបរ១ចាននិងទឹកដឹកមួយចានទាបក្នុងមួយពេល ។ ពុករំពុកថា «បើនិយាយពីបបរគ្មានឃើញគ្រាប់អង្ករដូចបបរដែលកូនហូបរាល់ថ្ងៃនេះទេ គឺរាវកក្កុកឃើញតែទឹក ។ រីឯទឹកដឹកវិញមានអ្នកខ្លះដឹកមិនឆ្អែតក៏តវ៉ា ប៉ុន្តែមិនត្រឹមតែមិនបានទឹកថែមទេ ថែមទាំងត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលថែមទៀត» ។ ឪពុកខ្ញុំបានបានមកលេងផ្ទះតែ២ដងប៉ុណ្ណោះក្នុងមួយឆ្នាំ គឺនៅពេលបុណ្យចូលឆ្នាំខ្មែរនិងបុណ្យភ្ជុំបិណ្ឌ ហើយមកផ្ទះម្តងបានតែមួយថ្ងៃប៉ុណ្ណោះ ។ ក្រោយមក ឪពុកខ្ញុំ ត្រូវអង្គការបញ្ជូនមកភូមិវិញ ប៉ុន្តែគណៈសហករណ៍បញ្ជូនគាត់ទៅដាំបន្លែនៅអាងកន្សែង ដើម្បីផ្គត់ផ្គង់ប្រជាជនចំនួន១៥០គ្រួសារ ។ ទីនោះស្ថិតនៅឆ្ងាយពីភូមិ និងខ្វះខាតស្បៀងអាហារខ្លាំងណាស់ ។

ម្តាយខ្ញុំរំពុកថា ថ្ងៃមួយឪពុកខ្ញុំមកលេងផ្ទះដោយបានដំឡូងជ្វាមកជាមួយផង ។ ម្តាយខ្ញុំក៏ធ្វើដំឡូងនឹង ។ កូរដំឡូងឆ្អិនហើយម្តាយខ្ញុំដួសដំឡូងនឹងដាក់ក្នុងចានរួចបែរទៅកោសស្ករនិងដំឡូងដែលជាប់បាតឆ្នាំង ។ ពេលដែលម៉ែងាកមកវិញឃើញពុកហូបដំឡូងនឹងក្នុងចានអស់រលីងទៅហើយ ។ ពេលនោះម៉ែខឹងនឹងពុកខ្លាំងណាស់ ប៉ុន្តែគាត់យល់ថា ដោយសារតែការស្រេកឃ្លានទើបបណ្តាលឲ្យពុកភ្លេចគិតដល់ប្រពន្ធកូន ។ តាមពិត ពុកខានហូបបបរជាយូរថ្ងៃមកហើយ ។

ម្តាយខ្ញុំសម្រាលបងស្រីទី៣របស់ខ្ញុំមិនយូរប៉ុន្មានបន្ទាប់ពីខ្មែរក្រហមកាន់អំណាច ។ គាត់ត្រូវអង្គការចាត់តាំងឲ្យធ្វើស្រែ កើបជីរដាក់ស្រែទាំងនៅសរសៃខ្ចី ។

បងស្រីរបស់ម្តាយខ្ញុំឈ្មោះ ឡេង សំយ៉ាវ និងប្តីឈ្មោះ ពារ បានរត់ទៅភាគខាងលិចប្រទេស ដោយសារ អ៊ំពារ ជាអតីតទាហានលន់នល់ ហើយបារម្ភខ្លាចអង្គការយកទៅសម្លាប់ចោល ។

លោកយាយនិងលោកតា ស្រែចំការនៅក្នុងភូមិ ប៉ុន្តែ

ក្រោយមកគាត់ត្រូវអង្គការបញ្ជូនឲ្យទៅដាំកប្បាសនៅស្រុកស្វាយ (បច្ចុប្បន្នស្រុកសិរីសោភ័ណ) ។

កាលនោះបងប្រុសទី១របស់ខ្ញុំមានអាយុ៨ឆ្នាំ ចំណែកបងប្រុសទី២ទើបតែមានអាយុ៥ឆ្នាំ ។ គាត់ទាំងពីរនាក់មិនដឹងអ្វីទាំងអស់ក្រៅពីកើបអាចម៍គោនិងកាប់ដើមទន្ទ្រានខែត្រតាមបញ្ជារបស់មេកង និងរត់ទៅមុខផ្ទះរបស់ តាអ៊ិន ដើម្បីបើករបបបបរនៅពេលព្រលប់ ។ ពេលណាដែលបងៗរបស់ខ្ញុំមិនបានព្រលប់ លោកយាយជាអ្នកស្រែកហៅគាត់ ។ បងទាំងពីរបានជួបលោកយាយនិងលោកតារបស់ខ្ញុំនៅពេលហូបបបរ ចំណែកពុកនិងម៉ែយូរៗទើបបានជួបម្តង ។ ពេលដែលលោកយាយនិងលោកតាត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅដាំកប្បាសនៅស្រុកស្វាយ បងប្រុសទាំងពីររបស់ខ្ញុំក៏លែងបានជួបគាត់ទៀត ។

ឥឡូវនេះ លោកយាយនិងលោកតារបស់ខ្ញុំបានស្លាប់បាត់ទៅហើយ នៅសល់តែពុកនិងម៉ែនិងបងៗរបស់ខ្ញុំ ។ ជាមួយនឹងជីវភាពគ្រួសារសព្វថ្ងៃ ពុកនិងម៉ែខ្ញុំគ្មានចង់បានអ្វីផ្សេងក្រៅពីកុំឲ្យរបបខ្មែរក្រហមកើតឡើងម្តងទៀតឡើយ ។ គាត់សប្បាយចិត្តណាស់ពេលដែលឮថានឹងមានសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយគាត់សូមឲ្យការកាត់ទោសនេះដំណើរការឲ្យបានឆាប់និងមានយុត្តធម៌ ។

**ឡាត់ សោភ័ណ**

# បទពិសោធន៍របស់ម៉ែ

មុនឆ្នាំ១៩៧៥ ម៉ែជាកសិករនិងជាឆ្មបបុរាណ ។ មកដល់របបប៉ុលពត គាត់រស់នៅភូមិត្រពាំងកក់ក្នុង ក្បែរជើងភ្នំខ្នុរ ។ អ្នកភូមិដឹងថាម៉ែជាឆ្មប ម៉្លោះហើយចេះតែមកពឹងពាក់ឲ្យម៉ែជួយបង្កើតកូនឲ្យ ។ ជួនកាលម៉ែអត់ងងុយមួយយប់ទល់ភ្លឺក៏មាន ប៉ុន្តែម៉ែ នៅ តែ ជួ យ ដោ យ ចិ ត្ត ស ប្បុ រ ស ។

ក្នុងអំឡុងចុងឆ្នាំ១៩៧៦ដល់ដើមឆ្នាំ១៩៧៧ ជីតារបស់ខ្ញុំ ឪពុកខ្ញុំ បងប្រុស និងបងស្រី ស្លាប់ដោយជំងឺខ្វះអាហារ និងត្រូវខ្មែរក្រហមសម្លាប់ជាបន្តបន្ទាប់ ។ ក្រុមគ្រួសារខ្ញុំបាត់បង់សមាជិកអស់៨នាក់ នៅសល់តែខ្ញុំនិងម៉ែប៉ុណ្ណោះ ។

ម៉ែបានជួបប្រទះរឿងរ៉ាវជាច្រើន ម៉ែបានឃើញប្រធានកងប្រមូលកុមារជំទង់ៗទៅវាយកម្ទេចផ្ទះថ្មស្អាតៗដើម្បីយកកន្លែងចងគោនិងធ្វើជាជង្រុកជី និងយកកញ្ចក់មកឆ្លុះមុខ ដំបំបែកគ្រឿងសង្ហារិមយកឈើមកធ្វើខសដុត ។ ម៉ែត្រូវអង្គការឲ្យផ្លាស់ប្តូរទីកន្លែងរស់នៅជាញឹកញាប់ ។ ទៅនៅកន្លែងនីមួយៗ ម៉ែឆ្លៀតដាំដំណាំទុកសម្រាប់ហូប ប៉ុន្តែមិនទាន់បានទទួលផលដំណាំផងត្រូវអង្គការផ្លាស់ទៅកន្លែងផ្សេង ។

ព្រលប់មួយ អង្គការហៅប្រជាជនទៅប្រជុំក្រោយពេលហូបបាយល្ងាចរួច ។ គណៈសហករណ៍ប្រកាសថា «អង្គការបដិវត្តន៍យើងជំរុញឲ្យប្រជាជនសម្រុកបង្កបង្កើនផលនិងដាំដំណាំកសិកម្មឲ្យបានច្រើនដើម្បីកុំឲ្យខ្វះហូប ដោយអនុវត្តឲ្យបានមួយហិកតាបេ្តជ្ញាឲ្យបានបីតោន អង្គការយើងអង្គការមហាលោតផ្លោះ ។ ចាប់ពីពេលនោះតទៅយើងនឹងធ្វើការយប់ឲ្យបានបីម៉ោងបន្ថែមទៀតទើបសម្រាក» ។ ប្រជុំចប់ កសិករទាំងអស់បែកផ្លូវគ្នា ខ្លះយកចបបង្កី ខ្លះយកទងដំឡូង បែកមុខសញ្ញាគ្នាចុះធ្វើការរៀងៗខ្លួន ។ ក្រុមរបស់ម៉ែមាន មីងឈាន អ្នកពូនរងដំឡូង មីងពៅជាអ្នកដាំ ម៉ែជាអ្នកលប់ដី ។ កំពុងតែដាំបណ្តើរជជែកគ្នាបណ្តើរស្រាប់តែឈ្លបពីរនាក់ដើរតម្រង់មកហើយនិយាយថា : «មិត្តឈាន ចេញមកណេះ» ។ មីងឈាន លីចបដើរចេញមកបានប្រហែលបីម៉ែត្រ ឈ្លបម្នាក់បញ្ជាឲ្យមីងហុចដៃ ។ មីងដាក់ចបចុះ ឈ្លបយកខ្សែមកចងដៃមីងទៅក្រោយ ចំណែកឈ្លបម្នាក់ទៀតលីចបលើស្មា នាំមីងចូលទៅព្រៃខាងលិច ។ ម៉ែមិនហ៊ានងើបមុខមើលទេ ប៉ុន្តែបេះដូងម៉ែលោតញ័រស្ទើរផ្ទុះចេញពីទ្រូង ម៉ែថប់ដង្ហើម ។ មួយសន្ទុះក្រោយក្រោយមក ឈ្លបពីរនាក់ទៀតដើរមកក្បែរម៉ែហើយហៅ «មិត្តពៅ សុំដៃ» ។ មីងពៅ កំពុងតែដាក់ទងដំឡូងឲ្យម៉ែលុបដីទម្លាក់ដើមដំឡូងចុះ ហើយស្រែកយំ «ម៉ែអើយ គេចងកូនហើយ» ។ ឈ្លបម្នាក់ឈរក្បែរនោះសម្លុតថា «កុំយំ! មិនបាច់ហៅម៉ែអីទេ អង្គការយើងយកទៅរៀនសូត្រទេតើ» ឈ្លបចងដៃ មីងពៅ រួចបណ្តើរចេញទៅ ។ កាលណោះ

មីងពៅ មានកូនតូចអាយុមួយខួបទុកឲ្យម្តាយជរាមើលនៅផ្ទះ ។ ម៉ែភាំងស្មារតី ឈរទ្រឹងមួយកន្លែង ដៃជើងម៉ែស្ពឹកឈរលែងនឹង ។ ពេលនោះម៉ែគិតដល់កូនរបស់គាត់គឺរូបខ្ញុំដែលអាយុប្រាំពីរឆ្នាំ កំពុងតែដេកនៅខ្ទមក្នុងព្រៃម្នាក់ឯង បើគេចាប់ម៉ែទៅ តើកូនរស់នៅជាមួយអ្នកណាបើគ្មានបងប្អូនគ្មានឪពុកដូច្នេះ ។ ម៉ែបន់ស្រន់កុំឲ្យគាត់ជួបរឿងយ៉ាងនេះ "ទេវតាអើយ! មេត្តាទុកជីវិតខ្ញុំដូចនាងបដាចារផង" ។ ស្នូរជួងគោះឲ្យរំសាយពីការងារទៅសម្រាក ម៉ែគ្រេកអរគ្មានអ្វីប្រៀប ។ កសិករទាំងអស់បែកផ្លូវគ្នាទៅផ្ទះរៀងៗខ្លួន ។

ខ្ញុំដេកម្នាក់ឯងនៅក្នុងខ្ទមដ៏រខេករខាក ។ ពេលនោះខ្ញុំខ្លាចខ្លាំងណាស់ ។ សត្វមៀម ទីទុយ លលកខ្មោច ខ្លែងស្រាក មកយំក្បែរផ្ទះខ្ញុំ ។ ខ្ញុំខ្លាច ខ្ញុំនឹកម៉ែ ខ្លួនខ្ញុំញ័រចំប្រប់ ទឹកភ្នែកខ្ញុំហូររង់ចាំមើលផ្លូវម៉ែមកផ្ទះវិញ ។ ខ្ញុំយកសំបកស្បោងដ៏ខ្យាចមួយមករុំខ្លួនឲ្យជិតកុំឲ្យរងា ហើយដេកលង់លក់ទៅ ។ ពេលម៉ែមកដល់ គាត់រាវរកខ្ញុំទាំងព្រួយបារម្ភ ។ ម៉ែស្ទាបប៉ះក្បាលខ្ញុំ គាត់អរខ្លាំងណាស់សួរខ្ញុំថា "ម៉េចបែកញើសជោកម្ល៉េះ? កូនខ្លាចឬ?" ខ្ញុំឆ្លើយថា "ចា៎!" ហើយខ្ញុំក៏ដេកលក់បន្តក្បែរទ្រូងម៉ែ ។

យប់នោះម៉ែសម្រាន្តមិនលក់ពេញមួយយប់ ។ ព្រឹកឡើងម៉ែទៅធ្វើការដូចធម្មតា ។ ថ្ងៃត្រង់ដល់ពេលហូបបបរ ម៉ែឃ្លានប៉ុន្តែម៉ែលេបមិនចូល ។ ម៉ែអត់ហូបអីរហូតដល់ល្ងាច ។ ម៉ែស្គមខ្លាំងណាស់ ប៉ុន្តែម៉ែតស៊ូគ្រប់ឧបសគ្គគឺដើម្បីកូន ម៉ែទៅធ្វើការរាល់ថ្ងៃឲ្យតែដើរទៅរួច ។ ឪពុក ប្តី និងកូនប្រាំមួយនាក់របស់ម៉ែត្រូវខ្មែរក្រហមសម្លាប់ចោលអស់ ។ ម៉ែស្មើរឆ្កួតវង្វេង ម៉ែនិយាយជារឿយៗថា ម៉ែខំតស៊ូរស់ដើម្បីកូន ។ សព្វថ្ងៃម៉ែមានអាយុ៧៨ឆ្នាំហើយ ។

## នៅតែមានចម្ងល់

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ខ្មែរក្រហមនៅតែប្រមូលកម្លាំងបង្កើតជាបក្សផ្សេងៗដើម្បីរកឧបាយកលសម្លាប់ប្រជាជនកម្ពុជាជាបន្តបន្ទាប់ ដូចដាក់មីនផ្តាច់ស្ពាន ស្ទាក់បាញ់រថយន្ត រថភ្លើង ដុតផ្ទះប្រជាជននៅផ្សារកំពង់ត្រាច និងធ្វើបាបប្រជាជនដែលចូលព្រៃកាប់អុសជាដើម ។ ជាក់ស្តែងនៅក្នុងឆ្នាំ១៩៨៦ ខ្មែរក្រហមបានស្ទាក់បាញ់រថភ្លើងមួយខ្សែពីកំពតទៅភ្នំពេញ បណ្តាលប្រជាជនស្លាប់និងរបួសរាប់រយនាក់ ។ ពេលនោះវិទ្យុខ្មែរក្រហមប្រកាសថា "កងទ័ពបដិវត្តន៍យើងកម្ទេចខ្មាំងយួនបានជាងមួយរយក្បាលនៅខេត្តកំពត មិនតែប៉ុណ្ណោះខេត្តផ្សេងៗទៀតក៏កងទ័ពយើងស្ទាក់បាញ់សម្លាប់បានរាប់រយក្បាលទៀតដែរ" ។ ខ្មែរក្រហមអនុវត្តតាមពាក្យស្លោករបស់ខ្លួនថា "កម្ទេចខ្មាំងយួនឈ្លានពានឲ្យអស់ពីទឹកដី" ។ មនុស្សនៅលោកខាងលិចមួយចំនួនបាននិយាយថា នេះជាឆាកល្ខោននយោបាយមួយរបស់រាជរដ្ឋាភិបាលទេ គេធ្វើយ៉ាងនេះដើម្បីរកប្រាក់ជំនួយជួយជាតិ យើងជាប្រជាជនកុំចេះដឹង ។ ខ្ញុំឆ្ងល់ថា បើអ្នកដឹកនាំសម្តែងល្ខោនឲ្យគេសម្លាប់ចោលទាំងអស់តើរកប្រាក់ជំនួយមកធ្វើអ្វី? ឲ្យអ្នកណាចាយ? បើស្លាប់យ៉ាងនេះរាល់ថ្ងៃ តើប្រជាជនកម្ពុជានៅសល់ប៉ុន្មាននាក់? ហើយទឹកដីកម្ពុជាបានអ្នកណារស់នៅ? តើវិទ្យុខ្មែរក្រហមមានភស្តុតាងអ្វីថាអ្នកដែលស្លាប់រាប់រយពាន់នាក់នេះជាខ្មាំងយួន?

## សំណូមពរឲ្យបដិសេធ

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ អង្គការរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានប្រកាសថា អត្រាប្រជាជនស្លាប់បាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍គឺជាងបីលាននាក់ ប៉ុន្តែពេលកន្លងទៅថ្មីនេះ ខ្ញុំបានឮបានឃើញវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តីមួយចំនួន ផ្សាយថាប្រជាជនស្លាប់ជាងពីរលាននាក់ ។ ប្រជាជននៅភូមិជុំគ្រៀលយល់ថា អត្រានេះមិនសមស្របទៅនឹងចំនួនប្រជាជនដែលបាត់បង់ជីវិតទេ ។ យើងខ្ញុំសំណូមពរឲ្យដាក់អត្រាដូចដើមវិញពីព្រោះមានប្រជាជនបាត់បង់ជីវិតច្រើនណាស់ ។ គ្រួសារជាច្រើនស្លាប់អស់ទាំងពូជ ដូច្នេះមិនអាចស្រង់មតិបានទេ ។ ឧទាហរណ៍ ក្នុងខេត្តកំពត ការសម្លាប់រង្គាលមានច្រើនលើសលប់ ។ ប្រជាជននៅភូមិត្រពាំងកក់ ឃុំកូនសាត់ ក្នុងឆ្នាំ១៩៧៥មានប្រជាជនជាង២ពាន់នាក់ ដល់ឆ្នាំ១៩៧៨ នៅសល់តែ៧០គ្រួសារ ហើយច្រើនតែជាស្ត្រីមេម៉ាយ ។ ទីតាំងសំខាន់ៗដែលខ្មែរក្រហមសម្លាប់មនុស្សមាន ទំនប់កោះស្លា ទំនប់ទាក់ក្រឡា ឃុំកែប ជើងភ្នំព្រួល តំបន់ត្រពាំងកក់ក្នុង វត្តកំពង់ត្រឡាច ។ល ។ នេះគ្រាន់តែស្រុកកំពតមួយប៉ុណ្ណោះ ។ ចំណែកឯស្រុកដទៃទៀតក៏មានច្រើនដូចគ្នាដែរ ។

**ព្រុំ សាម៉ុន**

## សេចក្តីប្រកាសរកឪពុកឈ្មោះ ដួងស៊ីង សាន



ដួងស៊ុំង សាន

ខ្ញុំបាទឈ្មោះ ណាថារី ដួងស៊ុំង សូមសួររកឪពុកឈ្មោះ ដួងស៊ីង សាន កើតនៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៣៧ ស្រុកកំណើតនៅខេត្តសៀមរាប ។ គាត់ជាប្រធានផ្នែកខាងការសិក្សាសេដ្ឋកិច្ចនិងផែនការនៃក្រសួងកសិកម្មនៅក្នុងរបបសាធារណរដ្ឋខ្មែរ ។ នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមចូលទីក្រុងភ្នំពេញ ក្រុមគ្រួសារគាត់បានភៀសខ្លួនចូលស្ថានទូតបារាំង ។ ពេលនោះស្ថានទូតបារាំងត្រូវកងទ័ពខ្មែរក្រហមឡោមព័ទ្ធជិត ហើយគាត់និងប្រជាជនកម្ពុជាដែលបានរត់ទៅជ្រកកោនក្នុងស្ថានទូតនោះត្រូវបានបណ្តេញចេញ ។ ចាប់តាំងពីពេលនោះមកលែងមានដំណឹងអំពីគាត់ទៀត ។

បើបងប្អូនណាបានដឹងដំណឹងនេះឬស្គាល់សូមទំនាក់ទំនងមកខ្ញុំបាទតាមអាស័យដ្ឋានខាងក្រោម ៖ ប្រអប់សំបុត្រ៨៤៥ ភ្នំពេញ ទូរស័ព្ទលេខ ០៩២ ៩៦២ ៣៥៦ ឬ ០១២ ៨៧៦ ៥៣២ ឬតាមអាសយដ្ឋាន Buchsstr.20, D-73252 Lenningen, Germany, Tel: +49 7026 2104 or Email: peer_gatter@hotmail.com ។

## សេចក្តីប្រកាសសួររកប្អូនឈ្មោះ អាន់ មុត

នាងខ្ញុំឈ្មោះ អាន់ ណាស់ បច្ចុប្បន្នរស់នៅភូមិទឹកចេញ សង្កាត់បឹងតាព្រហ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។ ម្តាយឈ្មោះ ម៉ាន រស់ ។ នាងខ្ញុំមានបងប្អូនបីនាក់ ទី១ឈ្មោះ អាន សុះ, ទី២រូបខ្ញុំនិងប្អូន ទី៣ឈ្មោះ អាន់ មុត ។ នាងខ្ញុំសូមសុំសួររកប្អូនឈ្មោះ អាន់ មុត សព្វថ្ងៃមិនដឹងប្អូនរស់នៅទីណាទេ ហើយបើប្អូនបានឮដំណឹងហើយសូមប្អូនវិលមកជួបបងប្អូនតាមអាសយដ្ឋានខាងលើកុំខាន ។ សូមអរគុណ ។

## សេចក្តីប្រកាសរកកូននិងប្អូនប្រុស

នាងខ្ញុំឈ្មោះ អ៊ី វ៉ាន់ណេី អាយុ៦៥ឆ្នាំ រស់នៅក្នុងភូមិថ្លា ឃុំប្រវៀង ស្រុកកំពង់ធំ ខេត្តកំពង់ធំ ប្តីឈ្មោះ គុល ឡេង (ខ្មែរក្រហមយកទៅសម្លាប់នៅឆ្នាំ១៩៧៧) សូមសួររកកូនប្រុសឈ្មោះ គុល មុន្នីវណ្ណ ដែលបានបាត់ខ្លួនតាំងពីអាយុ១២ឆ្នាំ និងប្អូនប្រុសឈ្មោះ អ៊ី ស៊្រុន បាត់ខ្លួនតាំងពីឆ្នាំ១៩៧៥ ។ បើកូននិងប្អូនបានឃើញសេចក្តីប្រកាសនេះសូមមករកម្តាយនិងបងតាមអាសយដ្ឋានខាងលើ ឬបើ ញាតិមិត្តណាបានស្គាល់សូមជួយផ្តល់ដំណឹងផង ។ សូមអរគុណ ។

## សេចក្តីប្រកាសរកបងប្រុស ពិន ចាន់ថុល

ខ្ញុំបាទឈ្មោះ ពិន ថែត អាយុ៤៣ឆ្នាំ ស្រុកកំណើតនៅភូមិមហាលាភ ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម សព្វថ្ងៃជាអគ្គលេខាធិការរងទី១ សាលាខេត្តមណ្ឌលគិរី ។ ឪពុកឈ្មោះ ពិន ប៊ិន (ស្លាប់) ម្តាយឈ្មោះ ចឹក អួន សព្វថ្ងៃរស់នៅភូមិមហាលាត ឃុំពាមប្រធ្នោះ ស្រុកកោះសុទិន ខេត្តកំពង់ចាម ។ សូមសួររកបងប្រុសឈ្មោះ ពិន ចាន់ថុល បាត់ដំណឹងនៅឆ្នាំ១៩៧៧ កាលនោះឮថាអង្គការយកទៅធ្វើការរោងចក្រ ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះគ្មានដំណឹងសោះ ។ បើបងប្រុសទទួលបានដំណឹង ឬញាតិមិត្តណាបានស្គាល់ឈ្មោះនេះ សូមទាក់ទងមកខ្ញុំ បាទតាមទូរស័ព្ទលេខ ០៩២ ៩២៨ ៥៧៩ ។ សូមអរគុណ ។

## សេចក្តីប្រកាសរកបងស្រីឈ្មោះ អយ សាន្ត

ខ្ញុំបាទឈ្មោះ ខៀក សារឿន អាយុ៤៦ឆ្នាំ រស់នៅភូមិកណ្តាល ឃុំស្ពានមានជ័យ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី សូមសួររកបងស្រីបង្កើតឈ្មោះ អយ សាន្ត ធ្វើពេទ្យសម័យខ្មែរក្រហម ប្តីឈ្មោះ ញឹម សុផល ។ បើបងស្រីបានទទួលដំណឹង ឬញាតិមិត្តបានស្គាល់ឈ្មោះនេះ សូមទាក់ទងតាមទូរស័ព្ទលេខ ០១២ ៧៦៦ ០៨២ ឬតាមរយៈ មជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។



អ្នកទោសនៅក្នុងគុកធំ ខេត្តសៀមរាប អូសរទេះដឹកដីទៅដាក់ស្រែ (គំនូរដោយ ៖ ស៊ុំ រិទ្ធី)

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 79, July 2006 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.